# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ២១

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

ខេត្តបាត់ដំបង ព.ស ២៥៥០

# គាថាធម្មបទ

## បកិណ្ណកវគ្គទី ២១

១. មត្តាសុខបរិច្ចាគា  បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ  សម្បស្សំ វិបុលំ សុខំ ។
បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់
សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញ
សុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

២. បរទុក្ខូបធានេន  យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ  វេរា សោ ន បរិមុច្ចតិ ។
ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបន្តុំទុក្ខឲ្យ
អ្នកដទៃ ជននោះឈ្មោះថា ប្រឡូកប្រឡល់ហើយ
ដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាក
ពៀរទេ ។

៣. យញ្ហិ កិច្ចំ តទបវិទ្ធំ  អកិច្ចំ បន កយិរតិ
ឧន្នឡានំ បមត្តានំ  តេសំ វឌ្ឍន្តិ អាសវា ។
យេសញ្ច សុសមារទ្ធា  និច្ចំ កាយគតា សតិ
អកិច្ចន្តេ ន សេវន្តិ  កិច្ចេ សាតច្ចការិនោ
សតានំ សម្បជានានំ  អត្ថំ គច្ឆន្តិ អាសវា ។

របស់ដែលខ្លួនគួរធ្វើ របស់នោះពួកភិក្ខុណា លះបង់ចោលហើយ តែរបស់មិនគួរធ្វើ ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចំរើនឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅក្នុងកាយជានិច្ច ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះរមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយរបស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈរមែងដល់នូវការអស់ទៅ ។

**៤. មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ**
**រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិដូចស្តេចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចដែន ប្រព្រឹត្តទៅមួយអន្ទើដោយបុរសអ្នកដើរតាម គឺស្នៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

៥. មាតរំ បិតរំ ហន្ត្វា    រាជានោ ទ្វេ ច សោត្ថិយេ
វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិ-
មានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទ
ទិដ្ឋិដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់
វិចិកិច្ឆាដូចជាខ្លាធំជាគំរប់ប្រាំផង( ដែលនូវស្កាត់
ផ្លូវ ) បានហើយ រមែងបានទៅជាខីណាសវ-
ព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

៦. សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច  និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច  និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច  និច្ចំ សង្ឃគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច  និច្ចំ កាយគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច  អហឹសាយ រតោ មនោ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ    សទា គោតមសាវកា

**យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងយប់ ទាំងថ្ងៃ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់-រឭកៗដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះ

ថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តា ការនាទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗដោយ ប្រពៃ សព្វកាល ។

**៧. ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា**
**ទុក្ខោសមានសំវាសោ ទុក្ខានុបតិតទ្ធគូ**
**តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។**

ការចេញបួសបានដោយក្រ ការត្រេកអរបាន ដោយក្រ ផ្ទះទាំងឡាយ មានការនៅគ្រប់គ្រង ដោយលំបាក ជាការក្រ ការនៅរួមដោយជន ស្មើគ្នា ( ដែលមិនមានសេចក្តីកោតក្រែង ) ជា ការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្ដៈ តែងត្រូវសេចក្តី ទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បី ជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តី ទុក្ខធ្លាក់ជាប់តាមផង ។

**៨. សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលអ្នកមានសទ្ធា បរិបូរណ៍ដោយសីល ស្កប់ស្កល់ដោយយសនឹងភោគសម្បត្តិ គប់រកប្រទេសណាៗគេតែងបូជាក្នុងប្រទេសនោះៗ ។

**៩. ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**
**អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។**

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហេមពាន្តដូច្នោះ ពួកអសប្បុរស ( ទុកជាឋិតនៅ ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

**១០. ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ**
**ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។**

បុគ្គលគួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលប្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេចអរក្នុងព្រៃស្ងាត់ ។

---

# ២១ បកិណ្ណកវគ្គវណ្ណនា

## ១ រឿងបុព្វកម្មរបស់ព្រះអង្គ

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុព្វកម្មរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះថា “**មត្តាសុខបរិច្ចាគា**” ជាដើម ។*

### *កើតភ័យ ៣ យ៉ាងក្នុងក្រុងវេសាលី*

*សេចក្តីពិស្តារថា សម័យមួយ ក្រុងវេសាលីនោះជាក្រុងស្តុកស្តម្ភ ជាក្រុងរីកសាយ មានប្រជាជនច្រើន*

ជាក្រុងមានមនុស្សកុះករ ។ ក៏ក្នុងក្រុងវេសាលីនោះមានក្សត្រគ្រប់គ្រងរាជសម្បត្តិតាមវារៈ ៧៧០៧ ព្រះអង្គ ។ ប្រាសាទសម្រាប់ជាទីគង់នៅនៃក្សត្រទាំងនោះ ក៏មានប្រមាណប៉ុណ្ណោះដែរ, ផ្ទះកំពូលក៏មានប្រមាណប៉ុណ្ណោះដែរ, សួន និងស្រះបោក្ខរណីសម្រាប់ជាទីគង់នៅក្នុងព្រះរាជឧទ្យាន ក៏មានប្រមាណប៉ុណ្ណោះដែរ ។

សម័យខាងក្រោយមក ក្រុងវេសាលីនោះ ជាក្រុងមានភិក្ខារកបានដោយក្រ ជាក្រុងមានសន្ទូងខូចខាត ។ ដំបូងមនុស្សទុគ៌តក្នុងក្រុងវេសាលីនោះស្លាប់យ៉ាងច្រើន ដោយទោស គឺការអត់ឃ្លាន ។ ពួកអមនុស្សក៏ចូលទៅកាន់ព្រះនគរដោយសារក្លិនសាកសពរបស់មនុស្សទាំងនោះ ដែលគេបោះបោលក្នុងទីនោះៗ, មនុស្សទាំងឡាយបានស្លាប់ច្រើនក្រៃលែង ដោយសារឧបទ្រពដែលកើតអំពីអមនុស្ស ។ អហិវាតករោគ ( អាសន្នរោគ ) កើតឡើងដល់សត្វទាំងឡាយ ព្រោះបដិកូលដោយក្លិនសាកសពនៃមនុស្សទាំងនោះ ។ ភ័យ ៣ យ៉ាង គឺ “ ភ័យកើតអំពីភិក្ខារកបានដោយ

ក្រ ( ទុព្ភិក្ខភ័យ ) ១ ភ័យកើតអំពីអមនុស្ស ( អមនុស្សភ័យ ) ១ ភ័យកើតអំពីរោគ ( រោគភ័យ ) ១ ” កើតឡើងហើយ ដោយប្រការដូច្នេះ ។

អ្នកនគរប្រជុំគ្នាហើយ ក្រាបទូលព្រះរាជាថា “បពិត្រមហារាជ ភ័យ ៣ យ៉ាងកើតឡើងហើយក្នុងព្រះនគរនេះ, ក្នុងកាលមុនអំពីកាលនេះ រហូតដល់ព្រះរាជា ៧ ជំនាន់ ឈ្មោះថាភ័យបែបនេះមិនធ្លាប់កើតឡើងហើយ, ព្រោះថា ក្នុងរាជកាលរបស់ព្រះរាជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ភ័យបែបនេះរមែងមិនកើតឡើង ” ។

ព្រះរាជា បញ្ជារាជបុរសឲ្យធ្វើការប្រជុំជនទាំងឡាយក្នុងព្រះរាជសណ្ឋាគារហើយ ត្រាស់ថា “ ប្រសិនបើការមិនទ្រទ្រង់ធម៌របស់យើងមានសោត, អ្នកទាំងឡាយចូរពិចារណារកមើលនូវហេតុនោះ ” ។

អ្នកក្រុងវេសាលី ពិចារណារកមើលនូវប្រពៃណីទាំងពួង មិនឃើញទោសអ្វីៗ របស់ព្រះរាជា ទើបក្រាបទូលថា “ បពិត្រមហារាជ ទោសរបស់ព្រះអង្គមិនមានទេ ” ទើប

ប្រឹក្សាគ្នាថា “ ភ័យរបស់ពួកយើងនេះគប្បីដល់នូវការ ស្ងប់រម្ងាប់ទៅដោយបការៈដូចម្ដេចហ្ន៎ ? ” បណ្ដាជនទាំងនោះ កាលជនពួកខ្លះពោលថា “ ភ័យគប្បីដល់ការស្ងប់ ដោយពលីកម្ម ដោយការបួងសួង ដោយការធ្វើនូវមង្គល ”, ជនទាំងនោះធ្វើពិធីនោះទាំងអស់ហើយ ក៏មិនអាចកម្ចាត់ភ័យនោះបាន ។

គ្រានោះ ជនពួកដទៃពោលយ៉ាងនេះថា “គ្រូទាំង ៦ មានអានុភាពច្រើន, កាលគ្រូទាំង ៦ នោះមកដល់ទីនេះភ្លាម, ភ័យ និងស្ងប់រម្ងាប់ទៅ ” ។ មួយពួកទៀតពោលថា “ ព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងហើយក្នុងលោក, ព្រះមានព្រះ-ភាគអង្គនោះមានឫទ្ធិច្រើន ទ្រង់មានអានុភាពច្រើន ទ្រង់សម្ដែងធម៌ដើម្បីប្រយោជន៍ដល់សព្វសត្វ, កាលព្រះអង្គស្ដេចមកកាន់ទីនេះ, ភ័យទាំងនេះនឹងស្ងប់រម្ងាប់បាន” ។ ជនសូម្បីទាំងអស់ ពេញចិត្តនឹងពាក្យរបស់ជនទាំងនោះហើយពោលថា “ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទ្រង់គង់នៅទីណាហ្ន៎ ?” ។

# អ្នកក្រុងវេសាលីឲ្យទៅអារាធនាព្រះសាស្ដា

ក៏ក្នុងកាលនោះ កាលតិថីជាទីចូលចាំវស្សាជិតមកដល់ហើយ, ព្រះសាស្ដា ទ្រង់ប្រទានការប្ដេជ្ញាដល់ព្រះបាទពិម្ពិសារ ហើយទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ។

ក៏ក្នុងសម័យនោះ ស្ដេចលិច្ឆវីព្រះនាមមហាលិដែលជាសោតាបន្នបុគ្គលជាមួយ និងព្រះរាជាព្រះនាមពិម្ពិសារក្នុងសមាគមព្រះបាទពិម្ពិសារ ទ្រង់គង់នៅក្នុងទីជិតនៃបរិស័ទទាំងនោះ ។ អ្នកក្រុងវេសាលីចាត់ចែងបណ្ណាការដ៏ធំ ហើយបញ្ជូនទៅថ្វាយស្ដេចលិច្ឆវីព្រះនាមមហាលិ និងបុត្ររបស់បុរោហិតដោយផ្ដាំថា “ អ្នកទាំងឡាយ ចូរញ៉ាំងព្រះបាទពិម្ពិសារ ឲ្យទ្រង់យល់ព្រមហើយ នាំព្រះសាស្ដាមកកាន់នគរនេះ ” ។ ស្ដេចលិច្ឆវីព្រះនាមមហាលិ និងបុត្ររបស់បុរោហិតនោះទៅហើយ ថ្វាយបណ្ណាការដល់ព្រះរាជា ក្រាបទូលព្រឹត្តិការណ៍នោះឲ្យទ្រង់ជ្រាបហើយទូលអង្វរថា “បពិត្រមហារាជ សូមព្រះអង្គទ្រង់បញ្ជូនព្រះសាស្ដាទៅកាន់នគររបស់ខ្ញុំព្រះអង្គ ” ។

ព្រះរាជាត្រាស់ថា “ អ្នកទាំងឡាយចូរដឹងខ្លួនឯងចុះ ” ហើយមិនទ្រង់ទទួល ( បណ្ណាការនោះ ) ។ ជនទាំងនោះចូលទៅគាល់ព្រះមានព្រះភាគថ្វាយបង្គំហើយ ទូលអារាធនាថា “ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងវេសាលីកើតភ័យ ៣ យ៉ាង, កាលព្រះអង្គស្តេចទៅ, ភ័យទាំងនោះនឹងស្ងប់រម្ងាប់, សូមព្រះអង្គស្តេចទៅកាន់នគរនោះចុះ ខ្ញុំព្រះអង្គទាំងឡាយនឹងទៅ ” ។ ព្រះសាស្តាទ្រង់ព្រះសណ្តាប់នៅពាក្យរបស់ជនទាំងនោះហើយ ទ្រង់រំពឹងមើលក៏ទ្រង់ជ្រាប់ថា “ ក្នុងក្រុងវេសាលី កាលតថាគតសូត្ររតនៈសូត្រ, អាជ្ញានឹងផ្សាយទៅកាន់សែនកោដិចក្រវាឡ, ក្នុងកាលចប់ព្រះសូត្រ ការសម្រេចធម៌នឹងមានដល់សត្វ ៨៤០០០, ភ័យទាំងនោះក៏នឹងស្ងប់រម្ងាប់ទៅ ” ហើយទ្រង់ទទួលការអារាធនារបស់ជនទាំងនោះ ។

## ព្រះសាស្តាស្តេចទៅកាន់ក្រុងវេសាលី

ព្រះបាទពិម្ពិសារ ទ្រង់ព្រះសណ្តាប់ថា “ព្រះសាស្តាទ្រង់ទទួលការអារាធនារបស់អ្នកក្រុងវេសាលីហើយ” ហើយ

បញ្ជាឲ្យធ្វើការឃោសនាក្នុងព្រះនគរ ចូលទៅគាល់ព្រះសាស្ដាទូលសួរថា " បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ទទួលការអារាធនារបស់អ្នកក្រុងវេសាលីហើយឬ ?" កាលព្រះសាស្ដាត្រាស់ថា " ថ្វាយព្រះពរ មហាបពិត្រ " ទូលថា " បើដូច្នោះ សូមព្រះអង្គទ្រង់រង់ចាំសិន, ខ្ញុំព្រះអង្គនឹងចាត់ចែងផ្លូវសិន " ហើយទ្រង់បញ្ជាឲ្យធ្វើផែនដីប្រមាណ ៥ យោជន៍ ក្នុងចន្លោះក្រុងរាជគ្រឹះ និងទន្លេគង្គាឲ្យរាបស្មើ ឲ្យចាត់ចែងវិហារទុកក្នុងទីមួយយោជន៍ៗ ( មួយយោជន៍មួយមួយយោជន៍មួយ ) ហើយទើបក្រាបទូលកាលជាទីស្ដេចទៅចំពោះព្រះសាស្ដា ។

គ្រានោះ ព្រះសាស្ដាស្ដេចយាងទៅកាន់ផ្លូវនោះជាមួយនិងភិក្ខុ ៥០០ រូប ។ ព្រះរាជាទ្រង់បញ្ជាឲ្យរោយផ្កាឈើ ៥ ពណ៌ កម្ពស់ប្រមាណត្រឹមជង្គង់ ក្នុងចន្លោះមួយយោជន៍ៗ ហើយត្រាស់ឲ្យលើកទង់ជ័យ ទង់ផ្ទាំងសំពត់និងដើមចេកជាដើមឡើង ត្រាស់ឲ្យបាំងស្វេតច្ឆត្រពីរជាន់ចំពោះព្រះមាន-ព្រះភាគ ត្រាស់ឲ្យបាំងស្វេតច្ឆត្រមួយជាន់ដល់ភិក្ខុមួយរូបៗ

ព្រមទាំងបរិវារ ទ្រង់បូជាផ្កានិងគ្រឿងក្រអូបជាដើម ទ្រង់អារាធនាព្រះសាស្ដាឲ្យគង់ក្នុងវិហារនិមួយៗ ទ្រង់ថ្វាយមហាទានហើយ ញុំាងព្រះសាស្ដាឲ្យស្ដេចដល់ឆ្នេរទន្លេគង្គាដោយ ៥ ថ្ងៃ ទ្រង់តាក់តែងទូកក្នុងទីនោះ ទ្រង់បញ្ជូនដំណឹងទៅប្រាប់អ្នកក្រុងវេសាលីថា " អ្នកក្រុងវេសាលីទាំងឡាយ ចូរតាក់តែងផ្លូវ ចូរធ្វើការក្រោកទទួលព្រះសាស្ដាចុះ " ។

## អ្នកក្រុងវេសាលីចាត់ការទទួលព្រះសាស្ដា

អ្នកក្រុងវេសាលីទាំងនោះគិតថា " យើងទាំងឡាយនិងធ្វើការបូជាជាទ្វេគុណ ហើយធ្វើផ្ទៃដីប្រមាណ ៣ យោជន៍ក្នុងចន្លោះក្រុងវេសាលី និងទន្លេគង្គាឲ្យរាបស្មើ ហើយចាត់-ចែងឆត្រតម្រួតឆត្រដើម្បីព្រះមានព្រះភាគ ៤ ជាន់ ដើម្បីភិក្ខុមួយរូបៗ ២ ជាន់ ធ្វើការបូជាព្រះមានព្រះភាគ ហើយមកឈរនៅនាឆ្នេរទន្លេគង្គា ។

ព្រះបាទពិម្ពិសារ ទ្រង់ចាត់ឲ្យគាបទូកពីរ ឲ្យធ្វើមណ្ឌប ឲ្យប្រដាប់ដោយគ្រឿងប្រដាប់ទាំងឡាយមានចង្កោមផ្កាជាដើម ឲ្យក្រាលពុទ្ធាសនៈដែលសម្រេចដោយរតនៈទាំង

ពួង ។ព្រះមានព្រះភាគទ្រង់គង់លើពុទ្ធាសនៈនោះ។ ចំណែក ពួកភិក្ខុក៏ឡើងកាន់ទូក ហើយគង់ចោមរោមព្រះមានព្រះ-ភាគ ។ ព្រះរាជាកាលទ្រង់ជូនព្រះមានព្រះភាគទៅ ស្តេចចុះទៅកាន់ទឹកទន្លេប្រមាណត្រឹមព្រះសុរង ( ក៏ ) ក្រាប់ទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគស្តេចត្រឡប់មកដរាបណា, ខ្ញុំព្រះអង្គនឹងនៅនាឆ្នេរទន្លេគង្គានេះដរាបនោះ " បញ្ជូនទូកទៅហើយ ក៏ស្តេចត្រឡប់មកវិញ ។ ព្រះសាស្តាស្តេចទៅតាមទន្លេគង្គាអស់ចម្ងាយផ្លូវប្រមាណ ១ យោជន៍ ទើបដល់ព្រំដែននៃអ្នកនគរវេសាលី ។

ស្តេចលិច្ឆវីទាំងឡាយ ទ្រង់ទទួលព្រះសាស្តា ស្តេចចូលទៅកាន់ទឹកប្រមាណត្រឹមព្រះសុរង នាំទូកចូលទៅកាន់ឆ្នេរហើយ អារាធនាព្រះសាស្តាឲ្យស្តេចចុះចាកទូក ។ គ្រាន់តែព្រះសាស្តា ស្តេចចុះចាកទូកជាន់លើឆ្នេរទន្លេគង្គាភ្លាម, មហាមេឃក៏តាំងឡើងហើយ បង្អុរចុះមកនូវភ្លៀងបោក្ខរព័ស្ស ( ភ្លៀងមានអាការដូចជាទឹកធ្លាក់លើស្លឹកឈូក ) ។ ទឹកមានប្រមាណត្រឹមជង្គង់ ត្រឹមភ្លៅ ត្រឹមចង្កេះជាដើមក្នុងទីទាំងពួង

ហូរនាំយកសាកសពទាំងពួងចូលទៅកាន់ទន្លេគង្គា ។ ប្រទេស ជាចំណែកនៃផែនដី ជាប្រទេសដ៏ស្អាត ។ ស្ដេចលិច្ឆវីទាំង-ឡាយ អារាធនាព្រះសាស្ដាឲ្យគង់នៅក្នុងទីមួយយោជន៍ៗ ថ្វាយមហាទានធ្វើការបូជាជាទ្វេគុណ នាំព្រះសាស្ដាចូលទៅ កាន់ក្រុងវេសាលីដោយ ៣ ថ្ងៃ ។ សក្កទេវរាជដែលមានពួក ទេវតាចោមរោមហើយ ស្ដេចបានទៅកាន់ទីនោះ ។ អមនុស្ស ទាំងឡាយរត់គេចចេញទៅយ៉ាងច្រើន ដោយសារទេវតាទាំង ឡាយអ្នកមានសក្តិធំប្រជុំគ្នាហើយ ។

## ទឹកមន្តនៃព្រះបរិត្តមានអានុភាពខ្លាំង

ព្រះសាស្ដា ទ្រង់ឈរនៅជិតទ្វារព្រះនគរក្នុងវេលា ល្ងាច ត្រាស់ហៅព្រះអានន្ទមកហើយ ត្រាស់ថា “ ម្នាល អានន្ទ អ្នកចូររៀនរតនៈសូត្រនេះ ហើយត្រាច់ទៅជាមួយ នឹងលិច្ឆវីកុមារទាំងឡាយ ចូរធ្វើព្រះបរិត្តក្នុងចន្លោះនៃកំពែង ៣ ជាន់នៃក្រុងវេសាលី ” ។

ព្រះថេរៈ រៀនរតនៈសូត្រដែលព្រះសាស្ដាប្រទានឲ្យ ហើយ យកបាត្រដែលសម្រេចអំពីថ្មរបស់ព្រះសាស្ដាផង

ទឹក ឈរនៅក្បែរទ្វារព្រះនគរហើយពិចារណាដល់ព្រះពុទ្ធ-
គុណរបស់ព្រះតថាគតគ្រប់ទាំងអស់ ចាប់ដើមអំពីសេចក្តី
ផ្តើមតាំងប្រាថ្នាជាព្រះពុទ្ធមកថា “ បារមី ៣០ គឺបារមី ១០
ឧបបារមី ១០ បរមត្ថបារមី ១០ មហាបរិច្ចាគ ៥ ចរិយា ៣
គឺលោកត្ថចរិយា ១ ញាតត្ថចរិយា ១ ពុទ្ធត្ថចរិយា ១ កិរិយា
យាងចុះកាន់គភ៌នៃព្រះមាតាក្នុងបច្ឆិមភព កិរិយាប្រសូត្រ
កិរិយាយាងចេញសាងអភិនេស្រ្កម កិរិយាបំពេញនូវទុក្ករ-
កិរិយា កិរិយាផ្ចាញ់មារ កិរិយាត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ
លើពោធិបល្ល័ង្ក ការញ៉ាំងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ និង
លោកុត្តរធម៌ ៩ ” ហើយចូលទៅកាន់ព្រះនគរធ្វើព្រះបរិត្ត
ក្នុងចន្លោះកំពែងទាំង ៣ អស់យាម ៣ នៃរាត្រី ។ ពាក្យ
ត្រឹមតែថា “ **យំកិញ្ចិ** ” ជាដើម គ្រាន់តែព្រះអានន្ទពោល
ហើយប៉ុណ្ណោះ ទឹកដែលព្រះអានន្ទបាចទៅខាងលើនោះ
ធ្លាក់ចុះមកលើក្បាលអមនុស្សទាំងឡាយ ។

ចាប់ផ្តើមអំពីការពោលគាថាថា “ **យានីធ ភូតានិ** ”
ជាដើម, តំណក់ទឹកដូចជាក្រវិលប្រាក់អណ្តែតឡើងទៅឰដ៏-

អាកាស ហើយធ្លាក់ចុះមកលើក្បាលមនុស្សឈើទាំងឡាយ ។ មនុស្សឈើទាំងនោះ ជាសះស្បើយរោគក្នុងខណៈនោះភ្លាម ហើយក្រោកឡើងចោមរោមព្រះថេរៈ ។

ចាប់ផ្ដើមពីបទថា " **យំកិញ្ចិ** " ជាដើម គ្រាន់តែព្រះអានន្ទពោលហើយប៉ុណ្ណោះ អមនុស្សទាំងឡាយដែលមិនទាន់រត់ទៅក្នុងកាលមុន ដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានគំនរសម្រាមនិងជញ្ជាំងផ្ទះជាដើម ត្រូវតំណក់ទឹកពាល់ត្រូវហើយ ក៏រត់ទៅតាមទ្វារនោះៗ ។ ទ្វារទាំងឡាយមិនមានឱកាស ។ អមនុស្សទាំងនោះកាលមិនបានឱកាស ក៏ទម្លាយកំផែងរត់ចេញទៅ ។ មហាជនប្រស់ព្រំរោងទទួលភ្ញៀវដែលនៅកណ្ដាលព្រះនគរដោយគ្រឿងក្រអូបទាំងពួង ចងពិដានដែលវិចិត្រដោយផ្កាយមាសជាដើមខាងលើ តាក់តែងពុទ្ធាសនៈហើយ អារាធនាព្រះសាស្ដាមកកាន់រោងនោះ ។

ព្រះសាស្ដា ទ្រង់គង់លើអាសនៈដែលគេតាក់តែងហើយ ។ ទាំងភិក្ខុសង្ឃ ទាំងពួកស្ដេចលិច្ឆវីក៏គង់ចោមរោមព្រះសាស្ដា ចំណែកសក្កទេវរាជដែលមានពួកទេវតាចោម

រោមហើយ បានប្រថាប់ឈរក្នុងឱកាសដ៏សមគួរ ។ ចំណែក ព្រះអានន្ទ ក៏ត្រាច់ទៅកាន់ព្រះនគរទាំងមូលដោយលំដាប់ ហើយ មកជាមួយនឹងមហាជនដែលមានរោគជាសះស្បើយ ហើយថ្វាយបង្គំព្រះសាស្ដា ព្រះសាស្ដាទ្រង់ទតមើលបរិស័ទ ហើយ បានទ្រង់កាសិតរតនសូត្រនោះទៀត ។ ក្នុងកាល ចប់ទេសនា ការត្រាស់ដឹងធម៌បានមានដល់សត្វ ៨៤០០០ ។

ព្រះសាស្ដា ទ្រង់សម្ដែងរតនសូត្រនោះអស់ ៧ ថ្ងៃ ទ្រង់ជ្រាបថាភ័យទាំងពួងស្ងប់រម្ងាប់ហើយ ទ្រង់ជាស់តឿន ពួកស្ដេចលិច្ឆវីហើយ ស្ដេចចេញចាកក្រុងវេសាលី ។ ស្ដេចលិច្ឆវីទាំងឡាយបូជាព្រះសាស្ដាជាទ្វេគុណ ហើយនាំ ព្រះសាស្ដាទៅកាន់ឆ្នេរទន្លេគង្គាអស់ ៣ ថ្ងៃទៀត ។

## ពួកស្ដេចនាគធ្វើការបូជាព្រះសាស្ដា

ស្ដេចនាគទាំងឡាយ ដែលកើតនៅក្នុងទន្លេគង្គានោះ គិតថា “ មនុស្សទាំងឡាយ រមែងធ្វើសក្ការៈបូជាចំពោះព្រះ តថាគត, យើងទាំងឡាយនឹងអ្វីហ្ន៎ ? ” ស្ដេចនាគទាំងនោះ និម្មិតទូកមាស ទូកប្រាក់ និងទូកកែវមណី ហើយតាក់តែង

បល្ល័ង្កមាស ប្រាក់ និងកែវមណី ធ្វើទឹកឲ្យជេរជាសទៅ ដោយផ្កាឈូក ៥ ពណ៌ ហើយទូលអារាធនាព្រះសាស្ដា ដើម្បីប្រយោជន៍ដល់ការឡើងកាន់ទូករបស់ខ្លួនៗ ថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ធ្វើសេចក្ដីអនុគ្រោះដល់ពួកខ្ញុំព្រះអង្គទាំងឡាយចុះ” មនុស្សនិងនាគទាំងឡាយរមែងធ្វើការបូជាព្រះតថាគត ។

ទេវតាទាំងឡាយ ចាប់តាំងពីភុម្មទេវតារហូតដល់ព្រហ្មលោកឈ្មោះអកនិដ្ឋគិតថា “ ពួកយើងនឹងធ្វើអ្វីហ្ន៎ ? ” ហើយធ្វើសក្ការៈបូជាព្រះតថាគត ។

បណ្ដាមនុស្ស និងអមនុស្សទាំងនោះ នាគទាំងឡាយលើកឆត្រតម្រួតឆត្រឡើងប្រមាណមួយយោជន៍ ។ ឆត្រដែលត្រួតគ្នា ដែលមនុស្សនិងអមនុស្សទាំងឡាយលើកនោះ គឺនាគលើកឡើងពួដ៏ខាងក្រោម មនុស្សទាំងឡាយលើកឡើងលើផ្ទៃផែនដី ភុម្មដ្ឋកទេវតាលើកឡើងពួដ៏ប្រទេសទាំងឡាយមានដើមឈើ គុម្ពឈើ និងភ្នំជាដើម ពួកទេវតាដែលឋិតនៅពួដ៏អាកាសលើកឡើងពួដ៏អាកាស មនុស្ស និងអមនុស្ស

លើកឆត្រឡើងហើយ ចាប់តាំងពីពិភពនាគរហូតដល់ព្រហ្ម-លោកដោយជុំវិញចក្រវាឡ ដោយប្រការដូច្នេះ ។ ក្នុងចន្លោះឆត្រមានទង់ជ័យ, ក្នុងចន្លោះទង់ជ័យ មានទង់ផ្ទាំងសំពត់, ក្នុងចន្លោះៗ នៃទង់ទាំងនោះ មានគ្រឿងសក្ការៈទាំងឡាយ មានក្លួងផ្កា លំអិតនៃគ្រឿងអប់និងធូបជាដើម ។ ទេវបុត្រទាំងឡាយប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកភេទជាអ្នកលេងមហោស្រព ត្រាច់ទៅក្នុងអាកាសញ៉ាំងសំឡេងឲ្យគឹកកង ។ បានឮថា សមាគម ៣ គឺ “ សមាគមក្នុងវេលាសំដែងយមកប្បាដិហារ្យ ១ សមាគមក្នុងវេលាស្ដេចចុះចាកទេវលោក ១ សមាគមន៍ក្នុងវេលាស្ដេចចុះកាន់ទន្លេអង្គានេះ ១” ជាសមាគមធំ ។

## ព្រះបាទពិម្ពិសារត្រាស់ឲ្យត្រៀមរៀបចំទទួលព្រះពុទ្ធម្ដងទៀត

ចំណែកព្រះបាទពិម្ពិសារ ទ្រង់ចាត់ចែងសក្ការៈជាទ្វេគុណ អំពីសក្ការៈដែលពួកស្ដេចលិច្ឆវីធ្វើ កាលទ្រង់ទន្ទឹងរង់ចាំព្រះដំណើររបស់ព្រះមានព្រះភាគ ក៏បានយាងមកឈរនៅ

នាត្រើយខាងនាយ ។ ព្រះសាស្តាទ្រង់ទតមហាបរិច្ចាគរបស់ព្រះរាជទាំងឡាយ ក្នុងចំណែកទាំងពីរនៃច្រាំងទន្លេគង្គា ហើយទ្រង់ជ្រាបអធ្យាស្រ័យរបស់សត្វទាំងឡាយ មាននាគជាដើម ហើយទ្រង់និម្មិតព្រះពុទ្ធនិម្មិតមួយព្រះអង្គៗ មានភិក្ខុ ៥០០ ជាបរិវារក្នុងទូកមួយៗ ។ ព្រះពុទ្ធដែលព្រះអង្គទ្រង់និម្មិតនោះ ដែលមានពួកនាគចោមរោមហើយ ទ្រង់គង់នៅក្រោមស្វេតច្ឆត្រមួយដើមៗ និងដើមកល្បព្រឹក្សមួយដើមៗ និងក្លួងផ្កាមួយដើមៗ ។ ទ្រង់និម្មិតព្រះពុទ្ធនិម្មិតមួយអង្គៗមួយអន្ទើដោយបរិវារក្នុងឱកាសមួយៗ សូម្បីក្នុងទេវតាទាំងឡាយ មានភុម្មដ្ឋកទេវតាជាដើម ។ កាលផ្ទៃចក្រវាឡទាំងអស់ដូចជាមានរបាំ និងមហោស្រពតែមួយ ដោយប្រការយ៉ាងនេះហើយ, ព្រះសាស្តា កាលនឹងទ្រង់ធ្វើសេចក្តីអនុ-គ្រោះដល់នាគទាំងឡាយ បានស្តេចឡើងកាន់ទូកកែវមួយ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូបៗ ក៏ឡើងកាន់ទូកកែវនីមួយៗ ដែរ ។

ស្តេចនាគទាំងឡាយ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យចូលទៅកាន់នាគភព ស្តាប់ធម្មកថាក្នុងសំណាក់ព្រះសាស្តារហូតមួយយប់ទល់ភ្លឺ ក្នុងថ្ងៃទី ២ អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយវត្ថុដែលគួរទំពាស៊ីនិងវត្ថុដែលគួរបរិភោគដ៏ជាទិព្វ ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយចេញចាកនាគភព ដែលទេវតាក្នុងសកលចក្រវាឡបូជាហើយ ទ្រង់ឆ្លងទន្លេគង្គាដោយទូក ៥០០ ។

ព្រះរាជាទ្រង់ទទួលព្រះសាស្តាហើយ ទ្រង់អារាធនាឲ្យស្តេចចុះចាកទូក ទ្រង់ធ្វើសក្ការៈជាទ្វេគុណ អំពីសក្ការៈដែលស្តេចលិច្ឆវីទាំងឡាយធ្វើក្នុងវេលាស្តេចមក ទ្រង់នាំព្រះសាស្តាមកកាន់ក្រុងរាជគ្រឹះអស់ ៥ ថ្ងៃ ដូចក្នុងកាលមុនដែរ ។

## ពួកភិក្ខុសរសើរពុទ្ធានុភាព

ក្នុងថ្ងៃទី ២ ពួកភិក្ខុត្រឡប់មកពីបិណ្ឌបាតហើយ ក្នុងវេលារសៀលអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា "គួរឲ្យសរ-សើរ ពិតមែនហ្ន៎ ! អានុភាពរបស់ព្រះពុទ្ធទាំងឡាយ គួរ

ឲ្យអស្ចារ្យពិតមែនហ្ន៎ ! ទេវតា និងមនុស្សទាំងឡាយ នាំគ្នាជ្រះថ្លានឹងព្រះសាស្តា, ព្រះរាជាទាំងឡាយទ្រង់ធ្វើផែនដីឲ្យមានផ្ទៃស្មើក្នុងផ្លូវ ៨ យោជន៍ ទាំងត្រើយខាងអាយ ទាំងត្រើយខាងនាយនៃទន្លេគង្គា ទ្រង់រោយដីខ្សាច់ ក្រាលផ្កាឈើដែលមានពណ៌ផ្សេងៗ ប្រមាណត្រឹមជង្គង់ ដោយសេចក្តីជ្រះថ្លាដែលប្រព្រឹត្តទៅក្នុងព្រះពុទ្ធ, ទឹកក្នុងទន្លេគង្គា ក៏ដេរដាសដោយផ្កាឈូក ៥ ពណ៌ ដោយអានុភាពរបស់នាគ, ទេវតាទាំងឡាយលើកឆត្រឡើងរហូតដល់អកនិដ្ឋភព, ផ្ទៃនៃចក្រវាឡទាំងមូល ហាក់ដូចជាមានគ្រឿងអលង្ការតែមួយនិងដូចជាមានរបាំតែមួយ " ។

ព្រះសាស្តា ស្តេចមកហើយត្រាស់សួរថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ? " កាលភិក្ខុទាំងឡាយនោះ ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ដោយកថាឈ្មោះនេះ ", ទើបត្រាស់ថា គ្រឿងបូជានិងសក្ការៈនេះ មិនមែនកើតឡើងដល់តថាគតដោយពុទ្ធានុភាពទេ, មិនមែនកើតឡើងដោយអានុភាពរបស់នាគ, ទេវតា

និងព្រហ្មទេ, ប៉ុន្តែថា កើតឡើងដោយអានុភាពនៃការបរិច្ចាគ ដែលមានប្រមាណតិចក្នុងអតីត " កាលភិក្ខុទាំងឡាយទូល អារាធនាហើយ ប្រាថ្នានឹងប្រកាសសេចក្តីនោះ ទើបទ្រង់នាំ និទានមកត្រាស់ថា ៖-

# រឿងសុសិមាណព

ក្នុងអតីតកាល ក្នុងក្រុងតក្កសីលា មានព្រាហ្មណ៍ម្នាក់ ឈ្មោះសង្ខ ។ ព្រាហ្មណ៍នោះមានបុត្រម្នាក់ ជាមាណព ឈ្មោះសុសិមៈ មានអាយុប្រហែលជា ១៦ ឆ្នាំ ។ ក្នុងថ្ងៃមួយ សុសិមាណពនោះចូលទៅរកបិតាហើយ ពោលថា " បពិត្រ បិតា ខ្ញុំចង់ចូលទៅកាន់ក្រុងពារាណសីដើម្បីរៀនមន្ត "។ គ្រា នោះ បិតាពោលទៅកាន់បុត្រថា " នែបា ព្រាហ្មណ៍ឯណោះ ជាសម្លាញ់របស់បិតា ដូច្នោះ កូនឯងចូរទៅកាន់សម្នាក់របស់ សម្លាញ់នោះ ហើយរៀនចុះ " ។ សុសិមៈ ទទួលពាក្យថា " ប្រពៃហើយបិតា " ហើយទៅដល់ក្រុង ពារាណសីដោយ លំដាប់ ចូលទៅរកព្រាហ្មណ៍នោះហើយ ប្រាប់ព្រាហ្មណ៍ នោះថា កាលដែលខ្ញុំមកនេះដោយសារបិតាបញ្ជូនមក ។

គ្រានោះ ព្រាហ្មណ៍នោះទទួលសុសិមៈ ដោយគិតថា "បុត្រសម្លាញ់របស់យើង" ហើយផ្តើមប្រាប់មន្តដល់សុសិម-មាណព អ្នកមានសេចក្តីក្រវល់ក្រវាយស្ងប់ហើយដោយថ្ងៃដ៏ចម្រើន ( ជាថ្ងៃមង្គល ) សុសិមមាណពនោះរៀនរហ័សផង រៀនបានច្រើនផង ទ្រទ្រង់ចាំនូវមន្តដែលរៀនហើយៗមិនឲ្យវិនាសទៅ ដូចជាទ្រទ្រង់នូវប្រេង ( ខ្លាញ់ ) សីហៈដែលគេដាក់នៅក្នុងកាជនៈមាស មិនយូរប៉ុន្មានបានរៀនមន្តទាំងអស់ដែលខ្លួនគប្បីរៀនអំពីមាត់របស់អាចារ្យ ធ្វើការស្វាធ្យាយ រមែងឃើញខាងដើម និងកណ្តាលនៃសិល្បៈដែលខ្លួនរៀនហើយប៉ុណ្ណោះ, ( ប៉ុន្តែ ) មិនឃើញទីបំផុត ។

សុសិមមាណពនោះ ចូលទៅរកអាចារ្យហើយពោលថា "បពិត្រអាចារ្យ ខ្ញុំរមែងឃើញខាងដើម និងកណ្តាលនៃសិល្បៈនេះប៉ុណ្ណោះ, រមែងមិនឃើញទីបំផុត", កាលអាចារ្យពោលថា "ម្នាលកូន សូម្បីខ្ញុំក៏មិនឃើញដែរ", ទើបសួរថា "បពិត្រអាចារ្យ កាលបើដូច្នោះ នរណាទៅនឹងដឹងទីបំផុត", កាលអាចារ្យពោលថា "ម្នាលកូន ឥសីទាំងឡាយ ដែលនៅ

ក្នុងព្រៃឥសិបតនៈ រមែងដឹង, កូនឯងចូរទៅកាន់សម្នាក់របស់ឥសីទាំងនោះហើយសួរចុះ ” ក៏ចូលទៅរកព្រះបច្ចេក-ពុទ្ធទាំងឡាយហើយ សួរថា “ បពិត្រលោកម្ចាស់ដ៏ចម្រើនបានឮថា លោកម្ចាស់ទាំងឡាយរមែងដឹងនូវទីបំផុតឬ ?” ។

បច្ចេក. ចម្រើនពរ ឧបាសក ។

សុសិមៈ. បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ ចូរប្រាប់ខ្ញុំព្រះករុណា ។

បច្ចេក. អាត្មាទាំងឡាយ រមែងមិនប្រាប់អ្នកដែលមិនមែនជាបព្វជិត, ប្រសិនបើអ្នកត្រូវការដឹងនូវទីបំផុត, ចូរបួសចុះ ។

សុសិមមាណពនោះយល់ព្រមដោយពាក្យថា “ប្រពៃហើយ លោកម្ចាស់ ” ហើយបួសក្នុងសម្នាក់ព្រះបច្ចេកពុទ្ធទាំងនោះ ។ គ្រានោះ ព្រះបច្ចេកពុទ្ធទាំងនោះប្រាប់សុសិមៈថា “ អ្នកចូរសិក្សាអភិសមាចារិកវត្ត ( វត្តប្រកបដោយរបៀបដែលបព្វជិតគប្បីប្រព្រឹត្តឲ្យសមរម្យ ) នេះជាមុន ”

ហើយប្រាប់អភិសមាចារិកវត្តដោយន័យជាដើមថា “អ្នកគប្បី ស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ” ។

សុសិមមាណពនោះ សិក្សាអភិសមាចារិកវត្តនោះ ព្រោះខ្លួនជាអ្នកមានឧបនិស្ស័យសំបូរណ៍ មិនយូរប៉ុន្មានក៏ជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ល្បីល្បាញក្នុងក្រុងពារាណសីទាំងមូល ដូចជាព្រះចន្ទពេញវង់ក្នុងផ្ទៃពពក ជាអ្នកដល់ព្រមដោយលាភ និងយស។ មិនយូរប៉ុន្មាន សុសិម-បច្ចេកពុទ្ធនោះក៏បរិនិព្វានទៅ ព្រោះភាវៈនៃកម្មដែលប្រព្រឹត្តទៅ ដើម្បីភាពជាអ្នកមានអាយុតិចដែលលោកធ្វើហើយ ។ គ្រានោះ ព្រះបច្ចេកពុទ្ធទាំងឡាយ និងមហាជន ( ជួយគ្នា ) ធ្វើសរីរកិច្ចរបស់លោកហើយកាន់យកធាតុទៅ ដំកល់ក្នុងព្រះស្តូប ដែលនៅជិតទ្វារព្រះនគរ ។

ចំណែកសង្ខព្រាហ្មណ៍ គិតថា “ បុត្ររបស់យើងទៅសិក្សាអស់កាលយូរហើយ, យើងនឹងដឹងនូវសុខទុក្ខរបស់គេ” ប្រាថ្នានឹងឃើញបុត្រនោះ ទើបចេញចាកក្រុងតក្កសិលាទៅដល់ក្រុងពារាណសីដោយលំដាប់ ឃើញពួកមហាជន

ដែលប្រជុំគ្នាហើយ គិតថា “បណ្ដាមហាជនទាំងនោះ ប្រាកដជាមានម្នាក់ដឹងនូវការប្រព្រឹត្តទៅនៃបុត្ររបស់យើង ដោយពិត” ។ ក៏ចូលទៅរកហើយសួរថា “មាណពឈ្មោះសុសិមៈ មកកាន់ទីនេះ, អ្នកទាំងឡាយស្គាល់គេទេ ?” មហាជនតបថា “អើ ព្រាហ្មណ៍ យើងទាំងឡាយស្គាល់, សុសិមមាណព នោះស្វាធ្យាយត្រៃវេទក្នុងសម្នាក់ព្រាហ្មណ៍ឯណោះ បួសហើយធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិបញ្ញា បរិនិព្វានហើយ, នេះស្តូបរបស់លោក ដែលយើងទាំងឡាយចាត់ចែងប្រ-តិស្ឋានហើយ ” ។ សទ្ធព្រាហ្មណ៍នោះ ប្រហារផែនដីដោយដៃ យំកន្ទក់កន្ទេញហើយ ទៅកាន់លានព្រះចេតិយ ដក់ស្មៅហើយ យកសំពត់ដណ្ដប់នាំខ្សាច់មករោយរាយឲ្យដ៏លានព្រះចេតិយ ប្រស់ព្រំដោយទឹកក្នុងឃ្លោក បូជាព្រះចេតិយដោយផ្កាឈើព្រៃទាំងឡាយ លើទង់ផ្ទាំងសំពត់ដោយសំពត់សា-ដក ចងឆត្ររបស់ខ្លួនខាងលើព្រះចេតិយហើយក៏ចៀសចេញទៅ ។

## អានិសង្សនៃការបរិច្ចាគសុខល្មមប្រមាណ

ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះតថាគតជាសង្ខព្រាហ្មណ៍, តថាគតបានដកស្មៅក្នុងលានព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធឈ្មោះសុសិមៈ, ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយធ្វើផ្លូវ ៨ យោជន៍ ឲ្យប្រាសចាក់ដង្គត់និងបន្លា ធ្វើឲ្យស្អាត ឲ្យមានផ្ទៃរាបស្មើ, តថាគតបានរោយខ្សាច់ដាក់ក្នុងលានព្រះចេតិយនោះ, ដោយផលនៃកម្មនោះ ទើបជនទាំងឡាយរោយខ្សាច់ក្នុងផ្លូវ ៨ យោជន៍, តថាគតបូជាព្រះចេតិយនោះដោយផ្កាឈើព្រៃ, ដោយផលនៃកម្មនោះ ទើបជនទាំងឡាយបាចផ្កាមានពណ៌ផ្សេងៗក្នុងផ្លូវ ៨ យោជន៍, ទើបទឹកក្នុងទន្លេគង្គាដែលមានប្រមាណមួយយោជន៍ដេរដាសដោយផ្កាឈូក ៥ ពណ៌, តថាគតបានប្រស់ព្រំលានព្រះចេតិយនោះ ដោយទឹកក្នុងឃ្នោក, ដោយផលនៃកម្មនោះ ទើបភ្លៀងបោក្ខរព័ស្សធ្លាក់ចុះក្នុងក្រុងវេសាលី, តថាគតបានលើទង់ផ្ទាំងសំពត់ឡើង និងបង់ឆត្រលើព្រះចេតិយនោះ, ដោយផលនៃកម្មនោះ ទើបផ្ទៃចក្រវាឡទាំង

មូល ហាក់ដូចជាមានមហោស្រពតែមួយ ដោយទង់ជ័យ ទង់ផ្កាំងសំពត់ និងឆត្រត្រួតជាដើមរហូតដល់អកនិដ្ឋព្រហ្ម, ម្នាលភិក្ខុទាំងឡាយគ្រឿងបូជា និងសក្ការៈនោះកើតឡើង ដល់តថាគតដោយពុទ្ធានុភាពក៏ទេ, កើតឡើងដោយអានុភាព នៃនាគទេវតា និងព្រហ្មក៏ទេ, ប៉ុន្តែថា កើតឡើងដោយ អានុភាពនៃការបរិច្ចាគមានប្រមាណតិច ក្នុងអតីតកាល ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ទើបត្រាស់ព្រះគាថា នេះថា ៖-

**១. មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**
**ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំសុខំ ។**

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់
សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញ
សុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **មត្តាសុខបរិច្ចាគា** សេចក្តីថា ព្រោះលះបង់សុខតិចតួចល្មមប្រមាណ ដែលព្រះមាន

ព្រះភាគត្រាស់ថា "**មត្តាសុខំ**" ។ សុខដ៏ទូលាយ បានដល់សុខក្នុងព្រះនិព្វាន ព្រះមានព្រះភាគត្រាស់ថា សុខដ៏ទូលាយ សេចក្ដីថា បើបុគ្គលឃើញសុខដ៏ទូលាយនោះ ។

លោកអធិប្បាយទុកដូច្នេះថា "ឈ្មោះថាសុខល្មមប្រមាណ រមែងកើតឡើងដល់បុគ្គលអ្នកប្រើគេឲ្យចាត់ចែងថាសភោជនមួយថាស ហើយបរិភោគ, ចំណែកនិព្វានសុខជាសុខដ៏ទូលាយ គឺដ៏ក្រៃលែង រមែងកើតឡើងដល់បុគ្គលអ្នកលះបង់សុខល្មមប្រមាណនោះចេញហើយ ធ្វើឧបោសថខ្លះ ឲ្យទានខ្លះ, ព្រោះហេតុនោះ បើបុគ្គលឃើញសុខដ៏ទូលាយ ព្រោះលះបង់សុខល្មមប្រមាណនោះ យ៉ាងនោះ, កាលបើដូច្នោះ បណ្ឌិតកាលឃើញសុខដ៏ទូលាយនោះដោយប្រពៃហើយ គប្បីលះបង់សុខល្មមប្រមាណនោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងបុព្វកម្មរបស់ព្រះអង្គ ចប់

## ២ រឿងកុមារិកាអ្នកស៊ីស៊ុតមាន់

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកា អ្នកស៊ីស៊ុតមាន់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា " **បរទុក្ខូបធានេន** " ជាដើម ។

# មេមាន់ចងអាឃាតនឹងកុមារិកា

បានឮថា មានស្រុកមួយឈ្មោះបណ្ឌុរៈ នៅមិនឆ្ងាយអំពីក្រុងសាវត្ថី, ក្នុងស្រុកនោះ មានព្រានសន្ទូចម្នាក់ ។ ព្រានសន្ទូចនោះទៅកាន់ក្រុងសាវត្ថី ឃើញពងអណ្ដើកក្បែរស្ទឹងអចិរវតីហើយ កាន់យកពងអណ្ដើកទាំងនោះទៅកាន់ក្រុងសាវត្ថី ប្រើគេឲ្យចំអិនក្នុងផ្ទះមួយហើយទំពាស៊ី បានឲ្យមួយពងដល់កុមារិកាដែលនៅផ្ទះនោះ ។ កុមារិកានោះទំពាស៊ីពងអណ្ដើកនោះហើយ ចាប់តាំងពីពេលនោះមក មិនព្រមបរិភោគរបស់ដទៃ ។ គ្រានោះ មាតារបស់នាងយកពងមាន់មួយពងអំពីមេមាន់ហើយ ឲ្យ (នាង) ។ នាងទំពាស៊ីពងមាន់នោះហើយ ជាប់ក្នុងរស ចាប់តាំងពីពេលនោះមក ក៏យកពងមាន់មកបរិភោគខ្លួនឯង ។ ក្នុងពេលធ្លាក់ពង មេ

មាន់ឃើញកុមារិកានោះកាន់យកពងរបស់ខ្លួនស៊ី ត្រូវកុមារិ-កានោះបៀតបៀន ក៏ចងអាឃាតថា "យើងឃ្លាតចាកអត្តភាពនេះហើយ គប្បីកើតជាយក្ខិនី ទំពាស៊ីកូនរបស់នាង" ធ្វើកាលកិរិយាហើយ កើតជាមេឆ្មាក្នុងផ្ទះនោះឯង ។

## ការចងពៀរគ្នាជាហេតុឲ្យកើតទុក្ខ

ចំណែកកុមារិកាក្រៅនេះ ធ្វើកាលកិរិយាហើយ កើតជាមេមាន់ក្នុងផ្ទះនោះដែរ ។ មេមាន់ពងហើយ ។ មេឆ្មាមកស៊ីពងអស់ សូម្បីលើកទីពីរ លើកទីបី ក៏ស៊ីអស់ដែរ ។ មេមាន់ចងអាឃាតនិងមេឆ្មាថា "នាងឯងស៊ីពងទាំងឡាយរបស់យើងរហូតអស់ ៣ ដង ឥឡូវនេះ ថែមទាំងចង់ស៊ីយើងទៀត, យើងឃ្លាតចាកអត្តភាពនេះហើយ គប្បីបានស៊ីនាងព្រមទាំងកូន", ឆាប់អំពីអត្តភាពនោះហើយ កើតជាមេខ្លាដំបង ។

ចំណែកមេឆ្មា ឆាប់ទៅកើតទៅជាមេម្រឹគ ។ ក្នុងពេលមេម្រឹគកើតកូន មេខ្លាដំបងក៏មកស៊ីមេម្រឹគនោះព្រមទាំងកូនទាំងឡាយ ។ សត្វទាំងពីរប្រភេទនោះស៊ីគ្នាយ៉ាងនេះ ញ៉ាំង

ទុក្ខឲ្យកើតឡើងដល់គ្នានិងគ្នាអស់៥០០ អត្តភាព ក្នុងទីបំផុត នាងម្នាក់កើតជាយក្ខិនី នាងម្នាក់ទៀតកើតជាកុលធីតាក្នុងក្រុងសាវត្ថី ។

ពាក្យដទៃអំពីនេះ គប្បីជ្រាបតាមន័យដូចដែលព្រះមានព្រះភាគសម្តែងទុកហើយក្នុងព្រះគាថាថា **"ន ហិ វេរេន វេរានិ"** ជាដើម ។

ប៉ុន្តែក្នុងរឿននេះ ព្រះសាស្តាត្រាស់ថា "ក៏ពៀររមែងរម្ងាប់ដោយការមិនមានពៀរ, រមែងមិនរម្ងាប់ដោយពៀរ", ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ដល់ជនទាំងពីរនោះ ទើបត្រាស់ព្រះគាថានេះថា ៖-

**២. បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ**
**វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។**

ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបន្ទុកទុក្ខឲ្យអ្នកដទៃ ជននោះឈ្មោះថា ប្រឡូកប្រឡំហើយដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បរទុក្ខូបធានេន** សេចក្ដីថា ដោយបន្ដុទុក្ខឲ្យអ្នកដទៃ, អធិប្បាយថា ព្រោះញុំាងទុក្ខឲ្យកើតឡើងដល់អ្នកដទៃ ។

បាទព្រះគាថាថា **វេរសំសគ្គសំសដ្ឋោ** សេចក្ដីថា បុគ្គលនោះឈ្មោះថា ច្របូកច្របល់ហើយដោយគ្រឿងច្របូកច្របល់គឺពៀរ ដែលខ្លួនធ្វើឲ្យដល់គ្នានិងគ្នា ដោយអំណាចនៃការជេរនិងការជេរតប ការប្រហារនិងការប្រហារតប ជាដើម ។

បាទព្រះគាថាថា **វេរា សោ ន បរិមុច្ចតិ** សេចក្ដីថា រមែងដល់នូវសេចក្ដីទុក្ខតែម្យ៉ាង អស់កាលជានិច្ច ដោយអំណាចនៃពៀរ ។

ក្នុងកាលចប់ទេសនា នាងយក្ខិនីតាំងនូវក្នុងសរណៈទាំងឡាយ សមាទានសីល ៥ ផុតហើយចាកពៀរ, ចំណែកកុលធីតាតាំងនៅក្នុងសោតាបត្តិផល, ទេសនាជាគុណជាតិ

ប្រព្រឹត្តទៅមួយអន្លើដោយប្រយោជន៍ សូម្បីដល់បរិស័ទអ្នកប្រជុំគ្នាហើយ ។

រឿងកុមារិកាស៊ីស៊ុតមាន់ ចប់

## ៣ រឿងភិក្ខុអ្នកនគរកទ្និយៈ

### សេចក្តីខាងដើម

ព្រះសាស្តា កាលស្តេចអាស្រ័យនគរកទ្និយៈ ទ្រង់គង់នៅក្នុងជាតិយាវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកនគរកទ្និយៈ ត្រាស់ព្រះធម្មទេសនានេះថា "**យំ ហិ កិច្ចំ**" ជាដើម ។

### ភិក្ខុលះបង់សមណកិច្ច

បានឮថា ភិក្ខុអ្នកនគរកទ្និយៈទាំងនោះ ជាអ្នកខ្វល់ខ្វាយក្នុងការតាក់តែងទ្រទាប់ជើង ។

សមដូចព្រះឧបាលីថេរពោលទុកថា "ក្នុងសម័យនោះឯង ពួកភិក្ខុនគរកទ្និយៈ តាមប្រកបសេចក្តីព្យាយាមក្នុងការតាក់តែងទ្រទាប់ជើងប្រភេទផ្សេងៗគ្នា ធ្វើខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ នូវទ្រទាប់ជើងស្មៅ ធ្វើខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ

នូវទ្រទាប់ជើងស្មៅយាប្ចង ទ្រទាប់ជើងស្មៅដំណេកទន្សាយ ទ្រទាប់ជើងស្មៅគែលលក ទ្រទាប់ជើងសំពត់កម្ពល, រមែង បោះបង់ចោលឧទ្ទេស (សិក្សារៀនសូត្រធម៌វិន័យ) បរិបុច្ឆា (ការសាកសួរ) អធិសីល អធិចិត្ត (សមថភាវនា) អធិបញ្ញា (វិបស្សនាភាវនា) ។ ភិក្ខុទាំងឡាយ តិះដៀលការធ្វើដូច្នោះ របស់ភិក្ខុទាំងនោះហើយ ទើបក្រាបទូលព្រះសាស្តា ។

## ព្រះសាស្តាទ្រង់តិះដៀលហើយទ្រង់ទេសនា

ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុទាំងនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមកដោយកិច្ចយ៉ាងដទៃហើយ ខ្វល់ខ្វាយក្នុងកិច្ចដទៃទៅវិញ" ដូច្នេះហើយ កាលនឹងទ្រង់សំដែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា ៖-

**៣. យញ្ហិ កិច្ចំ តទបវិទ្ធំ អកិច្ចំ បន កយិរតិ**
**ឧន្នឡានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា ។**
**យេសញ្ច សុសមារទ្ធា និច្ចំ កាយគតា សតិ**
**អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ**
**សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។**

របស់ណាដែលខ្ជួនគួរធ្វើ របស់នោះពួកភិក្ខុណា
លះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ
ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចំរើន
ឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្ដីប្រមាទ
មានមានះដូចជាដើមបបុសលើកឡើងហើយ ។
លុះតែសតិប្រព្រឹត្តទៅក្នុងកាយជានិច្ច ដែលពួក
ភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ
រមែងជាអ្នកធ្វើការដែលគួររឿយ ៗ មិនធ្វើការ
ដែលមិនគួរ អាសវៈទាំងឡាយ របស់ពួកភិក្ខុ
នោះ ដែលជាមានសតិ មានសម្បជញ្ញៈ រមែង
ដល់នូវការអស់ទៅ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **យំ ហិ កិច្ចំ** សេចក្ដីថា
ក៏កម្មមានជាអាទិយ៉ាងនេះគឺ ការរក្សានូវសីលក្ខន្ធដែលប្រ-
មាណមិនបាន ការនៅព្រៃជាវត្ត ការរក្សាធុតង្គ ភាពជាអ្នក
ត្រេកអរក្នុងភាវនា ឈ្មោះថាជាកិច្ចដែលគួរធ្វើរបស់ភិក្ខុ

ចាប់ដើមអំពីកាលដែលខ្ញុំនបួសហើយ ។ ប៉ុន្តែភិក្ខុទាំងនេះ លះលែង គឺបោះបង់នូវកិច្ចដែលគួរធ្វើរបស់ខ្លួនចោល ។

បទថា **អកិច្ចំ** ជាដើម សេចក្តីថា ក៏ការប្រដាប់ឆត្រ ការតាក់តែងស្បែកជើង ការតាក់តែងទ្រនាប់ជើង បាត្រ ភាជនៈនិងធម្មក្រក និងសំពត់សម្រាប់ចងកាយ និងសំពត់សម្រាប់ចងស្មា ឈ្មោះថាជាកិច្ចមិនគួរធ្វើរបស់ភិក្ខុ, អធិប្បាថា ភិក្ខុទាំងឡាយណាធ្វើនូវកិច្ចនោះ, អាសវៈទាំង ៤ រមែងចំរើនដល់ភិក្ខុទាំងនោះ អ្នកឈ្មោះថា មានមានៈដូចជាដើមបបុសលើកឡើងហើយ ព្រោះការប្រព្រឹត្តលើកស្ទួយមានៈដូចជាដើមបបុស ឈ្មោះថាប្រមាទហើយ ព្រោះការបណ្តែតបណ្តោយសតិ ការនៅប្រាសចាកសតិ ។

បទថា **សុសមារទ្ធា** បានដល់ ផ្គងទុកល្អហើយ ។

ពីរបទថា **កាយគតា សតិ** បានដល់ ភាវនាគឺការពិចារណារឿងៗនូវកាយក្នុងកាយ ។

បទថា **អកិច្ចំ** សេចក្តីថា ភិក្ខុទាំងនោះរមែងមិនសេព គឺមិនធ្វើនូវអំពើដែលគួរធ្វើនោះ មានការប្រកដាប់តាក់តែង ឆត្រជាដើម ។

បទថា **កិច្ចេ** សេចក្តីថា ក្នុងកិច្ចដែលខ្លួនគប្បីធ្វើ គឺ ក្នុងករណីយៈ មានការរក្សាសីលក្ខន្ធដែលប្រមាណមិនបាន ជាដើម ចាប់ដើមអំពីកាលដែលខ្លួនបួសហើយ ។

បទថា **សាតច្ចការិនោ** បានដល់ មានប្រក្រតីធ្វើរឿយ ៗ គឺធ្វើមិនឈប់, អធិប្បាយថា អាសវៈសូម្បីទាំង ៤ របស់ ភិក្ខុទាំងនោះ អ្នកឈ្មោះថាមានសតិ ព្រោះមិនទៅប្រាសចាក សតិ អ្នកឈ្មោះថាមានសម្បជញ្ញៈ ព្រោះសម្បជញ្ញៈ ៤ យ៉ាងគឺ សាតថកសម្បជញ្ញៈ សប្បាយសម្បជញ្ញៈ គោចរ សម្បជញ្ញៈ អសម្មោហសម្បជញ្ញៈ រមែងដល់ការតាំងនៅ មិនបាន គឺដល់ការវិនាសទៅ បានដល់ មិនមាន ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងព្រះ - អរហត្ត ។ ទេសនាបានជាគុណជាតិមានប្រយោជន៍ សូម្បី ដល់បុគ្គលអ្នកប្រជុំគ្នាហើយ ។

*រឿងភិក្ខុអ្នកនគរកុរុ្ទិយ ចប់*

## ៨ រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលកុណ្តកភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **មាតរំ បិតរំ ហន្ត្វា** ” ជាដើម ។*

### *អាគន្តុកភិក្ខុចូលគាល់ព្រះសាស្តា*

បានឮថា ថ្ងៃមួយភិក្ខុអាគន្តុកៈច្រើនរូប ចូលទៅគាល់ព្រះសាស្តា ដែលគង់នៅក្នុងទីសម្រាក់ពេលថ្ងៃ ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ គ្រានោះព្រះលកុណ្ឌកភទ្ទិយត្ថេរដើរច្ចងកាត់ក្នុងទីមិនឆ្ងាយអំពីព្រះមានព្រះភាគ ។

ព្រះសាស្តា ទ្រង់ជ្រាបវារចិត្ត ( គឺការគិត ) របស់ភិក្ខុទាំងនោះហើយ ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភិក្ខុនោះឬ ? ភិក្ខុនោះសម្លាប់មាតាបិតាហើយ ជាអ្នកមិនមានទុក្ខ ប្រព្រឹត្តទៅ ” កាលភិក្ខុទាំងនោះសម្លឹងមើលមុខគ្នាហើយ ស្ទុះទៅកាន់សេចក្តីសង្ស័យថា “ ព្រះសាស្តា ទ្រង់ត្រាស់ដូចម្តេចហ្ន៎ ? ” ទើបក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ត្រាស់នូវពាក្យនោះឈ្មោះអ្វី ?” កាលទឹងទ្រង់សំដែងធម៌ដល់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះគាថានេះថា ៖-

**៤. មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ**
**រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ។**

បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិ-

មានះដូចជាបិតាផង សម្រាប់សស្សតទិដ្ឋិនិងឧច្ឆេទ-
ទិដ្ឋិ ដូចស្ដេចជាក្សត្រពីរព្រះអង្គផង សម្រាប់
អាយតនៈដូចជាដែន ប្រព្រឹត្តទៅមួយអន្ទើដោយ
បុរសអ្នកដើរតាមគឺស្មៀនផង រមែងបានទៅជា
ខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សានុចរំ** បានដល់ អ្នក
ដើរតាមបុរសអ្នកញុំាងសេចក្ដីចំរើន ( សួយ ) ឲ្យសម្រេច
គឺស្មៀន ។

ក៏ក្នុងព្រះគាថានេះ បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យដូច្នេះ
ថា តណ្ហា ឈ្មោះថាមាតា ព្រោះញុំាងសត្វទាំងឡាយឲ្យកើត
ក្នុងភព ៣ ព្រោះក្នុងព្រះបាលីសំដែងថា " តណ្ហាញុំាងបុរស
ឲ្យកើត " ។

អស្មិមានះ ( ការប្រកាន់ថាជាយើង ) ឈ្មោះថា បិតា
ព្រោះអស្មិមានះអាស្រ័យបិតាកើតឡើងដូច្នេះថា " យើងជា

រាជឱរសរបស់ព្រះរាជាឈ្មោះឯណោះ ឬជាបុត្តរបស់មហា-អាមាត្យរបស់ព្រះរាជាឈ្មោះឯណោះ ” ជាដើម ។

ទិដ្ឋិគ្រប់ប្រភេទ រមែងអាង រមែងគប់រកសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិទាំងពីរ ដូចអ្នកស្រុកអាស្រ័យព្រះរាជាដូច្នោះ, ព្រោះហេតុនោះ ទើបសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋឈ្មោះថា ព្រះរាជាជាក្សត្រពីរព្រះអង្គ ។

អាយតនៈ ១២ ឈ្មោះថាដែន ព្រោះជាធម្មជាតិប្រាជកស្មើនិងដែន ដោយអត្ថថាជាធម្មជាតិដ៏ទូលាយ ។ ការត្រេកត្រអាលដោយអំណាចនៃសេចក្តីស្រើបស្រាល នូវទីអាស្រ័យគឺអាយតនៈនោះ ដូចបុរសអ្នកយកសួយ ចាត់ចែងសួយឲ្យសម្រេច ឈ្មោះថានាយស្មៀនអ្នកញុំាងសួយឲ្យសម្រេច ។

បទថា **អនីឃោ** បានដល់ មិនមានទុក្ខ ។ បទថា **ព្រាហ្មណោ** បានដល់ អ្នកមានអាសវៈអស់ហើយ ។

ក្នុងព្រះគាថានេះ មានអធិប្បាយដូច្នេះ “ឈ្មោះថាខីណាស្រព ដែលប្រែថា អ្នកមានអាសវៈអស់ហើយ ព្រោះ

កិលេសទាំងឡាយមានតណ្ហាជាដើម លោកកំចាត់បាន ដោយដាវគឺអរហត្តមគ្គញ្ញាណហើយ ទើបជាអ្នកមិនមានទុក្ខ

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងព្រះអរហត្ត ។

( ព្រះគាថាទី ២ )

សូម្បីក្នុងព្រះគាថាទី ២ រឿងក៏ដូចរឿងមុននោះឯង ។

សូម្បីក្នុងកាលនោះ ព្រះសាស្ដាក៏ទ្រង់ប្រារព្ធព្រះលកុណ្ឋកភទ្ទិយត្ថេរៈដែរ កាលនឹងទ្រង់សំដែងធម៌ដល់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះគាថានេះថា ៖-

**មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ**
**វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិដូចជាស្ដេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់វិចិកិច្ឆា ដូចជាខ្លាធំជាគំរប់ ៥ ផង ( ដែលនៅស្ទាក់ផ្លូវ ) បានហើយ រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នក

មិនមានទុក្ខ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **ទ្វេ ច សោត្ថិយេ** គឺជាព្រាហ្មណ៍ទាំងពីរផង ។

ក៏ក្នុងព្រះគាថានេះ ព្រះសាស្ដាត្រាស់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិឲ្យជាព្រះរាជាអ្នកជាព្រាហ្មណ៍ទាំងពីរ ព្រោះព្រះអង្គជាធំក្នុងព្រះធម្ម និងព្រោះព្រះអង្គជាអ្នកឈ្លាសក្នុងវិធីទេសនា ។

បណ្ឌិតគប្បីជ្រាបវិគ្រោះក្នុងបទ **វេយ្យគ្ឃបញ្ចមំ** នេះថាជាផ្លូវជាទីត្រាច់ទៅរៀយរបស់ខ្លាធំ ៗ ជាផ្លូវដែលប្រកបដោយភ័យជាក់ស្ដែង ដើរទៅបានដោយលំបាក ឈ្មោះថាផ្លូវដែលខ្លាធំត្រាច់ទៅហើយ ។ សូម្បីវិចិកិច្ឆានិវរណៈ ក៏ជាធម្មជាតិប្រាកដស្មើដោយផ្លូវជាទីត្រាច់ទៅរបស់ខ្លាធំដែរ ព្រោះវិចិកិច្ឆានិវរណៈនោះ ដូចជាផ្លូវជាទីត្រាច់ទៅរបស់ខ្លាធំនោះ, វិចិកិច្ឆានិវរណៈដូចជាផ្លូវជាទីត្រាច់ទៅរបស់ខ្លាធំហើយនោះជាទី ៥ នៃពួក ៥ នៃនិវរណៈនោះ ព្រោះហេតុនោះ ពួក ៥

នៃនិវរណៈ ទើបឈ្មោះថា មានវិចិកិច្ឆានិវរណៈ ដូចជាផ្លូវជាទីត្រាច់ទៅរបស់ខ្លាធំ ជាគំរប់ ៥ ។

ក្នុងព្រះគាថាទី ២ នេះ មានអធិប្បាយដូច្នេះថា " ក៏បុគ្គលអ្នកសម្លាប់ពួក ៥ នៃនិវរណៈមានវិចិកិច្ឆានិវរណៈដូចជាផ្លូវជាទីត្រាច់ទៅរបស់ខ្លាធំ ជាគំរប់ ៥ នេះ មិនឲ្យសេសសល់ ដោយដាវគឺអរហត្តមគ្គញាណ ជាព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ត្រាច់ទៅ ។

បទដ៏សេស ដូចបទដែលមានមកក្នុងកាលមុន នោះឯង ។

រឿងលកុណ្ឋកភទ្ទិយត្ថេរ ចប់

## ៥ រឿងបុរសអ្នកទេះខស

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ប្រារព្ធបុត្តរបស់នាយទារុសាកដិកៈ ត្រាស់ព្រះធម្មទេសនានេះថា “ **សុប្បពុទ្ធំ** ” ជាដើម ។

## ក្មេងពីរនាក់លេងអង្គញ់

សេចក្តីពិស្តារថា ក្មេងក្នុងព្រះនគររាជគ្រឹះពីរនាក់ គឺ “បុត្តរបស់បុគ្គលអ្នកជាសម្មាទិដ្ឋិម្នាក់ បុត្តរបស់បុគ្គលអ្នកជាមិច្ឆាទិដ្ឋិម្នាក់” តែងតែលេងអង្គញ់ជាមួយគ្នារឿយ ៗ ។

បណ្តាក្មេងទាំងពីរនាក់នោះ បុត្តរបស់បុគ្គលអ្នកជាសម្មាទិដ្ឋិ មុននឹងបោះអង្គញ់ទៅ បានរលឹកដល់ពុទ្ធានុស្សតិ ហើយពោលថា “ **នមោ ពុទ្ធស្ស** ” ហើយទើបបោះអង្គទៅ។ ក្មេងក្រៅនេះរលឹកដល់គុណទាំងឡាយរបស់ពួកតិរ្ថិយហើយពោលថា “ **នមោ អរហន្តានំ** ” ទើបបោះអង្គញ់ទៅ ។ ក្មេងទាំងពីរនាក់នោះ បុត្តរបស់បុគ្គលអ្នកជាសម្មាទិដ្ឋិ រមែងឈ្នះបុត្តរបស់បុគ្គលអ្នកជាមិច្ឆាទិដ្ឋិចាញ់ជានិច្ច ។បុត្តរបស់បុគ្គលអ្នកជាមិច្ឆាទិដ្ឋិនោះ ឃើញកិរិយានៃបុត្តរបស់អ្នកជាសម្មាទិដ្ឋិនោះហើយ គិតថា “ សំឡាញ់ម្នាក់នេះ រលឹកហើយយ៉ាង

នោះ ពោលហើយយ៉ាងនោះ ប្រោះអង្គញ់ទៅទើបឈ្មោះយើង, សូម្បីយើងកនឹងយ៉ាងនោះដែរ ” លុះគិតដូច្នោះហើយ ករលឹកដល់ព្រះគុណរបស់ព្រះពុទ្ធដែរ ។

## ក្មេងអ្នកជាសម្មាទិដ្ឋិទៅព្រៃជាមួយបិតា

ក្រោយមក នៅថ្ងៃមួយ បិតារបស់ក្មេងអ្នកជាសម្មា-ទិដ្ឋិនោះ ទឹមរទេះហើយបរទៅកាន់ព្រៃដើម្បីត្រូវការឈើ បានទាំក្មេងនោះទៅជាមួយ ទៅដល់ព្រៃហើយញុំាងរទេះឲ្យពេញដោយឈើក្នុងព្រៃហើយ បររទេះមក ( ដល់ ) ខាងក្រៅក្រុង ប្រលែងគោទៅក្នុងទីដែលសប្បាយដោយទឹកក្នុងទីជិតបច្ចា ហើយចាត់ចែងកត្ត ។

គ្រានោះ គោរបស់គាត់ចូលទៅកាន់ក្រុងជាមួយនិងហ្វូងគោដែលចូលទៅកាន់ក្រុងក្នុងវេលារសៀល ។ ចំណែកនាយសាកដិកៈតាមរកគោ បានចូលទៅកាន់ក្រុងក្នុងវេលារសៀល ឃើញគោហើយដឹកចេញមក មិនទាន់ដល់ទ្វារព្រះនគរ កកាលគាត់មិនទាន់មកដល់ទ្វារព្រះនគរនោះ, ទ្វារព្រះនគរនោះកបានបិទ ។ គ្រានោះ បុត្តរបស់គាត់ដេកនៅក្រោម

រទេះតែម្នាក់ឯង ក្នុងចំណោកនៃរាត្រីកឈានចុះកាន់ការលេង លក ។

## ចំរើនពុទ្ធានុស្សតិការពារអមនុស្សបាន

កក្នុងក្រុងរាជគ្រឹះ តាមប្រក្រតីច្រើនទៅដោយ អមនុស្ស, ម្យ៉ាងទៀត ក្មេងនេះកដេកក្នុងទីជិតព្រៃស្មសាន។ ពួកអមនុស្សដែលនៅក្នុងព្រៃស្មសាននោះ បានឃើញក្មេង នោះ ។ អមនុស្សម្នាក់ ជាមិច្ឆាទិដ្ឋិ ជាបច្ចាមិត្តចំពោះព្រះសា-សនា, អមនុស្សម្នាក់ ជាសម្មាទិដ្ឋិ ។

បណ្ដាអមនុស្សទាំងពីរនាក់នោះ អមនុស្សដែលជា មិច្ឆាទិដ្ឋិពោលថា " ក្មេងនេះ ជាភិក្ខាហាររបស់ពួកយើង, ពួកយើងចូរទំពាស៊ីក្មេងនេះ " ។ អមនុស្សដែលជាសម្មាទិដ្ឋិ ក្រៅនេះ ហាមឃាត់អមនុស្សដែលជាមិច្ឆាទិដ្ឋិនោះ ដោយ ពាក្យថា " កុំឡើយ, អ្នកកុំពេញចិត្តដូច្នោះឡើយ " ។ អមនុស្សអ្នកជាមិច្ឆាទិដ្ឋិនោះ សូម្បីត្រូវអមនុស្សដែលជា សម្មាទិដ្ឋិនោះហាមឃាត់យ៉ាងនោះកដោយ កនៅតែមិនអើពើ

និងពាក្យរបស់អមនុស្សអ្នកជាសម្មាទិដ្ឋិនោះ ចាប់ជើងក្មេងនោះទាញមក ។

ក្នុងខណៈនោះ ក្មេងនោះពោលថា " **នមោ ពុទ្ធស្ស** " ព្រោះភាវៈនៃខ្លួនជាអ្នកមានពុទ្ធានុស្សតិអប់រំហើយ ( សន្សំ ) ។ អមនុស្សនោះភ័យខ្លាចយ៉ាងខ្លាំង ទើបបានថយទៅឈរនៅក្នុងទីមួយ ។

## អមនុស្សរក្សាក្មេងដែលដេកក្នុងព្រៃតែម្នាក់ឯងនោះ

គ្រានោះ អមនុស្សអ្នកជាសម្មាទិដ្ឋិក្រៅនេះ ពោលទៅកាន់អមនុស្សអ្នកជាមិច្ឆាទិដ្ឋិនោះថា " ពួកយើងបានធ្វើនូវអំពើដែលមិនគួរធ្វើហើយ, ពួកយើងចូរធ្វើទណ្ឌកម្មដើម្បីក្មេងនេះចុះ " ដូច្នេះហើយ បានឈររក្សាក្មេងនោះ ។ អមនុស្សអ្នកជាមិច្ឆាទិដ្ឋិចូលទៅកាន់ព្រះនគរ ញ៉ាំងថាសភោជនរបស់ព្រះរាជាឲ្យពេញហើយ នាំភោជនមក ។

ក្រោយមក អមនុស្សស្ទូម្បីទាំងពីរនាក់ដូចជាមាតានិងបិតារបស់ក្មេងនោះ ដាសក្មេងនោះឲ្យក្រោកឡើងហើយឲ្យបរិភោគភោជននោះ ប្រកាសរឿងនោះហើយ ចារឹកអក្សរ

ក្នុងថាសភោជនដោយអានុភាពរបស់យក្ស ដោយអធិដ្ឋានថា “ ព្រះរាជាប៉ុណោះ ចូរឃើញអក្សរទាំងនេះ, អ្នកដទៃចូរកុំឃើញ ” ដូច្នេះហើយ ទើបទៅ ។

ថ្ងៃស្អែកឡើង ពួករាជបុរសចលាចលថា “ ពួកចោរលួចយកភ័ណ្ឌៈគឺភាជនៈអំពីរាជត្រកូលហើយ ” ប្រើឲ្យបិទទ្វារទាំងឡាយហើយ ដែកឆេររក កាលរកមិនឃើញក្នុងព្រះនគរ ក៏ចេញចាកព្រះនគរ រកមើលខាងនោះនិងនេះក៏ឃើញថាសមាសនៅលើរទេះដែលផ្ទុកឧសនោះ ក៏ចាប់ក្មេងនោះដោយសំគាល់ថា “ ក្មេងនេះជាចោរ ” ដូច្នេះហើយ នាំក្មេងនោះទៅគាល់ព្រះរាជា ។

## ក្មេងត្រូវសួរចម្លើយ

ព្រះរាជាទ្រង់ទតឃើញអក្សរទាំងឡាយហើយ ត្រាស់សួរថា “ នែបា នេះជាអ្វី ? ” ក្មេងនោះក្រាបទូលថា “ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនដឹងទេ, មាតាបិតារបស់ខ្ញុំព្រះអង្គយកអាហារមកឲ្យខ្ញុំព្រះអង្គបរិភោគហើយ ឈររក្សាខ្ញុំព្រះអង្គ ។ ខ្ញុំព្រះអង្គគិតថា មាតាបិតារក្សាយើង ”

ទើបមិនមានការខ្លាច ចូលដល់ការលេក, ខ្ញុំព្រះអង្គដឹងត្រឹមតែប៉ុណ្ណោះ " ។

គ្រានោះ មាតានិងបិតារបស់ក្មេងនោះ ក៏បានទៅកាន់ទីនោះដែរ ។ ព្រះរាជាទ្រង់ជ្រាបរឿងនោះហើយ ទ្រង់នាំជនទាំងបីនោះទៅកាន់សំណាក់ព្រះសាស្តា ក្រាបទូលរឿងទាំងនោះហើយ ទូលសួរថា " បពិត្រព្រះអង្គដ៏ចំរើន ពុទ្ធានុស្សតិប៉ុណ្ណោះឬ ទើបជាគុណជាតិជាគ្រឿងរក្សា ? ឬថាអនុស្សតិដទៃ ក៏ជាគុណជាតជាគ្រឿងរក្សាដែរ " ។

## ព្រះសាស្តាទ្រង់សំដែងឋានៈ ៦

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ព្រះរាជាថា " បពិត្រមហារាជ ពុទ្ធានុស្សតិតែម្យ៉ាងប៉ុណ្ណោះ ជាគុណជាតិជាគ្រឿងរក្សាក៏ទេ, ក៏ចិត្តដែលជនពួកណាបានអប់រំល្អហើយក្នុងឋាន ៦ ។ កិច្ចដោយការរក្សានិងការការពារយ៉ាងដទៃ ឬ ដោយមន្តនិងឱសថ រមែងមិនមានដល់ជនទាំងនោះ ដូច្នេះហើយ កាលនឹងទ្រង់សំដែងឋាន ៦ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សុប្បពុទ្ធំ បពុជ្ឈន្តិ** សេចក្ដីថា ជនទាំងនោះកាន់យកសតិដែលប្រព្រឹត្តទៅក្នុងព្រះពុទ្ធ ហើយលក់ទៅបណ្ដាយ កាលភ្ញាក់ឡើង ឈ្មោះថាភ្ញាក់ដោយល្អ ។

បាទព្រះគាថាថា **សទា គោតមសាវកា** សេចក្ដីថា ឈ្មោះថាជាសាវការបស់ព្រះគោតម ព្រោះកើតហើយក្នុងទីបំផុតនៃការស្ដាប់ព្រះពុទ្ធអ្នកជាគោតម ( និង ) ព្រោះភាពជាអ្នកបានស្ដាប់អនុសាសនីរបស់ព្រះពុទ្ធអង្គនោះ ។

ពីរបទថា **ពុទ្ធគតា សតិ** សេចក្ដីថា សតិរបស់ជនពួកណាប្រារព្ធព្រះពុទ្ធគុណទាំងឡាយ ដែលផ្សេងដោយគុណមានជាអាទិថា " **ឥតិបិ សោ ភគវា** " ជាដើមកើតឡើងហើយ អស់កាលជានិច្ច, ជនទាំងនោះ ឈ្មោះថាភ្ញាក់ហើយដោយល្អគ្រប់កាលទាំងពួង ។ ក៏ជនទាំងនោះ កាលមិនអាច ( ដើម្បីនឹងធ្វើ ) យ៉ាងនោះបាន ធ្វើនូវពុទ្ធានុស្សតិ

ទុកក្នុងចិត្ត ក្នុងមួយថ្ងៃ ៣, ២ ដង ( ឬ ) សូម្បីតែដង ក៏ឈ្មោះថាភ្នាក់ហើយដោយល្អដែរ ។

ពីរបទថា **ធម្មគតា សតិ** សេចក្តីថា សតិដែលប្រារព្ធព្រះធម្មគុណទាំងឡាយ ដែលផ្សេងដោយគុណមានជាអាទិថា " **ស្វាក្ខាតោ ភគវតា ធម្មោ** " ជាដើមដែលកើតឡើង ។

ពីរបទថា " **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** " ជាដើមដែលកើតឡើង ។

ពីរបទថា **កាយគតា សតិ** សេចក្តីថា សតិដែលកើតឡើង ដោយអំណាចនៃអាការ ៣២ ដោយអំណាចនៃការនៅក្នុងព្រៃស្មសាន ៩ ដោយអំណាចនៃរូបជ្ឈានដែលមាននីលកសិណដែលប្រព្រឹត្តទៅខាងក្នុងជាដើម ។

ពីរបទថា **អហឹសាយ រតោ** សេចក្តីថា ត្រេកអរហើយក្នុងករុណាភាវនា ( ការចំរើនករុណា ) ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា " ភិក្ខុនោះមានចិត្តសហគតដោយករុណា ផ្សាយទៅកាន់ទិសមួយ " ។

បទថា **ភាវនាយ** បានដល់ មេត្តាភាវនា ។ ពិតណាស់ ភាវនាដ៏សេស សូម្បីទាំងអស់ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងបទថា “ **ភាវនាយ** ” នេះ ព្រោះករុណាភាវនាព្រះអង្គត្រាស់ទុកហើយក្នុងបទមុនដោយពិត, សូម្បីដូច្នោះក៏ពិតមែនហើយ ប៉ុន្តែមេត្តាភាវនាប៉ុណ្ណោះ ព្រះអង្គទ្រង់ប្រាថ្នាយកក្នុងបទថា “ **ភាវនាយ** ” នេះ ពាក្យដ៏សេសអ្នកសិក្សាគប្បីជ្រាបតាមន័យដូចពោលហើយ ក្នុងគាថាដើមនោះចុះ ។

ក្នុងកាលចប់ទេសនា ទារកនោះព្រមទាំងមាតាបិតារបស់គេតាំងនៅក្នុងសោតាបត្តិផល, ក្រោយមក ជនទាំងបីនាក់នោះបួសហើយ បានសម្រេចព្រះអរហត្ត ។ ទេសនាបានជាកថាមានប្រយោជន៍ សូម្បីដល់បរិស័ទអ្នកប្រជុំគ្នាហើយនៅទីនោះ ។

រឿងនាយទារុសាកដិកៈ ចប់

# ៦ រឿងភិក្ខុវជ្ជីបុត្ត

## សេចក្តីខាងដើម

ព្រះសាស្តាកាលទ្រង់អាស្រ័យក្រុងវេសាលី ទ្រង់នៅក្នុងព្រៃមហាវ័ន ទ្រង់ប្រារព្ធភិក្ខុដែលជាឱរសរបស់ព្រះបាទវជ្ជីមួយរូប ដែលព្រះធម្មសង្គាហកាចារ្យពោលសំដៅយកថា "ភិក្ខុអ្នកជាឱរសរបស់ព្រះបាទវជ្ជីមួយរូប នៅក្នុងព្រៃមួយ ជិតក្រុងវេសាលី ក៏ក្នុងសម័យនោះឯង នៅក្នុងក្រុងវេសាលីមានការលេងមហោស្រពមួយយប់ទល់ភ្លឺ ។ គ្រា

នោះ ភិក្ខុនោះបានឮសម្លេងគឹកកងនៃការវាយនិងការប្រគំតន្ត្រី ក៏ខ្សឹកខ្សួលពោលគាថានេះក្នុងវេលានោះថា ៖-

យើងមកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើ
ដែលគេចោលក្នុងព្រៃ ក្នុងរាត្រីប្រាកដដូច្នេះ មិន
មានអ្នកណាអន់ជាងយើងទៅទៀតទេ ។

ត្រាស់ព្រះធម្មទេសនានេះថា " **ទុប្បព្វជ្ជំ ទុរភិរមំ** " ជាដើម ។

## សំឡេងគឹកកងជាសត្រូវនឹងសមណភេទ

បានឮថា ភិក្ខុនោះជារាជឱរសក្នុងដែនវជ្ជី លះបង់រាជសម្បត្តិដែលដល់ហើយតាមវារៈ បួសហើយ ក្នុងក្រុងវេសាលី, កាលទូទៅទាំងព្រះនគរដែលគេប្រដាប់ហើយដោយគ្រឿងប្រដាប់ទាំងឡាយ មានទង់ជ័យនិងទង់ផ្កាំងសំពត់ជាដើម ធ្វើឲ្យជាប់និងឋានចាតុមហារាជ, កាលវារៈជាទីលេងមហោស្រពមួយយប់ទល់ភ្លឺ ក្នុងថ្ងៃពេញបូរមីដែលជាថ្ងៃរីកនៃផ្កាកោមុទ, បានឮសំឡេងគឹកកងនៃតន្ត្រី មានស្គរជាដើមដែលគេវាយហើយ និងសំឡេងតន្ត្រីមានពិណាជាដើម

ដែលគេប្រគំហើយ, កាលព្រះរាជា ៧០៧៧ ព្រះអង្គ, និង មន្ត្រីទាំងឡាយ មានឧបរាជានិងសេនាបតីជាដើមរបស់ព្រះរាជាទាំងនោះ ក៏មានចំនួនប៉ុណ្ណោះដែរ ដែលមាននៅក្នុងក្រុងវេសាលី ប្រដាប់តុបតែងហើយ ឈានចុះកាន់ថ្នលដើម្បីនឹងលេងនក្ខត្តឫក្ស, ចង្រ្កម ( ដើរទៅដើរមក ) នៅលើទីចង្រ្កមធំ ប្រមាណ ៦០ ហត្ថ ឃើញព្រះចន្ទពេញវង់អណ្តែតនៅលើផ្ទៃមេឃ ឈរផ្អែកផ្ទាំងក្តានៅក្នុងទីបំផុតនៃទីចង្រ្កមហើយ សម្លឹងមើលអត្តភាពដូចជាកំណាត់ឈើដែលបោះបោលក្នុងព្រៃ ព្រោះមិនមានសំពត់សម្រាប់ជូតក្បាលនិងគ្រឿងអលង្ការ គិតថា " អ្នកដទៃដែលអន់ជាងយើង មានដែរឬ ? " ស្លូវប្រែកបដោយគុណមានការនៅព្រៃជាវត្តជាដើមតាមប្រក្រតី ក្នុងខណៈនោះ ត្រូវសេចក្តីមិនត្រេកអរបៀតបៀន ទើបពោលយ៉ាងនោះ ។

## ទេវតាពោលគាថាឲ្យកើតសេចក្តីសង្វេគ

លោកបានឮគាថានេះ ដែលទេវតាឋិតនៅក្នុងព្រៃសណ្ឌនោះ ពោលហើយថា ៖-

លោកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើ ដែលគេចោលនៅក្នុងព្រៃមែន តែមានជនច្រើន គ្នាស្រឡាញ់លោកនោះ ដូចពួកសត្វក្នុងឋាននរក ស្រឡាញ់ពួកទេវតាក្នុងឋានសួគ៌ ។

ដោយសេចក្ដីប្រាថ្នាថា " យើងនឹងញុាំងភិក្ខុនេះឲ្យសង្វេគ " ថ្ងៃស្អែកឡើងចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ ។

## ព្រះសាស្ដាទ្រង់សំដែងទុក្ខ ៥ យ៉ាង

ព្រះសាស្ដាទ្រង់ជ្រាបរឿងនោះហើយ ប្រាថ្នានឹងប្រកាសយកវាសជាទុក្ខ ទើបទ្រង់រួបរួមទុក្ខ ៥ យ៉ាងហើយ ត្រាស់ព្រះគាថានេះថា ៖-

**៦. ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុក្ខា**
**ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ**
**តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។**

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបាន ដោយក្រ ផ្ទះទាំងឡាយមានការគ្រប់គ្រងដោយ

លំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា (ដែលមិនមានសេចក្ដីកោតក្រែង) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្ដៈ តែងត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្ដីទុក្ខជាប់តាមផង ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា **ទុប្បព្វជ្ជំ** សេចក្ដីថា ឈ្មោះថា ការលះបង់គំនរភោគៈតិចក្ដី ច្រើនក្ដី និងញាតិបួសប្រគល់ឧរៈ ( ថ្វាយជីវិត ) ចំពោះសាសនានេះ ជាការក្រ ។

បទថា **ទុរភិរមំ** សេចក្ដីថា ការដែលកុលបុត្របួសហើយយ៉ាងនោះ ញុំាងការប្រព្រឹត្តទៅនៃជីវិតដោយការត្រាច់ទៅដើម្បីភិក្ខា ត្រេកអរយ៉ាងក្រៃលែងដោយអំណាចនៃការគ្រប់គ្រងគុណគឺសីលដែលមិនមានប្រមាណ និងបំពេញការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ឲ្យបរិបូរណ៍ ជាការក្រ ។

បទថា **ទុរាវាសា** សេចក្តីថា ក៏រាជកិច្ចរបស់ព្រះរាជាឥស្សរកិច្ចរបស់ឥស្សរជនទាំងឡាយ ដែលអ្នកគ្រប់គ្រងផ្ទះត្រូវនាំទៅ, ជនដែលនៅជិតខាងគ្នានិងសមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ ដែលអ្នកគ្រប់គ្រងផ្ទះត្រូវសង្គ្រោះ, សូម្បីយ៉ាងនេះក៏ដោយ ការគ្រប់គ្រងផ្ទះក៏បំពេញឲ្យពេញបានដោយក្រដូចធ្លាំងធ្លុះនិងដូចមហាសមុទ្រដូច្នេះ, ព្រោះហេតុដូច្នោះ ផ្ទះទាំងនោះ ដែលគ្រប់គ្រងមិនល្អ ទើបឈ្មោះថា ឲ្យកើតទុក្ខ គឺឲ្យលំបាកក្នុងការគ្រប់គ្រង ។

បាទព្រះគាថាថា **ទុក្ខោ សមានសំវាសោ** សេចក្តីថា ពិតណាស់ ជនពួកណា ជាគ្រហស្ថ សូម្បីស្មើគ្នាដោយជាតិគោត្រ ត្រកូល និងភោគៈក្តី ជាបព្វជិត ស្មើគ្នាដោយគុណទាំងឡាយ មានសីល អាចារៈនិងពាហុសច្ចៈជាដើមក្តី (តែ) ពោលពាក្យជាដើមថា “ អ្នកជានរណា ? យើងជានរណា?” ជាអ្នកខ្វល់ខ្វាយក្នុងអធិករណ៍, ជនទាំងនោះ ឈ្មោះថា អ្នកមិនស្មើគ្នា, ឈ្មោះថា ការនៅរួមនិងជនទាំង នោះជាទុក្ខ ។

បាទព្រះគាថាថា **ទុក្ខានុបតិតទ្ធគូ** សេចក្តីថា ជនទាំងឡាយណា ឈ្មោះថា អ្នកដើរផ្លូវឆ្ងាយ ព្រោះជាអ្នកធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយ ពោលគឺវដ្តៈ ជនទាំងនោះត្រូវទុក្ខជាប់តាមដោយពិត ។

ពីរបទថា **តស្មា ន ចទ្ធគូ** សេចក្តីថា សូម្បីជនអ្នកដែលទុក្ខជាប់តាម ក៏ជាទុក្ខ សូម្បីជនអ្នកដើរផ្លូវឆ្ងាយ ក៏ជាទុក្ខ, ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយ ព្រោះការដើរផ្លូវឆ្ងាយពោលគឺវដ្តៈផង មិនគប្បីជាអ្នកត្រូវទុក្ខមានប្រការដូចពោលហើយជាប់តាមផង ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះនៀយណាយក្នុងទុក្ខដែលព្រះអង្គទ្រង់ត្រាស់ក្នុងឋានៈ ៥ ហើយ ទំលាយសំយោជនៈដែលជាចំណែកខាងក្រោម ៥ ដែលជាចំណែកខាងលើ ៥ តាំងនៅក្នុងព្រះអរហត្ត ។

រឿងភិក្ខុវជ្ជីបុត្រ ចប់

## ៧ រឿងចិត្តគហបតី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចិត្តគហបតី ត្រាស់ព្រះធម្មទេសនានេះថា " **សទ្ធោ សីលេន សម្បន្នោ** " ជាដើម ។

## លាភសក្ការៈកើតឡើងដល់ចិត្តគហបតី

រឿងខ្ញុំម្ចាស់ឲ្យពិស្ដាហើយ ក្នុងវណ្ណនានៃព្រះគាថាក្នុងពាលថា " **អសន្តំ ភាវមិច្ឆេយ្យ** " ជាដើម ។ សូម្បីព្រះគាថា ( នេះ ) ក៏មកហើយក្នុងពាលវគ្គនោះដែរ ។ ពិតណាស់ ក្នុងពាលវគ្គនោះ ខ្ញុំម្ចាស់ពោលទុកថា

( ព្រះអានន្ទត្ថេរៈ ទូលសួរព្រះសាស្ដាថា ) " បពិត្រព្រះអង្គដ៏ចំរើន ក៏សក្ការៈនេះកើតឡើងដល់ចិត្តគហបតី អ្នកមកកាន់សំណាក់ព្រះអង្គប៉ុណ្ណោះឬ ? ឬសូម្បីទៅកាន់ទីដទៃក៏កើតឡើងដែរ ? "

ព្រះសាស្ដាត្រាស់ថា " ម្នាលអានន្ទ កាលចិត្តគហបតីនោះមកកាន់សំណាក់តថាគតក្ដី ទៅកាន់ទីដទៃក្ដី, សក្ការៈរមែងកើតឡើងទាំងអស់, ព្រោះឧបាសកនេះ ជាអ្នក

មានសទ្ធា មានសេចក្ដីជ្រះថ្លា បរិបូរណ៍ដោយសីល, ឧបាសកបែបនេះ ទៅកាន់ប្រទេសណា ៗ លាភសក្ការៈរមែងកើតឡើងដល់គេក្នុងប្រទេសនោះ ៗ ” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖-

**៧. សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ**
**យំ យំ ទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលអ្នកមានសទ្ធា បរិបូរណ៍ដោយសីល ស្កប់ស្កល់ដោយយសនិងភោគសម្បត្តិ គប់រកប្រទេសណា ៗ គេតែងបូជាក្នុងប្រទេសនោះ ៗ

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សទ្ធោ** បានដល់ អ្នកប្រកបដោយសទ្ធាដែលជាលោកិយៈនិងលោកុត្តរៈ ។

បទថា **សីលេន** សេចក្ដីថា សីលមានពីរយ៉ាងគឺ សីលសម្រាប់អ្នកគ្រប់គ្រងផ្ទះ ១ សីលសម្រាប់អ្នកមិនគ្រប់គ្រងផ្ទះ ១, សីលទាំងពីរយ៉ាងនោះ សីលសម្រាប់អ្នក គ្រប់

គ្រងផ្ទះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងបទនេះ, សេចក្ដីថា អ្នកប្រកបដោយសីលសម្រាប់អ្នកគ្រប់គ្រងផ្ទះនោះ ។

បាទព្រះគាថាថា **យសោភោគសមប្បិតោ** សេចក្ដីថា អ្នកស្កប់ស្កល់ដោយយសសម្រាប់អ្នកគ្រប់គ្រងផ្ទះ ពោលគឺការមានឧបាសក ៥០០ ជាបរិវារ ដូចរបស់ជនទាំងឡាយមានអនាថបិណ្ឌិកសេដ្ឋីជាដើម និងដោយភោគៈពីរយ៉ាងគឺ ភោគៈទាំងឡាយ មានទ្រព្យនិងស្រូវអង្ករជាដើម ១ ភោគៈគឺអរិយទ្រព្យ ៧ ប្រការ ១។

ពីរបទថា **យំ យំ** ជាដើម សេចក្ដីថា កុលបុត្របែបនេះ ទៅកាន់ប្រទេសណា ៗ ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម, រមែងជាអ្នកដែលគេបូជាហើយក្នុងប្រទេសនោះ ៗ ដោយលាភនិងសក្ការៈបែបនោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងចិត្តគហបតី ចប់

# ៨ រឿងនាងចូឡសុភទ្រា

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធិតារបស់អនាថបិណ្ឌិកសេដ្ឋី ឈ្មោះចូឡសុភទ្រា ត្រាស់ព្រះធម្មទេសនានេះថា “ **ទូរេ សន្តោ បកាសេន្តិ** ” ជាដើម។

## សេដ្ឋីពីរនាក់ធ្វើកតិកាចំពោះគ្នា

បានឮថា សេដ្ឋីបុត្រឈ្មោះឧគ្គៈ អ្នកស្រុកឧគ្គនគរជាសម្លាញ់និងអនាថបិណ្ឌិកសេដ្ឋី តាំងតែពីនៅកំឡោះ ។

សម្លាញ់ទាំងពីរនាក់នោះ រៀនសិល្បៈក្នុងសំណាក់អាចារ្យជាមួយគ្នា ធ្វើកតិកាជាមួយគ្នាថា “ ក្នុងវេលាដែលយើងទាំងពីរនាក់ចំរើនវ័យ កាលបុត្រនិងធិតាកើតហើយ, អ្នកណាសូមធិតាដើម្បីប្រយោជន៍ដល់បុត្រ អ្នកនោះត្រូវឲ្យធិតាដល់អ្នកនោះ ” សម្លាញ់ទាំងពីរនាក់នោះចំរើនវ័យហើយ តាំងនៅក្នុងតំណែងជាសេដ្ឋីក្នុងនគររបស់ខ្លួន ៗ ។

សម័យមួយ ឧគ្គសេដ្ឋីប្រកបការជួញ បានទៅកាន់ក្រុងសាវត្ថីជាមួយនិងរទេះ ៥០០ ។ អនាថបិណ្ឌិកសេដ្ឋីហៅនាងចូឡសុភទ្រាធិតារបស់ខ្លួនមកផ្តាំថា “ ម្នាលនាងដ៏ចំរើន បិតារបស់កូនឯងឈ្មោះឧគ្គសេដ្ឋីមកហើយ, កិច្ចដែលគួរធ្វើចំពោះបិតារបស់កូនឯង ជាភារៈរបស់កូនឯង ” ។

## ឧគ្គសេដ្ឋីសូមនាងចូឡសុភទ្រាដើម្បីបុត្រ

នាងយល់ព្រមដោយពាក្យថា “ ប្រពៃហើយ បិតា ” ទើបចាត់ចែងភោជនមានសម្លនិងម្ហូបគ្រៀមជាដើម ដោយដៃរបស់ខ្លួន ចាប់តាំងពីថ្ងៃដែលឧគ្គសេដ្ឋីមក, ត្រៀមវត្ថុផ្សេងៗ មានកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាដើមទុក, ក្នុងពេលបរភោគ ក៏ចាត់ចែងទឹកសម្រាប់ងូតទុក ( រង់ចាំ ) សេដ្ឋីនោះ ចាប់តាំងអំពីពេលងូតទឹកទៅ រមែងធ្វើកិច្ចគ្រប់យ៉ាងសម្រេចដោយរៀបរយល្អ ។

ឧគ្គសេដ្ឋី ឃើញអាចារសម្បត្តិរបស់នាងចូឡសុភទ្រានោះហើយ មានចិត្តជ្រះថ្លា ថ្ងៃមួយ អង្គុយជាមួយនិងអនាថបិណ្ឌិកសេដ្ឋី ដោយកថាដែលប្រារព្ធអំពីសេចក្តីសុខហើយ

នឹកបានថា " ក្នុងកាលដែលយើងនៅកំឡោះ យើងពីរនាក់ធ្វើកតិកាគ្នាយ៉ាងនេះទុកហើយ " ទើបសូមនាងចូឡសុភទ្រាឲ្យបុត្ររបស់ខ្លួន ។ ប៉ុន្តែ ឧគ្គសេដ្ឋីនោះ តាមប្រក្រតីជាមនុស្សមិច្ឆាទិដ្ឋិ, ព្រោះហេតុនោះ ទើបអនាថបិណ្ឌិកសេដ្ឋីក្រាបទូលរឿងនោះចំពោះព្រះទសពល ព្រះសាស្ដាទ្រង់ឃើញឧបនិស្ស័យរបស់ឧគ្គសេដ្ឋីហើយទ្រង់អនុញ្ញាត, ទើបប្រឹក្សានិងភរិយា ហើយទទួលពាក្យរបស់ឧគ្គសេដ្ឋីនោះ កំណត់ថ្ងៃ ( អាពាហ៍ពិពាហ៍ )ហើយ, ធ្វើសក្ការៈជាច្រើន ដូចធនញ្ជ័យសេដ្ឋីធ្វើឲ្យនាងវិសាខដែលជាធិតា ហើយបញ្ជូនទៅដូច្នោះ, ហៅនាងចូឡសុភទ្រាមកហើយ ឲ្យឱវាទ ១០ ប្រការជាដើមថា " ម្នាលកូនសម្លាញ់ ធម្មតាស្ត្រីដែលនៅក្នុងត្រកូលម្ដាយក្មេកពុកក្មេក មិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅទេ " តាមន័យដូចដែលធនញ្ជ័យសេដ្ឋីឲ្យដល់នាងវិសាខដូច្នោះ កាលនឹងបញ្ជូនទៅ ចាត់កុដុម្ពី ៨ នាក់ឲ្យជាអ្នកទទួលខុសត្រូវថា " ប្រសិនបើទោសរបស់ធិតាខ្ញុំកើតឡើងក្នុងទីដែលទៅហើយ, ពួកលោកត្រូវជំរះ, " ក្នុងថ្ងៃដែលជាទី

បញ្ជូនធិតានោះទៅ បានថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន, ហើយបញ្ជូនធិតាទៅដោយសក្ការៈជាច្រើន ដូចសំដែងការចំរើននៃផលសុចរិតទាំងឡាយ ដែលធិតារបស់ខ្លួនធ្វើទុកហើយក្នុងកពមុន ឲ្យប្រាកដដល់សត្វលោក ។ ក្នុងវេលាដែលនាងទៅដល់ឧគ្គនគរ មហាជនព្រមទាំងត្រកូលខាងស្វាមី បានធ្វើការទទួលនាង ។

ចំណែកនាងចូឡសុភទ្រានោះ សំដែងខ្លួនដល់អ្នកនគរទាំងអស់ ដូចនាងវិសាខា ដើម្បីធ្វើសិរិមសម្បត្តិរបស់ខ្លួនឲ្យប្រាកដ បានឈរនៅលើរថចូលទៅកាន់នគរ ទទួលគ្រឿងបណ្ណាការដែលអ្នកនគរបញ្ជូនមកហើយ បញ្ជូនតបទៅជនទាំងនោះវិញ ដោយអំណាចនៃវត្តតាមសមគួរ បានធ្វើអ្នកនគរទាំងអស់ឲ្យជាប់និងគុណរបស់ខ្លួន ។

## ឪពុកក្មេកឲ្យនាងចូឡសុភទ្រាថ្វាយបង្គំអ្នកបួសស្រោត

ក្នុងថ្ងៃមង្គលជាដើម ឪពុកក្មេករបស់នាង កាលនឹងធ្វើគ្រឿងសក្ការៈបូជាអ្នកបួសស្រោតទាំងនោះ បានបញ្ជូនមនុស្សឲ្យទៅហៅនាងដោយពាក្យថា “ នាងចូរមកថ្វាយបង្គំ

ព្រះសមណៈទាំងឡាយរបស់ពួកយើង " នាងមិនអាចនឹងមើលអ្នកបួសស្រោតទាំងឡាយបាន ព្រោះខ្មាសអៀន មិនប្រាថ្នានឹងទៅ, ឪពុកក្មេករបស់នាងប្រើគេឲ្យទៅហៅនាងរឿយ ៗ នាងក៏ប្រកែករឿយ ៗ ដែរ ឪពុកក្មេករបស់នាងក្រោធហើយពោលពាក្យថា " ពួកអ្នកចូរបញ្ចេញវាចេញអំពីផ្ទះរបស់យើង " នាងគិតថា " ឪពុកក្មេករបស់យើងមិនអាចដាក់ទោសយើង ដោយហេតុមិនសមគួរបានទេ " ឲ្យគេទៅហៅកុដុម្ពីមកហើយ ប្រាប់សេចក្តីនោះ, កុដុម្ពីទាំងនោះដឹងថានាងមិនមានទោស ទើបញុំាងសេដ្ឋីឲ្យយល់ព្រម ។ សេដ្ឋីនោះប្រាប់ភរិយារបស់ខ្លួនថា " កូនប្រសានេះមិនថ្វាយបង្គំព្រះសមណៈទាំងឡាយរបស់យើង ដោយយល់ថា " ជាអ្នកមិនមានសេចក្តីខ្មាសអៀន " ។

ភរិយាសេដ្ឋីនោះគិតថា " ពួកសមណៈរបស់កូនប្រសាយើងនោះ ដូចម្តេចទៅហ្ន៎ ? នាងសរសើរសមណទាំងនោះខ្លាំងណាស់" ឲ្យគេទៅហៅនាងមកហើយ សួរថា ៖-

" ពួកសមណៈរបស់នាង ប្រាកដយ៉ាងណា ?

ហេតុដូចម្ដេច ទើបនាងសរសើរសមណៈទាំងនោះ ខ្លាំងក្លាម៉្លេះ ? ព្រះសមណៈទាំងនោះ មានសីល យ៉ាងណា ? មានសមាចារយ៉ាងណា ? នាងដែល យើងសួរហើយ ចូរប្រាប់រឿងនោះដល់យើង ”

គ្រានោះ នាងចូឡសុភទ្រាប្រកាសគុណទាំងឡាយ របស់ព្រះពុទ្ធ និងព្រះសាវករបស់ព្រះពុទ្ធ ដល់ម្ដាយក្មេក របស់នាងហើយ ញុំាងម្ដាយក្មេករបស់នាងឲ្យត្រេកអរ ដោយពាក្យទាំងឡាយ មានជាដើមយ៉ាងនេះថា ៖-

## កូនប្រសាប្រាប់សមណភាពដល់ម្ដាយក្មេក

“ លោកអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ លោក ដើរ ឈរបៀបរយល្អ មានចក្ខុដាក់ចុះ និយាយល្មម ប្រមាណ, ពួកសមណៈរបស់ខ្ញុំប្រាកដដូច្នោះ ។ កាយកម្មរបស់លោកស្អាត, វចីកម្មមិនកករល្អក់, មនោកម្មស្អាតស្អំដោយប្រពៃ ពួកសមណរបស់ ខ្ញុំប្រាកដដូច្នោះ ។ លោកមិនមានមន្ទិល មានរស្មី ដូចស័ង្ខនិងមុក្តា បរិសុទ្ធិទាំងខាងក្នុង ទាំងខាង

ក្រៅ ពេញទៅដោយធម៌ដ៏បរិសុទ្ធិទាំងឡាយ ។ ពួកសមណៈរបស់ខ្ញុំប្រាកដដូច្នោះ ។ លោកខ្ពស់ឡើងដោយលាភផង ទាបចុះដោយសារការមិនមានលាភផង, លោកតាំងនៅដោយភាវៈតែម្យ៉ាងដោយសារលាភនិងការមិនមានលាភ, ពួកសមណៈរបស់ខ្ញុំប្រាកដដូច្នោះ ។ លោកខ្ពស់ឡើងព្រោះយស ទាបចុះព្រោះមិនមានយស, លោកតាំងនៅដោយភាវៈតែម្យ៉ាង ព្រោះយសនិងព្រោះមិនមានយស, ពួកសមណៈរបស់ខ្ញុំប្រាកដដូច្នោះ ។ លោកខ្ពស់ឡើងព្រោះសរសើរ និងទាបចុះព្រោះនិន្ទា, លោកជាអ្នកស្មើព្រោះនិន្ទានិងសរសើរ, ពួកសមណៈរបស់ខ្ញុំប្រាកដដូច្នោះ ។ លោកខ្ពស់ឡើងព្រោះសុខ និងទាបចុះព្រោះទុក្ខ, លោកមិនញាប់ញ័រក្នុងសុខនិងទុក្ខ, ពួកសមណៈរបស់ខ្ញុំប្រាកដដូច្នោះ " ។

**នាងចូឡសុភទ្រានិមន្តភិក្ខុសង្ឃទទួលភត្ត**

គ្រានោះ ម្តាយក្មេកពោលទៅកាន់នាងថា “ នាងអាចសុំដែងសមណៈទាំងឡាយរបស់នាងដល់ពួកយើងបានឬ”? កាលនាងតបថា “ អាច ” ក៏ពោលថា “ បើដូច្នោះ នាងចូរធ្វើយ៉ាងណាឲ្យពួកយើងបានឃើញសមណៈទាំងនោះ ” នាងយល់ព្រមថា “ ប្រពៃហើយ ” ត្រៀមមហាទានដើម្បីភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានហើយ ឈរនៅលើផ្ទៃប្រាសាទជាន់លើ បែរមុខឆ្ពោះទៅរកវត្តជេតពន ថ្វាយបង្គំដោយគោរព ដោយបញ្ចង្គបតិស្ឋាន រលឹកដល់ព្រះពុទ្ធគុណទាំងឡាយ ធ្វើការបូជាដោយគ្រឿងក្រអូប គ្រឿងលាប ផ្កាឈើនិងធូប ពោល ( និមន្ត ) ថា “ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះ អង្គនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភត្តក្នុងថ្ងៃស្អែក, ដោយសញ្ញាណរបស់ខ្ញុំព្រះអង្គនេះ សូមព្រះសាស្តាទ្រង់ជ្រាបថា ព្រះអង្គជាអ្នកដែលខ្ញុំព្រះអង្គនិមន្តហើយ ” ដូច្នេះហើយ ទើបបាច់ផ្កាម្លិះ ៨ ក្តាប់ទៅក្នុងអាកាស ។

ផ្កាឈើទាំងឡាយ អណ្តែតទៅជាពិតានដែលសម្រេចដោយកម្រងផ្កា បានតាំងនៅខាងលើព្រះសាស្តាដែលកំពុងសំដែងធម៌កណ្តាលបរិស័ទទាំង ៤ ។

## សប្បុរសរមែងប្រាកដក្នុងទីឆ្ងាយ

ក្នុងខណៈនោះ អនាថបិណ្ឌិកសេដ្ឋីស្តាប់ធម៌កថាហើយ និមន្តព្រះសាស្តាដើម្បីទទួលភត្តក្នុងថ្ងៃស្អែក ។ ព្រះសាស្តាត្រាស់ថា “ គហបតី តថាគតបានទទួលការនិមន្តហើយ ” កាលអនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន អ្នកដទៃដែលមកមុនខ្ញុំព្រះអង្គមិនមាន, តើព្រះអង្គទ្រង់ទទួលការនិមន្តរបស់អ្នកណាហ្ន៎ ?” ត្រាស់ថា “ម្នាលគហបតី នាងចូឡសុភទ្រានិមន្តតថាគតទុកហើយ ” ។ កាលអនាថបិណ្ឌិកសេដ្ឋីពោលថា “ នាងសុភទ្រានៅក្នុងទីឆ្ងាយប្រមាណ ១២០ យោជន៍អំពីទីនេះមិនមែនឬ ព្រះអង្គ ?” ត្រាស់ថា “ អើ គហបតី ក៏សប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយ ក៏រមែងប្រាកដដូចឈរនៅចំពោះមុខ ” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៈ-

៨. ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តិខិត្តា យថា សរា ។

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិម-ពាន្តដូច្នោះ ពួកអសប្បុរស ( ទុកជាឋិតនៅ ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សន្តោ** ជាដើម សេចក្ដីថា អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ឈ្មោះថា សប្បុរស ព្រោះកិលេសទាំងឡាយ មានរាគៈជាដើម ស្ងប់ហើយ, ប៉ុន្តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកសត្វអ្នកមានអធិការ ( បុណ្យ ) ដែលបានធ្វើទុកហើយ ក្នុងព្រះពុទ្ធក្នុងកាលមុន មានកុសលមូលសន្សំទុកហើយ ( និង ) អប់រំភាវនាហើយថា " សប្បុរស " ។

បទថា **បកាសេន្តិ** សេចក្តីថា សូម្បីឈរនៅក្នុងទីឆ្ងាយ កាលមកកាន់គន្លងព្រះញាណរបស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា រមែងប្រាកដបាន

បទថា **ហិមវន្តោវ** សេចក្តីថា ដូចយ៉ាងថា ភ្នំហិមពាន្តទំហំ ៣,០០០ យោជន៍ កំពស់ ៥០០ យោជន៍ ប្រកបដោយកំពូល ៨៤,០០០ រមែងប្រាកដសូម្បីដល់ជនទាំងឡាយដែលឈរនៅទីឆ្ងាយ ដូចប្រាកដនៅចំពោះមុខ យ៉ាងណា, សប្បុរសទាំងឡាយ រមែងប្រាកដ ដូច្នោះដែរ ។

បទថា **អសន្តេត្ថ** សេចក្តីថា បុគ្គលពាលធ្ងន់ក្នុងទិដ្ឋិធម៌ មានបរលោកកន្លងទៅហើយ ឃើញតែអាមិស បួសដើម្បីចិញ្ចឹមជីវិត ឈ្មោះថា អសប្បុរស, អសប្បុរសទាំងនោះ សូម្បីអង្គុយនៅក្នុងទីជិត គឺក្នុងទីជិតមណ្ឌលនៃព្រះជានុខាងស្តាំរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនប្រាកដ គឺរមែងមិនជ្រាប ។

ពីរបទថា **រត្តឹ ខិត្តា** គឺដូចព្រួញដែលបុគ្គលបាញ់ទៅក្នុងវេលាយប់ គឺក្នុងទីងងឹតប្រកបដោយអង្គ ៤ ( អង្គ ៤ គឺ

ថ្ងៃ ១៤, ១៥ កេច ១ ពាក់កណ្ដាលយប់ ១ ព្រៃក្រាស់ ១ មេឃមានដុំពពកក្រាស់ ១ ) ។

អធិប្បាយថា អសប្បុរសទាំងនោះ រមែងមិនប្រាកដ ព្រោះមិនមានបុព្វហេតុ ដែលជាឧបនិស្ស័យបែបនោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

## វិស្សុកម្មទេវបុត្រនិមិត្តផ្ទះកំពូល ៥០០ ខ្នង

ចំណែកសក្កទេវរាជ ទ្រង់ជ្រាបថា " ព្រះសាស្ដាទ្រង់ទទួលការនិមន្តរបស់នាងចូឡសុភទ្រាហើយ " ក៏ទ្រង់បញ្ជាវិស្សុកម្មទេវបុត្រថា " ម្នាលវិស្សុកម្ម អ្នកចូរនិមិត្តផ្ទះកំពូល ៥០០ ខ្នង ហើយនាំភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានទៅកាន់ឧគ្គនគរក្នុងថ្ងៃស្អែក " ។

ថ្ងៃស្អែកឡើង វិស្សុកម្មទេវបុត្រនោះ និម្មិតផ្ទះកំពូល ៥០០ ខ្នងហើយ ឈរនៅក្បែរក្លោងទ្វារវត្តជេតពន ។ ព្រះសាស្ដាទ្រង់ជ្រើសរើសហើយ នាំភិក្ខុខីណាស្រពអ្នកបរិសុទ្ធិ

ទាំងអស់ ៥០០ រូប មួយអន្ទើដោយបរិវារគង់នៅក្នុងផ្ទះកំ-
ពូលនោះហើយ ស្តេចទៅកាន់ឧគ្គនគរ ។

## ឧគ្គសេដ្ឋីត្រឡប់មកជ្រះថ្លានិងព្រះពុទ្ធសាសនាវិញ

ចំណែកឧគ្គសេដ្ឋីមួយអន្ទើដោយបរិវារ ចាំមើលផ្លូវព្រះសម្មាសម្ពុទ្ធ ដោយន័យដូចដែលនាងចូឡសុភទ្រាឲ្យហើយ ឃើញព្រះសាស្តាស្តេចមកដោយសិរីសម្បត្តិដ៏ធំ មានចិត្តជ្រះថ្លាហើយ ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានកម្រងផ្កាជាដើម ទទួលព្រះសាស្តាហើយ ថ្វាយបង្គំ ថ្វាយមហាទាន និមន្តព្រះសាស្តាម្តងទៀតហើយ ថ្វាយមហាទានអស់ ៧ ថ្ងៃ ។

ចំណែកព្រះសាស្តា ទ្រង់កំណត់ធម៌ដែលជាទីសប្បាយរបស់សេដ្ឋីនោះហើយ ទ្រង់សំដែងធម៌, សត្វប្រាំបីម៉ឺនបួនពាន់ ធ្វើសេដ្ឋីនោះឲ្យជាដើម ហើយបានត្រាស់ដឹងធម៌

ព្រះសាស្តា ដើម្បីទ្រង់អនុគ្រោះនាងសុភទ្រា ទើបបញ្ជាឲ្យព្រះអនុរុទ្ធត្ថេរៈត្រឡប់ ដោយព្រះតម្រាស់ថា “ម្នាលអនុរុទ្ធ អ្នកចូរសម្រាក់នៅទីនេះចុះ ” ហើយបានស្តេច

ទៅកាន់ក្រុងសាវត្ថី, ចាប់តាំងពីពេលនោះមក អ្នកនគរនោះ មានសទ្ធាជ្រះថ្លាហួត ។

រឿងចូឡសុភទ្រា ចប់

## ៩ រឿងព្រះថេរៈឈ្មោះឯកឧទាន

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈមួយព្រះអង្គឈ្មោះឯកវិហារី ត្រាស់ព្រះធម្មទេសនានេះថា “ **ឯកាសនំ** ” ជាដើម ។

## ពួកភិក្ខុក្រាបទូលរឿងព្រះថេរៈចំពោះព្រះសាស្តា

បានឮថា ព្រះថេរៈអង្គនោះបានជាអ្នកប្រាកដក្នុងចន្លោះបរិស័ទទាំង ៤ ថា “ អង្គុយតែម្នាក់ឯង ដើរតែម្នាក់ឯង ឈរតែម្នាក់ឯង ” គ្រានោះ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះចំពោះព្រះសាស្តាថា “ បពិត្រព្រះអង្គដ៏ចំរើន ព្រះថេរៈអង្គនេះ មានគំរូយ៉ាងនេះ ” ។

## ភិក្ខុគប្បីជាអ្នកស្ងាត់

ព្រះសាស្តា ទ្រង់ប្រទានសាធុការថា “សាធុ សាធុ” ដូច្នេះហើយ ទ្រង់ទូន្មានថា “ធម្មតាភិក្ខុ គប្បីជាអ្នកស្ងាត់” ហើយត្រាស់អានិសង្សក្នុងវិវេក ហើយទើបត្រាស់ព្រះគាថានេះថា ៖-

**៩. ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ**

**ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។**

បុគ្គលគួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឯកាសនំ ឯកសេយ្យំ** សេចក្តីថា ទីអង្គុយរបស់ភិក្ខុអ្នកមិនលះបង់មូលកម្មដ្ឋានសូម្បីអង្គុយក្នុងកណ្តាលភិក្ខុទាំងពាន់ ដោយការធ្វើទុកក្នុងចិត្តនោះឯង ឈ្មោះថា ទីអង្គុយតែម្នាក់ឯង ។ ក៏ទីដេករបស់ភិក្ខុអ្នកចូលទៅតាំងសតិទុកហើយ ដេកលើទីដេកដែលតម្លៃច្រើន មានវត្ថុជាគ្រឿងទ្រដ៏វិចិត្រ ដែលគេតាក់តែងហើយក្នុងប្រសាទប្រាកដស្មើលោហប្រសាទក្តី សូម្បីកណ្តាលភិក្ខុទាំងពាន់រូបក្តី ដោយការធ្វើទុកក្នុងចិត្តនូវមូលដ្ឋានឈ្មោះថា ទីដេកតែម្នាក់ឯង ។ ភិក្ខុគប្បីគប់រកទីអង្គុយតែម្នាក់ឯង និងទីដេកតែម្នាក់ឯងបែបនោះ ។

បទថា **អតន្ទិតោ** សេចក្តីថា ជាអ្នកមិនខ្ជិលច្រអូស

ដោយការចិញ្ចឹមជីវិតអាស្រ័យកម្លាំងស្មួង ជាអ្នកតែម្នាក់ឯង ក្នុងឥរិយាបថទាំង ៤ ។

បាទព្រះគាថាថា **ឯកោ ទមយមត្តានំ** សេចក្ដីថា ជាអ្នកតែម្នាក់ឯងប៉ុណ្ណោះទូន្មានខ្លួន ដោយអំណាចនៃការតាមប្រកបកម្មដ្ឋានក្នុងទីទាំងឡាយ មានទីសម្រាក់ពេលថ្ងៃជាដើម ហើយសម្រេចមគ្គនិងផល ។

បាទព្រះគាថាថា **វនន្តេ រមិតោ សិយា** សេចក្ដីថា ភិក្ខុកាលទូន្មានខ្លួនយ៉ាងនោះ ឈ្មោះថា គប្បីជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ចាកសំឡេងទាំងឡាយ មានសំឡេងស្ត្រី និងបុរសជាដើម ។ ព្រោះភិក្ខុអ្នកមានប្រក្រតីនៅដោយប្រឡូកប្រឡំ មិនអាចទូន្មានខ្លួនបានទេ ។

ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។ តាំងពីពេលនោះមក មហាជនរមែងប្រាថ្នាការនៅតែម្នាក់ឯងប៉ុណ្ណោះ ។

( រឿងព្រះថេរៈឈ្មោះឯកវិហារី ចប់ )

**បកិណ្ណវណ្ណនា ចប់ វគ្គទី ២១ ចប់**

# គាថាធម្មបទ

## និរយវគ្គទី ២២

១. អភូតវាទី និរយំ ឧបេតិ
យោ វាបិ កត្វា ន ករោមីតិ ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា បរត្ថ ។

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយ និយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅកាន់នរក ជនទាំងពីរនាក់ ដែលមានអំពើទាបថោក ( ស្មើគ្នា ) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា ( ដោយគតិ ) ក្នុងលោកខាងមុខទៀត ។

២. កាសាវកណ្ឋា ពហវោ    បាបធម្មា អសញ្ញតា

បាបា បាបេហិ កម្មេហិ និរយេន្តិ ឧបបជ្ជរេ ។
ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ន្ធ ដោយសំពត់កាសាវៈ តែ ( ប្រព្រឹត្ត ) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរកដោយសារកម្មទាំងឡាយដ៏លាមកនោះ។
សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ
បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែកដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។

៣. ជត្តារិ ឋានានិ នរោ បមត្តោ
អាបជ្ជតិ បរទារូបសេវី
អបុញ្ញលាភំ ន និកាមសេយ្យំ
និន្ទំ តតិយំ និរយំ ចតុត្ថំ ។

នរជនអ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គល

ដទៃ រមែងដល់នូវហេតុនៃសេចក្ដីទុក្ខ ៤ គឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទីបួន ការធ្លាក់នរក ។

៤. អបុញ្ញលាភោ ច គតី ច បាបិកា
ភីតស្ស ភីតាយ រតី ច ថោកិកា
រាជា ច ទណ្ឌំ គរុកំ បណេតិ
តស្មា នរោ បរទារំ ន សេវេ ។

( ហេតុនៃសេចក្ដីទុក្ខ ៤ យ៉ាងផ្សេងទៀត )គឺ បានរបស់មិនជាបណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាច ជាមួយនិងស្ត្រីដែលខ្លាចដែរមានប្រមាណតិច ១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ ។

៤. កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយូបកឌ្ឍតិ ។
យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ

សង្កិស្សរំ ព្រហ្មចរិយំ   ន តំ ហោតិ មហប្ផលំ។
កយិរា ចេ កយិរាថេនំ   ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ   ភិយ្យោ អាកិរតេ រជំ។
ស្បូវក្លាំងដែលបុគ្គលកាន់មិនចំណាប់ រមែងលះ
ដៃ យ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិត
កាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះ
ទៅនរក យ៉ាងនោះឯង ។
កម្មណាមួយ ដែលធូរថយក្តី វត្តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ ។
បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិក្កិលេសដល់បុគ្គលដោយក្រៃលែង
**៥. អកតំ ទុក្កតំ សេយ្យោ   បច្ឆា តបតិ ទុក្កតំ**

**កតត្តា សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។**

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង ( ព្រោះថា ) អំពើអាក្រក់ រមែងធ្វើឲ្យក្ដៅក្រហាយ ក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្ដៅក្រហាយក្រោយ អំពើនោះជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

**៦. នគរំ យថា បច្ចន្តំ　　គុត្តំ សន្តរពាហិរំ**
**ឯវំ គោបេថ អត្តានំ　　ខណោ មា វោ ឧបច្ចគា**
**ខណាតីតា ហិ សោចន្តិ　និរយម្ហិ សមប្បិតា ។**

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយទាំងខាងក្នុង ទាំងខាងក្រៅយ៉ាងណា អ្នកទាំងឡាយគួររក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថាជនទាំងឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្ដាយក្នុងនរកមីរជេរជាស ។

៧. អលទ្ធិតាយេ លជ្ជន្តិ  លជ្ជិតាយេ ន លជ្ជរេ
មិច្ឆាទិដ្ឋិសមាទានា  សត្តា គច្ឆន្តិ ទុគ្គតឹ ។
អភយេ ភយទស្សិនោ  ភយេ ច អភយទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា  សត្តា គច្ឆន្តិ ទុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាចផង យល់ឃើញហេតុដែលគេត្រូវខ្លាច ថាជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងឡាយនោះ តែងទៅកាន់ទុគ្គតិ ។

៨. អវជ្ជេ វជ្ជមតិនោ  វជ្ជេ ច  អវជ្ជទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា  សត្តា គច្ឆន្តិ ទុគ្គតឹ ។
វជ្ជញ្ច វជ្ជតោ ញត្វា  អវជ្ជញ្ច អវជ្ជតោ
សម្មាទិដ្ឋិសមាទានា  សត្តា គច្ឆន្តិ សុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញ ក្នុងហេតុ

ដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។
សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

ចប់ និរយវគ្គ ទី ២២ ។

# ២២ និរយវគ្គវណ្ណនា

## ១ រឿងនាងបរិពាជិកាឈ្មោះសុន្ទរី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងបរិពាជិកាឈ្មោះសុន្ទរី ត្រាស់ព្រះធម្មទេសនានេះថា ***“អភូតវាទី”*** ជាដើម ។

## ពួកតិរ្ថិយគិតកាត់លាភសក្ការៈព្រះសាស្តា

រឿងមកដោយពិស្តារក្នុងឧទាននោះថា “ ក៏ក្នុងសម័យនោះ ព្រះមានព្រះភាគ ជាអ្នកដែលមហាជនធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាយ៉ាងខ្លាំង ” ជាដើម ។ ចំណែកសេចក្តីសង្ខេបក្នុងរឿងនេះ មានដូចតទៅនេះ ៖-

បានឮថា កាលលាភសក្ការៈដូចជ្រលងទឹកធំនៃបញ្ចមហានទី កើតឡើងចំពោះព្រះមានព្រះភាគនិងភិក្ខុសង្ឃនោះ, ពួកអញ្ញតិរ្ថិយក៏សាបសូន្យលាភសក្ការៈ ជាអ្នកអប្បពន្លឺស្មើដូចសត្វអំពិលអំពែកក្នុងវេលាព្រះអាទិត្យរះឡើងដូច្នោះ រួមប្រជុំប្រឹក្សាគ្នាថា “ ចាប់តាំងពីពេលព្រះសមណៈគោតមឧប្បត្តិឡើង ពួកយើងក៏សាបសូន្យលាភសក្ការៈ, អ្នកណាៗក៏មិនដឹងថាយើងទាំងឡាយមាន, ពួកយើងគប្បីរួមដៃនិងអ្នកណាហ្ន៎ ? បន្តទោសឲ្យកើតឡើងដល់ព្រះសមណៈគោតមហើយញុំាងលាភសក្ការៈរបស់សមណៈគោតម ឲ្យសាបសូន្យ ” ។

## ពួកតិរ្ថិយឲ្យនាងសុន្ទរីទំលាយព្រះកិត្តិយល់ព្រះសាស្តា

គ្រានោះ ការគិតបានកើតឡើងដល់អញ្ញតិរ្ថិយទាំងនោះថា " ពួកយើងរួមដៃជាមួយនិងនាងសុន្ទរីនឹងអាច ( ធ្វើបាន ) " ។ ថ្ងៃមួយ ពួកគេ ( ក្រុង ) មិននិយាយជាមួយនិងនាងសុន្ទរី ដែលចូលទៅកាន់អារាមតិរ្ថិយ ថ្វាយបង្គំ ហើយឈរនៅក្នុងទីដ៏សមគួរ ។ សូម្បីនាងនិយាយចរចាជាមួយនិងពួកតិរ្ថិយយ៉ាងណាក៏ដោយ ក៏មិនបានការឆ្លើយតបដែរ ទើបនាងសួរថា " លោកម្ចាស់ទាំងឡាយ ត្រូវអ្នកណាបៀតបៀនឬ ?"

តិរ្ថិយ. ប្អូនស្រី នាងមិនឃើញព្រះសមណៈគោតមបៀតបៀនពួកយើង ធ្វើឲ្យសាបសូន្យលាភសក្ការៈទេឬ ?

នាងសុន្ទរី. បពិត្រលោកម្ចាស់ទាំងឡាយ តើខ្ញុំគួរធ្វើយ៉ាងណា ក្នុងរឿងនេះ ?

តិរ្ថិយ. ម្នាលប្អូនស្រី នាងមានរូបល្អ ទ្រង់ទ្រាយល្អដល់នូវភាពជាអ្នកស្អាតលើសគេ ចូរលើកទោសឡើងដល់

ព្រះសមណៈគោតម ញ៉ាំងមហាជនឲ្យជឿពាក្យរបស់នាង ហើយ ធ្វើឲ្យសាបសូន្យលាភសក្ការៈចុះ ។

នាងសុន្ទរីនោះយល់ព្រមដោយពាក្យថា “ ប្រពៃហើយ លោកម្ចាស់ទាំងឡាយ ” ហើយចៀសចេញទៅ ចាប់តាំងពីពេលនោះមក នាងតែងតែកាន់វត្ថុទាំងឡាយមានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប និងវត្ថុក្តៅជាដើម ដើរសំដៅទៅវត្តជេតពន ក្នុងវេលាដែលមហាជនស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ត្រឡប់ចូលកាន់ព្រះនគរក្នុងវេលារសៀល, កាលមហាជនសួរថា “ ម្នាលនាងដ៏ចំរើន នាងទៅណា ? ” ក៏ឆ្លើយតបថា “ ខ្ញុំទៅសំណាក់ព្រះសមណៈគោតម, ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណៈគោតមនោះ ” ហើយនៅក្នុងអារាមរបស់ពួកតិរ្ថិយ ដើរទៅកាន់ផ្លូវ ( ទីទៅកាន់ ) វត្តជេតពនអំពីព្រលឹម ដើរសំដៅទៅកាន់ព្រះនគរ, នាងត្រូវមហាជនសួរថា ទៅណានាងសុន្ទរី? ក៏ឆ្លើយតបថា “ ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណៈ

គោតម ឲ្យព្រះសមណៈគោតមត្រេកអរដោយសេចក្ដីត្រេកអរព្រោះកិលេសហើយ ទើបត្រឡប់មកវិញ ” ។

## ពួកភិក្ខុត្រូវពួកតិរ្ថិយចោទថាសម្លាប់នាងសុន្ទរី

ចាប់តាំងពីពេលនោះមក កន្លងទៅបាន ២-៣ ថ្ងៃ ពួកតិរ្ថិយឲ្យកហាបណៈដល់ពួកអ្នកលេងហើយពោលថា “ ពួកអ្នកចូរទៅសម្លាប់នាងសុន្ទរី ហើយកប់ក្នុងគំនរសំរាមនៃកម្រងផ្កាជិតព្រះគន្ធកុដិរបស់ព្រះសមណៈគោតម ហើយត្រឡប់មកវិញ ” ពួកអ្នកលេងក៏បានធ្វើយ៉ាងនោះ ។

គ្រានោះ តិរ្ថិយទាំងឡាយបានធ្វើកោលាហលឡើងថា “ ពួកយើងមិនឃើញនាងសុន្ទរី ”, ហើយក្រាបទូលព្រះរាជា ត្រូវព្រះរាជាត្រាស់សួរថា “ ពួកអ្នកមានសេចក្ដីសង្ស័យក្នុងទីណា ? ” ទូលថា “ នាងសុន្ទរីនៅក្នុងវត្តជេតពនអស់ថ្ងៃប៉ុណ្ណោះ, ពួកអាត្មាភាពមិនដឹងការប្រព្រឹត្តទៅរបស់នាងក្នុងវត្តជេតពននោះទេ ” កាលព្រះរាជាទ្រង់អនុញ្ញាតថា “ បើដូច្នោះ ពួកអ្នកចូរទៅរកក្នុងវត្តជេតពនចុះ ” ក៏នាំឧបដ្ឋាករបស់ខ្លួនទៅកាន់វត្តជេតពន ស្វែងរកក៏ឃើញនាងសុន្ទរីនោះ

ក្នុងគំនរសំរាមនៃកម្រងផ្កា ក៏លើកឡើងដាក់លើគ្រែនាំចូលទៅកាន់ព្រះនគរ ទូលព្រះរាជាថា “ បពិត្រព្រះសម្មតិទេព ព្រះសាវករបស់ព្រះសមណៈគោតម សម្លាប់នាងសុន្ទរីហើយកប់ក្នុងគំនរសំរាមនៃកម្រងផ្កា ដោយគិតថា នឹងបិទបាំងកម្មដ៏លាមកដែលព្រះសាស្តាធ្វើ ។ ព្រះរាជាត្រាស់ថា “ បើដូច្នោះ ពួកអ្នកចូរទៅប្រកាសឲ្យពេញព្រះនគរចុះ ” ពួកតិរ្ថិយនាំគ្នាពោលពាក្យជាដើមថា “ សូមអ្នកទាំងឡាយចូរមើលកម្មរបស់ពួកសមណសក្យបុត្តចុះ ” តាមថ្នល់នៃព្រះនគរហើយ បានទៅកាន់ទ្វារព្រះរាជនិវេសន៍ទៀត ។ ព្រះរាជា បញ្ជាឲ្យលើកសាកសពនាងសុន្ទរីឡើងដាក់គ្រែក្នុងព្រៃស្មសានហើយឲ្យរក្សាទុក ។ អ្នកនគរសាវត្ថីវៀរព្រះអរិយសាវកចេញ ដោយច្រើននាំគ្នាពោលពាក្យជាដើមថា “ អ្នកទាំងឡាយ ចូរមើលកម្មរបស់ពួកសមណសក្យបុត្តចុះ ” ហើយដើរជេរពួកភិក្ខុ ខាងក្នុងព្រះនគរខ្លះ ក្រៅព្រះនគរខ្លះ ក្នុងព្រៃខ្លះ ។ ភិក្ខុទាំងឡាយ ក្រាបទូលរឿងនោះចំពោះព្រះតថាគត ។

ព្រះសាស្ដាទ្រង់ត្រាស់ថា “ បើដូច្នោះ ពួកអ្នកចូរត្រេ-ឡប់ចោទមនុស្សទាំងនោះយ៉ាងនេះ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**១.អភូតវាទី និរយំ ឧបេតិ**
**យោ វាបិ កត្វា ន ករោមីតិ ចាហ**
**ឧភោបិ តេ បេច្ច សមា ភវន្តិ**
**និហីនកម្មា មនុជា បរត្ថ ។**

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ ( អំពើអាក្រក់ ) ហើយ និយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅកាន់នរក ជនទាំងពីរនាក់ដែលមានអំពើថោកទាប ( ស្មើគ្នា ) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា ( ដោយគតិ ) ក្នុងលោកខាងមុខទៀត ។

**អធិប្បាយគាថា**

បណ្ដាបទទាំងនោះ បទថា **អភូតវាទី** បានដល់ អ្នកមិនឃើញទោសរបស់បុគ្គលដទៃហើយ ក្លែងពោលពាក្យកុហក បន្ទំអ្នកដទៃដោយពាក្យទទេ ។

បទថា **កត្វា** សេចក្ដីថា ឬបុគ្គលណាធ្វើកម្មលាមកហើយ ពោលពាក្យថា " ខ្ញុំមិនបានធ្វើកម្មនោះទេ " ។

ច្រើនបទថា **បេច្ច សមា ភវន្តិ** សេចក្ដីថា ជនសូម្បីទាំងពីរនោះទៅកាន់បរលោក រមែងជាអ្នកស្មើគ្នាដោយគតិព្រោះការចូលកាន់នរក, គតិរបស់ជនទាំងនោះប៉ុណ្ណោះ អ្នកប្រាជ្ញលោកកណត់ទុកហើយ, ប៉ុន្តែអាយុរបស់គេលោកមិនបានកំណត់ទុកទេ, ព្រោះថា ជនទាំងឡាយធ្វើបាបកម្មទុកច្រើន រមែងឆេះក្នុងនរកយូរ ធ្វើបាបកម្មទុកតិច រមែងឆេះអស់កាលត្រឹមតែតិចតួចប៉ុណ្ណោះ, ក៏ព្រោះកម្មដ៏លាមករបស់ជនទាំងពីរនោះឯង ( ជាហេតុ ), ទើបព្រះមានព្រះភាគត្រាស់ថា " **និហីនកម្មា មនុជា បរត្ថ** " ។

ក៏បទថា **បរត្ថ** សម្ពន្ធចូលនិងបទថា **បេច្ច** ខាងមុខ, អធិប្បាយថា ជនអ្នកមានកម្មដ៏ថោកទាបទាំងនោះ លុះលះ

លោកនេះទៅកាន់លោកដទៃ គឺទៅអំពីលោកនេះ រមែងជាអ្នកស្មើគ្នាក្នុងបរលោក ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

## ពួកអ្នកសម្លាប់នាងសុន្ទរីត្រូវប្រហារជីវិត

ព្រះរាជា ទ្រង់បញ្ជូនរាជបុរសទៅដោយព្រះរាជតម្រាស់ថា " ពួកអ្នកចូរដឹងការដែលអ្នកដទៃសម្លាប់នាងសុន្ទរី " ។ គ្រានោះ អ្នកលេងទាំងនោះផឹកសុរាដោយកហាបណៈទាំងនោះហើយ ឈ្លោះទាស់ទែងគ្នា ។ ម្នាក់ពោលនិងម្នាក់ទៀតថា " អញសម្លាប់នាង សុន្ទរីដោយការប្រហារត្រឹមតែម្តងហើយ កប់ក្នុងគំនរសំរាមនៃកម្រងផ្កាផឹកសុរាដោយកហាបណៈ ដែលបានមកអំពីការប្រហារនោះ, រឿងនោះលើកទុកសិនចុះ " ។ ពួករាជបុរសក៏ចាប់អ្នកលេងទាំងនោះទៅសំដែងដល់ព្រះរាជា ។ គ្រានោះ ព្រះរាជាត្រាស់សួរអ្នកលេងទាំងនោះថា " ពួកអ្នកឯងសម្លាប់នាងសុន្ទរីឬ ? "

ពួកអ្នកលេង. ព្រះករុណាថ្លៃវិសេស

ព្រះរាជា. អ្នកណាប្រើពួកអ្នកឲ្យសម្លាប់ ?

ពួកអ្នកលេង. បពិត្រព្រះសម្មតិទេព ពួកតិរ្ថិយ ។

ព្រះរាជា បញ្ជាឲ្យហៅពួកតិរ្ថិយមកហើយ ទ្រង់បញ្ជាថា " ពួកអ្នកចូរទៅប្រកាសឲ្យពេញព្រះនគរយ៉ាងនេះថា នាងសុន្ទរី ត្រូវពួកយើងអ្នកប្រាជ្ញាលើកទោសព្រះសមណគោតមឡើង សម្លាប់ហើយ, ទោសរបស់ព្រះសាវកនៃព្រះសមណគោតមមិនមានទេ, នេះជាទោសរបស់ពួកយើងតែប៉ុណ្ណោះ " ។ ពួកតិរ្ថិយបានធ្វើហើយដោយប្រការដូច្នោះ មហាជនអ្នកល្ងង់ខ្លៅជឿហើយក្នុងគ្រានោះ, ពួកតិរ្ថិយក្តី ពួកអ្នកលេងក្តី ដល់នូវអាជ្ញាព្រោះការសម្លាប់មនុស្ស ។ ចាប់តាំងពីពេលនោះមក សក្ការៈបានកើតមានចំពោះព្រះពុទ្ធនិងសាវកទាំងឡាយយ៉ាងច្រើន ។

រឿងនាងបរិពាជកឈ្មោះសុន្ទរី ចប់

## ២ រឿងសត្វរុយរត្រួចទន្ទ្របៀតបៀន

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសត្វទាំងឡាយ ដែលត្រូវអានុភាពនៃផលទុច្ចរិតបៀតបៀនត្រាស់ព្រះធម្មទេសនានេះថា " **កាសាវកណ្ឋា** " ជាដើម ។

## ព្រះមហាមោគ្គល្លានឃើញប្រេតមានតែរាងឆ្អឹង

សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានចុះអំពីភ្នំគិជ្ឈ-កូដជាមួយនិងព្រះលក្ខណត្ថេរ ឃើញប្រេតទាំងឡាយ មានប្រេតដែលមានតែរាងឆ្អឹងជាដើម ទើបធ្វើការញញឹម ត្រូវព្រះលក្ខណត្ថេរសួរដល់ការញញឹមនោះ ក៏ពោលថា " ម្នាលអ្នកមានអាយុ កាលនេះ មិនមែនជាកាលនៃបញ្ហានេះទេ, អាវុសោចាំសួរខ្ញុំក្នុងសម្នាក់ព្រះតថាគតចុះ " កាលព្រះថេរៈសួរក្នុងសម្នាក់ព្រះតថាគតហើយ ក៏ប្រាប់ការដែលខ្លួនឃើញអត្តភាពរបស់ប្រេតទាំងឡាយ មានប្រេតដែលមានតែរាងឆ្អឹងជាដើមហើយ ទើបប្រាប់សហធម្មិកទាំង ៥ អ្នកដែលភ្លើងកំពុងឆេះជាមួយនិងសមណបរិក្ខារមានបាត្រចីវរ និង

វត្តពន្ធចង្កេះជាដើម ដោយន័យថា " អ្នកមានអាយុ កាលខ្ញុំចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុក្នុងពុទ្ធសាសនានេះទៅកាន់អាកាស, ចំណែកកាយរបស់ភិក្ខុនោះត្រូវភ្លើងឆេះ " ។

## អ្នកមានកម្មដ៏លាមករមែងចូលកាន់នរក

ព្រះសាស្តាត្រាស់ប្រាប់ថា សត្វទាំងនោះបួសក្នុងសាសនាព្រះកស្សបទសពល ប៉ុន្តែមិនបដិបត្តិឲ្យសមគួរដល់បព្វជ្ជា ជាអ្នកលាមក កាលទឹងទ្រង់សម្តែងផលនៃទុច្ចរិតកម្មរបស់ភិក្ខុលាមកទាំងឡាយ ដែលអង្គុយនៅទីនោះទើបត្រាស់ព្រះគាថានេះថា ៖-

**២. កាសាវកណ្ឋា ពហវោ   បាបធម្មា អសញ្ញតា**
**បាបា បាបេហិ កម្មេហិ   និរយន្តេ ឧបបជ្ជរេ ។**

ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ទ្ធដោយសំពត់កាសាវៈ តែ ( ប្រព្រឹត្ត ) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កាសាវកណ្ឋា** បានដល់ អ្នកមានកព័ន្ធព័ទ្ធដោយសំពត់កាសាវៈ ។

បទថា **បាបធម្មា** ប្រែថា អ្នកមានធម៌ដ៏លាមក ។

បទថា **អសញ្ញតា** បានដល់ អ្នកវៀរចាកការសង្រួម កាយជាដើម ។ អធិប្បាយថា បុគ្គលលាមកបែបនោះ រមែងចូលទៅកាន់នរក ព្រោះអកុសលកម្មទាំងឡាយដែលខ្លួនធ្វើទុកហើយ, ជនទាំងនោះ ឆេះក្នុងនរកនោះហើយ ចុតិចាកនរកនោះ រមែងឆេះក្នុងប្រេតវិស័យទាំងឡាយយ៉ាងនោះ ព្រោះកម្មដែលឲ្យផលនៅសល់ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងសត្វដែលត្រូវទុក្ខបៀតបៀន

## ៣ រឿងភិក្ខុអ្នកនៅឆ្នេរស្ទឹងឈ្មោះវគ្គុមុទា

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលស្តេចអាស្រ័យក្រុងវេសាលី ទ្រង់គង់នៅក្នុងព្រៃមហាវន ទ្រង់ប្រារព្ធពួកភិក្ខុដែលនៅក្បែរឆ្នេរស្ទឹងវគ្គុមុទា ត្រាស់ព្រះធម្មទេសនានេះថា “ **សេយ្យោ អយោគុឡោ** ” ជាដើម ។*

### *ព្រះសាស្តាទ្រង់តិះដៀលភិក្ខុដែលឃើញតែអំពីផ្ទៃ*

*រឿង ( មាន ) មកហើយក្នុងឧត្តរិមនុស្សធម្មបារាជិកសិក្ខាបទនោះឯង ។ ក៏ក្នុងកាលនោះ ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនាំគ្នាពោលគុណនៃឧត្តរិមនុស្សធម្មនៃគ្នានិងគ្នា ដល់ពួកគ្រហស្ថដើម្បីផ្ទៃឬ ? ” កាលភិក្ខុទាំងនោះក្រាបទូលថា “ ព្រះករុណា ព្រះអង្គ ” ដូច្នេះហើយ ទ្រង់តិះដៀលភិក្ខុទាំងនោះដោយអនេកបរិយាយ ហើយត្រាស់ព្រះគាថានេះថា ៖-*

**សោយ្យោ អយោគុឡ្យោ ភុត្តោ តត្តោ អគ្គិសិខូបមោ**
**យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។**

បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែក ដែលកំពុងក្តៅ មានពណ៌ដូចអណ្តាត់ភ្លើង ប្រសើរជាងបព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែននឹងប្រសើរដូចម្តេចបាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **យញ្ចេ ភុញ្ជេយ្យ** សេចក្តីថា ភិក្ខុទ្រុស្តសីល គឺភិក្ខុអ្នកមិនមានសីល មិនសង្រួមកាយជាដើម បដិញ្ញាខ្លួនថា " យើងជាសមណៈ " ទទួលដុំបាយដែលអ្នកដែនប្រគេនដោយសទ្ធា ដែលឈ្មោះថារដ្ឋបិណ្ឌៈឯណា ហើយឆាន់, ដុំដែកដ៏ក្តៅមានពណ៌ដូចអណ្តាត់ភ្លើង ដែលភិក្ខុបរិភោគហើយ ប្រសើរជាង គឺល្អជាងនោះ ។ សួរថា ព្រោះហេតុអ្វី ?" ឆ្លើយថា ព្រោះអត្តភាពតែមួយប៉ុណ្ណោះ ដែលភ្លើងគប្បីឆេះ ព្រោះការបរិភោគ

ជុំដែកនោះជាបច្ច័យ, ប៉ុន្តែភិក្ខុទ្រុស្តបរិភោគជុំបាយដែលអ្នកគេប្រគេនដោយសទ្ធា គប្បីឆេះក្នុងនរកអស់ច្រើនរយជាតិ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងភិក្ខុអ្នកនៅក្បែរឆ្នេរស្ទឹងឈ្មោះវគ្គមុទា ចប់

# ៤ រឿងសេដ្ឋីបុត្រឈ្មោះខេមកៈ

## សេចក្តីខាងដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុត្រសេដ្ឋីឈ្មោះខេមកៈ ដែលក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា “ **ចត្តារិ ឋានានិ** ” ជាដើម ។*

## ខេមកៈជាព្រាននារី ត្រូវចាប់ដល់ ៣ ដង

*បានឮថា សេដ្ឋីបុត្រឈ្មោះខេមកៈនោះ ជាអ្នកមានរូបល្អ មានរូបឆើត ដោយច្រើនស្ត្រីទាំងឡាយឃើញហើយត្រូវរាគៈគ្របសង្កត់ មិនអាចទឹងតាំងនៅតាមភាវៈរបស់ខ្លួនបាន ។ ចំណែកខេមកៈនោះ ក៏ជាអ្នកត្រេកអរក្នុងបរទារកម្ម ( កម្មគឺការគប់រកកិរិយារបស់អ្នកដទៃ ) ដែរ ។*

*ក្រោយមក ក្នុងវេលារាត្រី ពួករាជបុរសចាប់គេនាំទៅសម្តែងចំពោះព្រះរាជា ។ ព្រះរាជាមិនបានត្រាស់នូវព្រះ*

តម្រាស់អ្វី ៗ ទៅកាន់គេឡើយ ដោយទ្រង់តម្រិះថា " យើងខ្លាសមហាសេដ្ឋី " ហើយទ្រង់ត្រាស់ឲ្យលែងទៅ ។ ចំណែកខេមកៈនោះមិនបានវៀរចាកនូវអំពើនោះឡើយ ។ ក្រោយមក ( ទៀត ) ពួករាជបុរសក៏ចាប់ខេមកៈនោះមកសម្តែងចំពោះព្រះរាជាលើកទី ២ ទី ៣ ។ ព្រះរាជាក៏ត្រាស់ឲ្យលែងដូចមុនទៀត ។ មហាសេដ្ឋីជ្រាបរឿងនោះហើយ នាំខេមកៈទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះចំពោះព្រះសាស្តាថា " បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គមេត្តាសំដែងធម៌ដល់នាយខេមកៈនេះ " ។

## ព្រះសាស្តាទ្រង់សម្តែងទោសនៃបរទារកម្ម

ព្រះសាស្តាត្រាស់សង្វេគកថា ( កថានាំមកនូវសេចក្តីតក់ស្លុត ) ដល់គេហើយ កាលនឹងទ្រង់សម្តែងទោសនៃការសេពកិរិយារបស់អ្នកដទៃ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៤. ចត្តារិ ឋានានិ នរោ បមត្តោ
អាបជ្ជតី បរទារូបសេវី

អបុញ្ញលាភំ ន និកាមសេយ្យំ
និន្ទំ តតិយំ និរយំ ចតុត្ថំ
អបុញ្ញលាភោ ច គតី ច បាបិកា
ភីតស្ស ភីតាយ រតី ច ថោកិកា
រាជា ច ទណ្ឌំ គរុកំ បណេតិ
តស្មា នរោ បរទារំ ន សេវេ ។

ជនអ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្ដីទុក្ខ ៤ យ៉ាងគឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់នរក ។ ( ហេតុនៃសេចក្ដីទុក្ខ ៤ យ៉ាងផ្សេងទៀត ) គឺ បានរបស់មិនជាបុណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាច ជាមួយនិងស្ត្រីដែលខ្លាចដែរ មានប្រមាណតិច ១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឋានានិ** បានដល់ ហេតុនៃសេចក្ដីទុក្ខទាំងឡាយ ។ បទថា **បមត្តោ** បានដល់ ប្រកបដោយការបណ្ដែតបណ្ដោយសតិ ។ បទថា **អាបជ្ជតិ** គឺរមែងដល់ ។

បទថា **បរទារូបសេវី** សេចក្ដីថា ចូលទៅសេពកិរិយារបស់អ្នកដទៃ ឈ្មោះថាអ្នកប្រព្រឹត្តខុសផ្លូវ ។

បទថា **អបុញ្ញលាភំ** បានដល់ ការបានអកុសល ។

បទថា **ន និកាមសេយ្យំ** សេចក្ដីថា បុគ្គលនោះមិនបានការដេកដូចដែលខ្លួនប្រាថ្នា រមែងបានការដេកអស់កាលតែបន្តិចបន្តួចប៉ុណ្ណោះ ដែលខ្លួនមិនប្រាថ្នា ។

បទថា **អបុញ្ញលាភោ ច** សេចក្ដីថា ការបាននូវអំពើមិនមែនជាបុណ្យនេះផង គតិដ៏លាមក ពោលគឺនរក ព្រោះអំពើដែលមិនមែនជាបុណ្យនោះ ( ជាហេតុ ) ផង រមែងមានដល់បុគ្គលនោះ យ៉ាងនេះ ។

ពីរបទថា **រតី ច ឋោកិកា** សេចក្តីថា សូម្បីសេចក្តីត្រេកអររបស់បុរសអ្នកខ្វាចនោះ ជាមួយនិងស្រ្តីអ្នកខ្វាចមានប្រមាណតិច គឺមានតិចតួច ។

បទថា **គរុកំ** សេចក្តីថា ម្យ៉ាងទៀត ព្រះរាជារមែងដាក់អាជ្ញាយ៉ាងធ្ងន់ មានការកាត់ដៃជាដើម ។

បទថា **តស្មា** ជាដើម សេចក្តីថា បុគ្គលអ្នកសេពកិរិយារបស់អ្នកដទៃ រមែងដល់នូវឋានៈទាំងឡាយ មានការបាននូវអំពើដែលមិនមែនជាបុណ្យជាដើមនោះ ព្រោះហេតុនោះ បុគ្គលមិនគួរគប់រកកិរិយារបស់អ្នកដទៃឡើយ ។

ក្នុងកាលចប់ទេសនា នាយខេមកៈតាំងនៅក្នុងសោតាបត្តិផល, ចាប់តាំងអំពីពេលនោះមក មហាជនញុំាងកាលឲ្យកន្លងទៅយ៉ាងសប្បាយ ។

## បុព្វកម្មរបស់ខេមកៈ

សួរថា “ ក៏បុព្វរបស់នាយខេមកៈនោះ យ៉ាងណា ?”

ឆ្លើយថា “ បានឮថា ក្នុងសម័យនៃព្រះពុទ្ធព្រះនាមជាកស្សប ខេមកៈនោះជាអ្នកចំបាប់យ៉ាងពូកែជាទីបំផុត

លើកទង់មាសពីរផ្ទាំងឡើង ក្នុងកាលព្រះទសពលហើយ តាំងសេចក្តីប្រាថ្នាទុកថា “ រៀរស្រ្តីដែលជាញាតិសាលោហិតចេញ ស្រ្តីដ៏សេសឃើញយើងហើយចូរត្រេកអរ ” ។ នេះជាបុព្វកម្មរបស់គេដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ស្រ្តីរបស់ជនដទៃឃើញគេក្នុងទីដែលគេកើតហើយ ទើបមិនអាចតាំងនៅតាមភាវៈរបស់ខ្លួនបាន ។

រឿងបុត្តរបស់សេដ្ឋីឈ្មោះខេមកៈ ចប់

## ៥. រឿងភិក្ខុអង្គប្រដៅក្រ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **កុសោ យថា** ” ជាដើម ។

### ភិក្ខុកាត់ស្មៅហើយសង្ស័យ

បានឮថា ភិក្ខុមួយរូបមិនក្លែងកាត់ស្មៅមួយទង កាលសេចក្តីសង្ស័យកើតឡើង, ក៏ចូលទៅរកភិក្ខុមួយរូប ប្រាប់

នូវកម្មដែលខ្លួនធ្វើហើយសួរថា “ ម្នាលអ្នកមានអាយុ ភិក្ខុណាកាត់ស្មៅ, ទោសអ្វី រមែងមានដល់ភិក្ខុនោះ ? ” គ្រានោះ ភិក្ខុក្រៅនេះ ឆ្លើយតបថា “ ម្នាលអាវុសោ អ្នកសម្គាល់ ទោសណា ៗ រមែងមាន ព្រោះហេតុនៃស្មៅដែលអ្នកកាត់ហើយឬ, ទោសណា ៗ រមែងមិនមានក្នុងទីនេះ, ប៉ុន្តែអ្នកសម្តែងអាបត្តិហើយ រមែងផុតបាន ” ចំណែកខ្លួនឯងក៏បានយកដៃទាំងពីរដកស្មៅ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះចំពោះព្រះសាស្តា ។

## កម្មដែលបុគ្គលធ្វើធូររមែងមិនមានផលច្រើន

ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុនោះដោយអនេកបរិយាយ កាលទឹងទ្រង់សម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៥. កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយូបកឌ្ឍតិ
យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ។

កយិរញ្ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ ។

ស្បូវភ្លាំងដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃយ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅកាន់នរក យ៉ាងនោះឯង ។

កម្មណាមួយដែលធូរថយក្តី វតណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលីគឺរាគាទិក្កិលេសដល់បុគ្គលដោយក្រៃលែង ។

## អធិប្បាយគាថា

ស្មៅមានមុខដ៏មុតឯណានីមួយ ដោយហោចទៅសូម្បី តែស្មឹកត្នោត ក៏ឈ្មោះថា **កុសោ** ក្នុងព្រះគាថានេះដែរ ។ ស្មៅនោះ បុគ្គលឯណាចាប់កាន់មិនល្អ រមែងលះ គឺរមែង ញុំាងដៃរបស់បុគ្គលនោះឲ្យរយះ យ៉ាងណា សូម្បីគុណជាតិ ជាសមណៈពោលគឺសមណៈធម៌ ក៏ដូច្នោះដែរ ដែលបុគ្គល ពាល់ត្រូវមិនល្អ ព្រោះភាពជាអ្នកមានសីលដាច់ជាដើម ។

បាទព្រះគាថាថា **និរយាយូបកឌ្ឍតិ** សេចក្តីថា រមែង ឲ្យកើតក្នុងនរក ។

បទថា **សិថិលំ** បានដល់ កិច្ចការណា ៗ ដែលបុគ្គល ធ្វើនូវការចាប់កាន់ធូរ ៗ ហើយធ្វើ ធ្វើដោយមិនប្រុងប្រយ័ត្ន ធ្វើដោយមិនប្រពៃ ធ្វើដោយបង្អែរបង្អង់ ។

បទថា **សង្កិលិដ្ឋំ** សេចក្តីថា ឈ្មោះថាសៅហ្មងព្រោះ ការត្រាច់ទៅក្នុងទីអគោចរ មានកន្លែងស្រីពេស្យាជាដើម ។

បទថា **សង្កស្សរំ** បានដល់ រលឹកដោយសេចក្តី សង្ស័យ គឺឃើញសង្ឃដែលប្រជុំគ្នាដោយកិច្ចឯណានីមួយ មានឧបោសថកិច្ចជាដើម ហើយរលឹកដោយសេចក្តីសង្ស័យ

គឺវង្វៀស បានដល់ សង្ស័យយ៉ាងនេះថា “ ភិក្ខុទាំងនេះដឹងនូវការប្រព្រឹត្តរបស់យើងមាន បំណាន់នឹងលើករំតរបស់យើងឡើង ទើបប្រជុំគ្នាដោយពិត ” ។

ពីរបទថា **ន តំ ហោតិ** សេចក្តីថា ព្រហ្មចរិយៈពោលគឺសមណធម៌នោះ គឺបែបនោះ រមែងមិនមានផលច្រើនដល់បុគ្គលនោះ, ព្រោះមិនមានផលច្រើនដល់លោក ក៏រមែងមិនមានផលច្រើន សូម្បីដល់ទាយកអ្នកថ្វាយភិក្ខាចំ-ពោះលោកដែរ ។

បទថា **កយិរា ច** សេចក្តីថា ព្រោះហេតុនោះ ប្រសិនបើបុគ្គលធ្វើនូវកិចណា, គប្បីធ្វើនូវកិច្ចនោះឲ្យមែនទែន ។

បាទព្រះគាថាថា **ទឡ្ហមេនំ បរក្កមេ** សេចក្តីថា គួរធ្វើនូវកិច្ចនោះឲ្យជាកម្មដែលខ្លួនធ្វើហើយដោយខ្ជាប់ខ្ជួន គឺជាអ្នកមានការសមាទានដ៏ស្ថិតស្ថាញហើយធ្វើនូវកិច្ចនោះ ។

បទថា **បរិព្វាជោ** បានដល់ សមណធម៌ដែលបុគ្គលធ្វើដោយការសមាទានធូរ ៗ ដែលដល់ភាវៈមានការដាច់ជាដើម ។

បទថា **ភិយ្យោ** សេចក្តីថា សមណធម៌បែបនោះ រមែងមិនអាចនឹងនាំចេញនូវធូលី មានធូលីគឺរាគៈជាដើម ដែលមាននៅខាងក្នុង, ដោយពិត រមែងរោយរាយធូលី មានធូលីគឺរាគៈជាដើម សូម្បីយ៉ាងជាទៃខាងលើបុគ្គលនោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម សូម្បីភិក្ខុនោះ ក៏តាំងនៅក្នុងការសង្រួម ខាងក្រោយមក ចំរើនវិបស្សនា បានសម្រេចព្រះអរហត្ត ។

រឿងភិក្ខុប្រដៅក្រ ចប់

## ៦ រឿងស្ត្រីដែលត្រូវសេចក្តីប្រច័ណ្ឌគ្របសង្កត់

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្ត្រីដែលត្រូវសេចក្តីប្រច័ណ្ឌគ្របសង្កត់មួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **អកតំ** ” ជាដើម ។

### ស្ត្រីប្រច័ណ្ឌធ្វើកម្មអាក្រក់ហើយគិតបិទបាំង

បានឮថា ស្វាមីរបស់ស្ត្រីនោះបានធ្វើសេចក្ដីស្និទ្ធ ស្នាលនិងស្ត្រីបំរើម្នាក់ ។

ស្ត្រីដែលត្រូវសេចក្ដីប្រច័ណ្ឌគ្របសង្កត់នោះ ចងដៃ ចងជើងស្ត្រីបំរើនោះហើយ កាត់ត្រចៀក កាត់ច្រមុះរបស់ ស្ត្រីបំរើនោះ ហើយឃុំទុកក្នុងបន្ទប់ទទេមួយ បិទទ្វារហើយ ដើម្បីនឹងបិទបាំងអំពើដែលខ្លួនធ្វើហើយ ( ក៏បានបបួល ស្វាមី ) ថា " បពិត្រម្ចាស់ ចូរមក, យើងនឹងទៅវត្តស្ដាប់ ព្រះធម៌ " នាំស្វាមីទៅវត្តអង្គុយស្ដាប់ធម៌ ។ គ្រានោះ ពួក ជនដែលជាញាតិរបស់នាងមកកាន់ផ្ទះ ( របស់នាង ) ហើយ បើកទ្វារឃើញអាការដ៏ប្លែកនោះហើយ ដោះលែង ស្ត្រីបំរើនោះ ។ ស្ត្រីបំរើនោះទៅវត្ត ក្រាបទូលរឿងនោះចំ- ពោះព្រះទសពលក្នុងកណ្ដាលបរិស័ទទាំង ៤ ។

## កម្មអាក្រក់រមែងធ្វើឲ្យក្ដៅក្រហាយក្នុងកាលខាងក្រោយ

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ស្ត្រីបំរើ នោះហើយ ត្រាស់ថា " ដែលឈ្មោះថា អំពើទុច្ចរិត សូម្បី មានប្រមាណតិចបុគ្គលមិនគួរធ្វើដោយការសម្គាល់ថា ពួក

ជនដទៃ រមែងមិនដឹងនូវអំពើរបស់យើង ( ចំណែក ) អំពើសុចរិតនោះ សូម្បីអ្នកដទៃមិនដឹង ក៏គួរធ្វើដែរ, ព្រោះថាដែលឈ្មោះថាអំពើទុច្ចរិត សូម្បីបុគ្គលធ្វើដោយការបិទបាំង ក៏រមែងធ្វើឲ្យក្ដៅក្រហាយក្នុងកាលខាងក្រោយ, ( ចំណែក ) អំពើសុចរិត រមែងញ៉ាំងសេចក្ដីរីករាយតែម្យ៉ាងឲ្យកើតឡើង ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖-

**៦. អកតំ ទុក្កតំ សេយ្យោ   បច្ឆា តប្បតិ ទុក្កតិ**
**កតញ្ច សុកតិ សេយ្យោ   យំ កត្វា នានុតប្បតិ។**

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង ( ព្រោះថា ) អំពើអាក្រក់ រមែងធ្វើឲ្យក្ដៅក្រហាយក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្ដៅក្រហាយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ទុក្កតំ** សេចក្ដីថា កម្ម ប្រកបដោយទោស ជាកម្មញុំាងសត្វឲ្យទៅកើតក្នុងអបាយ មិនធ្វើល្អជាង គឺប្រសើរជាង បានដល់ខ្ពង់ខ្ពស់បំផុត ។

ពីរបទថា **បច្ឆា តប្បតិ** សេចក្ដីថា ព្រោះកម្មនោះ រមែងធ្វើឲ្យក្ដៅក្រហាយក្នុងកាលដែលខ្លួនរលឹកដល់ ។

បទថា **សុកតំ** សេចក្ដីថា ចំណែកកម្មដែលមិនមាន ទោស មានសុខជាផល ញុំាងសត្វឲ្យប្រព្រឹត្តទៅក្នុងសុគតិ តែម្យ៉ាង បុគ្គលធ្វើហើយ ប្រសើរជាង ។

ពីរបទថា **យំ កត្វា** សេចក្ដីថា បុគ្គលធ្វើកម្មណា ហើយ រមែងមិនក្ដៅក្រហាយក្នុងកាលខាងក្រោយ គឺក្នុង កាលដែលខ្លួនរលឹកដល់ ឈ្មោះថា រមែងមិនតាមដុតឲ្យក្ដៅ ក្រហាយ គឺជាអ្នកមានសោមនស្សតែម្យ៉ាង, កម្មនោះដែល បុគ្គលធ្វើហើយ ប្រសើរ ។

ក្នុងកាលចប់ទេសនា ឧបាសកនិងស្ត្រីនោះ តាំងនៅ ក្នុងសោតាបត្តិផល ។ មិនត្រឹមតែប៉ុណ្ណោះសោត ជនទាំង

ឡាយធ្វើស្ត្រីបំរើនោះឲ្យជាស្ត្រីជាក្នុងទីនោះហើយ ធ្វើឲ្យជាស្ត្រីមានប្រក្រតីប្រព្រឹត្តធម៌ ដូច្នេះឯង ។

រឿងស្ត្រីដែលត្រូវសេចក្តីប្រច័ណ្ឌគ្របសង្កត់ ចប់

## ៧ រឿងអាគន្តុកភិក្ខុ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ភិក្ខុអាគន្ដុកច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា “ **នគរំ យថា** ” ជាដើម ។

## ពួកភិក្ខុទៅកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះសាស្ដា

បានឮថា ភិក្ខុទាំងនោះ ចាំវស្សានៅឯបច្ចន្តនគរមួយកន្លែង បាននៅជាសុខក្នុងខែដំបូង ។ ក្នុងខែកណ្ដាល ពួកចោរបានមកប្លន់ស្រុក ដែលជាទីគោចររបស់ភិក្ខុទាំងនោះ ចាប់អ្នកស្រុកធ្វើឈ្លើយសឹក ។ ចាប់តាំងអំពីពេលនោះមក អ្នកស្រុកទាំងឡាយនាំគ្នាមកជួសជុលបច្ចន្តនគរនោះ ដើម្បីការពារពួកចោរ ទើបមិនមានពេលឧបដ្ឋាកភិក្ខុទាំងនោះឲ្យបានជិតដល់ ។ ភិក្ខុទាំងនោះចាំវស្សាដោយមិនសប្បាយ ( លុះ ) ចេញវស្សាហើយ បានទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។

## ព្រះសាស្ដាត្រាស់សួរសុខទុក្ខភិក្ខុទាំងនោះ

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារកិច្ចទាំងនោះហើយ ត្រាស់សួរថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនៅជាសុខឬ ? ” កាលភិក្ខុទាំងនោះក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គនៅជាសុខបានតែមួយខែដំបូងប៉ុណ្ណោះ, ក្នុងខែកណ្តាល ពួកចោរបានមកប្លន់អ្នកស្រុក, ចាប់តាំងពីពេលនោះមកអ្នកស្រុកទាំងឡាយនាំគ្នាជួសជុលនគរ មិនមានពេលទំនុកបម្រុងឲ្យបានជិតដល់, ព្រោះហេតុនោះ ទើបពួកខ្ញុំព្រះអង្គចាំវស្សាមិនបានសប្បាយ ” ក៏ត្រាស់ថា “ ណ្ហើយចុះ ភិក្ខុទាំងឡាយ, អ្នកទាំងឡាយកុំគិតឡើយ, ធម្មតាថា ការនៅជាសុខអស់កាលជានិច្ច ជារបស់ដែលបុគ្គលរកបានដោយកម្រ, ធម្មតាថា ភិក្ខុគួរតែរក្សាខ្លួនឲ្យជាដូចអ្នកនគររក្សាគ្រប់គ្រងនគរដូច្នោះ” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៈ-

៧. នគរំ យថា បច្ចន្តំ     គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ  ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ  និរយម្ហិ សមប្បិតា ។

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ
ទាំងខាងក្នុង ទាំងខាងក្រៅយ៉ាងណា អ្នកទាំង
ឡាយ គួររក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លង
អ្នកទាំងឡាយបានឡើយ ព្រោះថាជនទាំងឡាយ
ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយ
ក្នុងនរកមីដេរដាស ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សន្តរពាហិរំ** ជាដើម សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បច្ចន្តនគរនោះ ដែលអ្នកនគរទាំងនោះធ្វើនូវគ្រឿងការពារទីទាំងឡាយ មានទ្វារ និងកំពែងជាដើមយ៉ាងមាំ ឈ្មោះថា ធ្វើការគ្រប់គ្រងខាងក្នុង កាលធ្វើនូវគ្រឿងការពារទីទាំងឡាយ មានប៉មនិងគូជាដើមយ៉ាងមាំ ឈ្មោះថា ធ្វើនូវការគ្រប់គ្រងខាងក្រៅ ព្រោះហេតុនោះ បច្ចន្តនគរនោះ ទើបឈ្មោះថាជានគរដែលគេគ្រប់គ្រងល្អហើយទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចូលទៅតាំងសតិទុក ចូរបិទទ្វារ

ទាំង ៦ ដែលប្រព្រឹត្តទៅព្វង់ខាងក្នុង ហើយមិនបោះបង់សតិដែលរក្សាទ្វារ ធ្វើអាយតនៈខាងក្នុងទាំង ៦ នោះឲ្យមាំ ដោយការមិនកាន់យក ដោយប្រការដែលអាយតនៈខាងក្រៅ ៦ កាន់យក នឹងប្រព្រឹត្តទៅដើម្បីកំចាត់អាយតនៈខាងក្នុងចេញ មិនលះបង់សតិដែលរក្សាទ្វារ ដើម្បីមិនឲ្យអាយតនៈខាងក្រៅទាំងនោះចូលទៅខាងក្នុង យ៉ាងនេះឈ្មោះថារក្សាខ្លួនទុកដូច្នោះ ។

បាទព្រះគាថាថា **ខណោ វោ មា ឧបច្ចគា** សេចក្តីថា ក៏បុគ្គលណាមិនគ្រប់គ្រងខ្លួនយ៉ាងនោះ, ខណៈសព្ទនេះ ប្រែថា "ពេលល្អ" ចែកចេញជា ៤ យ៉ាងគឺ " ពេលដែលព្រះពុទ្ធបានត្រាស់ ១ ពេលដែលសត្វកើតឡើងក្នុងមជ្ឈិមប្រទេស ១ ពេលដែលត្រូវបានសម្មាទិដ្ឋិ ១ ពេលដែលមិនវិកលនៃអាយតនៈទាំង ៦ ប្រការ ១ រមែងឈានកន្លងនូវបុគ្គលនោះ, ខណៈនោះចូរកុំកន្លងអ្នកទាំងឡាយឡើយ ។

បទថា **ខណាតីតា** ជាដើម សេចក្តីថា ព្រោះថា បុគ្គលទាំងឡាយណាឈានកន្លងនូវខណៈនោះ, ហើយ

ខណៈនោះឈានកន្ទងបុគ្គលទាំងនោះ, ជនទាំងនោះនឹងណែនណាន់ក្នុងនរក គឺកើតក្នុងនរកនោះហើយ សោកសៅ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះកើតសេចក្ដីសង្វេគតាំងនៅក្នុងព្រះអរហត្តផល ។

រឿងភិក្ខុអាគន្តុក ចប់

# ៨ រឿងនិគ្រន្ថ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកនិគ្រន្ថ ត្រាស់ព្រះធម្មទេសនានេះថា “ **អលជ្ជិតាយេ** ” ជាដើម ។

## ពួកនិគ្រន្ថឈ្មោះនិងពួកភិក្ខុ

សេចក្តីពិស្តារថា ថ្ងៃមួយភិក្ខុទាំងឡាយឃើញពួកនិគ្រន្ថហើយ សន្ទនាគ្នាថា “ ម្នាលអាវុសោ ពួកនិគ្រន្ថទាំងនេះប្រសើរគ្រាន់បើជាងអចេលក៍ទាំងឡាយ, ( ព្រោះថា ) ពួកនិគ្រន្ថតែងបិទបាំងនូវចំហៀងខាងមុខ មួយចំហៀងតែប៉ុណ្ណោះ ប្រហែលជាប្រកបដោយសេចក្តីអៀនខ្មាសខ្លះហើយមើលទៅ ” ។ ពួកនិគ្រន្ថស្តាប់ពាក្យនោះហើយ

ពោលថា “ ពួកយើងរមែងបិទបាំងព្រោះហេតុនោះក៏ទេ ពួកយើងបិទបាំងព្រោះហេតុនេះគឺ ក៏សភាវៈទាំងឡាយ មានអាចម៍ដីនិងធូលីជាដើមនោះ ជារបស់ជាប់ទាក់ទងនិងឥន្ទ្រិយ៍គឺជីវិត, កាលបើដូច្នោះ លំអងផ្សេង ៗ មានអាចម៍ដីនិងធូលីជាដើមនោះ កុំធ្លាក់ចុះក្នុងភាជនៈភិក្ខាទាំងឡាយរបស់ពួកយើង ” ដូច្នេះហើយ ធ្វើនូវពាក្យពោលដ៏ច្រើនដោយអំណាចនៃការពោលទៅនិងការពោលតបជាមួយនិងភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយចូលទៅគាល់ព្រះសាស្តា ក្រាបទូលរឿងនោះក្នុងកាលដែលអង្គុយហើយ ។

## អ្នកសមាទានខុសរមែងដល់ទុគ្គតិ

ព្រះសាស្តាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាសអំពើដែលគេមិនត្រូវខ្មាស មិនខ្មាសអំពើដែលគេត្រូវខ្មាស បុគ្គលនោះរមែងជាអ្នកមានទុគ្គតិជាទីទៅខាងមុខដោយពិត ” ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៨. អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
អភយេ ភយទស្សិនោ ភយេ ច អភយទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងហេតុដែលគេមិនត្រូវខ្មាស រមែងមិនខ្មាសក្នុងហេតុដែលគេត្រូវខ្មាស សត្វទាំងឡាយនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាចផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្លាច ថាជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អលជ្ជិតាយេ** បានដល់ព្រោះភាជនៈភិក្ខាដែលមិនគួរខ្មាស ។ ពិតណាស់ ភាជនៈ

ភិក្ខា ឈ្មោះថា វត្ថុដែលមិនគួរខ្លាស ។ ក៏សត្វទាំងនោះ កាលបិទបាំងកាជនះភិក្ខានោះហើយត្រាច់ទៅ ឈ្មោះថា រមែងខ្លាសព្រោះកាជនះភិក្ខាដែលមិនគួរខ្លាសនោះ ។

បទថា **លជ្ជិតាយេ** សេចក្តីថា ព្រោះអវយវៈជាគ្រឿងញុាំងហិរិឲ្យកម្រើកដែលបុគ្គលមិនបិទបាំង ។ ពិតណាស់ អវយវៈដែលញុាំងហិរិឲ្យកម្រើក ឈ្មោះថា វត្ថុដែលគួរខ្លាស ក៏សត្វទាំងនោះ កាលមិនបិទបាំងអវយវៈដែលញុាំងហិរិឲ្យកម្រើកនោះត្រាច់ទៅ ឈ្មោះថា រមែងមិនខ្លាសហេតុដែលគួរខ្លាស ។ ព្រោះហេតុនោះ កាលសត្វទាំងនោះខ្លាសហេតុដែលមិនគួរខ្លាស មិនលះបង់ហេតុដែលគួរខ្លាស ឈ្មោះថា ជាមនុស្សមិច្ឆាទិដ្ឋិ ព្រោះភាវៈគឺការកាន់យកទទេផង ព្រោះភាវៈគឺការកាន់យកដោយប្រការដទៃផង, សត្វទាំងនោះសមាទានមិច្ឆាទិដ្ឋិនោះហើយត្រាច់ទៅ ឈ្មោះថា សមាទានមិច្ឆាទិដ្ឋិ រមែងទៅកាន់ទុគ្គតិដែលផ្សេងដោយអបាយមាននរកជាដើម ។

បទថា **អភយេ** ជាដើម សេចក្តីថា ភាជនៈកិច្ចា ជាវត្ថុដែលមិនគួរខ្លាច ព្រោះកិលេសគឺរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ និងភ័យគឺទុច្ចរិតមិនកើតឡើងព្រោះអាស្រ័យភាជនៈកិច្ចានោះទេ ។ ក៏សត្វទាំងឡាយបិទបាំងភាជនៈនោះព្រោះការខ្លាច ឈ្មោះថាមានប្រក្រតីយល់ឃើញហេតុដែលមិនគួរខ្លាចថាជាហេតុដែលគួរខ្លាច ។ ក៏អវយវៈដែលញុំាងហិរិឲ្យកម្រើកនោះ ឈ្មោះថាហេតុដែលគួរខ្លាច ព្រោះកិលេសទាំងឡាយមានរាគៈជាដើម រមែងកើតឡើងព្រោះអាស្រ័យអវយវៈដែលញុំាងហិរិឲ្យកម្រើកផង ព្រោះមិនបិទបាំងអវយវៈដែលញុំាងហិរិឲ្យកម្រើកនោះផង ទើបឈ្មោះថា អ្នកមានប្រក្រតីឃើញហេតុដែលគួរខ្លាចថាមិនគួរខ្លាច ។ សត្វទាំងឡាយឈ្មោះថាសមាទានមិច្ឆាទិដ្ឋិ ព្រោះការដែលខ្លួនសមាទានកាន់យកទទេនោះផង ព្រោះការកាន់យកដោយប្រការដទៃផង រមែងទៅកាន់ទុគ្គតិ ។

ក្នុងកាលចប់ទេសនា ពួកនិគ្រន្ថជាច្រើនមានចិត្តសង្វេគហើយបួស, ទេសនាបានកជាសម្រេចប្រយោជន៍សូម្បីដល់បុគ្គលអ្នកប្រជុំគ្នាហើយ ។

រឿងពួកនិគ្រន្ថ ចប់

## ៩ រឿងសាវកតិរ្ថិយ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាវករបស់ពួកតិរ្ថិយ ត្រាស់ព្រះធម្មទេសនានេះថា "**អវជ្ជេ**" ជាដើម ។

## បុត្រពួកតិរ្ថិយទូន្មានកូនមិនឲ្យថ្វាយបង្គំសមណៈ

សេចក្តីពិស្តារថា សម័យមួយពួកសាវកអញ្ញតិរ្ថិយ ឃើញពួកកូន ៗ របស់ខ្លួនព្រមទាំងបរិវារកំពុងលេងជាមួយនិងពួកកូនរបស់ឧបាសកទាំងឡាយដែលជាសម្មាទិដ្ឋិ ពេលដែលកូនទាំងនោះមកផ្ទះវិញ ក៏ឲ្យកូន ៗ ទាំងនោះប្តេជ្ញាថា "ពួកឯងមិនគប្បីថ្វាយបង្គំពួកសមណសក្យបុត្រ, សូម្បីវិហាររបស់សមណៈទាំងនោះ ពួកឯងក៏ត្រូវចូលទៅដែរ" ។ ថ្ងៃមួយ កូនរបស់ពួកអញ្ញតិរ្ថិយទាំងនោះកំពុងលេងនៅជិតក្លោងទ្វារក្រៅវត្តជេតពន ក៏ស្រេកទឹក, ពេលនោះពួកគេក៏ប្រើក្មេងរបស់ឧបាសកម្នាក់ទៅកាន់វិហារដោយពាក្យថា " ពួកឯងទៅផឹកទឹកក្នុងវិហារនោះហើយ ចូរនាំមកឲ្យពួកយើងខ្លះផង " ។ ក្មេងនោះក៏ចូលទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលសេចក្តីនោះ ។

## បុត្ររបស់ពួកតិរ្ថិយរាប់អានព្រះពុទ្ធសាសនា

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ក្មេងនោះថា " ឯងផឹកទឹកហើយ ចូរទៅបញ្ជូនពួកក្មេងក្រៅនេះមក ដើម្បីផឹក

ទឹកនៅទីនេះ ” ។ ក្មេងនោះបានធ្វើហើយដោយប្រការដូច្នោះ ពួកក្មេងទាំងនោះបានមកផឹកទឹកនៅទីនោះ ។ ព្រះសាស្ដា បញ្ជាឲ្យហៅក្មេងទាំងនោះមកហើយ ត្រាស់ធម្មកថាដ៏ជាទី សប្បាយដល់ក្មេងទាំងនោះ ទ្រង់ធ្វើក្មេងទាំងនោះឲ្យមាន សទ្ធាមិនកម្រើកហើយ ឲ្យតាំងនៅក្នុងសរណៈនិងសីល ។ ក្មេងទាំងនោះទៅកាន់ផ្ទះរបស់ខ្លួន ៗ ហើយ ប្រាប់រឿងនោះ ដល់មាតានិងបិតា ។ គ្រានោះមាតានិងបិតារបស់ពួកគេដល់ នូវទោមនស្សប្បរិទេវនាថា “ កូនរបស់ពួកយើងទៅជាអ្នក មានទិដ្ឋិវិបត្តិហើយ ” គ្រានោះអ្នកដែលស្និទ្ធស្នាលនិងមាតា បិតារបស់ក្មេងទាំងនោះជាអ្នកឈ្លាសវៃ មកពោលធម៌ដល់ មាតាបិតារបស់ក្មេងទាំងនោះដើម្បីញុំាងទោមនស្សឲ្យស្ងប់។

មាតានិងបិតារបស់ក្មេងទាំងនោះ ស្ដាប់ធម៌របស់អ្នក នោះហើយ ក៏ពោលថា “ ពួកយើងនឹងប្រគល់ក្មេង ៗ ទាំង នេះឲ្យព្រះសមណគោតម ” លុះពោលដូច្នេះហើយ ក៏នាំ ក្មេងទាំងនោះព្រមទាំងពួកញាតិជាច្រើនទៅកាន់វិហារ ។

**ការយល់ឃើញជាហេតុឲ្យសត្វទៅកាន់ទុគ្គតិនិងសុគតិ**

ព្រះសាស្ដា ទ្រង់ទតមើលនូវអធ្យាស្រ័យរបស់សាវកតិរ្ថិយទាំងនោះហើយ កាលនឹងទ្រង់សម្ដែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៩. អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ

**មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។**
**វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ**
**សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគ្គតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញ ក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង

សត្វទាំងនោះ តែងទៅកាន់សុគតិ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អវជ្ជេ** គឺ ក្នុងសម្មាទិដ្ឋិ ដែលមានវត្ថុ ១០ និងក្នុងធម៌ដែលជាឧបនិស្ស័យនៃសម្មា-ទិដ្ឋិ ។

បទថា **វជ្ជមតិនោ** គឺមានមតិកើតឡើងថា “ នេះមានទោស ” ។ ប៉ុន្តែសត្វទាំងនោះ មានប្រក្រតីឃើញថាមិនមានទោស ក្នុងធម៌ដែលមានទោស គឺមិច្ឆាទិដ្ឋិដែលមានវត្ថុ ១០ និងធម៌ដែលជាឧបនិស្ស័យនៃមិច្ឆាទិដ្ឋិនោះ, អធិប្បាយថា សត្វទាំងឡាយ អ្នកមានការប្រកាន់មាំនូវមិច្ឆាទិដ្ឋិ ព្រោះខ្លួនជាអ្នកប្រកាន់មាំនូវមិច្ឆាទិដ្ឋិនោះ គឺការដឹងធម៌ដែលមិនមានទោសថាជាធម៌មានទោស និងដឹងធម៌ដែលមានទោសថាជាធម៌មិនមានទោសហើយប្រកាន់មាំ រមែងទៅកាន់ទុគ្គតិ ។

សេចក្ដីនៃព្រះគាថាទី ២ បណ្ឌិតគប្បីជ្រាបដោយន័យផ្ទុយនិងព្រះគាថាទី ១ ដូចដែលបានពោលហើយចុះ

ក្នុងកាលចប់ទេសនា  សាវករបស់ពួកតិត្ថិយទាំងនោះ តាំងនៅក្នុងសរណៈ ៣ ហើយស្តាប់ធម៌ដទៃ ៗ ទៀត ក៏បាន តាំងនៅក្នុងសោតាបត្តិផល ។

( រឿងសាវករបស់ពួកតិត្ថិយ ចប់ )

និរយវគ្គវណ្ណនា ចប់

វគ្គទី ២២ ចប់

## នាគវគ្គទី ២៣

១. អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ។
ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។
វរមស្សតរា ទន្តា អាជានីយា វ សិន្ធវា
កុញ្ជរា វ មហានាគា អត្តទន្តោ តតោ វរំ ។

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់។ ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ

ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថាជាបុគ្គលប្រ-
សើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជា-
នេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី
ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថាជា
សត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទ
ហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

**២. ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ**
**យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។**

បុគ្គលទូន្មានខ្លួនបានហើយ ទូន្មានខ្លួនល្អហើយ
ឈ្មោះថាទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួន
មិនធ្លាប់ទៅគឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅ
កាន់ទិសដែលខ្លួនមិនធ្លាប់ទៅ ដោយសារយាន
ទាំងឡាយនោះឡើយ ។

**៣. ធនបាលកោ នាម កុញ្ជរោ**
**កដុកប្បភេទនោ ទុន្និវារយោ**
**ពទ្ធោ កពឡំ ន កុញ្ជតិ**

**សុមរតិ នាគវនស្ស កុញ្ជរោ ។**

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្តៀវក្លា នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ទឹង ដែលដំរីនោះធ្លាប់នៅ ។

**៤. មិទ្ធី យទា ហោតិ មហគ្ឃសោ ច**
**និទ្ទាយិតា សម្បរិវត្តសាយី**
**មហាវរាហោវ និវាបបុដ្ឋោ**
**បុនប្បុនំ គព្ភមុបេតិ មន្ទោ ។**

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះននៀលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹម ដោយសូករភត្ត កាលនោះ បុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយ ៗ ។

**៥. ឥទំ បុរេ ចិត្តមចារិ ចារិកំ**

យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ
ហត្ថិប្បភិន្នំ វិយ អំកុសគ្គហោ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្ដីសប្បាយ ក្នុងថ្ងៃនេះអញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

៦. អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូរលើខ្លួនចេញចាកភក់គឺកិលេស ដែលឆ្លងបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់ លើខ្លួនឲ្យរួចបាន ។

៧. សចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ

អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតីគ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនិងសំឡាញ់នោះឯង ។ បើស្វែងរកមិនបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សា

ខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿង ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយស្ដេចទៅតែឯកអង្គពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈដែលលះហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតិប្រសើរបំផុត ( ព្រោះថា ) សហាយតាគុណរមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្ដីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

**៨. អត្ថម្ហិ ជាតម្ហិ សុខា សហាយា**
**តុដ្ឋី សុខា យា ឥតរីតរេន**

បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។
សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។

កាលបើសេចក្ដីត្រូវការកើតឡើងហើយ សំឡាញ់ទាំងឡាយនាំសេចក្ដីសុខមកឲ្យ សេចក្ដីត្រេកអរដោយបច្ច័យតាមមានតាមបាន ជាហេតុនាំសេចក្ដីសុខមកឲ្យ បុណ្យនាំសេចក្ដីសុខមកឲ្យ ក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្ដីសុខមកឲ្យ ។

ការប្រតិបត្តិល្អចំពោះមាតា នាំសេចក្ដីសុខមកឲ្យក្នុងលោក មួយទៀត ការប្រតិបត្តិល្អចំពោះបិតានាំសេចក្ដីសុខមកឲ្យ ការប្រតិបត្តិល្អចំពោះសមណៈនាំសេចក្ដីសុខមកឲ្យក្នុងលោក មួយទៀត ការប្រតិ-

បត្តិល្អចំពោះព្រាហ្មណ៍ នាំសេចក្ដីសុខមកឲ្យ សីល នាំសេចក្ដីសុខមកឲ្យ ដរាបដល់ចាស់ជរា សទ្ធា ដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្ដីសុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្ដីសុខមកឲ្យ ការមិនធ្វើបាប ទាំងឡាយ នាំសេចក្ដីសុខមកឲ្យ ។

# ២៣ នាគវគ្គវណ្ណនា

## ១ រឿងរបស់ព្រះអានន្ទ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងកោសម្ពី ទ្រង់ប្រារព្ធ ព្រះអានន្ទ ត្រាស់ព្រះធម្មទេសនានេះថា “ **អហំ នាគោវ** ” ជាដើម ។

### ព្រះសាស្ដាត្រូវពួកមិច្ឆាទិដ្ឋិជេរ

រឿងខ្ញុំម្ចាស់ឲ្យពិស្តារហើយ ក្នុងវណ្ណនានៃព្រះគាថាដំបូងនៃអប្បមាទវគ្គនោះឯង ។ ពិតណាស់ ក្នុងទីនោះខ្ញុំម្ចាស់ពោលទុកដូច្នេះថា “ ព្រះនាងមាគន្ទិយាមិនអាចអ្វី ៗ ស្ត្រី ៥០០ មានព្រះនាងសាមាវតីជាប្រធានបាន ” ទើបទ្រង់ព្រះតម្រិះថា “ យើងនឹងធ្វើកិច្ចដែលគួរធ្វើចំពោះព្រះសមណគោតមឲ្យទាល់តែបាន ” លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏បានប្រាក់អ្នកនគរទាំងឡាយហើយ ពោលថា “ អ្នកទាំងឡាយព្រមទាំងពួកបុរសដែលជាទាសនិងកម្មករ ចូរជេរព្រះសមណគោតមក្នុងកាលដែលស្តេចចូលកាន់ព្រះនគរ ឲ្យចៀសចេញទៅ ” ។

ពួកមិច្ឆាទិដ្ឋអ្នកមិនជ្រះថ្លាក្នុងព្រះរតនៈត្រៃ បានជាប់តាមព្រះសាស្តា ដែលស្តេចចូលទៅខាងក្នុងព្រះនគរ ជេរបរិភាសដោយអក្កោសវត្ថុ ១០ យ៉ាងថា “ ឯងជាចោរ ឯងជាបុគ្គលពាល ជាមនុស្សវង្វេង ឯងជាអូដ្ឋ ឯងជាគោ ឯងជាលា ឯងជាសត្វនរក ឯងជាសត្វតិរច្ឆាន, សុគតិមិនមានសម្រាប់ឯងទេ, ទុគ្គតិប៉ុណ្ណោះដែលឯងគប្បីសង្ឃឹម ” ។

## ព្រះអានន្ទទូលឲ្យស្ដេចទៅកាន់នគរដទៃក៏ស្ដេចមិនទៅ

ព្រះអានន្ទស្ដាប់ពាក្យនោះហើយ បានក្រាបទូលពាក្យនេះចំពោះព្រះសាស្ដាថា “ បពិត្រព្រះអង្គដ៏ចំរើន អ្នកនគរទាំងនេះ តែងតែជេរ តែងតែបរិភាសយើងទាំងឡាយ, យើងទាំងឡាយទៅកាន់ទីដទៃវិញចុះ ” ។

ព្រះសាស្ដា. ម្នាលអានន្ទ តើយើងទៅកាន់ទីណា ?

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចំរើន ទៅកាន់នគរដទៃ

ព្រះសាស្ដា. ប្រសិនបើមនុស្សទាំងឡាយក្នុងទីនោះជេរ បរិភាស, តើយើងនឹងទៅកាន់ទីណាទៀត ។

ព្រះអានន្ទ. ទៅកាន់នគរដទៃទៀត ព្រះអង្គ ។

ព្រះសាស្ដា. កាលមនុស្សក្នុងទីនោះ ជេរ បរិភាសយើងទៀត តើយើងទាំងឡាយនឹងទៅកាន់ទីណាទៀត អានន្ទ

ព្រះអានន្ទ. ទៅកាន់នគរដទៃទៀត ព្រះអង្គ ។

ព្រះសាស្ដា. ម្នាលអានន្ទ ការធ្វើយ៉ាងនោះមិនសមគួរទេ, អធិករណ៍កើតឡើងក្នុងទីណា, កាលវាស្ងប់ហើយក្នុងទី

នោះ, ការទៅកាន់ទីជទៃទើបសមគួរ, ម្នាលអានន្ទ តើពួកណា ជាជេរ ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចំរើន ជនទាំងអស់តាំងអំពីទាសនិងកម្មករ រមែងជេរ ។

## ព្រះសាស្តាទ្រង់អត់ទ្រាំពាក្យល្មើសបាន

ព្រះសាស្តាត្រាស់ថា " ម្នាលអានន្ទ តថាគតដូចជាដំរីដែលចូលកាន់សង្គ្រាម, ការអត់ទ្រាំចំពោះកូនសរទាំងឡាយដែលមកអំពីទិសទាំង ៤ ជាភារៈរបស់ដំរីដែលចូលកាន់សង្គ្រាម យ៉ាងណា, ឈ្មោះថាការអត់ទ្រាំចំពោះពាក្យដែលជនទ្រុស្តសីលដ៏ច្រើនពោលហើយ ជាភារៈរបស់តថាគត ដូច្នោះដែរ " ។ កាលនឹងប្រារព្ធព្រះអង្គដើម្បីសម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះ ក្នុងនាគវគ្គថា ៖-

**១.អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ**
**អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ។**
**ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ**
**ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។**

វរមស្សតរា ទន្តា　　អាជានីយា វ សិន្ធវា
កុញ្ជរា វ មហានាគា　អត្តទន្តោ តតោ វរំ ។

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញដែលរបូតចេញអំពីធ្នូក្នុងសង្គ្រាម ដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ៗ ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថាជាបុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

### អធិប្បាយគាថា

បណ្ដាបទថា បទថា **នាគោ** គឺ ដូចដំរី ។

ពីរបទថា **ចាបាតោ បតិតំ** សេចក្ដីថា របូតចេញអំពីធ្នូ ។

បទថា **អតិវាក្យំ** សេចក្ដីថា នូវពាក្យល្មើស ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃអនរិយវោហា ៨ ។

បទថា **តិតិក្ខិស្សំ** សេចក្ដីថា ដំរីធំដែលហត្ថាចារ្យហ្វឹកហាត់ល្អហើយ ចូលកាន់សង្គ្រាម ជាសត្វអត់ធន់ មិនរួញរា ( មិនញញើត ) ចំពោះកូនសរដែលរបូតចេញអំពីបំពង់ហើយធ្លាក់មកលើខ្លួន ឈ្មោះថា រមែងអត់ទ្រាំចំពោះការប្រហារទាំងឡាយ មានការប្រហារដោយលំពែងជាដើម យ៉ាងណា, តថាគតក៏នឹងអត់ទ្រាំ គឺនឹងអត់ធន់ចំពោះពាក្យល្មើលមានសភាពយ៉ាងនោះ ដូច្នោះដែរ ។

បទថា **ទុស្សីលោ ហិ** សេចក្ដីថា ព្រោះលោកិយមហាជននេះ ភាគច្រើនជាអ្នកទ្រុស្តសីល ដើរបញ្ចេញវាចាស៊កសៀតដោយអំណាចនៃសេចក្ដីគាប់ចិត្តរបស់ខ្លួន, ការ

អត់ធន់ គឺការព្រងើយកន្តើយចំពោះពាក្យនោះ ជាភារៈរបស់តថាគត ។

បទថា **សមិតី** សេចក្តីថា ក៏ជនទាំងឡាយ កាលនឹងទៅកាន់ទីប្រជុំជនក្នុងសមាគមទាំងឡាយ មានឧទ្យាននិងកីឡាឋានជាដើម ទឹមគោឬសេះដែលបង្ហឹកហើយប៉ុណ្ណោះក្នុងយានហើយ រមែងនាំទៅ ។

បទថា **រាជា** សេចក្តីថា សូម្បីព្រះរាជា កាលនឹងស្តេចទៅកាន់ទីបែបនោះ រមែងទ្រង់សត្វពាហនៈដែលបង្ហឹកហើយប៉ុណ្ណោះ ។

បទថា **មនុស្សេសុ** សេចក្តីថា សូម្បីក្នុងមនុស្សទាំងឡាយអ្នកទូន្មានខ្លួនហើយ គឺអ្នកមានការសេពខុសប្រាសចេញហើយ ដោយអរិយមគ្គទាំង ៤ ជាអ្នកប្រសើរ ។

បទថា **យោតិវាក្យំ** សេចក្តីថា បុគ្គលណាតែងអត់ធន់ គឺរមែងមិនតបត មិនក្រហល់ក្រហាយចំពោះពាក្យរំលោកបែបនោះ សូម្បីគេពោលរឿយ ៗ ។ បុគ្គលអ្នកមានខ្លួនទូន្មានហើយបែបនោះ ជាបុគ្គលប្រសើរ ។

សេះដែលកើតអំពីមេសេះជាមួយនិងបាលា ឈ្មោះថា សេះអស្សតរ ។ បទថា **អាជានិយា** សេចក្ដីថា សេះដែលដឹងនូវហេតុការណ៍ ដែលសារថីអ្នកបង្ហាត់សេះឲ្យធ្វើនូវការណ៍ឯណាយ៉ាងឆាប់រហ័ស ។

សេះដែលកើតក្នុងដែនឈ្មោះសិន្ធវៈ ឈ្មោះថា សេះសិន្ធព ។ ដំរីធំ ៗ ទាំងឡាយ ដែលហៅថាកុញ្ជរ ឈ្មោះថា មហានាគ ។

បទថា **អត្តទន្តោ** ជាដើម សេចក្ដីថា សេះអស្សតរក្ដី សេះសិន្ធពក្ដី ដំរីកុញ្ជរក្ដី ទាំងនោះ ដែលបុគ្គលបង្វឹកហើយ ឈ្មោះថាជាសត្វប្រសើរ, ដែលបុគ្គលមិនទាន់បានបង្វឹក មិនប្រសើរ, ប៉ុន្តែបុគ្គលណា មានខ្លួនទូន្មានហើយ គឺអស់យល់ហើយ ព្រោះបានទូន្មានខ្លួនដោយអរិយមគ្គទាំង ៤ បុគ្គលនោះ រមែងប្រសើរជាងសត្វពាហនៈ មានសេះអស្សតរជាដើមនោះ គឺជាអ្នកក្រៃលែងជាងសត្វពាហនៈ មានសេះអស្សតរជាដើមនោះ ។

ក្នុងកាលចប់ទេសនា មហាជនអ្នកទទួលយកថ្លៃឈ្នួលហើយ ឈរជេរក្នុងទីទាំងឡាយ មានថ្នលនិងផ្លូវបែកជាបីជាដើមនោះ បានសម្រេចសោតាបត្តិផល ។

រឿងរបស់ព្រះអង្គ ចប់

## ២ រឿងភិក្ខុអ្នកធ្លាប់ជាហ្លួងដំរី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូបដែលធ្លាប់ជាហ្មដំរី ត្រាស់ព្រះធម្មទេសនានេះថា " **ន ហិ ឯតេហិ** " ជាដើម ។

## ហត្ថាចារ្យបង្ហាត់ដំរីបានល្អព្រោះបានន័យអំពីភិក្ខុ

បានឮថា ថ្ងៃមួយ ភិក្ខុនោះឃើញបុរសអ្នកបង្ហាត់ដំរីតាំងចិត្តថា " យើងនឹងបង្ហាត់ដំរីមួយ " ហើយមិនអាចនឹងញ៉ាំងដំរីឲ្យរៀននូវហេតុដែលខ្លួនប្រាថ្នាបាន នៅជិតឆ្នេរស្ទឹងអចិរវតី ក៏ហៅភិក្ខុទាំងឡាយដែលឈរនៅជិតមកហើយពោលថា " អ្នកមានអាយុទាំងឡាយ ប្រសិនបើហត្ថាចារ្យនេះ គប្បីចាក់ដំរីនោះក្នុងទីឈ្មោះឯណោះសោត, គេនឹងអាចឲ្យវារៀនហេតុនេះបានដោយឆាប់រហ័ស " ។ ហត្ថាចារ្យនោះស្ដាប់ពាក្យរបស់ភិក្ខុនោះហើយ ទើបធ្វើយ៉ាងនោះ ក៏បង្ហាត់ដំរីនោះឲ្យជាសត្វដែលបង្ហឹកល្អហើយ ។ ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនោះចំពោះព្រះសាស្ដា ។

**ទូន្មានខ្លួនល្អហើយរមែងទៅកាន់ទីដែលមិនធ្លាប់ទៅបាន**

ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា “ ម្នាលភិក្ខុ បានឮថា អ្នកនិយាយយ៉ាងនោះពិតមែនឬ ?” កាលភិក្ខុនោះក្រាបទូលថា “ ព្រះករុណា ព្រះអង្គ ” ទ្រង់តិះដៀលភិក្ខុនោះហើយ ត្រាស់ថា “ ម្នាលមោឃបុរស ប្រយោជន៍អ្វីដោយយានគឺដំរី ឬយានដទៃដែលបង្ហាត់ល្អហើយ ដល់អ្នក ? ព្រោះថាបុគ្គលអាចនឹងទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅបានដោយយានទាំងនេះក៏ទេ, ប៉ុន្តែបុគ្គលអ្នកមានខ្លួនទូន្មានល្អហើយ អាចទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅបាន, ព្រោះហេតុនោះ អ្នកចូរទូន្មានខ្លួនប៉ុណ្ណោះ, ការបង្ហាត់សត្វពាហនៈទាំងនោះនឹងមានប្រយោជន៍អ្វីដល់អ្នក” ហើយ ត្រាសព្រះគាថានេះថាៈ-

**២. ន ហិ ឯតេហិ យានេហិ  គច្ឆេយ្យ អគតំ ទិសំ**
**យថាត្តនា សុទន្តេន  ទន្តោ ទន្តេន គច្ឆតិ ។**

បុគ្គលទូន្មានខ្លួនបានហើយ ទូន្មានខ្លួនល្អហើយ
ឈ្មោះថាទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួន

មិនធ្លាប់ទៅគឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅ
កាន់ទិសដែលខ្លួនមិនធ្លាប់ទៅ ដោយសារយាន
ទាំងឡាយនោះឡើយ ។

## អធិប្បាយគាថា

ព្រះគាថានោះ មានសេចក្តីថា ក៏បុគ្គលណា ៗ គប្បី
ទៅកាន់ទិសគឺព្រះនិព្វានដែលខ្លួនមិនទាន់បានទៅ ព្រោះជា
ទិសដែលខ្លួនមិនធ្លាប់ទៅ ដោយហោចទៅ សូម្បីតែយល់
សប្តិ ដោយយានទាំងឡាយ មានយានគឺដំរីជាដើមបាន, ដូច
បុគ្គលអ្នកទូន្មានខ្លួនហើយ គឺអ្នកអស់ការយល់ខុស មាន
បញ្ញា ទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺដល់ភូមិនៃអ្នក
ដែលទូន្មានខ្លួនហើយ ដោយខ្លួនដែលទូន្មានល្អហើយ ដោយ
ការទូន្មានឥន្ទ្រិយ៍ក្នុងចំណែកខាងដើម ទូន្មានល្អហើយដោយ
អរិយមគ្គការនាក្នុងចំណែកខាងចុងដូច្នេះក៏ទេ ព្រោះហេតុ
នោះ ការទូន្មានខ្លួនប៉ុណ្ណោះ ទើបប្រសើរសម្រាប់អ្នក ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ
ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងភិក្ខុជាប់ជាហ្វដីរ ចប់

## ៣ រឿងបុត្ររបស់ព្រាហ្មណ៍ចាស់ទុរន់

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធបុត្ររបស់ព្រាហ្មណ៍ចាសទូរន់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា " **ធនបាលកោ** " ជាដើម ។

### បុត្របំរើបិតាព្រោះចង់បានសម្បត្តិ

បានឮថា ព្រាហ្មណ៍ម្នាក់ដែលមានប្រក្រតីនៅក្នុងក្រុងសាវត្ថី មានសម្បត្តិប្រមាណ ៨ សែន រៀបអាវាហមង្គលឲ្យបុត្របួននាក់ ចំរើនវ័យហើយបានឲ្យទ្រព្យម្នាក់បួនសែន។

គ្រានោះ កាលព្រាហ្មណីធ្វើកាលកិរិយាទៅ បុត្រទាំងបួននាក់នោះក៏ប្រឹក្សាគ្នាថា " ប្រសិនបើបិតារបស់ពួកយើងនឹងនាំព្រាហ្មណីដទៃមកទៀតសោត, ត្រកូលនឹងបែកដោយអំណាចបុត្រទាំងឡាយដែលកើតក្នុងផ្ទៃរបស់នាង, ណ្ហើយ

ចុះ ពួកយើងនឹងជួយគ្នាចិញ្ចឹមបីបាច់ថែរក្សាគាត់ ” បុត្រទាំង បួននាក់នោះ ចិញ្ចឹមថែរក្សាព្រាហ្មណ៍ចាស់ជរានោះ ដោយ បច្ច័យមានអាហារ និងគ្រឿងស្លៀកដណ្ដប់ជាដើមដ៏ប្រណិត ធ្វើកិច្ចទាំងឡាយ មានការគក់ប្រេបាច់ដៃជើងជាដើម លុះ ចិញ្ចឹមបីបាច់ថែរក្សាហើយ ថ្ងៃមួយ កាលព្រាហ្មណ៍ចាស់ ជរានោះដេកលក់ពេលថ្ងៃហើយក្រោកឡើង ក៏នាំគ្នាគក់ប្រេ បាច់ដៃជើងរបស់បិតាបណ្ដើរ និយាយទោសក្នុងការនៅគ្រប់ គ្រងផ្ទះប្លែក ៗ គ្នា ( ដោយឡែក ៗ អំពីគ្នា ) ហើយអង្វរ លួងលោមថា “ ពួកខ្ញុំនឹងចិញ្ចឹមបីបាច់ពុកបែបនេះរហូត ជីវិត, សូមពុកមេត្តាឲ្យទ្រព្យដែលនៅសល់ដល់ពួកខ្ញុំចុះ ”។ ព្រាហ្មណ៍នោះបានឲ្យទ្រព្យដល់បុត្រម្នាក់បួនសែនទៀត បែង គ្រឿងឧបភោគទាំងអស់ឲ្យទៅជាបួនចំណែកហើយ ប្រគល ឲ្យបុត្រទាំងបួននាក់នោះ បន្សល់ទុកតែសំពត់ស្លៀកដណ្ដប់ របស់ខ្លួនប៉ុណ្ណោះ, បុត្រច្បងចិញ្ចឹមបីបាច់ថែរក្សាព្រាហ្មណ៍ នោះបាន ២-៣ ថ្ងៃ ។

## ព្រាហ្មណ៍ដើរសូមទានគេស៊ី

ក្រោយមក នៅថ្ងៃមួយ កូនប្រសាស្រីឈរនៅត្រង់ក្លោងទ្វារ និយាយនិងព្រាហ្មណ៍ចាស់ដែលងូតទឹកហើយដើរមកនោះយ៉ាងនេះថា " ទ្រព្យ ១០០ ឬ ១០០០ ដែលពុកឲ្យដល់បុត្រច្បងក្រៃលែងជាងបុត្រទាំងឡាយមានឬ, ពុកបានបែងចែកទ្រព្យឲ្យបុត្រម្នាក់ប្អូនសែនមិនមែនឬ ? ហេតុដូចម្តេច ទើបពុកមិនស្គាល់ផ្លូវទៅកាន់ផ្ទះកូន ៗ ដទៃ ? "

ចំណែកព្រាហ្មណ៍នោះ ខឹងនិងកូនប្រសាស្រីនោះហើយជេរថា " នែមេចង្រៃ នាងឯងចូរវិនាសទៅ, " ដូច្នេះហើយ ក៏ចៀសចេញទៅកាន់ផ្ទះកូនដទៃ, ដោយកាលកន្លងបាន ២-៣ ថ្ងៃ ព្រាហ្មណ៍នោះក៏ត្រូវកូនប្រសាដទៃធ្វើឲ្យរត់ចេញអំពីផ្ទះនោះ ដោយឧបាយនេះដដែល ( បានទៅកាន់ផ្ទះកូនដទៃទៀត ) កាលមិនបានចូលផ្ទះរបស់កូនណាមួយ ក៏បួសជាអ្នកស្លៀកសពាក់ស ដើរសូមកិក្ខា ដោយកាលកន្លងទៅគាត់ក៏គ្រាំគ្រាដោយជរា មានសរីរៈសៅហ្មងព្រោះភោជនមិនល្អនិងទីដេកដ៏លំបាក ត្រាច់ទៅដើម្បីកិក្ខា (ត្រឡប់មក) វិញ ដាក់ខ្នងលើតាំងតូចមួយហើយក៏ដេកលក់ទៅ ក្រោក

ឡើងអង្គុយមើលខ្លួន ដែលមានសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ មិនឃើញទីពឹងរបស់ខ្លួនក្នុងបុត្រទាំងឡាយ ក៏គិតថា " បានឮថា ព្រះសមណគោតមជាមនុស្សមិនក្រញិវក្រញូវ មានព្រះភក្ត្ររីករាយ ( ញញឹម ) ទ្រង់មានព្រះវាចាពីរោះ នាំមកនូវសេចក្តីសុខ ទ្រង់ឈ្លាសវៃក្នុងបដិសណ្ឋារៈ, យើងអាចចូលទៅគាល់ព្រះសមណគោតមហើយ បានទទួលបដិសណ្ឋារៈ " ។ ព្រាហ្មណ៍នោះស្លៀកដណ្តប់រៀបរយហើយ ចាប់យកភាជនៈភិក្ខា កាន់ឈើច្រត់ទៅកាន់សំណាក់ព្រះមានព្រះភាគ ។

សមដូចព្រះធម្មសង្គាហកាចារ្យទាំងឡាយ សម្តែងទុក " គ្រានោះ ព្រាហ្មណ៍មហាសាលមួយរូប ជាអ្នកសៅហ្មង មានសពត់ដណ្តប់ដ៏សៅហ្មង ចូលទៅគាល់ព្រះមានព្រះភាគដល់កន្លែងដែលព្រះអង្គគង់ " ។

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រាហ្មណ៍នោះហើយ បានត្រាស់ពាក្យនេះថា " ម្នាលព្រាហ្មណ៍ ព្រោះ

ហេតុអ្វីហ្ន៎ ទើបអ្នកជាមនុស្សសៅហ្មង មានសំពត់ដណ្តប់ដ៏សៅហ្មងបែបនេះ ?”

ព្រាហ្មណ៍នោះក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានបុត្រ ៤ នាក់ក្នុងលោកនេះ, បុត្រទាំងនោះត្រូវកិរិយាញុះញង់ បណ្តេញខ្ញុំព្រះអង្គចេញអំពីផ្ទះ ” ។

## ព្រះសាស្តាឲ្យព្រាហ្មណ៍រៀនគាថា

ព្រះសាស្តាត្រាស់ថា “ ម្នាលព្រាហ្មណ៍ បើដូច្នោះអ្នកចូររៀនគាថាទាំងនេះ ហើយសូត្រក្នុងរោងជាទីប្រជុំ នៅវេលាដែលពួកមហាជនប្រជុំគ្នាផង នៅវេលាដែលកូនទាំងឡាយរបស់អ្នកអង្គុយហើយផងថា ៖-

ខ្ញុំត្រេកអរដោយកូនទាំងឡាយណា ដែលកើតហើយផង ប្រាថ្នានូវសេចក្តីចំរើនដល់កូនទាំងឡាយណាផង កូនទាំងនោះ ក៏សមគំនិតគ្នាជាមួយនិងប្រពន្ធទាំងឡាយ ហើយបណ្តេញខ្ញុំ ដូចជាឆ្កែដេញជ្រូក ក៏កូនទាំងឡាយ ជាអសប្បុរសលាមក គ្រាន់តែហៅខ្ញុំថា បិតា បិតាប៉ុណ្ណោះទេ

ប៉ុន្តែកូនទាំងនោះ ដូចអារក្សទឹកដែលមកដោយ
រូបជាកូន លះបង់នូវខ្ញុំដែលមានអាយុ ចូលដល់
បច្ឆិមវ័យហើយ បិតាចាស់របស់បុគ្គលពាល
ទាំងឡាយតែងសូមទានប្រែបផ្ទះនៃជនដទៃដូចជា
សេះចាស់ប្រើប្រាស់មិនបាន គេនាំចេញចាកចំណី
ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយដែលមិន
ស្តាប់បង្គាប់ មិនប្រសើរដូចឈើច្រត់ឡើយ
ព្រោះឈើច្រត់ រមែងការពារគោកាចក៏បាន ការ
ពារឆ្កែកាចក៏បាន ច្រត់ក្នុងខាងមុខ ក្នុងទីងងឹតក៏
បាន ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិល
គង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់ ។

## ព្រាហ្មណ៍បានឧបាយល្អ

ព្រាហ្មណ៍រៀនគាថាទាំងនោះ ក្នុងសម្នាក់ព្រះមានព្រះភាគហើយ កាលពួកបុត្រប្រជាប់ដោយគ្រឿងអលង្ការទាំងឡាយហើយ ចូលទៅកាន់រោងជាទីប្រជុំនោះ អង្គុយអាសនៈដែលមានតម្លៃច្រើន ក្នុងកណ្តាលពួកព្រាហ្មណ៍ ក្នុងថ្ងៃប្រជុំ

ពួកព្រាហ្មណ៍បែបនោះ, សម្រេចចិត្តថា “ កាលនេះជាកាលរបស់យើងហើយ ” ចូលទៅកាន់រោងជាទីប្រជុំ លើកដៃឡើងហើយពោលថា “ នែលោកអ្នកដ៏ចំរើនទាំងឡាយ ខ្ញុំប្រាថ្នានឹងពោលគាថាចំពោះអ្នកទាំងឡាយ, តើអ្នកទាំងឡាយចង់ស្តាប់ទេ ? ” កាលព្រាហ្មណ៍ទាំងនោះតបថា “ ម្នាលព្រាហ្មណ៍ អ្នកចូរពោលចុះ ពួកយើងនឹងស្តាប់ ”, ក៏បានឈរពោលនៅកណ្តាលពួកព្រាហ្មណ៍នោះឯង ។

ក៏ក្នុងសម័យនោះ មនុស្សទាំងឡាយមានវត្តយ៉ាងនេះថា “ បុត្រទាំងឡាយណា ទទួលយកទ្រព្យដែលជារបស់មាតាបិតាហើយ ( ប៉ុន្តែ ) មិនចិញ្ចឹមមាតាបិតា បុត្រទាំងនោះត្រូវសម្លាប់ ” ។ ព្រោះហេតុនោះ បុត្ររបស់ព្រាហ្មណ៍ទាំងនោះ ក៏ក្រាបចុះក្បែរជើងរបស់បិតាហើយ អង្វរថា “ បពិត្របិតា សូមបិតាមេត្តាឲ្យជីវិតដល់ពួកខ្ញុំផងចុះ ” ។

ព្រោះភាវៈនៃហឫទ័យបិតា ជាធម្មជាតិដ៏ទន់ ទើបព្រាហ្មណ៍នោះពោលថា “ នែលោកអ្នកដ៏ចម្រើនទាំងឡាយ

សូមអ្នកទាំងឡាយ កុំឲ្យបុត្រតូចទាំងឡាយរបស់ខ្ញុំវិនាសឡើយ ពួកគេនឹងចិញ្ចឹមមើលថែខ្ញុំហើយ ” ។

គ្រានោះ មនុស្សទាំងឡាយ ក៏ពោលទៅកាន់ពួកបុត្ររបស់ព្រាហ្មណ៍នោះថា “ នែអ្នកដ៏ចំរើនទាំងឡាយ ចាប់អំពីថ្ងៃនេះទៅ ប្រសិនបើអ្នកទាំងឡាយមិនចិញ្ចឹម មិនថែទាំបិតារបស់អ្នកទាំងឡាយឲ្យបានល្អទេ ពួកយើងសម្លាប់ពួកឯងចោល” ។ បុត្រទាំងនោះខ្លាចហើយ អញ្ជើញបិតាឲ្យអង្គុយលើតាំង លើកឡើងនាំទៅកាន់ផ្ទះដោយខ្លួនឯង លាបសរីរៈដោយប្រេង ដុសខាត ( ឲ្យស្អាត ) ផ្ងូតដោយវត្ថុទាំងឡាយមានលំអិត និងគ្រឿងក្រអូបជាដើមហើយ ឲ្យហៅព្រាហ្មណីទាំងឡាយមកហើយ ផ្ដាំថា “ ចាប់តាំងពីថ្ងៃនេះទៅ នាងទាំងឡាយ ត្រូវថែទាំបិតារបស់ពួកយើងឲ្យបានល្អ , ប្រសិនបើនាងទាំងឡាយ ធ្វេសប្រហែសមិនយកចិត្តទុកដាក់ក្នុងការថែទាំទេនោះ, ពួកយើងនឹងផ្ចាញ់ផ្ចាលនាងទាំងឡាយ ” លុះផ្ដាំកិរិយាទាំងឡាយរបស់ខ្លួនយ៉ាងនោះ ក៏ញុំាងបិតារបស់ខ្លួនឲ្យបរិភោគភោជនដ៏ប្រណីត ។

# ព្រាហ្មណ៍គិតដល់ឧបការគុណ
# របស់ព្រះមានព្រះភាគ

ព្រាហ្មណ៍អាស្រ័យភោជនដ៏ល្អផង ការដេកដ៏ជាសុខផង ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏ក្លាយទៅជាអ្នកមានកម្លាំងបរិបូណ៌ មានឥន្ទ្រិយ៍ផូរផង់ សម្លឹងមើលអត្តភាពរបស់ខ្លួនហើយគិតថា“សម្បត្តិនេះ យើងបានព្រោះអាស្រ័យព្រះសមណគោតម” កាន់យកសំពត់មួយគូដើម្បីប្រយោជន៍ដល់ភាពជាបណ្ណាការ ទៅកាន់សំណាក់ព្រះមានព្រះភាគ មានបដិសណ្ឋារៈដែលព្រះមានព្រះភាគទ្រង់ធ្វើហើយ អង្គុយក្នុងទីដ៏សមគួរមួយ ដាក់សំពត់នោះក្បែរបាទមូលរបស់ព្រះមានព្រះភាគហើយ ក្រាបទូលថា “ បពិត្រព្រះអង្គ ដ៏ចំរើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ រមែងស្វែងរកទ្រព្យជាចំណែកនៃអាចារ្យ ដើម្បីអាចារ្យ, សូមព្រះគោតមដ៏ចំរើន ដែលជាអាចារ្យរបស់ខ្ញុំព្រះអង្គ មេត្តាទទួលយកទ្រព្យជាចំណែកនៃអាចារ្យ” ព្រះមានព្រះភាគទ្រង់ទទួលយកសំពត់មួយគូនោះដើម្បីអនុគ្រោះព្រាហ្មណ៍នោះហើយ ទ្រង់សម្តែងធម៌ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសរណៈហើយ ទើបក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គថ្វាយធុវភត្ត ( ភត្តដ៏ទៀងទាត់ ) ២ អំពីភត្តដ៏ទៀតទាត់ដែលបុត្រទាំងឡាយឲ្យខ្ញុំព្រះអង្គនោះ ចំពោះព្រះអង្គ " ។

គ្រានោះ ព្រះសាស្ដាត្រាស់ថា "ម្នាលព្រាហ្មណ៍ ជាការល្អណាស់ , ក៏ប៉ុន្តែថា តថាគតនឹងទៅកាន់ទីជាទីគាប់ចិត្តប៉ុណ្ណោះ " ហើយទ្រង់បញ្ជូនព្រាហ្មណ៍នោះទៅ ។

ព្រាហ្មណ៍ទៅដល់ផ្ទះហើយ ប្រាប់ពួកបុត្រថា "នែកូនទាំងឡាយ ព្រះសមណគោតមជាសម្លាញ់របស់ពុក , ពុកថ្វាយធុវភត្ត ២ ចំពោះព្រះអង្គ , ពួកឯងកុំប្រមាទក្នុងកាលព្រះអង្គស្ដេចមកដល់ណ៎ា ", បុត្រទាំងឡាយ ទទួលថា " ប្រពៃហើយ លោកពុក " ។

## ព្រះសាស្ដាប្រោសបុត្ររបស់ព្រាហ្មណ៍

ថ្ងៃស្អែកឡើង ព្រះសាស្ដាស្ដេចយាងទៅបិណ្ឌបាត បានស្ដេចទៅដល់ទ្វារផ្ទះនៃបុត្រច្បង ( របស់ព្រាហ្មណ៍ ),គេ

ឃើញព្រះសាស្តាហើយ ទទួលបាត្រ អារាធនាស្តេចឲ្យចូល កាន់ផ្ទះ អារាធនាឲ្យស្តេចគង់លើបល្ល័ង្កដែលមានតម្លៃច្រើន ហើយបានថ្វាយភោជនដ៏ប្រណីត , ព្រះសាស្តាបានស្តេចទៅ កាន់ផ្ទះរបស់បុត្រព្រាហ្មណ៍ទាំងអស់តាមលំដាប់ គឺថ្ងៃស្អែក ឡើង របស់បុត្រក្រៅនេះ, ថ្ងៃស្អែកឡើង របស់បុត្រក្រៅនេះ ពួកគេគ្រប់គ្នាបានធ្វើសក្ការៈយ៉ាងនោះដូចគ្នា ។

ក្រោយមក នៅថ្ងៃមួយ បុត្រច្បង កាលមង្គលប្រាកដ ចំពោះហើយ ក៏សួរបិតាថា "បពិត្របិតា តើពួកខ្ញុំនឹងឲ្យ មង្គលដល់អ្នកណា ?" ។

ព្រាហ្មណ៍. ពុកមិនស្គាល់អ្នកដទៃទេ, ព្រះសមណ គោតមជាសម្លាញ់របស់ពុកមិនមែនឬ ?

បុត្រច្បង. បើដូច្នោះ សូមបិតាអារាធនានិមន្តព្រះអង្គ ព្រមទាំងភិក្ខុ ៥០០ រូប ដើម្បីទទួលភត្តក្នុងថ្ងៃស្អែក ។

ព្រាហ្មណ៍បានធ្វើយ៉ាងនោះ, ថ្ងៃស្អែកឡើង ព្រះសា ស្តា មួយអន្លើដោយបរិវារ បានស្តេចទៅកាន់ផ្ទះបុត្រច្បង របស់ព្រាហ្មណ៍នោះ ។ គេនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជា

ប្រធានឲ្យគង់ក្នុងផ្ទះ ដែលលាបដោយវត្ថុ មានពណ៌ខៀវស្រស់ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ហើយអង្គាសដោយមធុបាយាសខាប់ និងដោយខាទនីយៈដ៏ប្រណីត ។

ក៏ក្នុងចន្លោះនៃកត្តនោះ បុត្រ ៤ នាក់របស់ព្រាហ្មណ៍អង្គុយក្នុងសម្នាក់ព្រះសាស្តា ក្រាបទូលថា " បពិត្រគោតមដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយប្រតិបត្តិបិតារបស់ពួកខ្ញុំព្រះអង្គដោយមិនប្រមាទ , សូមព្រះអង្គទ្រង់ទតមើលអត្តភាពរបស់គាត់ចុះ ។

## ការបម្រើមាតាបិតាជាមង្គល

ព្រះសាស្តាត្រាស់ថា " អ្នកទាំងឡាយបានធ្វើកម្មដ៏ល្អ, ព្រោះថា ការចិញ្ចឹមមាតាបិតា បូរាណបណ្ឌិតទាំងឡាយធ្លាប់បានប្រព្រឹត្តមកហើយដែរ " ហើយត្រាស់មាតុបោសកនាគ-ជាតកក្នុងឯកាទសនិបាតនេះដោយពិស្តារថា " ព្រោះដំរីនោះចៀសចេញទៅ ទើបដើមអំពៅព្រៃ និងដើមក្លែងគង់លូតលាស់ឡើង " ដូច្នេះជាដើម ហើយបានទ្រង់ភាសិតព្រះគាថានេះថា ៖-

៣. ធនបាលកោ នាម កុញ្ជរោ
កដុកប្បភេទនោ ទុន្និវារយោ
ពទ្ធោ កពឡំ ន កុញ្ជតិ
សុមរតិ នាគវនស្ស កុញ្ជរោ ។

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្លៀវក្លា នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ទឹង ដែលដំរីនោះធ្លាប់នៅ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ធនបាលកោ នាម** នោះជាឈ្មោះរបស់ដំរីដែលព្រះបាទកាសិករាជ ទ្រង់បញ្ជូនហត្ថាចារ្យឲ្យទៅចាប់ក្នុងនាគវនដ៏មនោរម្យក្នុងកាលនោះ ។

បទថា **កដុកប្បភេទនោ** សេចក្តីថា ចុះប្រេងខ្លាំង ។ ក្នុងកាលជាទីចុះប្រេងរបស់ដំរីទាំងឡាយ គុម្ពត្រចៀកទាំងពីរ រមែងបែកទឹករងៃ, សូម្បីតាមប្រក្រតីក្នុងកាលនោះ ដំរីទាំងឡាយ រមែងមិនយកចិត្តទុកដាក់និងទំពក់ ជន្ទួន ឬលំ-

ពែង រមែងជាសត្វកាច, ប៉ុន្តែធនបាលកៈនោះ កាចខ្លាំង ណាស់, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **កដុកប្បភេទនោ ទុន្និវារយោ** ។

បាទព្រះគាថាថា **ពន្ធោ កពលំ ន ភញ្ជតិ** សេចក្ដីថា ដំរីធនបាលកៈនោះ មិនមែនត្រូវចងទេ, ប៉ុន្តែត្រូវគេនាំទៅកាន់រោងដំរី ព្រះរាជាត្រាស់ឲ្យហ៊ុំព័ទ្ធដោយវាំងននដ៏វិចិត្រ ហើយ ដាក់លើផែនដីដែលប្រស់ព្រំដោយគ្រឿងក្រអូប មានពិតានដ៏វិចិត្រនៅខាងលើ សូម្បីព្រះរាជាត្រាស់ឲ្យផ្គត់ផ្គង់ដោយភោជនៈដែលមានរសដ៏ប្រសើរផ្សេង ៗ ដែលគួរដល់ព្រះរាជា ក៏មិនព្រមបរិភោគអ្វីទាំងអស់ ។ ត្រង់ពាក្យថា "**ពន្ធោ កពលំ ន កុញ្ជតិ**" ( នេះ ) ព្រះមានព្រះភាគត្រាស់សំដៅយកអាការដែលដំរីត្រូវបញ្ជូនទៅកាន់រោងដំរី ។

ពីរបទថា **សុមរតិ នាគវនស្ស** សេចក្ដីថា ដំរីធនបាលកៈនោះរលឹកដល់ព្រៃឈ្មោះនាគវ័ន ដែលជាទីនៅដ៏មនោរម្យ ដែលបុគ្គលគប្បីត្រេកអរប៉ុណ្ណោះក៏ទេ, ក៏មាតារបស់ដំរីនោះ បានជាសត្វដល់នូវសេចក្ដីទុក្ខព្រោះព្រាត់

ប្រាសចាកបុត្រក្នុងព្រៃ, ដំរីឈ្មោះធនបាលកៈនោះជាសត្វបំពេញមាតុបិតុឧបដ្ឋានធម៌ , ទើបត្រិះរិះថា "ប្រយោជន៍អ្វីដល់យើងដោយកោជននេះ" រលឹកដល់មាតាបិតុបដ្ឋានធម៌ដែលប្រកបដោយធម៌ប៉ុណ្ណោះ, ក៏ដំរីនោះនៅក្នុងព្រៃនាគវ័ននោះ អាចបំពេញមាតាបិតុបដ្ឋានធម៌នោះបាន, ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **"សុមរតិ នាគវនស្ស កុញ្ជរោ"** ។

កាលព្រះសាស្តា ទ្រង់នាំបុព្វចរិយារបស់ព្រះអង្គមកត្រាស់យ៉ាងនោះហើយ បុត្ររបស់ព្រាហ្មណ៍សូម្បីទាំងអស់ញុំាំងទនៃទឹកភ្នែកឲ្យហូរចេញមក មានហឫទ័យដ៏ទន់ មានសោតប្បសាទដាក់ចុះដើម្បីស្តាប់ព្រះធម៌ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបនូវធម៌ដែលជាទីសប្បាយរបស់ពួកគេហើយ ទើបទ្រង់សម្តែងធម៌ប្រកាសសច្ចៈទាំងឡាយ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះ ព្រមទាំងបុត្រនិងកូនប្រសាស្រីទាំងឡាយ តាំងនៅក្នុងសោតាបត្តិផល ។

( រឿងបុត្ររបស់ព្រាហ្មណ៍ចាស់ ចប់ )

# ៤ រឿងព្រះបាទបសេនទិកោសល

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល បានត្រាស់ព្រះធម្មទេសនានេះថា " **មិទ្ធី យទា** " ជាដើម ។

## ព្រះបាទបសេនទិកោសលងោកងក់ព្រោះសោយច្រើនពេក

សេចក្ដីពិស្ដារថា សម័យមួយ ព្រះរាជាទ្រង់សោយបាយនៃអង្ករមួយទោណ ជាមួយនឹងម្ហូបទឹក និងម្ហូបគោកដែលគួរដល់បាយនោះ ។

ថ្ងៃមួយ ព្រះរាជាទ្រង់សោយព្រះក្រយាហារពេលព្រឹកហើយ ទ្រង់មិនទាន់បន្ទោបង់នូវសេចក្ដីស្រវឹកដោយអាហារនៅឡើយ ក៏ស្ដេចទៅកាន់សំណាក់ព្រះមានព្រះភាគមានព្រះរូបដ៏លំបាក ប្រែប្រួលទៅខាងនេះ ខាងនោះ សូម្បីត្រូវភាពងងុយគ្របសង្កត់ កាលមិនអាចនឹងទ្រង់ផ្ទុំឲ្យត្រង់បាន ទើបគង់ក្នុងចំណែកម្ខាង ។

## ព្រះសាស្ដាទ្រង់តិះដៀលការបរិភោគច្រើន

គ្រានោះ ព្រះសាស្ដា ត្រាស់ទៅកាន់ព្រះរាជាថា " បពិត្រមហារាជ ព្រះអង្គស្ដេចមកកាន់ទីនេះដោយមិនទាន់បានទ្រង់សម្រាក់ព្រះកាយទេដឹង ?" ។

ព្រះរាជា. " ព្រះករុណា ព្រះអង្គ , ចាប់តាំងពីកាលដែលខ្ញុំព្រះអង្គបរិភោគហើយ ខ្ញុំព្រះអង្គមានទុក្ខធំ " ។

គ្រានោះ ព្រះសាស្ដា ត្រាស់ទៅកាន់ព្រះរាជាថា "បពិត្រមហារាជ បុគ្គលបរិភោគច្រើនហួសប្រមាណ រមែងមានសេចក្ដីទុក្ខយ៉ាងនេះ" ហើយត្រាស់ព្រះគាថានេះថា ៖-

**៤. មិទ្ធី យទា ហោតិ មហគ្ឃសោ ច**
**និទ្ទាយិតា សម្បរិវត្តសាយី**
**មហាវរាហោវ និវាបបុដ្ឋោ**
**បុនប្បុនំ គព្ភមុបេតិ មន្ទោ ។**

កាលណា បុគ្គលអ្នកមានសេចក្ដីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះននៀលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹម ដោយសូករភត្ត កាល

នោះ បុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គតិរឿយៗ ។

<u>អធិប្បាយគាថា</u>

បណ្ដាបទទាំងនោះ បទថា **មិទ្ធី** សេចក្ដីថា អ្នកដែលត្រូវថីនៈនិងមិទ្ធគ្របសង្កត់ ។

បទថា **មហគ្ឃសោ** សេចក្ដីថា អ្នកបរិភោគច្រើនដូចអាហរហត្ថកព្រាហ្មណ៍ អលំសាដកព្រាហ្មណ៍ តត្ថវដ្ដកព្រាហ្មណ៍ កាកមាសកព្រាហ្មណ៍ និងភត្តវម្មិកព្រាហ្មណ៍ណាមួយ ។

បទថា **និវាបបុដ្ឋោ** សេចក្ដីថា ដែលត្រូវគេបំប៉នហើយដោយបាយសម្រាប់ជ្រូក មានបន្ទៃជាដើម ។ ពិតណាស់ ជ្រូកស្រុកគេចិញ្ចឹមកាលពីវានៅតូច ក្នុងពេលដែលមានសរីរៈធំធាត់ មិនបានដើម្បីនឹងចេញទៅខាងក្រៅ បម្រះនទៀលទៅមកក្នុងទីផ្សេងៗ មានក្រោមគ្រែ និងក្រោមតាំងជាដើមហើយ រមែងដេកដកដង្ហើមចេញ ដកដង្ហើមចូលប៉ុណ្ណោះ ។ លោកអធិប្បាយពាក្យនេះថា “ បុគ្គលអ្នកមាន

ការរង្គោកន្ទុយជាប្រក្រតីផង ជាអ្នកបរិភោគច្រើនផង ហើយកាលមិនអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយឥរិយាបថដទៃ ជាអ្នកមានការលក់ជាប្រក្រតីផង ជាអ្នកមានការដេកននៀលជាប្រក្រតី ដូចជាជ្រូកស្រុកដ៏ធំដែលគេបំប៉នដោយបាយបន្ទែងដូច្នោះផង ក្នុងខណៈណា, ក្នុងខណៈនោះ គេរមែងមិនអាចធ្វើទុកក្នុងចិត្តនូវត្រៃលក្ខណគឺ " **អនិច្ចំ ទុក្ខំ អនត្តា** " បាន , ព្រោះមិនអាចធ្វើទុកក្នុងចិត្តនូវត្រៃលក្ខណទាំងនោះបាន ទើបឈ្មោះមានបញ្ញាទន់ រមែងចូលទៅកាន់គភ៌រឿយៗ គឺមិនផុតអំពីការនៅក្នុងគភ៌ ។

## ព្រះសាស្ដាទ្រង់ប្រាប់ឧបាយ ដើម្បីបន្ថោបង់ការបរិភោគច្រើន

ក្នុងកាលចប់ទេសនា ព្រះសាស្ដាបានត្រាស់ព្រះគាថានេះដើម្បីអនុគ្រោះព្រះរាជាថា:-

" វេទនារបស់បុគ្គលអ្នកមានសតិសព្វកាល ដឹង
ប្រមាណក្នុងភោជនដែលខ្លួនបានហើយ រមែង
ជាវេទនាដ៏ស្រាលស្តើង អាហារដែលបរិភោគ

ហើយ រមែងរក្សាអាយុជីវិតរបស់បុគ្គលនោះ ហើយរមែងរលួយទៅសន្សឹមៗ ។

ដូច្នេះហើយ ត្រាស់ឲ្យឧត្តរមាណពរៀនយកហើយ ទ្រង់ប្រាប់ឧបាយថា "ម្នាលឧត្តរមាណព អ្នកគប្បីពោលគាថានេះ ក្នុងវេលាដែលព្រះរាជាសោយព្រះក្រយាហារ, រួចហើយ គប្បីពោលឲ្យព្រះរាជាទ្រង់បន្ថយភោជនដោយឧបាយនេះ" ឧត្តរមាណពក៏បានធ្វើហើយ ដោយប្រការដូច្នោះ ។

សម័យក្រោយមក ព្រះរាជាទ្រង់មានភាពរហ័សរហួន ទ្រង់មានព្រះសរីរៈស្រាល ទ្រង់ដល់នូវសេចក្ដីសុខ ព្រោះការដែលទ្រង់មានព្រះក្រយាហារមួយនាឡិ ជាយ៉ាងក្រៃលែង ទ្រង់មានសេចក្ដីស្និទ្ធស្នាល កើតឡើងហើយក្នុងព្រះសាស្ដា ញុំាងអសទិសទានឲ្យប្រព្រឹត្តទៅអស់ប្រាំពីរថ្ងៃ ។

មហាជនដែលមកប្រជុំក្នុងទីនោះ បានសម្រេចគុណវិសេសដ៏ធំ ព្រោះអាស្រ័យការអនុមោទនាទាន ។

( រឿងព្រះបាទបសេនទិកោសល ចប់ )

## ៥ រឿងសានុសាមណេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេរឈ្មោះ សានុ ត្រាស់ព្រះធម្មទេសនានេះថា “**ឥទំ បុរេ**” ជាដើម ។

# សានុសាមណេរប្រកាសធម៌

បានឮថា សាមណេរនោះជាបុត្រតូចតែមួយរបស់ឧបាសិកាមួយរូប ។ គ្រានោះ នាងឲ្យបុត្ររបស់នាងបួសក្នុងកាលដែលបុត្រនោះនៅក្មេងខ្ចី ។ សាមណេរនោះជាអ្នកសីល សម្បូរណ៍ដោយវត្ត ចាប់តាំងអំពីកាលដែលខ្លួនបួសមក ។ លោកបានធ្វើកិច្ចចំពោះអាចារ្យ ឧបជ្ឈាយ៍ និងអាគន្តុកៈទាំងឡាយ ។ អស់ថ្ងៃទាំងឡាយ ៨ នៃខែ លោកក្រោកឡើងអំពីព្រលឹម ចូលទៅតាំងទឹកក្នុងរោងទឹក បោសសំអាតរោងសម្រាប់ស្ដាប់ធម៌ អុជប្រទីប ប្រកាសការស្ដាប់ធម៌ដោយសំឡេងដ៏ពីរោះ ។ ភិក្ខុទាំងឡាយ ដឹងនូវកម្លាំង

របស់លោកហើយ រមែងពោលថា “ នែសាមណេរ អ្នកចូរពោលបទសរភញ្ញចុះ ” ។

សាមណេរនោះមិនបានប្រកែកថា “ ខ្យល់ចាក់ដោតហឫទ័យរបស់ខ្ញុំព្រះករុណា , ឬថា រោគក្អកបៀតបៀនខ្ញុំព្រះករុណា ” ឡើងកាន់ធម្មាសនៈ ពោលបទសរភញ្ញ ដូចញ៉ាំងគង្គាព្ទដ៏អាកាសឲ្យបង្អូរទឹកចុះមកដូច្នោះ ពេលចុះមកតែងតែពោលថា ខ្ញុំឲ្យចំណែកបុណ្យក្នុងការពោលបទសរភញ្ញនេះដល់មាតាបិតារបស់ខ្ញុំ ” មនុស្សទាំងឡាយ មិនបានដឹងថាលោកឲ្យចំណែកបុណ្យដល់មាតាបិតាណាទេ ។

## យក្ខិនីធ្លាប់ជាមាតារបស់សានុសាមណេរ

ក៏មាតារបស់សាមណេរនោះ ធ្លាប់កើតជាយក្ខិនីក្នុងអត្តភាពជាលំដាប់ នាងយក្ខិនីនោះមកជាមួយនិងទេវតាទាំងឡាយ ស្តាប់ធម៌ហើយ ( កាលនឹងអនុមោទនា ) ចំណែកបុណ្យដែលសាមណេរឲ្យដោយពាក្យថា “ខ្ញុំព្រះករុណាសូមអនុមោទនា លោកម្ចាស់ ” ក៏ធម្មតាភិក្ខុទាំងឡាយ អ្នកបរិបូណ៌ដោយសីល តែងតែជាទីស្រឡាញ់នៃទេវតា និង

មនុស្សទាំងឡាយ , ព្រោះហេតុនោះ ពួកទេវតាដែលមានសេចក្តីខ្មាសបាប មានការគោរពសាមណេរ រមែងសម្គាល់លោកដូចជាមហាព្រហ្ម និងដូចគំនរភ្លើង ។ ហើយរមែងឃើញនាងយក្ខិនីនោះថាគួរឲ្យគោរព ព្រោះគារវៈសាមណេរក្នុងសម័យទាំងឡាយ មានសម័យស្តាប់ធម៌និងសម័យដែលយក្ខប្រជុំគ្នាជាដើម អមនុស្សទាំងឡាយតែងតែឲ្យអាសនៈទឹក អាហារដល់នាងយក្ខិនីនោះ ដោយគិតថា " នាងយក្ខិនីនេះ ជាមាតារបស់សានុសាមណេរ " យក្ខទាំងឡាយសូម្បីមានសក្តិធំ ឃើញនាងយក្ខិនីនោះហើយ រមែងចៀសផ្លូវឲ្យ, រមែងក្រោកចាកអាសនៈ ។

## យក្ខិនីចូលក្នុងកាយសានុសាមណេរ

លុះសាមណេរនោះចំរើនវ័យ មានឥន្រ្ទីយ៍ចាស់ក្លាត្រូវសេចក្តីអផ្សុកយ៉ាងខ្លាំងគ្រប់សង្កត់បៀតបៀន មិនអាចនឹងបន្ទោបង់សេចក្តីអផ្សុកដ៏មានកម្លាំងនោះបាន ក៏ទុកសក់និងក្រចកឲ្យវែង មានសំពត់ស្បៀកនិងសំពត់ដណ្តប់ស្មុយកខ្វក់ មិនប្រាប់អ្នកណាៗ ទាំងអស់ ចាប់យកបាត្រចីវរ

ហើយ ដើរទៅកាន់ផ្ទះរបស់មាតាតែម្នាក់ឯង ។ ឧបាសិកា ឃើញហើយមកថ្វាយបង្គំសួរថា “ នៃលោកកូន កាលពីមុន លោកកូនមកកាន់ទីនេះជាមួយនឹងអាចារ្យ និងឧបជ្ឈាយ៍ ព្រមទាំងភិក្ខុកំលោះនិងសាមណេរទាំងឡាយ, ហេតុដូចម្ដេច ថ្ងៃនេះ លោកកូនមកតែម្នាក់ឯងយ៉ាងដូច្នេះ ?” សាមណេរ ប្រាប់ការដែលខ្លួនអផ្សុក ( ឲ្យមាតារបស់លោកជ្រាប ) ។ ឧបាសិកានោះជាអ្នកមានសទ្ធា សូម្បីសម្ដែងទោសរបស់ ឃរាវាសដោយប្រការផ្សេងៗ ដើម្បីជាស់ដៀនបុត្រ ក៏មិន អាចឲ្យសាមណេរត្រេកអរបាន ( ប៉ុន្តែ ) ក៏មិនបណ្ដេញ ចេញ ដោយគិតថា “ ទោះជាយ៉ាងណា លោកក៏កំណត់ដឹង បានសូម្បីតាមធម្មតារបស់ខ្លួន ” ពោលថា “ បពិត្រលោក កូន សូមលោកកូនរង់ចាំខ្ញុំព្រះករុណាចាត់ចែងយាគូនិងភត្ត ដើម្បីលោកកូនហើយសិន , ខ្ញុំព្រះករុណានឹងនាំសំពត់ដ៏ជាទី ពេញចិត្តមកប្រគេនលោកម្ចាស់អ្នកផឹកយាគូ ធ្វើភត្តកិច្ច ហើយ ។ ឧបាសិការចាត់ចែងយាគូ និងរបស់គួរទំពាស៊ី ស្រេចដោយពេលមួយរំពេចប៉ុណ្ណោះ រូបហើយបានប្រគេន

សានុសាមណេរ ។ គ្រានោះ ឧបាសិកាគិតថា “ យើងនឹងចាត់ចែងកត្ត ” អន្តុយក្នុងទីមិនឆ្ងាយអំពីអន្តុរ ។

សម័យនោះ នាងយក្ខិនីនោះពិចារណាមើលថា “ តើសាមណេរនៅទីណាហ្ន៎ ? លោកបានភិក្ខាហារហើយ ឬក៏មិនទាន់បានទេ ?” ដឹងថា លោកអត្ថុយហើយដោយភាពជាអ្នកប្រាថ្នានឹងសឹក ក៏គិតថា “ សូមកុំឲ្យលោកញ៉ាំងសេចក្តីខ្មាសឲ្យកើតឡើងដល់យើង ក្នុងចំណោមទេវតាទាំងឡាយឡើយ , យើងនឹងទៅ នឹងធ្វើឲ្យអន្តរាយក្នុងការសឹករបស់លោក ” លុះគិតដូច្នេះហើយ ក៏មកសណ្ឋិតក្នុងសរីរៈរបស់សាមណេរនោះ មួលកឲ្យដួលលើផែនដី ។ ភ្នែកទាំងពីររបស់លោកឡើងលឿង មានទឹកភ្នែកហូរចេញបម្រះនទៀលនៅលើផែនដី ។ ឧបាសិកាឃើញអាការៈដូច្នោះ ក៏ប្រញាប់មកលើកសាមណេរឲ្យដេកនៅលើគ្រែ ។ អ្នកស្រុកទាំងអស់មកធ្វើការបួងសួង មានពលីកម្មជាដើម ។

## ឧបាសិកាខ្សឹកខ្សួល

គ្រានោះឯង ឧបាសិកានោះខ្សឹកខ្សួល បានពោលគាថានេះ ក្នុងវេលានោះថា ៖-

ខ្ញុំបានឮព្រះអរហន្តទាំងឡាយថា បុគ្គលទាំងឡាយណា រក្សាឧបោសថប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ថ្ងៃទី ១៥ និងថ្ងៃទី ៨ នៃបក្ស ទាំងបាដិហារិកបក្ខផង ឈ្មោះថាប្រព្រឹត្តព្រហ្មចរិយៈ ពួកយក្សមិនយាយីបុគ្គលនោះឡើយ ឥឡូវនេះ ថ្ងៃនេះ ខ្ញុំឯងឃើញពួកយក្សយាយីសានុសាមណេរ ។

នាងយក្ខិនីស្តាប់ពាក្យរបស់ឧបាសិកានោះហើយតបថា នាងបានឮពាក្យព្រះអរហន្តទាំងឡាយដោយប្រពៃថា បុគ្គលទាំងឡាយណា រក្សាឧបោសថប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ថ្ងៃទី ១៥ ថ្ងៃទី ៨ នៃបក្ស ព្រមទាំងបាដិហារិកបក្ខផង ឈ្មោះថា ប្រព្រឹត្តព្រហ្មចរិយៈ ពួកយក្សមិនយាយីបុគ្គលទាំងនោះទេ នាងគប្បីនិយាយប្រាប់សានុសាមណេរ ដែលភ្ញាក់ឡើងថា នេះជាពាក្យ

របស់ពួកយក្ស ( ប្រាប់ ) ថា លោកកុំធ្វើអំពើអាក្រក់ក្នុងទីចំពោះមុខ ឬទីកំបាំងមុខឡើយ បើលោកនឹងធ្វើ ឬកំពុងធ្វើ នូវអំពើលាមក លោកទុកជាហោះរត់ទៅ ក៏មិនរួចអំពីសេចក្ដីដែរ ។

សានុសាមណេរភ្ញាក់ឡើង និយាយថា ញោម ពួកជនតែងយំរកបុគ្គលដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ ប៉ុន្តែគេមិនឃើញ ញោម ញោមឃើញអាត្មានៅរស់នៅឡើយ ញោម ហេតុអ្វីក៏ញោមយំរកអាត្មា ។

ឧបាសិកាតបថា លោកកូន ជនទាំងឡាយតែងយំរកបុគ្គល ដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញ ម្យ៉ាងទៀត បុគ្គលណា លះបង់កាមទាំងឡាយហើយ បែរជាត្រឡប់មករកកាម ក្នុងលោកនេះវិញ លោកកូន សូម្បីតែបុគ្គលនោះ ក៏ពួកជនយំរកដែរ ព្រោះថា បុគ្គលនោះរស់នៅមែន តែទុកដូចជាមនុស្សស្លាប់ហើយ

លោកកូន ខ្ញុំបានស្រង់លោកអំពីផែះក្តៅគឺយកវាស ហើយ លោកចង់ធ្លាក់ទៅក្នុងផែះក្តៅវិញ លោកកូន ខ្ញុំបានស្រង់លោកអំពីរណ្តៅហើយ លោកចង់ធ្លាក់ទៅ ក្នុងរណ្តៅវិញ លោកចូរស្មុះចេញទៅ សេចក្តីចំរើនចូរមានដល់លោក ខ្ញុំនឹងប្រាប់អ្នកណាកើតលោក ( ចេញអំពីយកវាសទៅបួសហើយ ) ដូចជាគ្រឿងកណ្ឌៈ ដែលគេនាំចេញអំពីផ្ទះភ្លើងឆេះ ហើយចង់ឆេះ ( ក្នុងយកវាស ) វិញ ។

សានុសាមណេរនោះ កំណត់ពាក្យរបស់ឧបាសិកាបានហើយ ទើបពោលថា "អាត្មាភាពមិនត្រូវការភាពជាគ្រហស្ថទេ" គ្រានោះ មាតារបស់លោកពោលថា "សាធុ សាធុ លោកកូន" ត្រេកអរហើយ ញុំាងសានុសាមណេរឲ្យឆាន់ភោជនដ៏ប្រណីតហើយ សួរថា "នែលោកកូន លោកកូនមានវស្សាប៉ុន្មានហើយ ?" ដឹងថាលោកកូនមានវស្សាគ្រប់ឧបសម្បទាហើយ ក៏ចាត់ចែងត្រៃចីវរប្រគេន, សានុ

សាមណេរនោះ កាលមានត្រៃចីវរគ្រប់គ្រាន់ហើយ ក៏បាន ឧបសម្បទា ។

ក្រោយមក ព្រះសាស្តាកាលនឹងទ្រង់ញ៉ាំងឧស្សាហៈ ក្នុងការសង្កត់សង្កិនចិត្តឲ្យកើតឡើង ដល់សានុសាមណេរ ដែលទើបតែឧបសម្បទាថ្មី ៗ ទើបត្រាស់ថា "ធម្មតាថាចិត្ត នេះតែងតែត្រាច់ទៅកាន់អារម្មណ៍ផ្សេង ៗ អសកាលដ៏យូរ មកហើយ, ឈ្មោះថាសិរីសួស្តី រមែងមិនមានដល់បុគ្គល ដែលមិនបានសង្កត់សង្កិនចិត្តនោះ, ព្រោះហេតុនោះ បុគ្គល គួរធ្វើសេចក្តីព្យាយាមក្នុងការសង្កត់សង្កិនចិត្ត ដូចជានាយ ហត្ថាចារ្យធ្វើសេចក្តីព្យាយាមក្នុងការសង្កត់សង្កិនដំរីដែលចុះ ប្រេងដោយកង្វេរដូច្នោះ" ហើយត្រាស់ព្រះគាថានេះថាៈ-

**៥. ឥទំ បុរេ ចិត្តមចារិ ចារិកំ**
**យេនិច្ឆកំ យត្ថកាមំ យថាសុខំ**
**តទជ្ជហំ និគ្គហេស្សាមិ យោនិសោ**
**ហត្ថិប្បភិន្នំ វិយ អំកុសគ្គហោ ។**

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅ

កាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយ ក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

## អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះថា ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់អារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមអស់កាលដ៏យូរ, តាមអាការដែលខ្លួនប្រាថ្នាដោយអំណាចនៃអាការរបស់កិលេសទាំងឡាយ មានរាគៈជាដើមដែលជាហេតុនៃសេចក្តីប្រាថ្នា, ឈ្មោះថា ( ត្រាច់ទៅ ) តាមអារម្មណ៍ដែលជាទីប្រាថ្នា ដោយអំណាចនៃអារម្មណ៍ជាទីកើតសេចក្តីប្រាថ្នារបស់ចិត្តនោះឯង, ឈ្មោះថា តាមសេចក្តីសប្បាយ ព្រោះកាលវាត្រាច់ទៅដោយអាការណា សេចក្តីសុខកើតមាន ក៏ត្រាច់ទៅដោយអាការនោះ, ថ្ងៃនេះ យើងនឹងសង្កត់សង្កិនចិត្តនោះដោយយោនិសោមនសិការ គឺមិន

ព្រមឲ្យវាឈានកន្លងបាន ដូចបុរសអ្នកកាន់កង្វេរដ៏ឈ្លាសវៃ គឺហត្ថាចារ្យសង្កត់សង្កិនដំរីដែលចុះប្រេងដោយកង្វេរដូច្នោះ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យបានកើតមានដល់ទេវតាជាច្រើន ដែលចូលទៅដើម្បីស្តាប់ធម៌ជាមួយនិងសានុសាមណេរនោះ ។ ចំណែកសានុសាមណេរនោះ រៀនព្រះពុទ្ធវចនៈគឺព្រះត្រៃបិដកអំពីព្រះសម្មាសម្ពុទ្ធហើយ បានក្លាយជាព្រះធម្មកថិកដ៏ជំនាញមួយរូប ។ លោកមានអាយុ ១២០ ឆ្នាំ ញ៉ាំងជម្ពូទ្វីបទាំងមូលឲ្យក្លកក្លឹកហើយ បរិនិព្វានដោយបការៈដូច្នេះ ។

រឿងសានុសាមណេរ ចប់

# ៦ រឿងដំរីឈ្មោះបាវេរកៈ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដំរីឈ្មោះបាវេរកៈរបស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះថា “**អប្បមាទរតា**” ជាដើម ។

## ដំរីរបស់ព្រះបាទកោសលជាប់ភក់

បានឮថា ដំរីនោះជាសត្វមានកម្លាំងខ្លាំង ក្នុងកាលដែលខ្លួននៅសាវ សម័យក្រោយមក ត្រូវកម្លាំងខ្យល់ដែល

កើតអំពីជរាខ្ញាំងខ្ញប់ ចុះទៅកាន់ស្រះធំមួយ ជាប់នៅក្នុងភក់ហើយ មិនអាចឡើងមកបាន ។ មហាជនឃើញដំរីនោះហើយ ក៏សន្ទនាគ្នាថា “អម្បាលដំរីបែបនេះ គង់ដល់នូវការៈជាសត្វមានកម្លាំងថយបែបនេះ” ។

ព្រះរាជាទ្រង់ព្រះសណ្តាប់នូវរឿងនោះហើយ ត្រាស់បញ្ជានាយហត្ថាចារ្យដោយព្រះតម្រាស់ថា “ម្នាលហត្ថាចារ្យអ្នកចូរទៅ ចូរលើកដំរីនោះចាកភក់” នាយហត្ថាចារ្យទៅដល់ទីនោះហើយ សម្តែងនូវទង់ជ័យដែលជាក្បាលនៃសង្គ្រាមប្រើគេឲ្យវាយស្គរសម្រាប់វាយដើម្បីសង្គ្រាម ។

ដំរីដែលប្រកបដោយជាតិជាសត្វមានមានៈ ក្រោកឡើងដោយរហ័ស ឈរនៅលើគោកបាន ។ ភិក្ខុទាំងឡាយឃើញហេតុនោះហើយ ក៏ក្រាបទូលព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ដំរីនោះរើខ្លួនឡើងចាកទីដ៏លំបាកគឺភក់តាមប្រក្រតី, ចំណែកអ្នកទាំងឡាយ ស្ទុះចុះទៅកាន់ភក់គឺកិលេស, ព្រោះហេតុនោះ សូម្បីអ្នកទាំងឡាយក៏ចូរធ្វើ ( សេចក្តីព្យាយាម ) ដោយឧបាយ

ដ៏ប្រពៃហើយ រើខ្លួនឡើងចាកភក់គឺកិលេសនោះចុះ” ហើយត្រាស់ព្រះគាថានេះថា ៖-

៦. អប្បមាទរតា ហោថ    សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ    បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ
ចូររក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចេញចាកភក់គឺ-
កិលេស ដែលធ្លាក់ចុះបានដោយកម្រ ដូចដំរីដែលជាប់
នៅក្នុងភក់ រើខ្លួនឲ្យរួចបាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បមាទរតា** សេចក្តីថា អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ គឺការមិននៅប្រាសចាកសតិ ។

បទថា **សចិត្តំ** សេចក្តីថា ចូររក្សាចិត្តរបស់ខ្លួនក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ដោយអាការដែលវាឈានកន្លងមិនបាន ។

បទថា **សន្នោ** សេចក្តីថា ដំរីដែលលិចចុះទៅក្នុងភក់ហើយ ធ្វើសេចក្តីព្យាយាមដោយជើងមុខនិងជើងក្រោយ រើខ្លួនឡើងផុតអំពីភក់ តាំងនៅគោកបាន យ៉ាងណា, សូម្បីអ្នកទាំងឡាយក៏ចូររើខ្លួនឡើងចាកភក់គឺកិលេស គឺញុំាងខ្លួនឲ្យតាំងនៅលើគោកគឺព្រះនិព្វាន ដូច្នោះចុះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងព្រះអរហត្តផល ។

រឿងដំរីឈ្មោះបាវេរកៈ ចប់

## ៧ រឿងភិក្ខុច្រើនរូប

### សេចក្តីខាងដើម

ព្រះសាស្តា ទ្រង់គង់នៅក្នុងជង់ព្រៃឈ្មោះរក្ខិតៈដែលអាស្រ័យព្រៃឈ្មោះបាលិលេយ្យកៈ ទ្រង់ប្រារព្ធភិក្ខុច្រើនរូបត្រាស់ព្រះធម្មទេសនានេះថា “**សចេ លភេថ**” ជាដើម ។

## ភិក្ខុ ៥០០ រូបចង់ចូលទៅគាល់ព្រះសាស្ដា

រឿងមានមកក្នុងអដ្ឋកថានៃព្រះគាថាថា **"បរេ ច ន វិជានន្តិ"** ជាដើម ក្នុងយមកវគ្គហើយ ។

ពិតណាស់ រឿងនេះខ្ញុំម្ចាស់បានពោលហើយថា "ការគង់នៅរបស់ព្រះមានព្រះភាគ អ្នកដែលស្ដេចដើរក្នុងជងព្រៃឈ្មោះរក្ខិតៈបំរើនោះ បានប្រាកដក្នុងជម្ពូទ្វីបទាំងមូលហើយ ត្រកូលធំ ៗ មានជាអាទិយ៉ាងនេះគឺ "អនាថបិណ្ឌិកសេដ្ឋី នាងវិសាខាមហាឧបាសិកា" បញ្ជូនដំណឹងទៅអំពីព្រះនគរសាវត្ថីប្រាប់ព្រះអានន្ទត្ថេរថា "បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ចូរសម្ដែងព្រះសាស្ដាដល់ខ្ញុំម្ចាស់ទាំងឡាយចុះ" ។ សូម្បីភិក្ខុប្រមាណ ៥០០ រូបដែលមានប្រក្រតីនៅក្នុងទិស ចេញវស្សាហើយ បានចូលទៅរកព្រះអានន្ទ អង្វរថា "អានន្ទដ៏មានអាយុ យើងទាំងឡាយខានបានស្ដាប់ធម្មកថាចំពោះព្រះភក្ត្រព្រះមានព្រះភាគ អស់កាលយូរហើយ, អានន្ទដ៏មានអាយុ ដូច្នេះ យើងទាំងឡាយគប្បីបានស្ដាប់ធម្មកថានៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ" ។

## ដំរីបាលិលេយ្យកៈចាប់ឈើបំណងនឹងប្រហារព្រះអានន្ទ

ព្រះថេរៈ នាំភិក្ខុទាំងនោះទៅកាន់ដងព្រៃឈ្មោះរក្ខិតៈនោះហើយ ត្រិះរិះថា “ការដែលយើងចូលទៅកាន់សំណាក់ព្រះតថាគត អ្នកមានប្រក្រតីគង់នៅតែមួយព្រះអង្គឯងអស់ត្រៃមាស ព្រមជាមួយនិងភិក្ខុមានប្រមាណប៉ុណ្ណេះ មិនសមគួរឡើយ” លុះគិតដូច្នេះហើយ ក៏បានចូលទៅគាល់ព្រះសាស្តាតែមួយអង្គឯង ។ ដំរីឈ្មោះបាលិលេយ្យកៈឃើញព្រះអានន្ទហើយ ចាប់កំណាត់ឈើស្ទុះចូលទៅរក ។

ព្រះសាស្តាទ្រង់ទតឃើញព្រះអានន្ទហើយ ត្រាស់ថា “នែបាលិលេយ្យកៈ អ្នកចូរចៀសចេញ កុំឃាត់ឡើយ, នោះជាពុទ្ធុបដ្ឋាក” ។ ដំរីឈ្មោះបាលិលេយ្យកៈនោះបោះកំណាត់នោះចោលក្នុងទីនោះឯង សួរដោយអើពើដល់ការទទួលបាត្រនិងចីវរ ។ ព្រះថេរៈមិនឲ្យ ។ ដំរីគិតថា “ប្រសិនបើភិក្ខុនេះ ជាអ្នកមានវត្តដែលបានរៀនហើយនោះ, លោកនឹងមិនដាក់បរិក្ខាររបស់ខ្លួនលើផែនថ្ម ដែលជាទីគង់នៃព្រះសាស្តាទេ” ។ ព្រះថេរៈដាក់បាត្រនិងចីវរលើដី ។ ពិតណាស់ ភិក្ខុ

អ្នកបរិបូណ៌ដោយវត្តទាំងឡាយ រមែងមិនដាក់បរិក្ខាររបស់ខ្លួនលើទីដេក ឬទីអង្គុយរបស់គ្រូឡើយ ។ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាត្រាស់សួរថា "ម្នាលអានន្ទ អ្នកមកតែម្នាក់ឯងទេឬ ?" ទ្រង់ព្រះសណ្តាប់ថា ព្រះអានន្ទមកជាមួយនិងភិក្ខុប្រមាណ ៥០០ រូប ក៏ទ្រង់ត្រាស់ថា "ម្នាលអានន្ទ តើភិក្ខុទាំងនោះនៅទីណា ?" កាលព្រះថេរៈក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ កាលមិនជ្រាបព្រះទ័យរបស់ព្រះអង្គ ទើបបញ្ឈប់ភិក្ខុទាំងនោះនៅខាងក្រៅហើយ ចូលមកគាល់ព្រះអង្គតែមួយអង្គឯង", ក៏ទ្រង់ត្រាស់ថា "ម្នាលអានន្ទ អ្នកចូរទៅហៅភិក្ខុទាំងនោះចូលមកចុះ" ។ ព្រះថេរៈក៏បានធ្វើដូច្នោះ ។

## ត្រាច់ទៅតែម្នាក់ឯងប្រសើរជាងទៅជាមួយមិត្តអាក្រក់

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈនិងភិក្ខុទាំងនោះហើយ កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គជាព្រះពុទ្ធដ៏សុខុមាល និងជាក្សត្រដ៏សុខុមាល, ព្រះអង្គទ្រង់ឈរផង ទ្រង់គង់ផង តែមួយព្រះអង្គឯងអស់ត្រៃមាស

ទ្រង់ធ្វើកម្មដែលបុគ្គលធ្វើបានដោយកម្រ, អ្នកធ្វើវត្តជំនិងវត្ត តូចក្ដី អ្នកថ្វាយវត្ថុទាំងឡាយ មានទឹកសម្រាប់លាងព្រះកក្រ្ក ជាដើមក្ដី ប្រហែលជាមិនមានហើយមើលទៅ” ទើបទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងពួង ដំរីបាលិលេយ្យ ជាអ្នកធ្វើ, ពិតណាស់ ការដែលបុគ្គលកាលបានសម្លាញ់ បែបនេះនៅរួមជាមួយ ប្រសើរពិត ៗ, កាលបុគ្គលមិនបាន ការត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះ ប្រសើរជាង” ហើយបាន ទ្រង់ភាសិតព្រះគាថាទាំងនេះទុកក្នុងនាគវគ្គថា ៖-

៧. សចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតីគ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនិងសំឡាញ់នោះឯង ។ បើស្វែងរកមិនបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយស្តេចទៅតែឯកអង្គពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈដែលលះហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតិ
ប្រសើរបំផុត ( ព្រោះថា ) សហាយតាគុណ
រមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះ
គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅ
តែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយ
ផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមាន
សេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯក
ឯងក្នុងព្រៃ ដូច្នោះដែរ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **និបកំ** គឺអ្នកប្រកបដោយបញ្ញាជាគ្រឿងរក្សាខ្លួន ។

បទថា **សាធុវិហារិធីរំ** គឺអ្នកមានធម៌ជាគ្រឿងនៅដ៏ចំរើន ជាបណ្ឌិត ។

បទថា **បរិស្សយានិ** ជាដើម សេចក្តីថា អ្នកកាលបានសម្លាញ់អ្នកមានមេត្តាជាវិហារធម៌ដូច្នោះ អាចគ្របសង្កត់អនតរាយទាំងឡាយ គឺ "អន្តរាយដែលប្រាកដ មានសីហៈ

និងខ្វាធំជាដើម និងអន្តរាយខាងក្នុង មានរាគៈនិងទោសៈជាដើម” ទាំងអស់ហើយ គប្បីជាអ្នកមានចិត្តត្រេកអរ មានសតិតាំងមាំ ត្រាច់ទៅ គឺនៅជាមួយនិងសម្លាញ់នោះ ។

ពីរបទថា **រាជាវ រដ្ឋំ** សេចក្ដីថា ដូចជាឥសីជាព្រះរាជា ទ្រង់លះបង់ដែនហើយបួសដូច្នោះ ។ លោកអធិប្បាយពាក្យនេះទុកថា “ព្រះរាជាអ្នកមានភូមិប្រទេសដែលព្រះអង្គទ្រង់ឈ្នះវិសេសហើយ ទ្រង់លះបង់ដែនដែលទ្រង់ឈ្នះវិសេសហើយនោះ ដោយទ្រង់ព្រះតម្រិះថា “ឈ្មោះថាភាពជាព្រះរាជានេះ ជាទីតាំងនៃសេចក្ដីប្រមាទដ៏ធំ, ប្រយោជន៍អ្វីរបស់យើងដោយរាជសម្បត្តិ ដែលយើងគ្រប់គ្រងសង្កត់ហើយនោះ លំដាប់នោះឯងស្ដេចចូលទៅកាន់ព្រៃធំ បួសជាតាបសហើយស្ដេចត្រាច់ទៅតែមួយព្រះអង្គឯងក្នុងឥរិយាបថទាំង ៤ យ៉ាងណា, បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯងដូច្នោះដែរ” ។

ពីរបទថា **មាតង្គរញ្ញេវ នាគោ** សេចក្ដីថា ដូចយ៉ាងថា ស្ដេចដំរីនេះមានឈ្មោះថា “មាតង្គ” ព្រោះពិចារណាឃើញច្បាស់យ៉ាងនេះថា អញជាអ្នកប្រឡូកប្រឡំដោយហ្វូង

ដំរីឈ្មោលទាំងឡាយ ដំរីញីទាំងឡាយ ដំរីស្ទាវទាំងឡាយ និងកូនដំរីទាំងឡាយ, យើងតែងតែទំពាស៊ីស្មៅដែលដំរីទាំងនោះច្រិបចុងហើយផង, យើងតែងតែទំពាស៊ីកំណាត់ឈើដែលគេបំបាក់ហើយផង, យើងតែងតែផឹកទឹកល្អក់ផង, កាលយើងចុះកាន់កំពង់ទឹក និងឡើងអំពីកំពុងទឹកមកវិញ ដំរីញីទាំងឡាយតែងតែចូលមកត្រដុសយើង, បើដូច្នោះមានតែយើងម្នាក់ឯងប៉ុណ្ណោះ ចៀសចេញចាកហ្វូង" លុះគិតដូច្នេះហើយ ក៏ធ្វើដំណើរទៅតាមការយល់ឃើញ លះបង់ហ្វូងហើយ រមែងត្រាច់ទៅក្នុងព្រៃតាមសប្បាយតែឯងប៉ុណ្ណោះក្នុងឥរិយាបថទាំងបួន យ៉ាងណា, បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះ ដូច្នោះដែរ ។

បទថា **ឯកស្ស** សេចក្តីថា ការត្រាច់ទៅនៃបព្វជិតអ្នកត្រេកអរដ៏ក្រៃលែងហើយ ក្នុងភាវៈតែម្នាក់ឯង ចាប់តាំងអំពីកាលដែលខ្លួនបួសហើយមក អ្នកតែម្នាក់គាប់ឯងប្រសើរ ។

បាទព្រះគាថាថា **នត្ថិ ពាលេ សហាយតា** សេចក្តីថា ព្រោះគុណធម៌ទាំងនេះគឺ "ចុល្លសីល មជ្ឈិមសីល មហា

សីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន" ឈ្មោះថា សហាយតាគុណ, បុគ្គលមិនអាចបាននូវសហាយតាគុណ អំពីជនពាលទាំងឡាយឡើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគសម្តែងថាសហាយតាគុណមិនមានក្នុងជនពាល ។

បទថា **ឯកោ** ជាដើម សេចក្តីថា ព្រោះហេតុនេះ បុគ្គលគប្បីជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ ត្រាច់ទៅក្នុងឥរិយាបថទាំងបួន ហើយមិនគប្បីធ្វើបាបទាំងឡាយសូម្បីមានប្រមាណតិច ។ អធិប្បាយថា "បុគ្គលនោះ គប្បីជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ ត្រាច់ទៅដូចដំរីឈ្មោះមាតង្គ អ្នកមានសេចក្តីខ្វល់ខ្វាយតិច គឺមិនមានសេចក្តីអាល័យ ត្រាច់ទៅជាសុខក្នុងទីដែលខ្លួនប្រាថ្នាហើយ ៗ ក្នុងព្រៃដូច្នោះ, ហើយមិនគប្បីធ្វើបាបទាំងឡាយ សូម្បីមានប្រមាណតិច ។

ព្រោះហេតុនោះ ព្រះសាស្តាកាលនឹងទ្រង់សម្តែងសេចក្តីនេះថា "សូម្បីអ្នកទាំងឡាយ កាលមិនបានសម្មាញ់

បែបនោះ គប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះ” ទើបទ្រង់សម្តែងព្រះធម្មទេសនានេះចំពោះភិក្ខុទាំងនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ សូម្បីទាំង ៥០០ រូបតាំងនៅក្នុងសោតាបត្តិផល ។

រឿងភិក្ខុច្រើនរូប ចប់

# ៨ រឿងមារ

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលគង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃហិមពាន្ត ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា "**អត្ថម្ហិ**" ជាដើម ។*

## *មារអារាធនាព្រះសាស្ដាឲ្យទ្រង់គ្រប់គ្រងរាជសម្បត្តិ*

*បានឮថា ក្នុងកាលនោះ ព្រះរាជាទាំងឡាយទ្រង់គ្រប់គ្រងរាជសម្បត្តិមិនប្រកបដោយធម៌ បៀតបៀនប្រជាជន ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ទតមើលមនុស្សទាំងឡាយត្រូវព្រះរាជាបៀតបៀនដោយការដាក់អាជ្ញា ក្នុងរាជសម័យនៃព្រះរាជាអ្នកមិនបានតាំងនៅក្នុងធម៌ ទ្រង់ព្រះតម្រិះដោយសេចក្ដីករុណាយ៉ាងនេះថា "កាលបើតថាគតមិនសម្លាប់*

ដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យសម្លាប់ មិនបំផ្លាញសត្វ ដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យបំផ្លាញ មិនញុំាងសត្វឲ្យសោយសោកដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យញុំាងសត្វឲ្យសោយសោក អាចនឹងសោយរាជ្យដោយធម៌បានឬហ្ន៎?”

គ្រានោះឯង មារមានចិត្តបាបដឹងនូវបរិវិតក្កក្នុងព្រះទ័យរបស់ព្រះមានព្រះភាគ ដោយចិត្តរបស់ខ្លួនហើយ ក៏ត្រិះរិះថា “ព្រះសមណគោតមទ្រង់ត្រិះរិះថា កាលបើតថាគតមិនសម្លាប់ដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យសម្លាប់ មិនបំផ្លាញ ប្រើអ្នកដទៃឲ្យបំផ្លាញ មិនសោកសៅ មិនធ្វើគេឲ្យសោកសៅ អាចនឹងសោយរាជ្យដោយធម៌បានដែរឬហ្ន៎ ? ឥឡូវនេះ ព្រះសមណគោតមនោះ នឹងជាអ្នកប្រាថ្នាដើម្បីគ្រប់គ្រងរាជសម្បត្តិ, ក៏ភាវៈនៃរាជសម្បត្តិនេះ ជាទីតាំងនៃសេចក្តីប្រមាទ, កាលបើព្រះសមណគោតមសោយរាជ្យនោះ, យើងនឹងបានឱកាល, យើងនឹងទៅ, នឹងញុំាងធ្នូះឲ្យកើតដល់ព្រះអង្គ” ។ លុះត្រិះរិះដូច្នេះហើយ ក៏ចូលទៅរកព្រះមានព្រះភាគក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន សូម

ព្រះមានព្រះភាគទ្រង់សោយរាជ្យ, សូមព្រះសុគតទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ មិនសម្លាប់ដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យសម្លាប់ មិនបំផ្លាញ មិនប្រើអ្នកដទៃឲ្យបំផ្លាញ មិនសោកសៅ មិនធ្វើគេឲ្យសោកសៅចុះ” ។

## ព្រះសាស្តាត្រាស់សួរហេតុដែលមារទូល

គ្រានោះ ព្រះសាស្តាត្រាស់សួរមារថា “ម្នាលមារមានចិត្តបាប ចុះអ្នកឯងឃើញហេតុដូចម្តេច របស់តថាគត បានជាអ្នកឯងពោលនឹងតថាគតយ៉ាងនេះ ?” កាលមារក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រោះឥទ្ធិបាទ ៤ ព្រះមានព្រះភាគបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីតាំងហើយ បានឲ្យឋិតនៅរឿយ ៗ ហើយ បានសន្សំហើយ បានប្រារព្ធដោយប្រពៃហើយ បពិត្រព្រះអង្គចំរើន ប្រសិនបើព្រះមានព្រះភាគ ប៉ុនប៉ងនឹងអធិដ្ឋានស្តេចភ្នំឈ្មោះហិមវន្ត ឲ្យទៅជាមាស ភ្នំនោះក៏ក្លាយទៅជាភ្នំមាសបាន សូម្បីខ្ញុំព្រះអង្គក៏នឹងធ្វើកិច្ចដែលគួរធ្វើដោយទ្រព្យដើម្បីព្រះអង្គដែរ, ព្រោះហេតុនេះ ព្រះអង្គ

នឹងសោយរាជ្យដោយធម៌បាន, ដូច្នេះហើយ ទ្រង់ញ៉ាំងមារ ឲ្យតក់ស្លុតដោយគាថាទាំងនេះថា ៖-

ភ្នំមាសសុទ្ធមានសម្បុរល្អ ទោះបីភ្នំពីរក៏មិនល្មម គ្រាន់ដល់បុគ្គលម្នាក់ឡើយ បុគ្គលដឹងដូច្នេះ គួរ ប្រព្រឹត្តស្មើ សត្វណា បានឃើញសេចក្តីទុក្ខដែល មានកាមជាហេតុ សត្វនោះនឹងបង្អោនចិត្តទៅរក កាមដូចម្តេចកើត លុះសត្វបានដឹងច្បាស់នូវឧបធិ ក្នុងលោកថាជាគ្រឿងចំពាក់ដូច្នេះហើយ គួរសិក្សា ដើម្បីកំចាត់បង់នូវឧបធិនោះចេញ ។

ហើយត្រាស់ថា "ម្នាលមារមានចិត្តបាប ឧវាទរបស់ អ្នកផ្សេង ឧវាទរបស់តថាគតផ្សេង ( ម្យ៉ាងម្នាក់ ), ឈ្មោះ ថាការប្រឹក្សាធម៌ជាមួយនឹងអ្នករមែងមិនមាន ព្រោះថាតថា- គតយ៉ាងនេះ" ហើយបានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៩. អត្ថម្ហិ ជាតម្ហិ សុខា សហាយា
តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ

សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។

កាលបើសេចក្តីត្រូវការកើតឡើងហើយ សំឡាញ់ទាំងឡាយនាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរដោយបច្ច័យតាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។

ការប្រតិបត្តិល្អចំពោះមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត ការប្រតិបត្តិល្អចំពោះបិតានាំសេចក្តីសុខមកឲ្យ ការប្រតិបត្តិល្អចំពោះសមណៈនាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត ការប្រតិបត្តិល្អចំពោះព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីល

នាំសេចក្តីសុខមកឲ្យ ជរាបដល់ចាស់ជរា សទ្ធា
ដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឲ្យ
ការបានប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាប
ទាំងឡាយ នាំសេចក្តីសុខមកឲ្យ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អត្ថម្ហិ** សេចក្តីថា ក៏កាល កិច្ចរបស់បព្វជិត មានការធ្វើចីវរជាដើមក្តី មានការរម្ងាប់ អធិករណ៍ជាដើមក្តី កើតឡើងហើយ ( ឬ ) កាលកិច្ចរបស់ គ្រហស្ថ មានកិច្ចគឺកសិរាស់ជាដើមក្តី ឬថាមានកិច្ចគឺការគ្រប់ សង្កត់ជាដើមដោយជនទាំងឡាយ ដែលអាស្រ័យពួកបក្ខដ៏ មានកម្លាំង កើតឡើងហើយ, សម្លាញ់ណាដែលអាចញ៉ាំង កិច្ចនោះឲ្យសម្រេច ឬញ៉ាំងកិច្ចនោះឲ្យស្ងប់រម្ងាប់បាន, សម្លាញ់បែបនោះ ជាសម្លាញ់នាំសេចក្តីសុខមកឲ្យ ។

ពីរបទថា **តុដ្ឋី សុខា** គ្រហស្ថទាំងឡាយ អ្នកមិន ត្រេកអរ មិនសន្តោសចំពោះទ្រព្យរបស់ខ្លួន រមែងប្រារព្ធនូវ ចោរកម្មទាំងឡាយ មានការកាត់នូវទីតជាដើម, សូម្បី

បព្វជិតទាំងឡាយ អ្នកមិនសន្តោសចំពោះបច្ច័យរបស់ខ្លួន ទើបប្រារព្ធនូវអនេសនា ( ការស្វែងរកមិនប្រពៃតាមធម៌ ) មានប្រការផ្សេង ៗ, ព្រោះហេតុនេះ ទើបគ្រហស្ថនិងបព្វជិតទាំងពីរពួកនោះ មិនជួបប្រសព្វនូវសេចក្ដីសុខ, ព្រោះហេតុនោះ សេចក្ដីសន្តោសចំពោះទ្រព្យរបស់ខ្លួនក្រៅនេះ គឺតិចឬច្រើននោះឯង ជាគុណជាតិនាំសេចក្ដីសុខមកឲ្យ ។

បទថា **បុញ្ញំ** សេចក្ដីថា កុសលកម្មដែលបុគ្គលផ្ដើមធ្វើហើយ តាមសមគួរដល់អធ្យាស្រ័យរបស់ខ្លួន ជាគុណជាតិនាំសេចក្ដីសុខមកឲ្យក្នុងពេលជិតស្លាប់ ។

បទថា **សព្វស្ស** សេចក្ដី ម្យ៉ាងទៀត ព្រះអរហត្ត គឺការលះបង់វដ្ដទុក្ខទាំងអស់បាននោះឯង ឈ្មោះថាជាគុណជាតិនាំសុខមកឲ្យក្នុងលោកនេះ ។

ការប្រតិបត្តិល្អចំពោះមាតា ឈ្មោះថា **មត្តេយ្យតា** ។ ការប្រតិបត្តិល្អចំពោះបិតា ឈ្មោះថា **បេត្តេយ្យតា** ។ ការប្រតិបត្តិដោយប្រពៃចំពោះមាតាបិតានេះឯង ព្រះមានព្រះភាគត្រាស់ហើយដោយបទសូម្បីទាំងពីរ ។ ពិតណាស់

មាតានិងបិតាដឹងថា បុត្តទាំងឡាយមិនគោរពប្រតិបត្តិហើយ រមែងកប់ទ្រព្យរបស់ខ្លួនដែលមានក្នុងផែនដីខ្លះ លះបង់ឲ្យ អ្នកដទៃខ្លះ, មិនតែប៉ុណ្ណោះ ការនិន្ទារមែងប្រព្រឹត្តទៅដល់ បុត្តទាំងនោះថា "បុគ្គលនេះមិនទំនុកបម្រុងមាតាបិតា" បុត្ត ទាំងនោះ រមែងកើតក្នុងគូថនរក ( នរកពេញដោយលាមក) បន្ទាប់អំពីសេចក្តីស្លាប់, ចំណែកបុត្តទាំងឡាយណា ទំនុក បម្រុងមាតាបិតាដោយគោរព បុត្តទាំងនោះរមែងបានទទួល ទ្រព្យដែលជាទ្រព្យរបស់មាតាបិតាទាំងនោះ ថែមទាំងបាន ទទួលការសរសើរទៀតផង, ក្រោយអំពីបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតក្នុងសុគតិទេវលោក, ព្រោះហេតុ នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ការប្រតិបត្តិល្អ ចំពោះមាតានិងបិតា "នាំសេចក្តីសុខមកឲ្យ" ដូច្នេះ ។

ការប្រតិបត្តិល្អចំពោះបព្វជិតទាំងឡាយ ឈ្មោះថា **សាមញ្ញតា** ។ ការប្រតិបត្តិល្អចំពោះព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះពុទ្ធទាំងឡាយ អ្នកមានបាបបណ្តេត ចោលហើយប៉ុណ្ណោះ ឈ្មោះថា **ព្រហ្មញ្ញតា** ។ ការប្រតិបត្តិ

ល្អចំពោះព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះពុទ្ធសាវកទាំងឡាយ ដោយបច្ច័យ ៤ ព្រះមានព្រះភាគត្រាស់ហើយ សូម្បីដោយ បទទាំងពីរ ។ សូម្បីសេចក្ដីនេះ ក៏ព្រះមានព្រះភាគត្រាស់ថា "ជាហេតុនាំសេចក្ដីសុខមកឲ្យក្នុងលោក" ( នេះ ) ។

បទថា **សីលំ** ជាដើម សេចក្ដីថា ពិតណាស់ គ្រឿង អលង្ការទាំងឡាយ មានទំហូដែលវិចិត្រដោយកែវមណីនិង សំពត់ពណ៌ក្រហមជាដើម រមែងល្អសម្រាប់ជនទាំងឡាយ អ្នកតាំងនៅក្នុងវ័យនោះ ៗ ប៉ុណ្ណោះ, គ្រឿងអលង្ការរបស់ មនុស្សក្មេងៗ នឹងលំអក្នុងកាលដែលខ្លួនចាស់ ឬគ្រឿង របស់មនុស្សចាស់ នឹងលំអសម្រាប់ក្មេងៗ ទាំងឡាយ ក៏ ទេ, មិនតែប៉ុណ្ណោះ ( គ្រឿងអលង្ការដែលប្រដាប់មិនត្រូវ កាលនេះ ) រមែងបង្កឲ្យកើតសេចក្ដីវិនាសតែម្យ៉ាង ព្រោះ ឲ្យកើតការនិន្ទាឡើងថា "បុគ្គលនោះប្រហែលជាឆ្កួតទេដឹង" ចំណែកប្រភេទនៃសីល មានសីល ៥ និងសីល ១០ ជា ដើម រមែងល្អបានគ្រប់វ័យ ទាំងចាស់ទាំងក្មេង, រមែងនាំមក តែសេចក្ដីរីករាយប៉ុណ្ណោះ ព្រោះឲ្យកើតសេចក្ដីសរសើរ

ឡើងថា "ឱ ! បុគ្គលនេះមានសីលហ្ន៎" ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "**សុខំ យាវ ជរា សីលំ**" ។

ពីរបទថា **សទ្ធា បតិដ្ឋិតា** សេចក្ដីថា សទ្ធាដែលជាលោកិយៈនិងលោកុត្តរៈសូម្បីទាំងពីរយ៉ាង ជាគុណជាតិមិនញាប់ញ័រ តាំងមាំហើយ នាំសេចក្ដីសុខមកឲ្យ ។

បាទព្រះគាថាថា **សុខោ បញ្ញាបដិលាភោ** សេចក្ដីថា ការបានចំពោះនូវបញ្ញាដែលលោកិយៈនិងលោកុត្តរៈ នាំសុខមកឲ្យ ។

ពីរបទថា **បាបានំ អករណំ** សេចក្ដីថា ម្យ៉ាងទៀត ការមិនធ្វើបាបទាំងពួងដោយអំណាចនៃសេតុឃាតៈ គឺអរិយមគ្គ នាំសេចក្ដីសុខមកឲ្យក្នុងលោកនេះ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យបានកើតមានដល់ទេវតាជាច្រើន ។

( រឿងមារ ចប់ )

8888888888888888

នាគវណ្ណនា ចប់

វគ្គទី ២៣ ចប់

# ធម្មបទគាថា

## តណ្ហាវគ្គទី ២៤

១ មនុជស្ស  បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ  បលវតី  ហុរាហុរំ

ផលមិច្ឆំវ វនស្មិ វានរោ ។
យំ ឯសា សហតិ ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំវ វីរណំ ។
យោ វេ តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ វីរណំ ។
មា វោ នឡំ វ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

តណ្ហា តែងចំរើនដល់មនុស្សអ្នកមានការប្រព្រឹត្ត ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិរួបរឹតដើមឈើហើយ ចំរើនឡើង បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើលោតទៅក្នុងព្រៃ ដូច្នោះដែរ ។

តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេង ៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយ តែងចំរើនឡើងដល់បុគ្គលនោះ ដូចស្បូវវណ្ណាស ដែលត្រូវភ្លៀងធ្លាក់

ចុះជញ្ជ្រាំហើយពន្លកលូតលេចឡើង ដូច្នោះដែរ ។ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។ ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំគ្នាក្នុងទីនេះ សេចក្តីចំរើនចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររំលើងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការស្បូវរណ្តាស គាស់ស្បូវរណ្តាសចោលចេញ ដូច្នោះ ។ មារកុំរុករានអ្នកទាំងឡាយរឿយ ៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុស ដូច្នោះឡើយ ។

២.យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

យស្ស ឆត្តឹសតី សោតា   មនាបស្សវនា ភុសា
មហា វហន្តិ ទុទ្ទិដ្ឋឹ   សង្កប្បា រាគនិស្សិតា ។
សវន្តិ សព្វធី សោតា   លតា ឧព្ភិជ្ជ តិដ្ឋតិ
តញ្ច ទិស្វា លតំ ជាតំ   មូលំ បញ្ញាយ ឆិន្ទថ ។

សរិតានិ សិនេហិតានិ ច
សោមនស្សានិ ភវន្តិ ជន្តុនោ
តេ វេ ជាតិជរូបគា នរា ។
តសិណាយ បុរក្ខតា បជា
បរសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្គសត្តា
ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។
តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ
ភិក្ខុ អាកង្ខំ វិរាគមត្តនោ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំ
មួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះ

ឡើងទៀតបាន មានឧបមាដូចម្ដេចមិញ កាលបើតណ្ហានុស័យ បុគ្គលកំចាត់មិនទាន់បានហើយ ទុក្ខ ( មានជាតិទុក្ខជាដើម ) នេះ ក៏តែងកើតរឿយ ៗ មានឧបមេយ្យដូច្នោះដែរ ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅក្នុងអារម្មណ៍ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់ របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចជាវល្លិនោះកើតឡើងហើយ ចូរកាត់ឫសបោលចេញ ដោយកាំបិតគឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្ដីរីករាយ អ្នកស្វែងរកសេចក្ដីសុខ នរជន

ទាំងឡាយនោះឯង តែងឈមទៅរកជាតិនិងជរា ។ ពួកសត្វដែលតណ្ហាជាទីញ៉ាំងសត្វឲ្យតក់ស្លុត ក្រុង ទុកហើយ តែងវន្ទត់ដូចទន្សាយដែលព្រានទាក់បាន ហើយដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈនិង សង្គធម៌ (ធម៌ជាគ្រឿងជំពាក់) តែងដល់នូវ សេចក្តីទុក្ខរឿយ ៗ អស់កាលអង្វែង ។ ពួកសត្វដែលតណ្ហា ជាទីញ៉ាំងសត្វឲ្យតក់ស្លុតក្រុង ទុកហើយ តែងវន្ទត់ដូចទន្សាយដែលនាយព្រានទាក់ បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នា ធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោ-បង់តណ្ហា ដែលជាគ្រឿងតក់ស្លុតចោលចេញ ។

**៣. យោ និព្វនថោ វនាធិមុត្តោ**
**វនមុត្តោ វនមេវ ធាវតិ**
**តំ បុគ្គលមេវ បស្សថ**
**មុត្តោ ពន្ធនមេវ ធាវតិ ។**

បុគ្គលណាមិនអាល័យក្នុងគិហិភាព ដូចដើមឈើ តាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃគឺតបធម៌

ជាអ្នករួចស្រឡះចាកព្រៃគឺតណ្ហា ហើយស្ទុះទៅរកព្រៃគឺតណ្ហាវិញ អ្នកទាំងឡាយចូរមើលបុគ្គលនោះឯង បុគ្គលនោះរួចចាកចំណងគឺឃរាវាសហើយស្ទុះទៅរកចំណង គឺឃរាវាសវិញ ។

៤.ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្វជញ្ច
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា
ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតំបិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ កាមសុខំ បហាយ ។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅឃាបូងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះថាជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យកូន

និងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ ( ទាញសត្វទំលាក់ទៅក្នុងអបាយ ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស ។

៥. យេ រាគរត្តានុបតន្តិ សោតំ
សយំ កតំ មក្កដកោវ ជាលំ
ឯតម្បិ ឆេត្វាន វជន្តិ ធីរា
អនបេក្ខិនោ សព្វទុក្ខំ បហាយ ។

ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់ទុក្ខទាំងពួងចេញទៅ ។

៦. មុញ្ច បុរេ មុញ្ច បច្ឆតោ
មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្វត្ថ វិមុត្តមានសោ
ន បុន ជាតិជរំ ឧបេហិសិ ។

អ្នកចូរដោះ ( សេចក្ដីអាល័យ ) ក្នុងកាលមុនចេញ ចូរដោះ ( សេចក្ដីអាល័យ ) ក្នុងកាលខាងក្រោយចេញ ចូរដោះ ( សេចក្ដីអាល័យ ) ក្នុងកាលជាកណ្ដាលចេញ ( កាលធ្វើយ៉ាងនេះ ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិ និងជរាទៀតឡើយ ។

៧ វិតក្កមថិតស្ស ជន្តុនោ
តិព្វរាគស្ស សុភានុបស្សិនោ
ភិយ្យោ តណ្ហា បវឌ្ឍតិ
ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ ។
វិតក្កូបសមេ ច យោ រតោ
អសុភំ ភាវយតី សទា សតោ

ឯស ខោ វុទ្ធិកាហតិ
ឯសច្ឆេច្ឆតិ មារពន្ធនំ ។

តណ្ហា រមែងចម្រើនក្រៃលែង ដល់ជនដែល វិតក្កញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអា- រម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថា ធ្វើចំណង ឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុង អសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់នូវវិតក្ក មានស្មារតីសព្វកាល តែចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គល នោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។

៨ ទិដ្ឋគ្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ
អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ
អក្ខរានំ សន្និបាតំ ជញ្ញាបុព្វាបរានិ ច
ស វេ អន្តិមសរីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

បុគ្គលណាដល់សេចក្តីសម្រេច គឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេស

ដូចទីទួល បានកាត់កូនសរ គឺកិលេស ជាហេតុញ៉ាំងសត្វឲ្យទៅកាន់កពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយនេះ របស់បុគ្គលនោះឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ ( វាចាជាគ្រឿងសម្តែងចេញ ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើម និងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈស្ថិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។

**៩ សព្វាភិភូ សព្វវិទូហមស្មិ**
**សព្វេសុ ធម្មេសុ អនូបលិត្តោ**
**សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ**
**សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។**

តថាគត ជាអ្នកសង្កត់គ្របមិកធម៌ទាំងអស់ ដឹងច្បាស់ចតុព្ភូមិកធម៌ទាំងអស់ មានចិត្តមិនបាន

ជាប់នៅ ក្នុងគេមិកធម៌ទាំងអស់ លះបង់គេកូមិក-
ធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា
បើតថាគតត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំ
បាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។

**១០ សព្វទានំ ធម្មទានំ ជិនាតិ**
**សព្វរសំ ធម្មរសោ ជិនាតិ**
**សព្វរតឹ ធម្មរតិ ជិនាតិ**
**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរស
ឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះ
សេចក្តីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខ
ទាំងពួង ។

**១១ ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

ភោគៈតាំងឡាយ រមែងសម្លាប់បុគ្គលអប្ប
ប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយ
គឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់

ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណាំក្នុង
ភោគៈ ។

១២ តិណទោសានិ ខេត្តានិ   រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ   ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វីគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមាន

ផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីអស់ហើយ រមែងជាទានមានផលច្រើន ។

ចប់តណ្ហាវគ្គទី ២៤

# ២៤. តណ្ហាវគ្គវណ្ណនា

## ១. រឿងត្រីឈ្មោះកបិលៈ

សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធត្រីឈ្មោះកបិលៈ ត្រាស់ព្រះធម្មទេសនានេះថា **“មនុជស្ស”** ជាដើម ។

## ពីរនាក់បងប្អូនចេញបួស

បានឮថា ក្នុងអតីតកាល ក្នុងកាលនៃព្រះមានព្រះភាគទ្រង់ព្រះនាមថាកស្សប បរិនិព្វានហើយ កុលបុត្តពីរនាក់បងប្អូនចេញបួសក្នុងសំណាក់នៃព្រះសាវកទាំងឡាយ ។

បណ្តាកុលបុត្តពីរនាក់បងប្អូននោះ បងមានឈ្មោះថាសោធនៈ, ប្អូនមានឈ្មោះថាកបិលៈ, ចំណែកមាតាបិតារបស់កុលបុត្តទាំងពីរនោះ មានឈ្មោះថាសាធនី, ប្អូនស្រីឈ្មោះថាតាបនា ។ សូម្បីមាតានិងប្អូនស្រីរបស់បុត្តទាំងនោះក៏បួសក្នុងសំណាក់ភិក្ខុនីដែរ ។ កាលមនុស្សទាំងនោះបួសហើយយ៉ាងនោះ ភិក្ខុជាបងប្អូនទាំងពីររូបនោះធ្វើវត្តធំនិងវត្តតូចចំពោះអាចារ្យនិងឧបជ្ឈាយ៍ ថ្ងៃមួយបានសួរអាចារ្យនិងឧបជ្ឈាយ៍ថា “បពិត្រលោកម្ចាស់ដ៏ចំរើន ធុរៈក្នុងសាសនានេះមានប៉ុន្មាន ?” បានឮថា “ធុរៈក្នុងព្រះសាសនានេះមាន

២ យ៉ាងគឺគន្ថធុរៈ ១ វិបស្សនាធុរៈ ១” ភិក្ខុជាបងគិតថា “យើងនឹងបំពេញវិបស្សនាធុរៈ” នៅក្នុងសំណាក់អាចារ្យនិងឧបជ្ឈាយ៍ប្រាំវស្សាហើយ រៀនកម្មដ្ឋានរហូតដល់ព្រះអរហត្ត ចូលទៅកាន់ព្រៃព្យាយាម ក៏បានសម្រេចព្រះអរហត្តផល ។

## ប្អូនប្រុសស្រវឹងនិងគន្ថធុរៈ

ភិក្ខុជាប្អូនគិតថា “យើងនៅក្មេងនៅឡើយ យើងមិនទាន់បំពេញវិបស្សនាធុរៈទេ, ចាំដល់ពេលចាស់ សឹមយើងបំពេញវិបស្សនាធុរៈ” ទើបតាំងគន្ថធុរៈ រៀនព្រះត្រៃបិដក, បរិវារជាច្រើនបានកើតឡើង ព្រោះអាស្រ័យព្រះបរិយត្តិរបស់លោក, លាភក៏កើតឡើងព្រោះអាស្រ័យបរិវារ, លោកស្រវឹងហើយដោយការស្រវឹងក្នុងភាពជាអ្នកស្តាប់ច្រើន ត្រូវតណ្ហាក្នុងលាភគ្របសង្កត់ ព្រោះជាអ្នកមានមានះថាខ្លួនជាបណ្ឌិតដ៏ក្រៃលែង រមែងពោលចំពោះវត្ថុដែលគួរ ដែលអ្នកដទៃពោលហើយថា “ជាវត្ថុដែលមិនគួរ”, ពោលចំពោះវត្ថុដែលមិនគួរថា “ជាវត្ថុគួរ” វត្ថុដែលមានទោស ពោលថា “មិនទោស” វត្ថុដែលមិនមានទោសពោលថា “មានទោស”

។ សូម្បីត្រូវភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយហាម ឃាត់ថា "នែកបិលៈ អ្នកកុំពោលយ៉ាងនេះឡើយ" ហើយ សម្ដែងធម៌និងវិន័យទូន្មានប្រៀនប្រដៅជាច្រើន ក៏ពោលថា "ពួកលោកចេះអ្វី ? ពួកលោកនេះប្រាកដ ស្មើដោយបាត់ ដៃទទេ" ជាដើមហើយ ក៏ដើរជេរ គម្រាមភិក្ខុទាំងឡាយ ។

## ប្អូនប្រុសមិនជឿបងប្រុស

គ្រានោះ ភិក្ខុទាំងឡាយប្រាប់រឿងនោះចំពោះព្រះ សោធនត្ថេរដែលជាបងប្រុសរបស់លោក ។ ចំណែកព្រះ សោធនត្ថេរចូលទៅរកលោកហើយ ទូន្មានលោកថា "ម្នាល អាវុសោកបិលៈ ក៏សម្មាបដិបត្តិគឺការប្រតិបត្តិដ៏ប្រពៃរបស់ ភិក្ខុទាំងឡាយ ដូចជាអ្នកឈ្មោះថាជាអាយុព្រះសាសនា, ព្រោះហេតុនោះ អ្នកកុំលះបង់សម្មាបដិបត្តិហើយ ពោល ឃាត់វត្តទាំងឡាយ មានវត្តកប្បិយៈជាដើមយ៉ាងនោះឡើយ" លោកមិនអើពើនិងពាក្យរបស់បងប្រុសលោក, ព្រះថេរ ទូន្មានលោកអស់ ២-៣ ដង ដឹងថាលោកមិនទទួលយកការ ទូន្មានរបស់ថា "ភិក្ខុនេះមិនធ្វើតាមពាក្យរបស់យើង" ក៏

ពោលថា "ម្នាលអាវុសោ បើដូច្នោះ អ្នកនឹងប្រាកដតាមកម្ម របស់អ្នកចុះ" លុះពោលដូច្នេះហើយ ក៏ចៀសចេញទៅ ។

ចាប់អំពីពេលនោះមក ភិក្ខុទាំងឡាយអ្នកមានសីល ជាស្រឡាញ់ សូម្បីដទៃ ក៏បោះបង់ ឈប់ទូន្មានប្រៀនប្រដៅ លោកតទៅទៀត, លោកក៏ជាអ្នកមានការប្រព្រឹត្តអាក្រក់ មានភិក្ខុដែលជាអ្នកប្រព្រឹត្តអាក្រក់ចោមរោមហែហម ។

ថ្ងៃមួយ លោកគិតថា " យើងនឹងសូត្របាតិមោក្ខ " ទើបកាន់យកផ្ចិតទៅគង់លើធម្មាសនៈ ក្នុងរោងឧបោសថ ហើយ សួរថា "អ្នកមានអាយុទាំងឡាយ បាតិមោក្ខរមែង ប្រព្រឹត្តដើម្បីភិក្ខុទាំងឡាយដែលប្រជុំគ្នាហើយក្នុងទីនេះឬ ?" ឃើញភិក្ខុទាំងឡាយគង់ស្ងៀមដោយគិតថា "ប្រយោជន៍អ្វី ដោយពាក្យឆ្លើយដែលយើងឲ្យដល់ភិក្ខុនេះ" ក៏ពោលថា "អ្នកមានអាយុទាំងឡាយ ធម្មិក្តី វិន័យក្តី រមែងមិនមាន, ប្រយោជន៍អ្វីដោយបាតិមោក្ខ ដែលពួកអ្នកនឹងស្តាប់ឬមិន ស្តាប់នោះ" លុះពោលដូច្នេះហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ លោកញុំាងសាសនាគឺព្រះបរិយត្តិរបស់ព្រះ

មានព្រះភាគទ្រង់ព្រះនាមថាកស្សប ឲ្យវិនាសសាបសូន្យដោយអាការយ៉ាងនេះ ។ ចំណែកព្រះសោធនត្ថេរក៏បរិនិព្វានក្នុងថ្ងៃនោះដែរ ។

ក្នុងកាលអស់អាយុ លោកកើតក្នុងអវិចីមហានរក ។ មិនត្រឹមតែប៉ុណ្ណោះ មាតានិងប្អូនស្រីរបស់លោក ដែលដល់នូវទិដ្ឋានុគតិរបស់លោក ជេរបរិភាសភិក្ខុទាំងឡាយ ដែលជាអ្នកមានសីលជាទីស្រឡាញ់ហើយ ក្រោយអំពីអស់អាយុជីវិត ក៏កើតក្នុងអវិចីមហានរកដែរ ។

## ចោរកើតក្នុងទេវលោកដោយអំណាចសីល

ក៏ក្នុងកាលនោះ បុរស ៥០០ នាក់ធ្វើចោរកម្មមានការប្លន់អ្នកស្រុកជាដើម ចិញ្ចឹមជីវិតដោយការធ្វើចោរកម្ម ត្រូវពួកស្រុកដែលនៅក្នុងជនបទដេញតាមចាប់ ក៏រត់ចូលកាន់ព្រៃ មិនឃើញទីពឹងណាៗក្នុងព្រៃនោះ ឃើញភិក្ខុដែលនៅក្នុងព្រៃជាវត្តមួយរូប ថ្វាយបង្គំហើយ ពោលថា "បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ចូរជាទីពឹងរបស់ខ្ញុំព្រះករុណាទាំងឡាយចុះ" ។

ព្រះថេរពោលថា "ទីពឹងដទៃក្រៅអំពីសីល រមែងមិនមានដល់អ្នកទាំងឡាយ, ដូច្នេះ អ្នកទាំងឡាយចូរសមាទានសីល ៥ ចុះ" ។

ចោរទាំងនោះយល់ព្រមដោយពាក្យថា "ប្រពៃហើយលោកម្ចាស់" ដូច្នេះហើយ សមាទានសីលទាំងឡាយ ។

គ្រានោះ ព្រះថេរទូន្មានចោរទាំងនោះថា "ឥឡូវនេះអ្នកទាំងឡាយជាអ្នកមានសីលហើយ អ្នកទាំងឡាយមិនគួរប្រព្រឹត្តកន្លងសីលសូម្បីព្រោះហេតុនៃជីវិតឡើយ, ការប្រទូស្តក្នុងចិត្ត ក៏មិនគប្បីធ្វើដែរ" ចោរទាំងនោះយល់ព្រមថា "ប្រពៃហើយ លោកម្ចាស់" ។

គ្រានោះ អ្នកស្រុកទាំងនោះមកដល់ទីនោះហើយ រកមើលខាងនេះខាងនោះ ឃើញចោរទាំងនោះហើយ ក៏ជួយគ្នាផ្តាច់ជីវិតទាំងអស់, ចោរទាំងនោះធ្វើកាលៈកិរិយាទៅ ក៏កើតក្នុងទេវលោក ។ ប្រធានចោរបានទៅជាប្រធានទេវបុត្ត ។

## ទេវបុត្តបដិសន្ធិក្នុងត្រកូលអ្នកនេសាទ

ទេវបុត្តទាំងនោះ អន្ទោលទៅក្នុងទេវលោកអស់មួយចន្លោះព្រះពុទ្ធ ដោយអំណាចអនុលោមនិងបដិលោម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលអ្នកនេសាទ ៥០០ ត្រកូល ដែលនៅជិតក្លោងទ្វារព្រះនគរសាវត្ថី ។ ប្រធានទេវបុត្តបដិសន្ធិក្នុងត្រកូលដែលជាប្រធានអ្នកនេសាទ, ពួកទេវបុត្តក្រៅនេះ បដិសន្ធិក្នុងត្រកូលអ្នកនេសាទក្រៅនេះ ។ ការបដិសន្ធិនិងប្រសូតិចាកផ្ទៃមាតានៃជនទាំងនោះ បានមានហើយក្នុងថ្ងៃជាមួយគ្នា ដោយប្រការដូច្នេះ ។

ប្រធានអ្នកនេសាទ ប្រើឲ្យគេដើរស្វែងរកទារកដទៃដែលកើតក្នុងថ្ងៃជាមួយនឹងកូនរបស់ខ្លួនដោយពាក្យថា "ពួកទារកសូម្បីដទៃក្នុងស្រុកនេះ កើតហើយក្នុងថ្ងៃនេះមានដែរឬទេ ?" បានដឹងថាទារកទាំងនោះកើតហើយ ក៏ញុំាងបុគ្គលឲ្យៗនូវទ្រព្យដែលជាតម្លៃនៃវត្ថុជាគ្រឿងចិញ្ចឹមដល់អ្នកនេសាទទាំងនោះ ដោយតាំងចិត្តថា "ទារកទាំងនោះ នឹងជាសម្លាញ់របស់កូនយើង" ។ ទារកទាំងនោះសូម្បីទាំងអស់ បានជាសម្លាញ់លេងដីជាមួយគ្នា ចំរើនវ័យហើយដោយលំដាប់

បណ្ដាក្មេងទាំងនោះ បុត្ររបស់ប្រធានអ្នកនេសាទ បានជាអ្នកខ្ពង់ខ្ពស់ដោយយស់និងអំណាច ។

## កបិលៈកើតជាត្រីធំ

ចំណែកភិក្ខុកបិលៈនោះ ធ្លាក់ក្នុងនរកអស់មួយចន្លោះព្រះពុទ្ធហើយ ក្នុងកាលនោះ កើតជាត្រីធំក្នុងស្ទឹងអចិរវតី មានពណ៌សម្បុរដូចមាស មានមាត់ស្អុយ ដោយអំណាចវិបាកដ៏សេស ។

ក្រោយមក សម្លាញ់ទាំងនោះប្រឹក្សាគ្នាថា "យើងនឹងចាប់ត្រី" ទើបកាន់យកឧបករណ៍ចាប់ត្រីទាំងឡាយ មានសំណាញ់ជាដើម បង់ទៅក្នុងស្ទឹង, ពេលនោះត្រីនោះបានមកជាប់ក្នុងសំណាញ់របស់សម្លាញ់ទាំងនោះ ។ អ្នកនេសាទដែលមានប្រក្រតីនៅកេវដ្ដគ្រាមទាំងអស់ បានឃើញត្រីនោះហើយ បានធ្វើសម្លេងដ៏ខ្លាំងថា "កូនរបស់ពួកចាប់ត្រីជាលើកដំបូង ចាប់បានត្រីមាស, គ្រានេះ ព្រះរាជានឹងព្រះរាជទានទ្រព្យដ៏ច្រើនដល់ពួកយើង" សម្លាញ់ទាំងនោះចាប់ដាក់ទូក លើកទូកឡើងហើយក៏នាំទៅកាន់ព្រះរាជដំណាក់ ។

ចំណែកព្រះរាជាកាលទ្រង់ទតឃើញត្រីនោះភ្លាម ក៏ទ្រង់សួរថា "នោះជាអ្វី ?" ពួកគេបានក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ត្រី" ព្រះរាជាទ្រង់ទតឃើញត្រីមានពណ៌សម្បុរដូចមាស ក៏ទ្រង់ព្រះតម្រិះថា "ព្រះសាស្ដានឹងទ្រង់ជ្រាប់នូវហេតុ ដែលត្រីនោះមានពណ៌សម្បុរដូចមាស" ដូច្នេះហើយ ទ្រង់បញ្ជារាជបុរសឲ្យកាន់យកត្រីនោះ ស្ដេចយាងទៅកាន់សម្នាក់ព្រះមានព្រះភាគ ។ កាលត្រីនោះហាមាត់ភ្លាម ក្លិនស្អុយពេញវត្តជេតពន ។

ព្រះរាជាទ្រង់ទូលសួរព្រះសាស្ដាថា "បពិត្រព្រះមានព្រះភាគ ព្រោះហេតុអ្វី ទើបត្រីនេះមានពណ៌សម្បុរដូចមាស ? ហើយព្រោះអ្វី ទើបក្លិនស្អុយផ្សាយចេញអំពីមាត់របស់វា ?" ។

ព្រះសាស្ដា. បពិត្រមហារាជ ត្រីនេះបានជាភិក្ខុឈ្មោះកបិលៈ ជាពហូសូត្រ មានបរិវារច្រើន ក្នុងធម្មវិន័យរបស់ព្រះមានព្រះភាគទ្រង់ព្រះនាមថាកស្សប, ត្រូវតណ្ហាដែលអាស្រ័យលាភគ្របសង្កត់ហើយ ជេរបរិភាសភិក្ខុដែលមិន

កាន់យកនូវទិដ្ឋានុគតិរបស់ខ្លួន ញ៉ាំងព្រះសាសនារបស់ព្រះមានព្រះភាគទ្រង់ព្រះនាមថាកស្សបឲ្យវិនាសសាបសូន្យ ។

ត្រីនេះកើតក្នុងអវិចីដោយកម្មនោះហើយ ឥឡូវនេះកើតជាត្រីដោយកម្មដ៏សេស, ក៏ព្រោះត្រីនេះពីជាតិមុនជាភិក្ខុ ហើយបានបង្រៀនព្រះពុទ្ធវចនៈ ពោលសរសើរគុណព្រះពុទ្ធអស់កាលដ៏យូរ ទើបបានអត្តភាពមានពណ៌សម្បុរដូចជាមាស ដោយផលនៃកម្មនោះ, ប៉ុន្តែបានជេរបរិភាសភិក្ខុទាំងឡាយ ទើបមានក្លិនស្អុយផ្សាយចេញអំពីមាត់ ដោយផលនៃកម្មនោះ, មហាបពិត្រ តថាគតនឹងឲ្យត្រីនេះនិយាយ ។

ព្រះរាជា. ឲ្យវានិយាយចុះ ព្រះអង្គ ។

គ្រានោះ ព្រះសាស្តាត្រាស់សួរត្រីនោះថា “ឯងឈ្មោះកបិលៈឬ ?”

ត្រី. ព្រះករុណា ព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះកបិលៈ ។

ព្រះសាស្តា. ឯងមកអំពីទីណា ?

ត្រី. បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមកអំពីអវិចីមហានរក ។

ព្រះសាស្តា. សោធនៈបងប្រុសរបស់ឯងទៅណា ?

ត្រី. បរិនិព្វានហើយ ព្រះអង្គ ។

ព្រះសាស្តា. ចុះនាងសាធនីជាមាតារបស់ឯងនោះទៅណា ?

ត្រី. កើតក្នុងនរក ព្រះអង្គ ។

ព្រះសាស្តា. នាងតាបនាប្អូនស្រីរបស់ឯងទៅណា ?

ត្រី. កើតក្នុងមហានរក ព្រះអង្គ ។

ព្រះសាស្តា. ឥឡូវនេះឯងនឹងទៅកាន់ទីណាទៀត ?

ត្រីឈ្មោះកបិលៈក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងទៅកាន់អវិចិមហានរកដដែល"លុះក្រាបទូលព្រះសាស្តាដូច្នេះហើយ ត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ ក៏បោកក្បាលនិងទូក ផាប់ទៅកើតក្នុងនរក, មហាជនកើតការតកស្លុត មានរោមព្រឺព្រួចឡើង ។

## ព្រះសាស្តាត្រាស់កបិលសូត្រ

គ្រានោះ ព្រះមានព្រះភាគទ្រង់ពិចារណាមើលវារៈចិត្តរបស់បរិស័ទដែលមកប្រជុំគ្នាក្នុងខណៈនោះ ដើម្បីនឹង

ទ្រង់សម្ដែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបត្រាស់កបិលសូត្រក្នុងសុត្តនិបាតថា "អ្នកប្រាជ្ញទាំងឡាយ បានពោលការប្រព្រឹត្តធម៌ ១ ការប្រព្រឹត្តព្រហ្មចារិយ ១ ថាជាកែវដ៏ឧត្ដម" ដូច្នេះជាដើមហើយ បានត្រាស់ព្រះគាថាទាំងនោះថា ៖-

១ មនុជស្ស បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បលវតី ហុរាហុរំ
ផលមិច្ឆំវ វនស្មិ វានរោ ។

យំ ឯសា សហតិ ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំវ វីរណំ ។
យោ វេ តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ វីរណំ ។
មា វោ នឡំវ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

តណ្ហា តែងចំរើនដល់មនុស្សអ្នកមានការប្រព្រឹត្ត

ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិរឭរីតដើម ឈើហើយ ចំរើនឡើង បុគ្គលនោះ តែងស្ទុះទៅ កាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃ ដូច្នោះដែរ ។

តណ្ហាទុះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុង អារម្មណ៍ផ្សេង ៗ ក្នុងលោក គ្របសង្កត់បុគ្គល ណា សេចក្តីសោកស្តាយ តែងចំរើនឡើងដល់ បុគ្គលនោះ ដូចស្មៅវណ្ណាស ដែលត្រូវភ្លៀងធ្លាក់ ចុះជញ្រាំហើយពន្លកលូតលេចឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមក ក្នុង លោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តី សោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូច ដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។

ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំង ឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រ- ជុំគ្នាក្នុងទីនេះ សេចក្តីចំរើនចូរមានដល់អ្នកទាំង

ឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររំលើង ឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការស្បូវ វណ្ណាស គាស់ស្បូវវណ្ណាសចោលចេញ ដូច្នោះ ។ មារកុំរុករានអ្នកទាំងឡាយរឿយ ៗ ដូចខ្សែទឹក កាច់បំបាក់ដើមបបុស ដូច្នោះឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បមត្តចារិនោ** សេចក្ដីថា ឈានមិនចំរើន វិបស្សនា មគ្គ និងផល ក៏មិនចំរើនដល់បុគ្គលអ្នកមានការប្រព្រឹត្ត ដោយសេចក្ដីប្រមាទជាប្រក្រតី ដោយសេចក្ដីប្រមាទ ដែលមានការបណ្ដោតបណ្ដោយសតិជាលក្ខណៈ ។ អធិប្បាយថា ដូចវល្លិ៍រួបរឹតដើមឈើហើយរមែងចំរើនឡើង ដើម្បីសេចក្ដីវិនាសទៅនៃដើមឈើយ៉ាងណា, តណ្ហាក៏ដូច្នោះដែរ ឈ្មោះថាចំរើនដល់បុគ្គលនោះ ព្រោះអាស្រ័យទ្វារទាំង ៦ កើតឡើងរឿយ ៗ ។

បាទព្រះគាថាថា **សោ បលវតី ហុរាហុរំ** សេចក្ដីថា បុគ្គលនោះ គឺអ្នកប្រព្រឹត្តទៅក្នុងគតិនៃតណ្ហា តែងត្រាច់គឺ

ស្ទុះទៅកាន់ភពតូចភពធំ ។ សួរថា "បុគ្គលនោះតែងស្ទុះដូចអ្វី ?" ឆ្លើយថា "ដូចស្វាកាលប្រាថ្នាផ្លែឈើ តែងលោតទៅក្នុងព្រៃ, វាចាប់មែកឈើនោះ ៗ ប្រលែងមែកនោះហើយចាប់មែកផ្សេងទៀត, ប្រលែងមែកសូម្បីនោះហើយ ចាប់មែកដទៃទៀត រមែងមិនដល់ភាពជាសត្វដែលបុគ្គលគួរពោលបានថា "វាមិនបានមែកឈើហើយអង្គុយស្ងៀម" យ៉ាងណា, បុគ្គលអ្នកប្រព្រឹត្តទៅក្នុងគតិនៃតណ្ហា ដូច្នោះដែរ តែងតែស្ទុះទៅកាន់ភពតូចភពធំ រមែងមិនដល់ភាពជាអ្នកដែលនរណាពោលបានថា "គេមិនបានអារម្មណ៍ ទើបមិនប្រព្រឹត្តទៅតាមតណ្ហា" ។

បទថា **យំ** ជាដើម សេចក្តីថា តណ្ហាដែលប្រព្រឹត្តទៅតាមទ្វារទាំង ៦ ឈ្មោះថា លាមក ព្រោះជារបស់អាក្រក់ដល់នូវការរាប់ថា **វិសត្តិកា** ព្រោះតណ្ហានោះ ជាធម្មជាតិផ្សាយទៅ គឺជាប់នៅក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ដូចជាអាហារលាយដោយថ្នាំពិស ដូចផ្កាឈើលាយដោយថ្នាំពិស ដូចផ្លែឈើលាយដោយថ្នាំពិស ដូចជាគ្រឿងបរិភោគ

លាយដោយថ្នាំពិស គ្របសង្កត់បុគ្គលណាហើយ សេចក្តីសោកទាំងឡាយដែលមានវដ្តៈជាមូល តែងចំរើនឡើងដល់បុគ្គលនោះ ដូចស្បូវរណ្តាសដែលត្រូវភ្លៀងធ្លាក់ចុះរឿយ ៗ រមែងមានពន្លកលូតលាស់ឡើងក្នុងព្រៃដូច្នោះដែរ ។

បទថា **ទុរច្ចយំ** ជាដើម សេចក្តីថា ចំណែកបុគ្គលណា គ្របសង្កត់តណ្ហាដ៏លាមកនោះ គឺមានប្រការដូចដែលខ្ញុំបានពោលហើយ ឈ្មោះថាដែលគេច្លងបានដោយកម្រនោះ ព្រោះជារបស់លំបាកនឹងឈានកន្លងគឺលំបាកនឹងលះបង់បាន, សេចក្តីសោកដែលមានវដ្តៈជាមូល រមែងធ្លាក់ចេញចាកបុគ្គលនោះ គឺតាំងនៅមិនបាន ដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក គឺមិនជាប់នៅដូច្នោះដែរ ។

ច្រើនបទថា **តំ វោ វទាមិ** គឺព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ ។

ពីរបទថា **ភទ្ទំ វោ** សេចក្តីថា សេចក្តីចំរើនចូរមានដល់អ្នកទាំងឡាយ, អធិប្បាយថា អ្នកទាំងឡាយ កុំបានដល់នូវសេចក្តីវិនាស ដូចកបិលភិក្ខុនេះឡើយ ។

បទថា **មូលំ** ជាដើម សេចក្តីថា អ្នកទាំងឡាយចូររំលើងឫសតណ្ហាដែលប្រព្រឹត្តទៅតាមទ្វារទាំង ៦ ដោយញាណដែលសម្បយុត្តជាមួយនិងអរហត្តមគ្គចោលចេញ ។ សួរថា "រំលើងឫសតណ្ហានោះ ដូចអ្វី ? ឆ្លើយថា ដូចបុគ្គលអ្នកត្រូវការដោយស្បូវក្លាំង គាស់ស្បូវរណ្តាសចោលចេញដូច្នោះ" ។ អធិប្បាយថា បុរសអ្នកត្រូវការស្បូវក្លាំង រមែងគាស់ស្បូវក្លាំងនោះចប់ធំ យ៉ាងណា, អ្នកទាំងឡាយ ចូរគាស់រំលើងឫសតណ្ហានោះចេញដូច្នោះដែរ ។

ពីរបាទគាថាថា **មា វោ នឡំ វ សោតោវ មារោ ភញ្ជិ បុនប្បុនំ** សេចក្តីថា កិលេសមារ មរណមារ និងទេវបុត្តមារចូរកុំរុករានអ្នកទាំងឡាយរឿយ ៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដែលដុះនៅក្បែរមាត់ស្ទឹងដូច្នោះឡើយ ។

ក្នុងកាលចប់ទេសនា បុត្តរបស់អ្នកនេសាទទាំង ៥០០ នាក់នោះកើតសេចក្តីសង្វេក ប្រាថ្នានឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ក៏បួសក្នុងសំណាក់ព្រះមានព្រះភាគ ធ្វើទីបំផុតនៃសេចក្តីទុក្ខអស់កាលមិនយូរ បានជាអ្នកមានការបរិភោគ

ជាមួយគ្នាដោយធម៌ជាគ្រឿងបរិភោគ គឺអនេញ្ជវិហារធម៌និងសមាបត្តិធម៌ រួមនិងព្រះសាស្តា ។

រឿងត្រីឈ្មោះកបិលៈ ចប់

## ២ រឿងកូនជ្រូកញី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធកូនជ្រូកស៊ីលាមកមួយ ត្រាស់ព្រះធម្មទេសនានេះថា "**យថាបិ មូលេ**" ជាដើម ។

### ព្រះសាស្តាត្រាស់បុព្វកម្មរបស់កូនជ្រូក

បានឮថា ថ្ងៃមួយ ព្រះសាស្តាស្តេចចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ទ្រង់ទតឃើញកូនជ្រូកមួយ ទើប

ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។ កាលព្រះអង្គទ្រង់ធ្វើការញញឹម ព្រះអានន្ទបានឃើញមណ្ឌលទស្សនោកាស ដែលផ្សាយចេញអំពីព្រះឱស្ឋរបស់ព្រះអង្គ ទើបទូលសួរហេតុនៃការញញឹមនោះថា "បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុ ? អ្វីជាបច្ច័យនៃការញញឹមរបស់ព្រះអង្គ" ។

គ្រានោះ ព្រះសាស្តាត្រាស់ប្រាប់ព្រះអានន្ទថា "ម្នាលអានន្ទ អ្នកឃើញកូនជ្រូកញីនោះទេ ?" ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញ ។

ព្រះសាស្តា. កូនជ្រូកញីនោះ ធ្លាប់កើតជាមេមាន់ នៅក្បែរោងឆាន់មួយ ក្នុងសាសនានៃព្រះពុទ្ធទ្រង់ព្រះនាមថាកកុសន្ធៈ, មេមាន់នោះ ស្តាប់សម្លេងប្រកាសធម៌របស់ភិក្ខុអ្នកជាយោគាវចរមួយរូប ស្វាធ្យាយវិបស្សនាកម្មដ្ឋាន ចុតិចាកអត្តភាពនោះហើយ កើតក្នុងរាជត្រកូល ជារាជធីតាព្រះនាមថាឧព្វរី, ក្នុងកាលតមក ព្រះនាងស្តេចចូលទៅកាន់ទីជាទីបន្ទោបង់ឧច្ចារៈ ទតឃើញហ្វូងដង្កូវហើយញ៉ាំងសញ្ញាថាដង្កូវ ៗ ដូច្នេះឲ្យកើតឡើងក្នុងទីនោះ បានបឋមជ្ឈាន, ព្រះ

នាងតាំងនៅក្នុងអត្តភាពនោះរហូតអស់អាយុ ចុតិចាកអត្តភាពនោះហើយ បដិសន្ធិក្នុងព្រហ្មលោក លុះចុតិចាកព្រហ្មលោក កករល្អក់ដោយអំណាចគតិ ទើបកើតក្នុងកំណើតជ្រូកក្នុងកាលឥឡូវនេះ, តថាគតឃើញហេតុនេះ ទើបតថាគតធ្វើការញញឹមឲ្យប្រាកដ ។

ភិក្ខុទាំងឡាយ មានព្រះអានន្ទជាប្រធាន ស្តាប់រឿងនោះហើយ កើតសេចក្តីសង្វេគយ៉ាងខ្លាំង ។

## រាគតណ្ហាឲ្យទោសច្រើន

ព្រះសាស្តា ទ្រង់ញុំាងសេចក្តីសង្វេគឲ្យកើតដល់ភិក្ខុទាំងនោះហើយ កាលនឹងទ្រង់ប្រកាសទោសរបស់រាគតណ្ហា ទ្រង់ប្រថាប់ឈរចន្លោះថ្នលនោះឯង ទ្រង់ភាសិតព្រះគាថាទាំងនោះថា ៖-

២.យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

យស្ស ឆត្តឹសតី សោតា   មនាបស្សវនា ភុសា
មហា វហន្តិ ទុទ្ទិដ្ឋឹ   សង្កប្បា រាគនិស្សិតា ។
សវន្តិ សព្វធី សោតា   លតា ឧព្ភិជ្ជ តិដ្ឋតិ
តញ្ច ទិស្វា លតំ ជាតំ   មូលំ បញ្ញាយ ឆិន្ទថ ។

សរិតានិ សិនេហិតានិ ច
សោមនស្សានិ ភវន្តិ ជន្តុនោ
តេ វេ ជាតិជរូបគា នរា ។
តសិណាយ បុរក្ខតា បជា
បរសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្កសត្តា
ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។
តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ
ភិក្ខុ អាកង្ខី វិរាគមត្តនោ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំ

មួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស័យ បុគ្គលកំចាត់មិនទាន់បានហើយ ទុក្ខ ( មានជាតិទុក្ខជាដើម ) នេះ ក៏តែងកើតរឿយ ៗ មានឧបមេយ្យដូច្នោះដែរ ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅក្នុងអារម្មណ៍ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់ របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចជាវល្លិនោះកើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិតគឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែង

មានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្តីរីករាយ អ្នកស្វែងរកសេចក្តីសុខ នរជនទាំងឡាយនោះឯង តែងឈមទៅរកជាតិនិងជរា ។

ពួកសត្វដែលតណ្ហាជាទីញុំាំងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងវន្ទត់ដូចទន្សាយដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈនិងសង្គធម៌ (ធម៌ជាគ្រឿងជំពាក់) តែងដល់នូវសេចក្តីទុក្ខរឿយ ៗ អស់កាលអង្វែង ។

ពួកសត្វដែលតណ្ហា ជាទីញុំាំងសត្វឲ្យតក់ស្លុតក្រុងទុកហើយ តែងវន្ទត់ដូចទន្សាយដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុតចោលចេញ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **មូលេ** ជាដើម សេចក្តីថា កាលឫសទាំង ៥ នៃដើមឈើឯង ដែលចាក់ទៅក្នុងទិស

ទាំង៤ និងចាក់ទៅខាងក្រោម ឈ្មោះថាមិនមានអន្តរាយ ព្រោះអន្តរាយប្រភេទណាមួយ មានការកាត់ ការកាប់ ការពុះ និងការចោះជាដើម ឈ្មោះថានៅមាំមួន ព្រោះការដែលឫសនៅមាំមួននោះ ដើមឈើនោះ សូម្បីត្រូវកាប់ខាងលើហើយក៏ដោយ ក៏តែងដុះឡើងទៀតបាន ដោយអំណាចមែកធំនិងមែកតូច យ៉ាងណា, ទុក្ខទាំងឡាយមានជាតិទុក្ខជាដើម កាលអនុស័យគឺការដេកត្រាំនៃតណ្ហា ដែលប្រព្រឹត្តទៅតាមទ្វារទាំង ៦ ដែលព្រះអរហត្តមគ្គញាណមិនទាន់កំចាត់ គឺមិនទាន់កាត់ផ្តាច់ តែងកើតឡើងរឿយ ៗ ក្នុងភពនោះ ៗ មានឧបមេយ្យដូច្នោះដែរ ។

បទថា **យស្ស** ជាដើម សេចក្តីថា តណ្ហាប្រកបដោយខ្សែ ៣៦ ដោយអំណាចនៃតណ្ហាវិចរិតទាំងនេះ គឺតណ្ហាវិចរិតដែលអាស្រ័យអាយតនៈខាងក្នុង ១៨ តណ្ហា-វិចរិតដែលអាស្រ័យអាយតនៈខាងក្រៅ ១៨ ដោយប្រការដូច្នេះ ឈ្មោះថាជាធម្មជាតិហូរទៅរកអារម្មណ៍ជាទីគាប់ចិត្ត ព្រោះអត្ថវិគ្រោះថា រមែងហូរទៅ គឺប្រព្រឹត្តទៅក្នុងអារម្មណ៍

មានរូបារម្មណ៍ជាដើម ដែលជាទីគប់ចិត្ត ជាធម្មជាតិក្លៀវក្លា គឺមានកម្លាំង មានដល់បុគ្គលណា, តម្រិះទាំងឡាយឈ្មោះថា ជាធម្មជាតិដ៏ធំ ព្រោះភាវៈជារបស់ធំ ដោយការកើតឡើង រឿយ ៗ មិនអាស្រ័យឈានឬវិបស្សនា អាស្រ័យរាគៈតែង នាំបុគ្គលអ្នកមានទិដ្ឋិអាក្រក់ ព្រោះជាអ្នកមានញាណវិបត្តិ នោះទៅ ។

បាទព្រះគាថាថា ***សវន្តិ សព្វធី សោតា*** សេចក្តីថា ខ្សែតណ្ហាទាំងនេះ ឈ្មោះថាតែងហូរទៅរកអារម្មណ៍ទាំងពួង ព្រោះហូរទៅរកអារម្មណ៍ទាំងពួង មានរូបារម្មណ៍ជាដើម ដោយអំណាចនៃទ្វារមានចក្ខុទ្វារជាដើម ឬព្រោះតណ្ហាទាំងអស់គឺ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា តែងហូរទៅកាន់ភពទាំងពួង ។

បទថា ***លតា*** សេចក្តីថា តណ្ហាដែលមានឈ្មោះថា ព្រោះអត្ថវិគ្រោះថា ប្រៀបដូចជាវល្លិ ព្រោះអត្ថថា ជាគ្រឿងចង និងដោយអត្ថថា ជាគ្រឿងរួបរឹត ។

ពីរបទថា **ឧពភិជ្ជ តិដ្ឋតិ** សេចក្តីថា តណ្ហាដែលដូចជាវល្លិកើតឡើងតាមទ្វារទាំង ៦ ហើយ រមែងតាំងនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ។

ពីរបទថា **តញ្ច ទិស្វា** សេចក្តីថា ក៏បុគ្គលអ្នកឃើញតណ្ហាដូចជាវល្លិនោះ ដោយអំណាចនៃឫសដែលកើតហើយថា "តណ្ហានេះ កាលនឹងកើតឡើង តែងកើតឡើងក្នុងបិយ-រូបនិងសាតរូបនេះ" ។

បទថា **បញ្ញា** សេចក្តីថា អ្នកទាំងឡាយចូរកាត់ឫសចោលចេញ ដោយមគ្គបញ្ញា ដូចបុគ្គលកាត់នូវវល្លិដែលដុះក្នុងព្រៃដោយកាំបិតដូច្នោះចុះ ។

បទថា **សរិតានិ** គឺផ្សាយទៅ បានដល់ផ្សព្វផ្សាយទៅ

បទថា **សិនេហិតានិ ច** សេចក្តីថា ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង ដោយអំណាចនៃសេចក្តីស្នេហាដែលប្រព្រឹត្តទៅក្នុងបរិក្ខាទាំងឡាយ មានចីវរជាដើមផង អធិប្បាយថា ដែលប្រឡាក់ដោយសេចក្តីស្រឡាញ់គឺតណ្ហា

បទថា **សោមនស្សានិ** សេចក្តីថា សោមនស្សទាំងឡាយបែបនោះ រមែងមានដល់បុគ្គលអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា ។

ពីរបទថា **តេ សាតសិតា** សេចក្តីថា បុគ្គលទាំងនោះ គឺបុគ្គលអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា ជាអ្នកអាស្រ័យសេចក្តីរីករាយ គឺអាស្រ័យសេចក្តីនោះឯង ទើបជាអ្នកស្វែងរកសេចក្តីសុខ គឺជាអ្នកស្វះស្វែងរកសេចក្តីសុខ ។

បទថា **តេ វេ** ជាដើម សេចក្តីថា នរជនទាំងឡាយនោះឯង រមែងចូលដល់ការកើត ការចាស់ ការឈឺ និងសេចក្តីស្លាប់ដោយពិតប្រាកដ ព្រោះហេតុនោះ ទើបនរជនទាំងនោះមានឈ្មោះថា ចូលដល់ជាតិនិងជរា ។

បទថា **បជា** ជាដើម សេចក្តីថា សត្វទាំងនេះជាអ្នកដែលតណ្ហាដែលចូលដល់ការរាប់ថា "**តសិណា**" (ក្រុងទុក) ព្រោះធ្វើនូវសេចក្តីតក់ស្លុតដោយជុំវិញ គឺព័ទ្ធជុំវិញហើយ ។

បទថា **ពាធិតោ** សេចក្ដីថា (សត្វទាំងនោះ) តែងរន្ធត់ គឺភ័យខ្លាច ដូចទន្សាយដែលព្រានទាក់បានហើយក្នុងព្រៃ ដូច្នោះ ។

បទថា **សំយោជនសង្គសត្តា** សេចក្ដីថា សត្វទាំងឡាយជាអ្នកដែលសំយោជនជាប់យ៉ាងនិងធម៌ជាគ្រឿងជំពាក់ គឺរាគៈជាដើមចងទុកហើយ ឬជាអ្នកជាប់ក្នុងសំយោជនជាដើមនោះ ។

បទថា **ចិរាយ** សេចក្ដីថា សត្វទាំងឡាយនោះតែងចូលដល់សេចក្ដីទុក្ខមានជាតិទុក្ខជាដើមរឿយ ៗ អស់កាលយូរ ។

បទថា **តស្មា** ជាដើម សេចក្ដីថា ព្រោះពួកសត្វដែលតណ្ហា ជាទីញ៉ាំងសត្វឲ្យតក់ស្លុតឡោមព័ទ្ធ ក្រងទុកហើយ គឺរួបរឹតទុកហើយ ។ ដូច្នោះ ភិក្ខុកាលប្រាថ្នាធម៌ជាគ្រឿងប្រាសចាករាគៈគឺព្រះនិព្វាន ដែលជាទីប្រាសចាកកិលេសមានរាគៈជាដើមដើម្បីខ្លួន គប្បីបន្ទោបង់ គឺគប្បីនាំចេញនូវតណ្ហា ជាគ្រឿងតក់ស្លុតនោះដោយព្រះអរហត្តមគ្គ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

កូនជ្រូកញីនោះ ឆាប់អំពីអត្តភាពនោះហើយ កើតក្នុងរាជត្រកូលក្នុងសុវណ្ណភូមិ, ចុតិចាកអត្តភាពនោះហើយ កើតក្នុងក្រុងពារាណសីដូច្នោះដដែល, ចុតិចាកអត្តភាពនោះហើយ កើតក្នុងត្រកូលឈ្មួញសេះ ដែលនៅក្បែរកំពង់ផែឈ្មោះសុប្បារកៈ, ចុតិចាកអត្តភាពនោះហើយ បដិសន្ធិក្នុងត្រកូលនាយសំពៅដែលនៅក្បែរកំពង់ផែឈ្មោះគាវិរៈ, ចុតិចាកអត្តភាពនោះហើយ បដិសន្ធិក្នុងត្រកូលឥស្សរជនក្នុងក្រុងអនុរាធបុរី, ចុតិចាកអត្តភាពនោះហើយ បដិសន្ធិជាធីតាក្នុងត្រកូលកុដុម្ពិកៈឈ្មោះសុមនៈ ក្នុងភេកកន្ទគ្រាម ខាងទិសទក្សិណនៃក្រុងនោះ ឈ្មោះសុមនាតាមឈ្មោះ (ឈ្មោះរបស់កុដុម្ពិកៈនោះ) ។ ក្រោយមក បិតារបស់នាង កាលជនទាំងឡាយបោះបង់ស្រុកនោះហើយ បានទៅកាន់ដែនឈ្មោះទីឃវាបិដែលនៅក្នុងស្រុកឈ្មោះមហាមុនីគ្រាម ។ អាមាត្យរបស់ព្រះបាទទុដ្ឋគាមណី នាមថាលកណ្ឌកអតិម្ពរៈ ទៅ

កាន់ស្រុកនោះដោយកិច្ចឯណានីមួយ ឃើញនាងហើយ ធ្វើនូវមង្គលដ៏ធំ នាំនាងទៅកាន់ស្រុកមហាបុណ្ណគ្រាម ។ គ្រានោះ ព្រះមហាអតុលថេរ អ្នកមានប្រក្រតីនៅក្នុងមហាវិហារឈ្មោះកោដិបពតិ ត្រាច់ទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាតឈរនៅក្លោងទ្វារផ្ទះរបស់នាង ឃើញនាងហើយ ក៏ប្រាប់ភិក្ខុទាំងឡាយថា "ម្នាលអាវុសោទាំងឡាយ កូនជ្រូកញីក្នុងកាលមុននោះ ឥឡូវនេះបានមកជាកិរិយារបស់អាមាត្យឈ្មោះលកុណាដកអតិម្ពរៈហើយ ឱ! គួរឲ្យអស្ចារ្យពិតមែនហ្ន៎" នាងស្តាប់ពាក្យនោះហើយ ស្រាវជ្រាវកពដែលកន្លងទៅហើយបាន ត្រឡប់បានញាណដែលជាហេតុរលឹកជាតិ ។ ក្នុងខណៈនោះឯង នាងមានសេចក្តីសង្វេគកើតហើយ សូមស្វាមីបួសក្នុងសំណាក់ព្រះថេរី អ្នកប្រកបដោយពលៈប្រាំដោយឥស្សរិយល់ដ៏ធំ បានស្តាប់កថាដែលពណ៌នាអំពីមហាសតិប្បដ្ឋានសូត្រ ក្នុងតិស្សមហាវិហារហើយ បានសម្រេចសោតាបត្តិផល, ក្រោយមក កាលព្រះបាទទុដ្ឋគាមណីទ្រង់បង្ក្រាបពួកទមិឡបានហើយ ព្រះនាងសុមនាថេរីទៅកាន់

ស្រុកកេក្កន្តគ្រាម ដែលជាទីនៅនៃមាតាបិតានោះ នៅក្នុងទីនោះ បានស្ដាប់អាសីវិសូបមសូត្រក្នុងកល្ហុកមហាវិហារ បានសម្រេចព្រះអរហន្ត ។

ក្នុងថ្ងៃបរិនិព្វាន នាងត្រូវពួកភិក្ខុនីសាកសួរ ក៏ពោលប្រវត្តិទាំងពួងដែលមានចន្លោះប្រាប់ពួកភិក្ខុនីសង្ឃ ហើយសន្ទនានិងព្រះមហាតិស្សត្ថេរ ដែលជាអ្នកពោលបទនៃធម៌ ដែលមានប្រក្រតីនៅក្នុងមណ្ឌលលាពម កណ្ដាលភិក្ខុសង្ឃ ដែលប្រជុំគ្នាហើយ ពោលថា "ក្នុងកាលមុន ខ្ញុំចុតិអំពីកំណើតមនុស្សហើយ កើតជាមេមាន់ ដល់នូវការដាច់ក្បាល អំពីសំណាក់សត្វខ្លែងក្នុងអត្តភាពនោះហើយ (ទៅ) កើតក្នុងក្រុងរាជគ្រឹះ ហើយបួសក្នុងសំណាក់នាងបរិព្វាជិកាទាំងឡាយ ហើយកើតក្នុងភូមិបឋមជ្ឈាន ចុតិចាកអត្តភាពនោះហើយ កើតក្នុងត្រកូលសេដ្ឋី មិនយូរប៉ុន្មាន ចុតិហើយទៅកាន់កំណើតជ្រូក ចុតិចាកអត្តភាពនោះហើយ ទៅកាន់សុវណ្ណភូមិ ចុតិចាកអត្តភាពនោះហើយ ទៅបដិសន្ធិក្នុងក្រុងពារាណសី ចុតិចាកអត្តភាពនោះហើយ ទៅកាន់កំពង់

ផៃឈ្មោះសុប្បារកៈ ចុតិចាកអត្តភាពនោះហើយទៅបដិសន្ធិ នៅក្បែរកំពង់ឈ្មោះគារិរៈ ចុតិចាកអត្តភាពនោះហើយទៅកាន់ក្រុងអនុរាធបុរី ចុតិចាកអត្តភាពនោះហើយ ទៅបដិសន្ធិក្នុងស្រុកភេក្កន្តគ្រាម, ខ្ញុំបានដល់អត្តភាព ១៣ ដែលសមខ្វះមិនសមខ្វះ ដោយប្រការយ៉ាងនេះ ឥឡូវនេះ កើតក្នុងអត្តភាពដ៏ឧក្រិដ្ឋហើយ សូមអ្នកទាំងឡាយសូម្បីទាំងអស់ ចូរញ៉ាំងធម៌ ដែលជាកុសលទាំងឡាយឲ្យដល់ព្រមដោយការមិនប្រមាទចុះ" ដូច្នេះហើយ ញ៉ាំងបរិស័ទទាំង ៤ ឲ្យសង្វេគហើយបរិនិព្វានទៅក្នុងពេលនោះឯង ។

( រឿងកូនជ្រូកញី ចប់ )

ෂෂෂෂෂෂෂෂෂෂෂෂෂෂෂෂෂෂෂෂ

## ៣ រឿងភិក្ខុអ្នកសឹក

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធភិក្ខុអ្នកសឹកមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **យោ និព្វនថោ** ” ជាដើម ។

### អ្នកសឹកចេញទៅធ្វើចោរកម្មបិញ្ចឹមជីវិត

បានឮថា ភិក្ខុជាសទ្ធិវិហារិករបស់ព្រះមហាកស្សបៈមួយរូប សូម្បីញ៉ាំងឈានទាំង ៤ ឲ្យកើតឡើងហើយ ឃើញរូបារម្មណ៍ដែលវិសភាគ ( សឹកសត្រូវ) ក្នុងផ្ទះជាងមាសដែលជាឪពុកធំរបស់ខ្លួន មានចិត្តជាប់ជំពាក់នឹងរូបនោះក៏លាចាកសិក្ខាបទទៅ ។

គ្រាក្រោយមក ព្រោះខ្លួនជាអ្នកខ្ជិលច្រអូស មិនជួយធ្វើការងារទាំងឡាយ ទើបពួកមនុស្សបណ្តេញគេចេញអំពី

ផ្ទះ ។ ក្រោយអំពីត្រូវគេដេញចេញចាកផ្ទះ ក៏ចិញ្ចឹមជីវិតដោយការធ្វើចោរកម្ម ព្រោះការសេពគប់មិត្រអាក្រក់ ។

ក្រោយមក នៅថ្ងៃមួយ ពួករាជបុរសចាប់គេបាន ក៏ចងក្រពាត់ដៃទៅខាងក្រោយយ៉ាងមាំ វាយដោយរំពាត់ផ្តៅគ្រប់ ៗ ផ្លូវបែកជាបួន ហើយនាំទៅកាន់ទីសម្លាប់ ។

ព្រះថេរៈ ចូលទៅដើម្បីបិណ្ឌបាត ឃើញបុរសនោះត្រូវពួករាជបុរសនាំចេញទៅតាមក្លោងទ្វារទិសទក្សិណ ក៏សូមឲ្យពួករាជបុរសបន្ធូរចំណងឲ្យធូរបន្តិចហើយ ពោលថា "នែអ្នកដ៏ចំរើន អ្នករលឹកដល់កម្មដ្ឋានដែលអ្នកធ្លាប់សន្សំមកហើយក្នុងកាលមុនទៀតចុះ" ។ បុរសនោះក៏កើតសតិស្មាតីដោយសារឱវាទនោះហើយ បានញ៉ាំងចតុត្ថជ្ឈានឲ្យកើតឡើងម្តងទៀត ។

គ្រានោះ ពួករាជបុរសនាំគេទៅកាន់ទីពិឃាត ឲ្យគេដេកផ្ងាលើឈើអណ្តោត ដោយគិតថា " ពួកយើងនឹងសម្លាប់ " ។ បុរសនោះមិនខ្លាច មិនតក់ស្លុត ។

# ពួកមនុស្សអស្ចារ្យក្នុងចិត្តដោយសារ
# ឃើញបុរសនោះមិនខ្លាចស្លាប់

គ្រានោះ មនុស្សទាំងឡាយដែលឈរនៅក្នុងទិសនោះ ៗ បានលើកឡើងនូវអាវុធផ្សេង ៗ មានដាវ, លំពែង និងច្បូក ( លំពែងស្នែងក្របី ) ជាដើមចំពោះបុរសនោះ កាលឃើញបុរសនោះមិនតក់ស្លុត មិនភ័យខ្លាច ម្នាក់ ៗ ក៏ពោលថា “នែអ្នកដ៏ចំរើនទាំងឡាយ អ្នកទាំងឡាយចូរមើលបុរសនេះចុះ គេមិនខ្លាច មិនរន្ធត់ មិនញាប់ញ័រក្នុងកណ្ដាលនៃអ្នកមានអាវុធក្នុងដៃ សូម្បីច្រើនរយនាក់ , ឱ ! គួរឲ្យអស្ចារ្យណាស់ហ្ន៎ ” ដូច្នេះហើយ កើតការអស្ចារ្យ និងចម្លែកក្នុងចិត្ត បន្លឺឡើងនូវសីហនាទដ៏ខ្លាំង ( ទៅ ) ក្រាបទូលរឿងនោះចំពោះព្រះរាជា ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ត្រាស់ថា “ អ្នកទាំងឡាយចូរប្រលែងបុរសនោះចុះ ” ដូច្នេះហើយ ស្ដេចទៅកាន់សំណាក់ព្រះសាស្ដាក្រាបទូលរឿងនោះ ។

ព្រះសាស្តា ទ្រង់ផ្សាយព្រះរស្មីទៅហើយ កាលនឹងទ្រង់ទ្រង់សម្តែងធម៌ដល់បុរសនោះ ទើបទ្រង់ត្រាស់ព្រះគាថាទាំងនេះថា ៖-

៣. យោ និព្វនថោ វនាធិមុត្តោ
វនមុត្តោ វនមេវ ធាវតិ
តំ បុគ្គលមេវ បស្សថ
មុត្តោពន្ធនមេវ ធាវតិ ។

បុគ្គលណាមិនអាល័យក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃគឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃគឺតណ្ហា ហើយស្ទុះទៅរកព្រៃគឺតណ្ហាវិញ អ្នកទាំងឡាយចូរមើលបុគ្គលនោះចុះ បុគ្គលនោះរួចចាកចំណងគឺឃរាវាសហើយស្ទុះទៅរកចំណង គឺឃរាវាសវិញ ។

## អធិប្បាយគាថា

សេចក្តីនៃព្រះគាថាទាំងនោះថា "បុគ្គលណាមានអាល័យ ដូចជាដើមឈើដែលតាំងនៅក្នុងព្រៃកិលេសប្រាស

ចេញហើយ ព្រោះខ្លួនលះបង់ដើមឈើដែលតាំងនៅក្នុងព្រៃ គឺអាល័យក្នុងកាមជាយរាវាសហើយបួស មានចិត្តចុះស៊ប់ទៅក្នុងព្រៃគឺតបធម៌ ពោលគឺវិហារធម៌ ជាអ្នករួចផុតស្រឡះចាកព្រៃគឺតណ្ហា ដែលចាត់ជាចំណងគឺការគ្រប់គ្រងផ្ទះហើយ ស្ទុះទៅរកព្រៃគឺតណ្ហា ដែលជាចំណងគឺការគ្រប់គ្រងផ្ទះវិញទៀត អ្នកទាំងឡាយ ចូរមើលបុគ្គលនោះចុះ , បុគ្គលនោះរួចស្រឡះចាកចំណង គឺការគ្រប់គ្រងផ្ទះហើយ ស្ទុះទៅរកចំណងគឺការគ្រប់គ្រងផ្ទះវិញ ។

បុរសនោះស្តាប់ទេសនានេះ នៅលើឈើអណ្តោតក្នុងចន្លោះនៃរាជបុរសទាំងឡាយ ផ្តើមនូវការកើតឡើង និងការរលត់ទៅហើយ លើកចិត្តឡើងកាន់ត្រៃលក្ខណ ពិចារណាសង្ខារទាំងឡាយ បានសម្រេចសោតាបត្តិផលហើយសោយសុខដែលកើតអំពីសមាបត្តិ ហោះឡើងទៅកាន់វេហាស៍មកកាន់សម្នាក់ព្រះមានព្រះភាគ តាមអាកាសនោះឯង ថ្វាយបង្គំព្រះមានព្រះភាគហើយបួស បានសម្រេចព្រះអរហត្តនៅកណ្តាលបរិស័ទ មួយអន្លើព្រះរាជានោះឯង ។

( រឿងភិក្ខុសឹក ចប់ )

88888888888888888

# ៨ រឿងពន្ធនាគារ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពន្ធនាគារ ត្រាស់ព្រះធម្មទេសនានេះថា “ **ន តំ ទឡ្ហំ** ” ជាដើម ។

## ពួកភិក្ខុឃើញចោរត្រូវគេចាប់ចងនឹកប្លែកក្នុងចិត្ត

បានឮថា ថ្ងៃមួយ ពួករាជបុរសនាំពួកចោរដែលកាត់ទីត ដែលប្លន់អ្នកស្រុកតាមផ្លូវ និងសម្លាប់មនុស្សជាច្រើនទៅថ្វាយព្រះរាជាដែនកោសល ។

ព្រះរាជាត្រាស់ឲ្យចងចោរទាំងនោះ ដោយចំណងគឺ ខ្នោះ ចំណងគឺខ្សែ និងចំណងគឺច្រវាក់ទាំងឡាយ ។ ពួកភិក្ខុដែលនៅក្នុងជនបទ មានប្រមាណ ៣០ រូប ប្រាថ្នានឹងចូល

ទៅគាល់ព្រះសាស្តា ចូលមកថ្វាយបង្គំព្រះសាស្តាហើយ ស្អែកឡើងចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ទៅដល់ពន្ធនាគារឃើញចោរទាំងនោះ ត្រឡប់មកអំពីបិណ្ឌបាតហើយ ចូលទៅគាល់ព្រះមានព្រះភាគក្នុងវេលារសៀល ទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះ ពួកខ្ញុំព្រះអង្គកំពុងត្រាច់ទៅបិណ្ឌបាត ឃើញចោរជាច្រើននៅក្នុងគុក ត្រូវចងដោយចំណងគឺខ្នោះជាដើម សោយទុក្ខយ៉ាងខ្លាំង, ពួកគេមិនអាចនឹងកាត់ចំណងទាំងនោះបាន, បពិត្រព្រះអង្គដ៏ចំរើន តើមានចំណងដទៃ ដែលមាំជាងចំណងទាំងនោះដែរឬទេ ?"

## ចំណងគឺកិលេសកាត់បានដោយកម្រ

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចំណងទាំងនោះ នឹងឈ្មោះថាជាចំណងអ្វី ចំណែកចំណងគឺកិលេស បានដល់តណ្ហាដែលប្រព្រឹត្តទៅក្នុងសវិញ្ញាណកទ្រព្យនិងអវិញ្ញាណកទ្រព្យទាំងឡាយ មានទ្រព្យគឺស្រូវអង្ករបុត្តនិងភរិយាជាដើម ទើបជាចំណងដ៏មាំជាងចំណងគឺខ្នោះជាដើមទាំងនោះ តាំងរយដង តាំងពាន់ដង តាំងសែនដង,

ថ្វីបើចំណង់នេះជាចំណង់ដ៏មាំ កាត់បានដោយកម្រយ៉ាងនេះ ក៏ដោយ ក៏បុរាណបណ្ឌិតនៅតែកាត់បានហើយ ចូលទៅកាន់ហិមវន្តប្រទេស បួសជាឥសី ។ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក (ត្រាស់) ថា ៖-

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងត្រកូលគហបតីទុគ៌តមួយ ។ កាលព្រះពោធិសត្វចំរើនវ័យ បិតាក៏បានធ្វើមរណកាលទៅ ។ ព្រះពោធិសត្វស៊ីឈ្នួលគេចិញ្ចឹមមាតា, ក្រោយមក មាតារបស់ព្រះពោធិសត្វបានទៅកាន់ត្រកូលមួយសូមធីតាមកទុកក្នុងផ្ទះ ដើម្បីព្រះពោធិសត្វ ទាំងដែលព្រះពោធិសត្វមិនត្រូវការ ។ មិនយូរប៉ុន្មានមាតារបស់ព្រះពោធិសត្វក៏ធ្វើមរណកាលទៅទៀត ។ ចំណែកភរិយារបស់ព្រះពោធិសត្វក៏មានគភ៌ ។ ព្រះពោធិសត្វមិនបានដឹងថាភរិយារបស់ខ្លួនមានគភ៌ទេ ទើបពោលថា "ម្នាលនាងដ៏ចំរើន នាងចូរស៊ីឈ្នួលគេចិញ្ចឹមជីវិតចុះ, ខ្ញុំនឹងបួស"។

នាងពោលថា "បពិត្រអ្នកជាម្ចាស់ ខ្ញុំមានគភ៌ហើយមិនមែនឬ ? កាលខ្ញុំប្រសូតិហើយ អ្នកនឹងឃើញទារកហើយ ទៅបួសចុះ" ព្រះពោធិសត្វក៏យល់ព្រមដោយពាក្យថា "ប្រពៃហើយ នាង" កាលនាងប្រសូត្រហើយ ក៏ពោលលាថា "ម្នាលនាងដ៏ចំរើន ឥឡូវនេះ នាងប្រសូត្របុត្តដោយសិរីសួស្តីហើយ, ខ្ញុំនឹងទៅបួសហើយ" ពេលនោះនាងក៏ពោលទៅកាន់ព្រះពោធិសត្វថា "បពិត្រអ្នកជាម្ចាស់ ចូររង់ចាំពេលដែលកូនតូចរបស់បងឈប់បៅដោះសិនចុះ" ហើយក៏មានគភ៌ទៀត ។

ព្រះពោធិសត្វត្រិះរិះថា "យើងមិនអាចឲ្យនាងនេះយល់ព្រមបានទេ, យើងមិនចាំបាច់លានាងទេ នឹងគេចចេញទៅបួសតែម្តង" ។ ព្រះពោធិសត្វមិនប្រាប់នាង ក្រោកឡើងក្នុងចំណែករាត្រីហើយ ចៀសចេញទៅតែម្តង ។

គ្រានោះ រាជបុរសអ្នករក្សាព្រះនគរ ចាប់ព្រះពោធិសត្វ ។ ព្រះពោធិសត្វពោលថា "នែអ្នកដ៏ចំរើន ខ្ញុំជាអ្នកចិញ្ចឹមមាតាបិតា, សូមអ្នកទាំងឡាយដោះលែងខ្ញុំទៅ" ញុំាង

រាជបុរសឲ្យដោះលែងខ្លួនហើយ សម្រាក់នៅក្នុងទីមួយ ហើយចូលទៅកាន់ព្រៃហិមពាន្តបួសជាឥសិ ញុំាងអភិញ្ញា និងសមាបត្តិឲ្យកើតឡើងហើយ ត្រេកអររីករាយនៅជាសុខក្នុងឈាន ។ ព្រះពោធិសត្វនៅក្នុងទីនោះ បានបន្លឺឧទានឡើងថា "ចំណងគឺបុត្តនិងភរិយា ចំណងគឺកិលេស ដែលបុគ្គលកាត់បានដោយក្របែបនោះ យើងកាត់បានហើយ ។

## ព្រះសាស្តាទ្រង់សម្តែងចំណងពីរយ៉ាង

ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ កាលនិងទ្រង់ប្រកាសឧទាន ដែលព្រះពោធិសត្វនោះបន្លឺហើយ បានត្រាស់ព្រះគាថាទាំងនេះថា ៖-

៤.ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្វជញ្ច
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា
ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ

ឯតំបិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ កាមសុខំ បហាយ ។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅឃាប្ឫងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះថាជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យកូននិងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះថាជាចំណងមាំមួន ជាចំណងនាំចុះ ( ទាញសត្វទំលាក់ទៅក្នុងអបាយ ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ធីរា** ជាដើម សេចក្ដីថា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម មិនហៅចំណង ដែលកើតអំពីដែក ដែលបណ្ឌិតហៅថាច្រវាក់ជាវិការៈនៃ ដែក ដែលកើតអំពីឈើ ពោលគឺខ្នោះ និងចំណងគឺខ្សែ ដែលគេយកស្មៅឃាបូង ឬវត្ថុយ៉ាងដទៃមានសម្បកព្រោល ( ក្រចៅ )ជាដើមធ្វើជាខ្សែថា "ជាចំណងដ៏មាំ"ទេ, ព្រោះជា ចំណងដែលបុគ្គលអាចកាត់ដោយសស្ត្រាទាំងឡាយ មាន ដាវជាដើមបាន ។

បទថា **សារត្តរត្តា** បានដល់ ជាអ្នកត្រេកអរដ៏ក្រៃ លែង, អធិប្បាយថា អ្នកត្រេកអរដោយរាគៈដ៏ក្រាស់ ។

បទថា **មណិកុណ្ឌលេសុ** គឺក្នុងកែវមណីនិងកុណ្ឌល ទាំងឡាយ,ម្យ៉ាងទៀត ( គឺ ) ក្នុងកុណ្ឌលទាំងឡាយដែល វិចិត្រដោយកែវមណី ។

បទថា **ទឡ្ហំ** សេចក្ដីថា សេចក្ដីត្រេកអរណា របស់ ជនទាំងឡាយ អ្នកត្រេកអរដ៏ក្រៃលែងក្នុងកែវនិងកុណ្ឌល ទាំងឡាយនោះ និងការហួងហែង គឺសេចក្ដីអាឡោះអាល័យ

កូននិងប្រពន្ធណា, បណ្ឌិតទាំងឡាយតែងហៅសេចក្តីត្រេកអរនិងសេចក្តីអាឡោះអាល័យនោះ ដែលជាចំណងសម្រេចអំពីកិលេសថា “ជាចំណងដ៏មាំ” ។

បទថា **ឱហារិនំ** សេចក្តីថា ឈ្មោះថា មានប្រក្រតីនាំចុះ ព្រោះរមែងទាញចុះ គឺនាំទៅកាន់ទីទាប ព្រោះទាញសត្វទំលាក់ទៅក្នុងអបាយភូមិទាំង ៤ ។

បទថា **សិថិលំ** សេចក្តីថា ឈ្មោះថា ធូរ ព្រោះមិនកាត់សម្បុរថ្ងៃ, ស្បែកនិងសាច់ គឺមិនធ្វើឲ្យមានលោហិតក្នុងទីដែលចង បានដល់ មិនឲ្យដឹងថាជាចំណង មិនឲ្យដឹងថាខ្លួនជាប់ចំណង អាចឲ្យធ្វើការងាយទាំងឡាយ ក្នុងទីទាំងឡាយមានផ្លូវគោកនិងផ្លូវទឹកជាដើមបាន ។

បទថា **ទុប្បមុញ្ចំ** សេចក្តីថា ឈ្មោះថា ស្រាយបានក្រ ក៏ព្រោះចំណងគឺកិលេស ដែលកើតឡើងដោយអំណាចការលោភសូម្បីតែម្តង រមែងជាកិលេសជាតិដែលបុគ្គលស្រាយបានដោយក្រ ដូចអណ្តើករួចចាកអំពីចំណងបានដោយលំបាកដូច្នោះ ។

ពីរបទថា **ឯតំបិ ឆេត្វាន** សេចក្ដីថា អ្នកប្រាជ្ញទាំងឡាយកាត់ចំណងគឺកិលេសនោះ សូម្បីជាចំណងដ៏មាំយ៉ាងនោះ ដោយព្រះខាន់គឺញាណហើយ ជាអ្នកមិនមានសេចក្ដីអាឡោះអាល័យ បានលះបង់សេចក្ដីសុខក្នុងកាមហើយ វៀរដោយជុំវិញ គឺចៀសចេញទៅ, អធិប្បាយថា រមែងបួស ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងពន្ធនាគារ ចប់

## ៥ រឿងព្រះនាងខេមា

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធព្រះអគ្គមហេសីរបស់ព្រះបាទពិម្ពិសារ ព្រះនាមថាខេមា ត្រាស់ព្រះធម្មទេសនានេះថា “**យេ រាគរត្តា**” ជាដើម ។

## **បន្ទាមុតយកបន្ទាជោះ**

បានឮថា ព្រះនាងខេមានោះតាំងសេចក្ដីប្រាថ្នាទុកទៀបបាទមូលព្រះពុទ្ធទ្រង់ព្រះនាមថាបទុមុត្តរ បានជាស្ត្រីមានព្រះរូបស្រស់ស្អាតគួរជាទីជ្រះថ្លាយ៉ាងក្រៃលែង ។

ក៏ព្រះនាងបានទ្រង់ព្រះសណ្ដាប់ថា “បានឮថា ព្រះសាស្ដាទ្រង់តិះដៀលទោសរបស់រូប” ទើបមិនប្រាថ្នានិងស្ដេចទៅកាន់សំណាក់ព្រះសាស្ដា ។ ព្រះរាជាទ្រង់ជ្រាបថាព្រះអគ្គមហេសីនោះស្រវឹងក្នុងរូប ទើបត្រាស់ឲ្យពួកអ្នកកវីនិពន្ធបទចម្រៀងពណ៌នាអំពីវត្តវេឡុវន ហើយក៏ឲ្យព្រះរាជទានបទចម្រៀងនោះដល់ពួកអ្នករបាំជាដើម ។ កាលអ្នករបាំទាំងនោះច្រៀងបទចម្រៀងនោះ ព្រះនាងទ្រង់ព្រះសណ្ដាប់ហើយ វត្តវេឡុវនប្រហែលដូចជាមិនធ្លាប់បានទត្តនិងមិនធ្លាប់

ទ្រង់ព្រះសណ្ដាប់ឥតចឹង ។ ព្រះនាងខេមាត្រាស់សួរថា “ពួកអ្នកច្រៀងសំដៅដល់ឧទ្យានមួយណា ?”

កាលពួកអ្នកចម្រៀងក្រាបទូលថា “បពិត្រព្រះទេវី ពួកខ្ញុំច្រៀងសំដៅដល់ឧទ្យានវេឡុវន” ក៏ទ្រង់ប្រាថ្នានឹងស្ដេចទៅកាន់ព្រះឧទ្យានវេឡុវន ។ ព្រះសាស្ដាទ្រង់ជ្រាបការយាងមករបស់ព្រះនាង កាលទ្រង់គង់សម្ដែងព្រះធម៌នៅក្នុងកណ្ដាលបរិស័ទ ទើបទ្រង់និមិត្តស្ត្រីរូបស្អាតម្នាក់ ឈរកាន់ផ្លិតជាងគ្នោតបក់ថ្វាយព្រះអង្គ ។

ចំណែកព្រះនាងខេមាទេវី ស្ដេចចូលទៅ ទ្រង់ទតឃើញស្ត្រីនោះ ក៏ទ្រង់ព្រះតម្រិះថា “ជនទាំងឡាយតែងនិយាយថា ព្រះសម្មាសម្ពុទ្ធទ្រង់តិះដៀលទោសរបស់រូប, ក៏ស្ត្រីនេះឈរបក់ផ្លិតថ្វាយព្រះអង្គក្នុងសំណាក់ព្រះអង្គ, យើងមិនចូលដល់សូម្បីមួយចំរៀកនៃស្ត្រីនេះ, រូបស្ត្រីដូច្នេះ យើងមិនធ្លាប់ឃើញពីមុនឡើយ, ជនទាំងឡាយប្រហែលជាពោលបង្កាច់ព្រះសាស្ដាដោយពាក្យមិនពិតហើយមើលទៅ” ដូច្នេះ

ហើយ ក៏មិនធ្វើទុកក្នុងចិត្តចំពោះព្រះតម្រាស់របស់ព្រះតថា-គត ទ្រង់ព្រះថាប់ឈរទត្តស្រ្តីនោះ ។

## ក្នុងរាងកាយនេះមិនមានសារៈ

ព្រះសាស្តាទ្រង់ជ្រាបថាព្រះនាងខេមានេះ មានមានៈខ្លាំងកើតឡើងក្នុងរូបនោះ កាលនឹងទ្រង់សម្តែងរូបនោះដោយអំណាចវ័យមានបឋមវ័យជាដើម ទើបទ្រង់សម្តែងធ្វើរូបនោះឲ្យសល់នៅតែរាងឆ្អឹងក្នុងបំផុត ដោយន័យដូចដែលខ្ញុំម្ចាស់បានពោលហើយក្នុងកាលមុននោះឯង ។

ព្រះនាងខេមាលុះទ្រង់ទតឃើញរូបនោះ មានអាការៈយ៉ាំនោះ ក៏ទ្រង់ព្រះតម្រិះថា "រូបនោះ សូម្បីបែបនេះ ក៏ដល់នូវការសាបសូន្យទៅដោយមួយរំពេចប៉ុណ្ណោះ, ខ្លឹមសារក្នុងរូបនេះ មិនមានហ្ន៎ ? " ។

ព្រះសាស្តាទ្រង់ជ្រាបវារៈចិត្តរបស់ព្រះនាងខេមានោះហើយ ក៏ទ្រង់ត្រាស់ថា "ម្នាលនាងខេមា នាងគិតថា សារៈមាននៅក្នុងរូបនេះឬ ? នាងចូរមើលរូបនោះមិនមានសារៈទេ ហើយត្រាស់ព្រះគាថានេះថា ៖-

ម្នាលនាងខេមា នាងចូរមើលកាយដ៏ក្តៅក្រហាយ មិនស្អាត ជាកាយស្អុយ គួរនឿយណាយ មានរបស់មិនស្អាតហូរចេញទាំងខាងលើ ហូរចេញទាំងខាងក្រោម ដែលជនពាលទាំងឡាយ តែងប្រាថ្នាក្រៃលែងណាស់ ។

ក្នុងកាលចប់ព្រះគាថា ព្រះនាងខេមាបាសម្រេចសោតាបត្តិផល ។

គ្រានោះ ព្រះតថាគតត្រាស់ទៅកាន់ព្រះនាងថា "ម្នាលនាងខេមា សត្វទាំងនោះត្រេកដោយរាគៈ ខឹងក្រោធមិនសប្បាយចិត្តដោយទោសៈ វង្វេងដោយមោហៈ ទើបមិនអាចឈានកន្លងខ្សែតណ្ហាបាន តែងធ្លាក់ចុះទៅកាន់ខ្សែតណ្ហានោះឯង" ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖-

**៥. យេ រាគរត្តានុបតន្តិ សោតំ**
**សយំ កតំ មក្កដកោវ ជាលំ**
**ឯតម្បិ ឆេត្វាន វជន្តិ ធីរា**

**អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**

ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់ទុក្ខទាំងពួងចេញទៅ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **មក្កដកោ ជាលំ** សេចក្តីថា ដូចពីងពាងធ្វើសំណាញ់គឺសំបុកហើយ ក៏ដេកនៅក្នុងសំបុកត្រង់កណ្តាលហើយ ក៏ប្រញាប់រត់ទៅសម្លាប់កណ្តូបឬសត្វល្អិតទាំងឡាយ ដែលធ្លាក់ទៅក្នុងសំបុក បើតស៊ីរសរបស់សត្វល្អិតទាំងនោះហើយ ក៏ត្រឡប់មកដេកនៅក្នុងទីដើមវិញ យ៉ាងណា ពួកជនណាត្រេកអរដោយអំណាចរាគៈ ក្រោធដោយអំណាចទោសៈ វង្វេងដោយមោហៈ, ជនទាំងនោះតែងធ្លាក់ទៅកាន់ខ្សែតណ្ហា ដែលធ្វើហើយដោយខ្លួន

ឯង គឺគេមិនអាចឈានកន្លងខ្សែតណ្ហានោះបានឡើយ ដូច្នោះដែរ, ខ្សែតណ្ហានោះ បុគ្គលកន្លងបង់បានដោយក្រ យ៉ាងនេះ ។

បាទព្រះគាថា **ឯតម្បិ ឆេត្វាន វជន្តិ ធីរា** សេចក្តីថា បណ្ឌិតទាំងឡាយ កាត់ខ្សែតណ្ហាទាំងនោះហើយ ជាអ្នកអស់ហួងហែង គឺមិនមានសេចក្តីអាឡោះអាល័យ លះបង់ទុក្ខទាំងពួងដោយអរហត្តមគ្គហើយ ក៏វៀរ គឺចេញទៅ ។

ក្នុងកាលចប់ទេសនា ព្រះនាងខេមាទ្រង់តាំងនៅក្នុងព្រះអរហត្ត ។ ទេសនាបានជាគុណជាតិមានប្រយោជន៍សូម្បីដល់មហាជន ។ ព្រះសាស្តាត្រាស់ទៅកាន់ព្រះរាជាថា "មហាបពិត្រ ព្រះនាងខេមានឹងបួសឬបរិនិព្វាន ទើបគួរ ?"

ព្រះរាជា. បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ព្រះមេត្តាឲ្យព្រះនាងបួសចុះ, កុំឲ្យព្រះនាងបរិនិព្វានឡើយ ។

ព្រះនាងបួសហើយ ក៏បានជាជាសាវិកាដ៏លើស ។

រឿងព្រះនាងខេមា ចប់

# ៦. រឿងបុត្តសេដ្ឋីឈ្មោះឧគ្គសេន

## *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធឧគ្គសេន ត្រាស់ព្រះធម្មទេសនានេះថា “**មុញ្ច បុរេ**” ជាដើម*

## *ឧគ្គសេនស្រឡាញ់ស្រីរបាំ*

*បានឮថា កាលគ្រប់បី ឬ ៦ ខែហើយ ពួកអ្នករបាំប្រមាណ ៥០០ នាក់ទៅកាន់ក្រុងរាជគ្រឹះ លេងមហោស្រពថ្វាយព្រះរាជា ៧ ថ្ងៃ បានមាសនិងប្រាក់យ៉ាងច្រើន, បានទទួលរង្វាន់ជាចន្លោះ ៗ មិនមានទីបំផុត ។ មហាជនម្នាក់ ៗ ក៏ឈរលើគ្រែជាដើម មើលមហោស្រព ។*

*គ្រានោះ ធីតាអ្នកដាំដូងម្នាក់ ឡើងទៅកាន់ក្តាបែន ដាំដូងនៅលើក្តាបែននោះ វាំនិងច្រៀងនៅលើអាកាសទីបំផុតនៃក្តាបែននោះ ។*

សម័យនោះ បុត្តសេដ្ឋីឈ្មោះឧគ្គសេន ឈរនៅលើ គ្រែដែលតម្រូតគ្នាជាមួយនិងសម្ងាញ់ សម្លឹងមើលស្ត្រីនោះ មានសេចក្តីស្រឡាញ់កើតឡើងក្នុងអាការទាំងឡាយ មាន ការគ្រវីដៃគ្រវីជើងជាដើមរបស់នាង ទៅផ្ទះវិញគិតថា កាល យើងបាននាងធ្វើជាប្រពន្ធ ទើបនឹងរស់នៅ, កាលបើយើង មិនបាននាងធ្វើជាប្រពន្ធទេ ក៏នឹងស្លាប់នៅទីនេះឯង លុះគិត ដូច្នេះហើយ ក៏ដេកអត់អាហារនៅលើគ្រែ, កាលមាតាបិតា សួរថា "នែកូនសំឡាញ់ កូនឯងកើតរោគអ្វី ?" ក៏ប្រាប់ថា "កាលខ្ញុំបានកូនស្រីរបស់អ្នករបាំនោះ ក៏នឹងមានជីវិត, កាល ខ្ញុំមិនបាន ក៏នឹងស្លាប់នៅទីនេះឯង" សូម្បីមាតាលួងលោម ថា "នែកូនសំឡាញ់ កូនឯងកុំធ្វើយ៉ាងនេះឡើយ, មាតា និងបិតានឹងនាំកុមារិកាដទៃ ដែលសមគួរដល់ត្រកូលនិង ភោគៈរបស់ពួកយើង មកឲ្យកូនឯង" ក៏នៅដេកពោល យ៉ាងនោះដដែល ។

## ឧគ្គសេនបានស្រីរបាំដូចបំណង

គ្រានោះបិតារបស់ឧគ្គសេន អង្វរឧគ្គសេនយ៉ាងច្រើន កាលមិនអាចញ៉ាំងឧគ្គសេនឲ្យយល់ព្រមបាន ក៏ហៅអ្នករបាំនោះមក ឲ្យទ្រព្យមួយពាន់កហាបណហើយបញ្ជូនទៅដោយពាក្យថា "អ្នកដ៏ចំរើន អ្នកឯងចូរទទួលយកកហាបណៈទាំងនេះហើយ ឲ្យកូនស្រីរបស់អ្នកឯងមកកូនប្រុសរបស់ខ្ញុំចុះ" ។

អ្នករបាំនោះពោលថា "ខ្ញុំទទួលយកកហាបណៈរបស់លោកហើយក៏ឲ្យមិនបាន, ប្រសិនបើបុត្ររបស់លោកនោះ មិនបានកូនស្រីរបស់ខ្ញុំហើយ មិនអាចនឹងរស់នៅបាន, បើដូច្នោះ ឲ្យកូនប្រុសរបស់លោកត្រាច់ទៅជាមួយនិងពួកខ្ញុំចុះ, ខ្ញុំនឹងឲ្យកូនស្រីរបស់ខ្ញុំដល់បុត្ររបស់លោក" មាតាបិតាប្រាប់សេចក្ដីនោះដល់ឧគ្គសេន ។ ឧគ្គសេននិយាយថា "ខ្ញុំនឹងត្រាច់ទៅជាមួយនិងពួកអ្នករបាំនោះ" លុះពោលដូច្នោះហើយ ក៏ចេញទៅកាន់សំណាក់ពួក

អ្នកបៅ ដោយមិនបានអើពើនឹងពាក្យអង្វររបស់មាតាបិតា ឡើយ ។

អ្នកបៅនោះ ឲ្យកូនស្រីដល់ឧគ្គសេនហើយ ដើរសម្តែងសិល្បៈក្នុងស្រុកនិគម និងរាជធានីជាមួយនឹងឧគ្គសេន ។

ចំណែកនាងនោះ អាស្រ័យការនៅរួមជាមួយនឹងបុត្តសេដ្ឋីនោះ មិនយូរប៉ុន្មានក៏បានបុត្ត ពេលបំពេបុត្តនោះ ក៏បំពេដោយពាក្យថា "នែកូនអ្នកចាំរទេះ, កូនអ្នករែករបស់, កូនអ្នកមិនចេះអ្វី ៗ " ។

ចំណែកបុត្តសេដ្ឋីនោះ ជញ្ជូនស្មៅមកឲ្យគោទាំងឡាយ, ( នឹង ) លើកយករបស់របរដែលបានក្នុងទីសម្តែងសិល្បៈហើយនាំទៅ, បានឮថា ស្ត្រីនោះសំដៅយកបុត្តសេដ្ឋីនោះឯង ពេលបំពេកូន ទើបពោលយ៉ាងនោះ, បុត្តសេដ្ឋីនោះដឹងថានាងច្រៀងបំពេកូនប្រារព្ធខ្លួន ក៏សួរថា "នាងនិយាយសំដៅដល់ខ្ញុំឬ ?"

ភរិយា. ចា៎ ខ្ញុំនិយាយសំដៅដល់លោក ។

បុត្តសេដ្ឋី. បើដូច្នោះ ខ្ញុំនឹងចៀសចេញទៅ ។

នាងពោលថា "នឹងប្រយោជន៍អ្វីដល់ខ្ញុំ ដោយការដែលលោកទៅ ឬមកនោះ" ដូច្នេះហើយ ក៏ច្រៀងបទនោះរឿយ ៗ ។

បុត្តសេដ្ឋីនោះ គិតថា "នាងនេះ មានការប្រកាន់ខ្លួនដូច្នេះ ព្រោះអាស្រ័យអ្វីហ្ន៎ ?" ដឹងថា "ព្រោះអាស្រ័យសិល្បៈ" ហើយក៏ចូលទៅរកឪពុកក្មេក រៀនសិល្បៈដែលជាចំណេះដឹងរបស់ឪពុកក្មេកនោះ សម្តែងសិល្បៈក្នុងស្រុកនិគមជាដើម មកដល់ក្រុងរាជគ្រឹះដោយលំដាប់ ឲ្យគេដើរប្រកាសថា "ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ បុត្តសេដ្ឋីឈ្មោះឧគ្គសេនទឹងសម្តែងសិល្បៈជូនអ្នកនគរ" ។

## ឧគ្គសេនសម្តែងសិល្បៈ

អ្នកនគរចងគ្រែតម្រួតគ្នាជាដើមហើយ ប្រជុំគ្នាក្នុងថ្ងៃទី ៧ ។

ចំណែកឧគ្គសេន បានឡើងទៅកាន់ឈើបែនកំពស់ ៦០ ហត្ថ ឈរនៅលើចុងឈើបែននោះ ។

ក្នុងថ្ងៃនោះ ព្រះសាស្ដាទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញឧគ្គសេននោះ ចូលទៅក្នុងសំណាញ់គឺព្រះញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាមើលថា "ហេតុអ្វីហ្ន៎ ? នឹងមាន" ទ្រង់ជ្រាបថា "ថ្ងៃស្អែកនេះបុត្តសេដ្ឋីនឹងឈរនៅលើចុងឈើបែន ដោយគិតថា នឹងសម្ដែងសិល្បៈ មហាជននឹងប្រជុំគ្នាដើម្បីមើលគេ, តថាគតនឹងសម្ដែងគាថាប្រកបដោយបទ ៤ ក្នុងសមាគមនោះ, ការសម្រេចធម៌នឹងមានដល់សត្វ ៨៤០០០ ព្រោះស្ដាប់ធម៌នោះ, សូម្បីឧគ្គសេនក៏នឹងតាំងនៅក្នុងព្រះអរហត្តផលដែរ" ។

ថ្ងៃស្អែកឡើង ព្រះអង្គទ្រង់កំណត់វេលាហើយ មានភិក្ខុសង្ឃចោមរោម ស្ដេចចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ចំណែកឧគ្គសេន កាលព្រះសាស្ដាមិនទាន់ស្ដេចចូលទៅខាងក្នុងព្រះនគរ ក៏បានឲ្យសញ្ញាដោយម្រាមដៃដល់មហាជន ដើម្បីឲ្យមានភាពឱឡារិក ឈរនៅលើចុងឈើបែនដាំដូងក្នុងអាកាសនោះឯងអស់ ៧ ដង ចុះមកហើយឈរនៅលើចុងឈើបែនទៀត ។

## ឧគ្គសេនសម្ដែងសិល្បៈប្រគេនព្រះមហាមោគ្គល្លាន

គ្រានោះ ព្រះសាស្ដាកំពុងស្ដេចទៅកាន់ព្រះនគរ , ទ្រង់ធ្វើបរិស័ទឲ្យឈប់មើលឧគ្គសេន , ឲ្យសម្លឹងមើលតែព្រះអង្គប៉ុណ្ណោះ ។ ឧគ្គសេនសម្លឹងមើលបរិស័ទហើយ ខូចចិត្តថា " បរិស័ទនឹងមិនមើលយើង " ក៏គិតថា " សិល្បៈនេះយើងគប្បីសម្ដែង ( ប្រចាំ ) ឆ្នាំ , ក៏កាលព្រះសាស្ដាស្ដេចចូលទៅកាន់ព្រះនគរ បរិស័ទមិនមើលយើង មើលតែព្រះសាស្ដាប៉ុណ្ណោះ , ការសម្ដែងសិល្បៈរបស់យើងឥតប្រយោជន៍ហើយហ្ន៎ " ។

ព្រះសាស្ដា ទ្រង់ជ្រាបការគិតរបស់ឧគ្គសេន ទើបត្រាស់ហៅព្រះមហាមោគ្គល្លានមកហើយ ត្រាស់ថា " ម្នាលមោគ្គល្លាន អ្នកចូរទៅ , ចូរនិយាយនឹងបុត្រសេដ្ឋីថា " នែអ្នកដ៏ចម្រើន អ្នកចូរសម្ដែងសិល្បៈចុះ " ។ ព្រះថេរៈទៅឈរខាងក្រោមឈើបែននោះ ហៅបុត្រសេដ្ឋីមកហើយពោលគាថានេះថា

ម្នាលឧគ្គសេនកូនអ្នករបាំដ៏ចម្រើន អ្នកមាន

កម្លាំងច្រើន អញ្ជើញអ្នកមើល ចូរធ្វើសេចក្តី
ត្រេកអរ ចូរញុំាងសេចក្តីរីករាយឲ្យកើតដល់
មហាជនចុះ ។

ឧគ្គសេន បានឮពាក្យរបស់ព្រះថេរៈហើយ ក៏មានចិត្តត្រេកអរថា ព្រះសាស្តាមានព្រះបំណងនឹងមើលសិល្បៈរបស់យើង ” ទើបឈរលើចុងឈើបែន ហើយពោលគាថានេះថា :

**បពិត្រព្រះមោគ្គល្លានដ៏ចម្រើន អ្នកមានបញ្ញាច្រើន មានឫទ្ធិច្រើន សូមលោកម្ចាស់មើលចុះ ខ្ញុំព្រះករុណានឹងញុំាងសេចក្តីរីករាយឲ្យកើតដល់បរិស័ទ នឹងញុំាងមហាជនឲ្យរីករាយ ។**

លុះពោលយ៉ាងនោះហើយ ក៏លោតអំពីចុងឈើបែនឡើងទៅកាន់អាកាស ជាំជួន ១៤ ជុំក្នុងអាកាសហើយ ចុះមកឈរលើចុងឈើបែននោះ ( ដូចដើម ) ។

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ឧគ្គសេនថា “ម្នាលឧគ្គសេន ធម្មតាបណ្ឌិត ត្រូវលះបង់សេចក្តីអាឡោះអាល័យ

សេចក្តីស្រឡាញ់ជាប់ជំពាក់ក្នុងខន្ធទាំងឡាយ ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្នចេញហើយ ផុតចាកទុក្ខទាំងឡាយ មានជាតិជាដើម ទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :

៦. មុញ្ច បុរេ មុញ្ច បច្ឆតោ
មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្វត្ថ វិមុត្តមានសោ
ន បុន ជាតិជរំ ឧបេហិសិ ។

អ្នកចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាលមុនចេញ ចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាលខាងក្រោយចេញ ចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាលជាកណ្តាលចេញ ( កាលធ្វើយ៉ាងនេះ ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិ និងជរាទៀតឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **មុញ្ច បុរេ** សេចក្ដីថា ចូរដោះសេចក្ដីអាល័យ គឺសេចក្ដីត្រេកអរ ការជាប់ជំពាក់ សេចក្ដីប្រាថ្នា ការជ្រមុជ ការប្រកាន់មាំ ការស្ទាបអង្អែលនូវខន្ធទាំងឡាយដែលជាអតីតចេញ ។

បទថា **បច្ឆតោ** សេចក្ដីថា ចូរដោះសេចក្ដីអាល័យជាដើម ក្នុងខន្ធទាំងឡាយដែលជាអនាគតចេញ ។

បទថា **មជ្ឈេ** សេចក្ដីថា ចូរដោះសេចក្ដីអាល័យជាដើម ក្នុងខន្ធទាំងឡាយដែលជាបច្ចុប្បន្នចេញ ។

ពីរបទថា **ភវស្ស បារគូ** សេចក្ដីថា កាលបើអ្នកបដិបត្តិបានយ៉ាងនេះ អ្នកនឹងដល់ត្រើយ គឺទៅកាន់ត្រើយនៃភពសូម្បីទាំង ៣ បាន ដោយអំណាចនៃការកំណត់ដឹង ការលះ ការចម្រើន និងការធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ប្រពៃ មានចិត្តរួចស្រឡះចាកសង្ខារទាំងពួង មានខន្ធ ធាតុ អាយតនៈជាដើម តទៅមិនត្រូវទៅកាន់ជាតិ ជរា និងមរណៈទៀតឡើយ ។

ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌ បានមានដល់សត្វ ៨៤០០០ ។

## ឧគ្គសេនទូលសូមបព្វជ្ជាឧបសម្បទា

ចំណែកបុត្រសេដ្ឋី កំពុងឈរនៅចុងឈើបែននោះ បានសម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទាហើយ ចុះអំពីឈើបែន មកកាន់ទីជិតព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ទូលសូមព្រះសាស្តាបព្វជ្ជា ។ គ្រានោះ ព្រះសាស្តា ទ្រង់លាតព្រះហស្តខាងស្តាំចេញហើយ ត្រាស់ទៅកាន់ឧគ្គសេននោះថា " ម្នាលឧគ្គសេន អ្នកចូរជាភិក្ខុចុះ " ឧគ្គសេនបានជាអ្នកទ្រទ្រង់នូវបរិក្ខារទាំង ៨ ដូចព្រះថេរៈដែលមានវស្សា ៦០ ក្នុងខណៈនោះឯង ។

ក្រោយមក ពួកភិក្ខុសួរព្រះឧគ្គសេនថា " អាវុសោឧគ្គសេន កាលអ្នកចុះអំពីចុងឈើបែន ( កំពស់ ) ៦០ ហត្ថ អាវុសោឯងមិនខ្លាចទេឬ ?" កាលលោកតបថា " "បពិត្រលោកម្ចាស់ដ៏ចំរើន ការខ្លាចរមែងមិនមានដល់ខ្ញុំឡើយ " ។ ទើបក្រាបទូលព្រះសាស្តាថា " បពិត្រព្រះអង្គដ៏ចំរើន ឧគ្គសេចនិយាយថា ខ្ញុំមិនខ្លាច លោកនិយាយពាក្យមិនពិត ពោលអួតគុណវិសេស " ព្រះសាស្តាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកមានសញ្ញោជនៈកាត់បាន

ហើយ ដូចជាឧគ្គសេនបុត្ររបស់តថាគត មិនខ្លាច មិនតក់ស្លុតទេ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះក្នុងព្រាហ្មណវគ្គថា ៖-

បុគ្គលណា កាត់សញ្ញោជនៈទាំងអស់បាន មិនតក់
ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេស
ជាគ្រឿងចំពាក់ អ្នករួចស្រឡះចាកកិលេសថាជា
ព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌បានកើតមានដល់ជនជាច្រើន ។

ស្អែកឡើង ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម៌ថា “ អ្នកមានអាយុទាំងឡាយ ហេតុគឺការអាស្រ័យកូនស្រីអ្នករបាំការត្រាច់ទៅជាមួយនឹងអ្នករបាំរបស់ភិក្ខុ អ្នកដល់ព្រមដោយឧបនិស្ស័យនៃព្រះអរហត្តយ៉ាងនេះ ជាយ៉ាងណាហ្ន៎ ? ហេតុនៃឧបនិស្ស័យព្រះអរហត្តជាយ៉ាងណា ? ”

## ព្រះសាស្ដាត្រាស់ប្រាប់ឧបនិស្ស័យរបស់ព្រះឧគ្គសេន

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី ? ”

កាលភិក្ខុទាំងនោះក្រាបទូលថា “ ដោយរឿងឈ្មោះនេះ ព្រះអង្គ ” ដូច្នេះហើយ ក៏ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ហេតុសួម្បីទាំង ២ នោះ ដែលឧគ្គសេនតែម្នាក់ធ្វើទុកហើយ” កាលនឹងទ្រង់ប្រកាសសេចក្តីនោះឲ្យពិស្តារ ទើបទ្រង់ទាញអតីតនិទានមក ( ត្រាស់ ) ថា :-

“ បានឮថា ក្នុងអតីតកាល កាលសុវណ្ណចេតិយសម្រាប់ព្រះកស្សបទសពល ដែលគេកំពុងកសាង ពួកកុលបុត្រ ដែលនៅក្នុងព្រះនគរពារាណសី ផ្ទុករបស់ទំពាស៊ីរបស់បរិភោគជាច្រើន ក្នុងយានទាំងឡាយ រួចហើយ ធ្វើដំណើរទៅកាន់ចេតិយ ដោយតាំងចិត្តថា “ ពួកយើងនឹងធ្វើហត្ថកម្ម ” ជួបព្រះថេរៈមួយអង្គ ដែលកំពុងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតក្នុងចន្លោះផ្លូវ ។ គ្រានោះ មានកុលធីតាម្នាក់ ក្រឡេកឃើញព្រះថេរៈនោះហើយ ក៏ពោលទៅកាន់ស្វាមីថា “ បពិត្រអ្នកជាម្ចាស់ លោកម្ចាស់របស់ពួកយើងចូលមកដើម្បីបិណ្ឌបាត , ម្យ៉ាងទៀត របស់ទំពាស៊ី និងរបស់បរិភោគរបស់ពួកយើងក្នុងយាន មានជាច្រើន , ដូច្នេះសូមអ្នកជាម្ចាស់ទៅយកបាត្ររបស់លោកម្ចាស់មក , យើង

ទាំងពីរនឹងថ្វាយកិច្ចា ” ។ បុរសដែលជាស្វាមីទៅយកបាត្រ មកតាមពាក្យរបស់ភរិយា , ស្ត្រីដែលជាភរិយាញ៉ាំងបាត្រ នោះឲ្យពេញដោយរបស់ទំពាស៊ី និងរបស់បរិភោគហើយ ឲ្យស្វាមីយកទៅប្រគេនព្រះថេរៈ ទាំងពីរនាក់ធ្វើសេចក្តី ប្រាថ្នាថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាទាំង ពីរនាក់ គប្បីមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញ ហើយផងចុះ ” ។ ព្រះថេរៈនោះជាព្រះខីណាស្រព , ព្រោះ ហេតុនោះ កាលលោកសម្លឹងមើល ក៏បានដឹងថា សេចក្តី ប្រាថ្នារបស់គេទាំងពីរនាក់នោះនឹងសម្រេច ក៏ធ្វើការញញឹម ឲ្យប្រាកដ ។ ស្ត្រីនោះឃើញអាការនោះហើយ ក៏ពោលទៅ កាន់ស្វាមីថា “ បពិត្រអ្នកជាម្ចាស់ លោកម្ចាស់របស់ពួក យើង រមែងធ្វើអាការញញឹម , ប្រហែលជាលោកកូនអ្នក របាំទេដឹង ” ចំណែកស្វាមីរបស់នាងក៏ឆ្លើយតបថា “ ម្នាល នាងដ៏ចម្រើន ប្រហែលជាយ៉ាងនោះពិតមែនហើយ ” ដូច្នេះ ហើយ ក៏ចៀសចេញទៅ ។ នេះជាបុព្វកម្មរបស់គេទាំងពីរ នាក់នោះ ។

ស្វាមីភរិយាទាំងពីរនោក់នោះ តាំងនៅក្នុងអត្តភាពនោះហើយ ក្រោយអំពីចុតិ ក៏បដិសន្ធិក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ , ស្ត្រីដែលជាភរិយាកើតក្នុងត្រកូលអ្នករបាំ ចំណែកបុរសដែលជាស្វាមី កើតក្នុងត្រកូលសេដ្ឋី ។ ព្រះឧគ្គសេននោះ ព្រោះឆ្លើយតបនឹងពាក្យរបស់ភរិយាថា " ម្នាលនាងដ៏ចម្រើន ប្រហែលជាយ៉ាងនោះពិតមែនហើយ " ទើបត្រូវត្រាច់ទៅជាមួយនឹងពួកអ្នករបាំ , អាស្រ័យបិណ្ឌបាតដែលប្រគេនចំពោះព្រះថេរៈអ្នកជាខីណាស្រព ទើបបានសម្រេចព្រះអរហត្ត ។

ចំណែកធីតារបស់អ្នករបាំនោះ គិតថា " អំពើណាជាគតិនៃស្វាមីរបស់យើង , អំពើនុ៎ះ ក៏ជាគតិរបស់យើងដែរ " ដូច្នេះហើយ បព្វជ្ជាក្នុងសម្នាក់ភិក្ខុនីទាំងឡាយហើយ តាំងនៅក្នុងព្រះអរហត្ត ។

( រឿងបុត្រសេដ្ឋីឈ្មោះឧគ្គសេន ចប់ )

## ៧ រឿងចូឡធនុគ្គហបណ្ឌិត

## សេចក្តីខាងដើម

ព្រះសាស្តា គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកម្នាក់មួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **វិតក្កមថិតស្ស** ” ជាដើម ។

# ភិក្ខុកំលោះស្រឡាញ់ស្ត្រីក្រមុំ

បានឮថា ភិក្ខុកំលោះមួយរូប ចាប់សលាកដើម្បីខ្ទួនក្នុងរោងសលាក ។ កាន់យកបបរតាមសលាកទៅកាន់រោងឆាន់ ដើម្បីឆាន់ ។ ភិក្ខុកំលោះនោះ មិនបានទឹកក្នុងរោងឆាន់នោះ ក៏បានទៅកាន់ផ្ទះមួយដើម្បីត្រូវការទឹក , កុមារីម្នាក់ក្នុងផ្ទះនោះ គ្រាន់តែឃើញភិក្ខុកំលោះនោះភ្លាម ក៏កើតសេចក្តីស្រឡាញ់ ហើយពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើលោកម្ចាស់ត្រូវការទឹកទៀត សូមលោកម្ចាស់និមន្តមកផ្ទះនេះទៀតចុះ ” ។

ចាប់តាំងពីពេលនោះមក ភិក្ខុកំលោះនោះ មិនបានទឹកក្នុងកាលណា ក៏ទៅកាន់ផ្ទះនោះក្នុងកាលនោះ ។

ចំណែកស្ត្រីនោះ ទទួលបាត្ររបស់ភិក្ខុនោះហើយប្រគេនទឹកឆាន់ ។ ពេលវេលាកន្លងទៅដោយអាការយ៉ាង

នោះ ថ្ងៃមួយ នាងប្រគេនបបរ ហើយនិមន្តភិក្ខុកំលោះនោះ ឲ្យគង់ក្នុងផ្ទះ ហើយប្រគេនកត្តទៀត ។ នាងអង្គុយជិតភិក្ខុកំលោះនោះ ហើយពោលឡើងថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងផ្ទះនេះ អ្វីៗ ដែលឈ្មោះថា មិនមាន រមែងមិនមាន , ខ្ញុំតែអ្នកមើលការខុសត្រូវប៉ុណ្ណោះ ” ។

ភិក្ខុនោះស្តាប់ពាក្យរបស់ស្ត្រីនោះហើយ កន្លងទៅបាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏កើតការអផ្សុកឡើង ។

## ភិក្ខុកំលោះត្រូវនាំទៅគាល់ព្រះសាស្តា

គ្រានោះ អាគន្តុកភិក្ខុទាំងឡាយ ឃើញភិក្ខុនោះហើយ ក៏សួរថា “ ម្នាលអាវុសោ ហេតុអ្វី ទើបអ្នកកើតរោគលឿង ?” កាលភិក្ខុនោះឆ្លើយតបថា “ ម្នាលអាវុសោទាំង-ឡាយ ខ្ញុំកើតការអផ្សុក ” ទើបនាំភិក្ខុនោះ ទៅកាន់សម្នាក់អាចារ្យ និងឧបជ្ឈាយ៍ ។ អាចារ្យ និងឧបជ្ឈាយ៍ក៏នាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តា ហើយក្រាបទូលរឿងនោះ ។

## ព្រះសាស្តាទ្រង់សម្តែងបុព្វកម្មរបស់ភិក្ខុកំលោះនោះ

ព្រះសាស្ដា ត្រាស់សួរថា “ ម្នាលភិក្ខុ អ្នកអផ្សុកពិតមែនឬ ?” កាលភិក្ខុនោះទូលថា “ ព្រះករុណា ព្រះអង្គ ” ក៏ទ្រង់ត្រាស់ថា “ ម្នាលភិក្ខុ ហេតុអ្វី ? អ្នកបួសក្នុងសម្នាក់ព្រះពុទ្ធ អ្នកប្រារព្ធសេចក្ដីព្យាយាមដូចជាតថាគត មិនឲ្យគេហៅខ្លួនថា ព្រះសោតាបន្ន ឬព្រះសកទាគាមី ត្រឡប់ឲ្យគេហៅថា អ្នកអផ្សុកទៅវិញ , អ្នកបានធ្វើកម្មដ៏ធ្ងន់ហើយ ” ទើបទ្រង់សាកសួរថា “ ព្រោះហេតុអ្វី ទើបអ្នកអផ្សុក ? ” កាលភិក្ខុនោះក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន ស្ត្រីម្នាក់និយាយទីងខ្ញុំព្រះអង្គយ៉ាងនេះ ” ទើបត្រាស់ថា “ ម្នាលភិក្ខុ កិរិយារបស់ស្ត្រីនោះ មិនគួរអស្ចារ្យទេ ព្រោះក្នុងកាលមុន នាងលះបង់បណ្ឌិតដ៏ថ្មើមក្នុងជម្ពូទ្វីបទាំងអស់ ហើយញ៉ាំងសេចក្ដីស្នេហាឲ្យកើតឡើងចំពោះចោរម្នាក់ ដែលខ្លួនទើបតែឃើញប៉ុណ្ណោះ ញ៉ាំងបណ្ឌិតដ៏ថ្មើមនោះឲ្យអស់ជីវិត” កាលភិក្ខុទាំងឡាយអារាធនា ដើម្បីឲ្យទ្រង់ប្រកាសរឿងនោះ ក៏ទ្រង់ធ្វើឲ្យជាក់ច្បាស់ នូវការដែលចូឡធនុគ្គហបណ្ឌិតរៀនសិល្បៈក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ក្នុងក្រុងតកសិលា

នាំធីតាដែលអាចារ្យនោះឲ្យហើយ ទៅកាន់ក្រុងពារាណសី កាលខ្លួនសម្លាប់ចោរអស់ ៤៩ នាក់ ដោយកូនសរ ៤៩ ក្បែរមាត់ព្រៃមួយ , កាលកូនសរអស់ ក៏ចាប់មេចោរផ្តួលទៅលើផែនដី ហើយពោលថា " ម្នាលនាងដ៏ចម្រើន នាងចូរនាំដាវមក " , នាង ( ត្រឡប់ ) ញុំាងសេចក្តីស្នេហាឲ្យកើតឡើងចំពោះចោរដែលខ្លួនឃើញក្នុងខណៈនោះ ហើយហុចដងដាវទៅចោរ ឲ្យចោរសម្លាប់ហើយក្នុងកាលជាចូឡធនុគ្គហបណ្ឌិតក្នុងអតីតកាល ហើយការដែលចោរនាំស្ត្រីនោះទៅបណ្តើរគិតបណ្តើរថា ស្ត្រីនេះ ឃើញបុរសដទៃហើយ នឹងឲ្យបុរសនោះសម្លាប់យើង ដូចស្វាមីរបស់នាងដូច្នោះដែរ , យើងមិនត្រូវការស្ត្រីនេះទេ " ឃើញស្ទឹងមួយ ក៏ទុកស្ត្រីនោះនៅត្រើយខាងអាយ កាន់យកបង្វិចទ្រព្យរបស់ស្ត្រីនោះទៅ ដោយផ្តាំថា " ម្នាលនាងដ៏ចម្រើន នាងចូររង់ចាំខ្ញុំនៅទីនេះសិន ខ្ញុំនឹងនាំយកបង្វិចទ្រព្យឆ្លងទៅមុន រួចហើយ នឹងត្រឡប់មកយកនាងជាខាងក្រោយ " លះបង់ស្ត្រីនោះនៅទីនោះឯង ( ចៀស )

បេញទៅ ហើយត្រាស់បូទ្បជនុគ្គហជាតកនេះ ក្នុងបញ្ចកនិបាត ឲ្យពិស្តារថា :-

( ស្ត្រីនោះនិយាយថា ) ម្នាលព្រាហ្មណ៍ អ្នក
នាំយកទ្រព្យទាំងអស់ ធ្វូងទៅកាន់ត្រើយនាយ
ម្នាលអ្នកដ៏ចម្រើន អ្នកចូរត្រឡប់មកវិញ យ៉ាង
ឆាប់រួសរាន់ សូមអ្នកចម្លងខ្ញុំ ឧឡូវនេះ ។
( ចោរនិយាយថា ) នាងផ្លាស់ប្តូរយកអញ អ្នក
ស្និទ្ធស្នាល ដោយប្តីដែលស្និទ្ធស្នាល អស់កាល
យូរ ផ្លាស់ប្តូរយកអញ ដែលមិនមែនជាប្តីទៀង
ទាត់ ដោយប្តីទៀងទាត់ នាងនឹងផ្លាស់ប្តូរយក
ប្រុសឯទៀត នឹងអញមិនខាន អញនឹងទៅកាន់
ទីឆ្ងាយជាងទីនេះ ។
( ចចកនិយាយថា ) ស្ត្រីនេះជាអ្វី ទើបធ្វើនូវ
សំណើចយ៉ាងខ្លាំង ទៀបគុម្ពព្រៃទឹក ការរាំក្តី
ច្រៀងក្តី ប្រគំក្តី ដែលគេតាំងទុកដោយល្អ ក្នុង
ទីនេះ មិនមានទេ ម្នាលស្ត្រី មានត្រគាកល្អ

មានរូបល្អ ហេតុដូចម្តេច ទើបនាងសើចក្អាកក្អាយ ក្នុងកាលគួរយំ ។

( នាងនោះនិយាយថា ) ម្នាលចចក ជម្ពូកៈពាលឥតប្រាជ្ញា ឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រី និងដុំសាច់ សញ្ជប់សញ្ជឹងដូចសត្វកំព្រា ។

( ចចកនិយាយថា ) ទោសរបស់ជនទាំងឡាយឯទៀត ឃើញបានដោយងាយ ចំណែកនាង ទោសរបស់ខ្លួន ឃើញបានដោយក្រលាស់ នាងឯងជាស្ត្រីសាបសូន្យចាកប្តី និងសាហាយ សញ្ជប់សញ្ជឹង ជាងអញទៅទៀត ។

( នាងនោះនិយាយថា ) ម្នាលស្តេចម្រឹគ ជម្ពូកៈអ្នកនិយាយយ៉ាងណា ពាក្យនុ៎ះ យ៉ាងហ្នឹងហើយខ្ញុំនោះ ទៅអំពីទីនេះ នឹងលុះអំណាចប្តី ដោយពិត។

( សក្កទេវរាជពោលថា ) អ្នកណា ហ៊ានលួចភាជន៍ដី អ្នកនោះ គង់ហ៊ានលួចភាជន៍សម្រិទ្ធ

ទៀត បាបដែលនាងបានធ្វើរួចហើយ នាងនឹងធ្វើយ៉ាងនេះទៀត មិនលែងឡើយ ។

ហើយត្រាស់ថា " ចូឡធនុគ្គហបណ្ឌិតក្នុងកាលនោះ បានមកជាអ្នក , ស្ត្រីនោះ បានមកជាកុមារិកាក្នុងឥឡូវនេះ , សក្កទេវរាជ ដែលមកដោយរូបជាចចក ធ្វើការផ្ចាញ់ផ្ចាល ស្ត្រីនោះ គឺតថាគតនេះឯង " ហើយទ្រង់ឱវាទភិក្ខុនោះថា " ម្នាលភិក្ខុ ស្ត្រីនោះផ្តាច់ផ្តិលជីវិតបណ្ឌិតដ៏ធ្វើមក្នុងជម្ពូទ្វីបទាំងមូល ដោយសារសេចក្តីស្នេហាចំពោះចោរម្នាក់ ដែលខ្លួនឃើញហើយ ក្នុងកាលមួយរំពេចប៉ុណ្ណោះ ដោយអាការយ៉ាងនេះ , ម្នាលភិក្ខុ អ្នកចូរកាត់តណ្ហារបស់អ្នក ដែលប្រារព្ធស្ត្រីនោះកើតឡើងចោលចេញ " ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា :-

**៧ វិតក្កមថិតស្ស ជន្តុនោ**
**តិព្វរាគស្ស សុភានុបស្សិនោ**
**ភិយ្យោ តណ្ហា បវឌ្ឍតិ**

ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ ។
វិតក្កូបសមេ ច យោ រតោ
អសុភំ ភាវយតី សទា សតោ
ឯស ខោ វ្យន្តិកាហតិ
ឯសច្ឆេច្ឆតិ មារពន្ធនំ ។

តណ្ហា រមែងចម្រើនក្រៃលែង ដល់ជនដែលវិតក្កញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថា ធ្វើចំណងឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់នូវវិតក្កមានស្មារតីសព្វកាល តែចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **វិតក្កមថិតស្ស** បានដល់អ្នកត្រូវវិតក្ក ៣ យ៉ាង មានកាមវិតក្កជាដើម ញាំញីហើយ ។

បទថា **តិព្វរាគស្ស** គឺអ្នកមានរាគៈដ៏ក្រាស់ ។

បទថា **សុភានុបស្សិនោ** សេចក្ដីថា ដែលឈ្មោះថា អ្នកតាមឃើញអារម្មណ៍ថា “ ល្អ ” ព្រោះជាអ្នកមានចិត្ត ដែលខ្វល់ខ្វាយទៅកាន់អារម្មណ៍ ដែលគួរប្រាថ្នាទាំងឡាយ ដោយអំណាចនៃកិលេស មានការកាន់យកនូវសុភនិមិត្តជា ដើម ។

បទថា **តណ្ហា** ជាដើម សេចក្ដីថា បណ្ដាគុណជាតិ ទាំងឡាយ មានឈានជាដើម សូម្បីតែឈានមួយ រមែងមិន ចម្រើនដល់បុគ្គលបែបនោះ ។ ដោយពិត តណ្ហាដែលកើត ឡើងតាមទ្វារទាំង ៦ ប៉ុណ្ណោះ រមែងចម្រើនឡើងរឿយៗ ។

បទថា **ឯស ខោ** សេចក្ដីថា បុគ្គលនោះ រមែងធ្វើ ចំណង គឺតណ្ហាឲ្យមាំ ។

បទថា **វិតក្កូបសមេ** សេចក្ដីថា បណ្ដាអសុភទាំង ១០ ក្នុងបឋមជ្ឈាន ពោលគឺ ធម៌ជាគ្រឿងរម្ងាប់មិច្ឆាវិតក្កទាំង- ឡាយ ។

ពីរបទថា **សហា សតោ** សេចក្តីថា ភិក្ខុណាជាអ្នកត្រេកអរក្រៃលែងក្នុងឈាននោះ ឈ្មោះថា ជាអ្នកមានសតិ ព្រោះជាអ្នកមានសតិចូលទៅតាំងទុកហើយ អស់កាលជានិច្ចចម្រើនអសុភឈាននោះ ។

បទថា **ព្យន្តិកាហតិ** សេចក្តីថា ភិក្ខុនោះ នឹងធ្វើតណ្ហាដែលញុំាំងសត្វឲ្យកើតក្នុងភព ៣ ឲ្យទៅប្រាសបាន ។

បទថា **មារពន្ធនំ** សេចក្តីថា ភិក្ខុនោះនឹងកាត់ចំណងរបស់មារ ពោលគឺវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិបីបាន ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។

ទេសនាបានជាគុណជាតិមានប្រយោជន៍ សូម្បីដល់បុគ្គលអ្នកប្រជុំគ្នាហើយ ។

( រឿងចូឡធនុគ្គហបណ្ឌិត ចប់ )

# ៨ រឿងមារ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះទេសនានេះថា “ **និដ្ឋំ គតោ** ” ជាដើម ។

បានឮថា នៅថ្ងៃក្នុងវេលាវិកាល ព្រះថេរជាច្រើនចូលទៅកាន់វត្តជេតពនមហាវិហារ លុះទៅដល់លំនៅរបស់ព្រះរាហុលហើយ ក៏ដាស់លោកឲ្យក្រោកឡើង, ព្រះរាហុលនោះ កាលមិនមានទីដទៃដែលខ្លួនគប្បីសឹង ក៏ទៅសឹងខាងមុខព្រះគន្ធកុដិរបស់ព្រះតថាគត ។ ពេលនោះ លោកអ្នកដ៏មានអាយុរូបនោះបានសម្រេចព្រះអរហត្តហើយ ប៉ុន្តែមិនទាន់មានវស្សានៅឡើយ ។

គ្រានោះ មារដែលឋិតនៅក្នុងកពណ្ឌឈ្មោះវសវត្តី ឃើញព្រះរាហុលសឹងនៅខាងមុខព្រះគន្ធកុដិ ក៏គិតថា "ព្រះពន្ធកតូចអ្នកចាក់ដោតព្រះសមណគោតម សឹងឰដ៏ខាងក្រៅចំណែកព្រះអង្គទ្រង់ផ្ទុំឰដ៏ខាងក្នុងព្រះគន្ធកុដិ, កាលអញបៀតបៀនព្រះរាហុល ក៏ដូចជាបៀតបៀនផ្ចាញ់ផ្ចាលព្រះសមណគោតមដែរ" មារនោះនិម្មិតភេទជាស្តេចដំរីមក យកប្រមោយរួបរឹតព្រះសិរព្រះថេរហើយ ស្រែកនូវសម្រែកដូចជាសម្រែកសត្វក្រៀលដោយសម្លេងដ៏ខ្លាំង ។

## ព្រះសាស្តាទ្រង់សម្តែងហេតុដែលព្រះរាហុលមិនខ្លាច

ព្រះសាស្តា ទ្រង់ផ្ទុំឰដ៏ខាងក្នុងព្រះគន្ធកុដិ ទ្រង់ជ្រាបថាដំរីនោះជាមារ ទើបត្រាស់ថា " ម្នាលមារ មនុស្សដូចជាអ្នកនោះ សូម្បីទាំងសែនអ្នក ក៏មិនអាចនឹងញុំាងការភ័យខ្លាចឲ្យកើតឡើងដល់បុត្តរបស់តថាគតបានដែរ, ព្រោះថាបុត្តរបស់តថាគតមានប្រក្រតីមិនតក់ស្លុត មិនខ្លាច មានតណ្ហាទៅប្រាសហើយ មានសេចក្តីព្យាយាមធំ មានបញ្ញាច្រើន" ដូច្នេះហើយ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៨ ទិដ្ឋន្តគោ អសន្តាសី វីតតណ្ហោ អនង្គណោ
អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ
អក្ខរានំ សន្និបាតំ ជញ្ញាបុញ្ញបរានិ ច
ស វេ អន្តិមសរីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

បុគ្គលណាដល់សេចក្ដីសម្រេច គឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេស ដូចទីទួល បានកាត់កូនសរ គឺកិលេស ជាហេតុញុំាងសត្វឲ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយនេះ របស់បុគ្គលនោះ ឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្ដីប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ ( វាចាជាគ្រឿងសម្ដែងចេញ ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើម និងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគត

ហៅថា អ្នកមានសរីរៈស្ថិតនៅក្នុងទីបំផុត មាន
បញ្ញាច្រើន ជាមហាបុរស ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **និដ្ឋំ គតោ** សេចក្ដីថា ព្រះអរហត្តឈ្មោះថា សេចក្ដីសម្រេចរបស់បព្វជិតទាំង-ឡាយ ក្នុងព្រះគាថានេះ, ដល់ គឺសម្រេចព្រះអរហត្តនោះ ។

បទថា **អសន្តាសី** គឺអ្នកដែលមិនតក់ស្លុត ព្រោះមិនមានកិលេសជាគ្រឿងតក់ស្លុត មានរាគៈជាដើមព្វដ៏ខាងក្នុង។

បាទព្រះគាថាថា **អច្ឆិន្ទិ ភវសល្លានិ** គឺបានកាត់កូនសរគឺកិលេស ជាហេតុញាំងសត្វឲ្យទៅកាន់ភពបានហើយ។

បទថា **សមុស្សយោ** គឺកាយនេះ របស់អ្នកនោះមាននៅក្នុងទីបំផុត ។

បទថា **អនាទានោ** គឺអ្នកមិនមានការប្រកាន់មាំក្នុងខន្ធជាដើម ។

បាទព្រះគាថាថា **និរុត្តិបទកោវិទោ** សេចក្ដីថា ជាអ្នកឈ្លាស ក្នុងបដិសម្ភិទាសូម្បីទាំង ៤ គឺក្នុងនិរុត្តិ (វាចាជាគ្រឿងសម្ដែងចេញ ) និងបទដ៏សេស ។

ពីរបាទព្រះគាថាថា **អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច** សេចក្ដីថា រមែងដឹងច្បាស់នូវពួកនៃអក្ខរៈ ពោលគឺប្រជុំនៃអក្ខរៈទាំងឡាយផង ដឹងនូវខាងដើមនិងខាងចុង នៃអក្ខរៈទាំងឡាយផង ។ ឈ្មោះថា ដឹងខាងចុងនៃអក្ខរដោយអក្ខរខាងដើម គឺកាលខាងដើមប្រាកដ ក្នុងកណ្ដាលនិងទីបំផុត សូម្បីមិនប្រាកដ, ក៏រមែងដឹងបានថា "នេះជាកណ្ដាលនៃអក្ខរ, នេះជាទីបំផុត" ឈ្មោះថា រមែងដឹងអក្ខរខាងដើមដោយអក្ខរខាងចុង គឺកាលទីបំផុតប្រាកដ កាលខាងដើមនិងកណ្ដាលសូម្បីមិនប្រាកដ, ក៏រមែងដឹងបានថា "នេះជាកណ្ដាលនៃអក្ខរទាំងនេះ, នេះជាខាងដើម" កាលកណ្ដាលប្រាកដ កាលខាងដើមនិងទីបំផុតសូម្បីមិនប្រាកដ, ក៏រមែងដឹងបានថា "នេះជាខាងដើមនៃអក្ខរទាំងនេះ, នេះជាទីបំផុតនៃអក្ខរ" ។

បទថា **មហាបញ្ញោ** សេចក្តីថា អ្នកមានសរីរៈឋិតនៅក្នុងទីបំផុតនោះ ព្រះសាស្តាត្រាស់ហៅថា អ្នកមានបញ្ញាច្រើន ព្រោះជាអ្នកប្រកបដោយបញ្ញាដែលកំណត់កាន់យកនូវអត្ថ ធម៌ និរុត្តិ និងបដិភាណ និងសីលក្ខន្ធជាដើមដ៏ធំ ហើយត្រាស់ហៅថាជាមហាបុរស ព្រោះជាអ្នកមានចិត្តផុតស្រឡះហើយ ដោយព្រះបាលីថា "ម្នាលសារីបុត្ត តថាគតហៅអ្នកដែលមានចិត្តផុតស្រឡះហើយនោះថា "មហាបុរស"

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចំណែកមារមានចិត្តបាបគិតថា "ព្រះសមណគោតមស្គាល់យើងហើយ" ក៏អន្តរធានទៅក្នុងទីនោះឯង ។

រឿងមារ ចប់

# ៩ រឿងឧបកាជីវក

## សេចក្ដីខាងដើម

ព្រះសាស្ដា ទ្រង់ប្រារព្ធឧបកាជីវក ក្នុងចន្លោះផ្លូវ ត្រាស់ព្រះធម្មទេសនានេះថា “**សព្វាភិភូ**” ជាដើម ។

## ឧបកាជីកាវកទូលសួរព្រះសាស្ដា

បានឮថា សម័យមួយ ព្រះសាស្ដាទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ទ្រង់ញ៉ាំងកាលឲ្យកន្លងទៅក្រោម

មណ្ឌលពោធិព្រឹក្សអស់ ៧ សប្តាហ៍ ទ្រង់កាន់បាត្រនិងចីវរ របស់ព្រះអង្គ ស្តេចដំណើរទៅអស់ចម្ងាយផ្លូវប្រមាណ ១៨ យោជន៍សំដៅទៅកាន់ក្រុងពារាណសី ដើម្បីទ្រង់ញ៉ាំងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ទតឃើញអាជីវកឈ្មោះឧបកៈ ក្នុងចន្លោះផ្លូវ ។

ចំណែកឧបកាជីវកនោះ ឃើញព្រះសាស្តាហើយ ទូលសួរថា "អ្នកមានអាយុ ឥន្ទ្រីយ៍របស់អ្នកផូរផង់, ពណ៌សម្បុរក៏បរិសុទ្ធផូរផង់ , អ្នកមានអាយុ អ្នកបួសចំពោះអ្នកណា ? អ្នកណាជាសស្តារបស់អ្នក ? ឬអ្នកពេញចិត្តធម៌របស់អ្នកណា ?" ។

## ព្រះសាស្តាត្រាស់តបឧបកាជីវក

គ្រានោះ ព្រះសាស្តាត្រាស់ថា "តថាគតមិនមានឧបជ្ឈាយ៍ឬអាចារ្យទេ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះដល់ឧបកាជីវកនោះថា ៖-

**៩ សព្វាភិភូ សព្វវិទូហមស្មិ**
**សព្វេសុ ធម្មេសុ អនូបលិត្តោ**

សព្វញ្ញុហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

តថាគត ជាអ្នកសង្កត់គ្របសង្កត់តេភូមិកធម៌ទាំងអស់ ដឹងច្បាស់ចតុភ្ញូមិកធម៌ទាំងអស់ មានចិត្តមិនបាន ជាប់នៅ ក្នុងតេមិកធម៌ទាំងអស់ លះបង់តេភូមិក-ធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគតត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សព្វាភិភូ** គឺគ្របសង្កត់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់បាន ។

បទថា **សព្វវិទូ** គឺដឹងច្បាស់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ។

ពីរបទថា **សព្វេសុ ធម្មេសុ** សេចក្ដីថា អ្នកដែលតណ្ហា និងទិដ្ឋិទាំងឡាយលាបមិនបាន ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ សូម្បីទាំងអស់ ។

បទថា **សព្វញ្ញុហោ** គឺអ្នកលះបង់ធម៌ដែលប្រព្រឹត្ត ទៅក្នុងភូមិ ៣ ទាំងអស់បាន ។

ពីរបទថា **តណ្ហក្ខយេ វិមុត្តោ** គឺអ្នកមានចិត្តរួចស្រឡះ ហើយ ព្រោះព្រះអរហត្តពោលគឺធម៌ជាទីអស់ទៅនៃតណ្ហា ដែលខ្លួនឲ្យកើតឡើងហើយ ក្នុងទីបំផុតនៃការអស់ទៅនៃ តណ្ហា ដោយវិមុត្តិដែលជារបស់ព្រះអសេក្ខៈ ។

ពីរបទថា **សយំ អភិញ្ញាយ** គឺដឹងធម៌ទាំងឡាយ មានអភិញ្ញេយ្យធម៌ជាដើម ដោយខ្លួនឯងហើយ ។

បទថា **កមុទ្ទិសេយ្យំ** សេចក្ដីថា តថាគតចាំបាច់យក អ្នកណាជាគ្រូអាចារ្យទៀត ។

ក្នុងកាលចប់ទេសនា ឧបកាជីវក មិនត្រេកអរ មិន ជំទាស់នឹងព្រះតម្រាស់របស់ព្រះតថាគតឡើយ , គ្រាន់តែ ងក់ក្បាល លៀនអណ្ដាត ហើយកាន់យកផ្លូវដែលបុគ្គល គប្បីដើរទៅដោយជើង បានទៅកាន់ទីលំនៅរបស់ព្រាហ្មណ៍ មួយ ។

( រឿងឧបកាជីវក ចប់ )

8888888888888888

# ១០ រឿងសក្កទេវរាជ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ សក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា " **សព្វទានំ** " ដូច្នេះជាដើម ។

## បញ្ហា ៤ ប្រការរបស់ទេវតា

សេចក្ដីពិស្ដារថា សម័យមួយ ទេវតាក្នុងជាន់តាវត្តិង្ស ប្រជុំគ្នាហើយ ញ៉ាំងបញ្ហា ៤ ប្រការឡើងថា “ បណ្ដាទាន ទាំងឡាយ ទានប្រភេទណាហ្ន៎ ទើបបណ្ឌិតពោលថា ឈ្នះ អស់ទានទាំងពួង , រសប្រភេទណាហ្ន៎ ទើបបណ្ឌិតពោលថា ជារសដ៏ប្រសើរ , បណ្ដាសេចក្ដីត្រេកអរទាំងឡាយ សេចក្ដី ត្រេកអរប្រភេទណាហ្ន៎ ទើបបណ្ឌិតពោលថា ជាសេចក្ដី ត្រេកអរដ៏លើស , ព្រោះហេតុអ្វី ទើបបណ្ឌិតពោលថា ការ អស់ទៅនៃតណ្ហាប្រសើរជាទីបំផុត ? ទេវតាទាំងអស់ សូម្បី តែមួយអង្គ ក៏មិនអាចនឹងដោះស្រាយបញ្ហាទាំងនោះបាន ។ ទេវតាមួយអង្គ សួរទេវតាមួយអង្គទៀត , សូម្បីទេវតាអង្គ នោះ ក៏សួរទេវតាអង្គដទៃទៀត , ក៏ទេវតាទាំងឡាយ សួរគ្នា យ៉ាងនេះ ដោយអាការយ៉ាងនេះ បានត្រាច់ទៅក្នុងម៉ឺនចក្រវាឡ អស់ ១២ ឆ្នាំ ។

## ទេវតានាំគ្នាទៅសួរបញ្ហាមហារាជទាំង ៤

ទេវតាក្នុងម៉ឺនចក្រវាឡ មិនអាចដោះស្រាយបញ្ហាបាន អស់កាលមានប្រមាណប៉ុណ្ណោះ ប្រជុំគ្នាហើយ ទៅកាន់សម្នាក់

មហារាជទាំង ៤ , កាលមហារាជពោលថា “ ម្នាលអ្នកទាំងឡាយ ហេតុដូចម្តេច ទើបមានទេវសន្និបាតដ៏ធំយ៉ាងនេះ ?” ក៏ពោលថា “ ពួកខ្ញុំតាំងបញ្ហាឡើង ៤ ខ.ហើយ កាលមិនអាចដោះស្រាយបាន ទើបមកកាន់សម្នាក់មហារាជ ”, កាលមហារាជពោលថា “ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ តើបញ្ហាអ្វី ?” ( ក៏ប្រាប់សេចក្តីនោះ ) ថា “ ពួកខ្ញុំមិនអាចដោះស្រាយបញ្ហាទាំងនេះបាន គឺបណ្តាទាន រស និងសេក្តីត្រេកអរ ទាន រស និងសេចក្តីត្រេកអរប្រភេទណាហ្ន៎ ទើបប្រសើរបំផុត ? ព្រោះហេតុអ្វី ទើបបណ្ឌិតទាំងឡាយពោលថា ការអស់ទៅនៃតណ្ហាប្រសើរបំផុត ?” ទើបមករកមហាបពិត្រ ។

មហារាជទាំង ៤ ពោលថា ម្នាលអ្នកទាំងឡាយ សូម្បីពួកយើងក៏មិនអាចដោះស្រាយបញ្ហាទាំងនេះបានដែរ , ប៉ុន្តែ ព្រះរាជារបស់ពួកយើង ទ្រង់ព្រះតម្រិះអត្ថ ដែលជនជទៃតាំងឡើងទាំងពាន់ហើយ រមែងទ្រង់ជ្រាបដោយខណៈតែមួយប៉ុណ្ណោះ , ព្រះអង្គប្រសើរវិសេសជាងពួកយើងទាំងឡាយ ទាំងផ្នែកខាងបញ្ញា ទាំងផ្នែកខាងបុណ្យ , ពួកយើង

ចូរទៅកាន់សម្នាក់ព្រះអង្គចុះ ” ហើយនាំពួកទេវតាទាំងនោះទៅកាន់សម្នាក់សក្កទេវរាជ ។ កាលសក្កទេវរាជត្រាស់សួរថា “ ម្នាលអ្នកទាំងឡាយហេតុដូចម្ដេច ទើបមានទេវសន្និបាតដ៏ធំយ៉ាងនេះ ?” ក៏ក្រាបទូលសេចក្ដីនោះ ។

## សក្កទេវរាជទ្រង់នាំពួកទេវតាទៅគាល់ព្រះសាស្ដា

សក្កទេវរាជត្រាស់ថា “ ម្នាលអ្នកទាំងឡាយ អ្នកដទៃរមែងមិនអាចដឹងសេចក្ដីនៃបញ្ហាទាំងនេះបានទេ , បញ្ហាទាំងនោះ ជាវិស័យរបស់ព្រះពុទ្ធ , ហើយត្រាស់សួរថា “ ឥឡូវនេះ ព្រះសាស្ដាទ្រង់គង់នៅទីណា ?” ទ្រង់ព្រះសណ្ដាប់ថា “ ក្នុងជេតពនមហាវិហារ ” ក៏ត្រាស់ថា “ ពួកអ្នកមកចុះ , ពួកយើងនឹងទៅកាន់សម្នាក់ព្រះអង្គ ” សក្កទេវរាជ ព្រមទាំងពួកទេវតា ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក្នុងចំណែកនៃរាត្រី ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយទ្រង់ឈរនៅក្នុងទីដ៏សមគួរមួយ , កាលព្រះសាស្ដាត្រាស់សួរថា “ បពិត្រមហារាជ ហេតុដូចម្ដេច ទើបព្រះអង្គស្ដេចមក មួយអន្លើដោយទេវតាដ៏ច្រើនយ៉ាងនេះ ?” ក៏ក្រាបទូល

ថា បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតានាំគ្នាបង្កើតបញ្ហាទាំង
នេះ , អ្នកដទៃដែលឈ្មោះថា អាចដឹងសេចក្តីនៃបញ្ហាទាំង
នោះ រមែងមិនមាន , សូមព្រះអង្គទ្រង់ប្រកាសនូវសេចក្តី
នៃបញ្ហាទាំងនេះដល់ពួកខ្ញុំព្រះអង្គចុះ ” ។

## ព្រះសាស្តាទ្រង់ដោះស្រាយបញ្ហា

ព្រះសាស្តា ត្រាស់ថា “ ប្រពៃហើយ មហាបពិត្រ
តថាគតបំពេញបារមី ៣០ បរិច្ចាគមហាបរិច្ចាគ សម្រេចព្រះ
សព្វញ្ញុតញ្ញាណហើយ ក៏ដើម្បីកាត់សេចក្តីសង្ស័យរបស់ជន
ទាំងឡាយ ដូចជាព្រះអង្គនេះឯង , សូមមហាបពិត្រទ្រង់ព្រះ
សណ្តាប់នូវបញ្ហាដែលមហាបពិត្រទ្រង់សួរហើយចុះ បណ្តា
ទានគ្រប់ប្រភេទ ធម្មទានប្រសើរបំផុត , បណ្តារសទាំងឡាយ
រសនៃព្រះធម៌ប្រសើរបំផុត, បណ្តាសេចក្តីត្រេកអរទាំងឡាយ
សេចក្តីត្រេកអរក្នុងព្រះធម៌ប្រសើរបំផុត, ចំណែកការអស់
ទៅនៃតណ្ហាប្រសើរបំផុត ព្រោះជាហេតុឲ្យសត្វទាំងឡាយ
បានសម្រេចព្រះអរហត្ត ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះ
ថា :-

១០ សព្វទានំ ធម្មទានំ ជិនាតិ
សព្វរសំ ធម្មរសោ ជនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ
តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្ដីត្រេកអរក្នុងធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។

## អធិប្បាយគាថា

បណ្ដាបទទាំង បទថា **សព្វទានំ** ជាដើម សេចក្ដីថា ប្រសិនបើបុគ្គលគប្បីថ្វាយត្រៃចីវរដែលសាច់ទន់ស្អាតដូចជាបណ្ដូលចេក ចំពោះព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះខីណាស្រពទាំងឡាយ ដែលគង់ក្នុងផ្ទៃចក្រវាឡមិនមានចន្លោះដរាបដល់ព្រហ្មលោក ។ ការអនុមោទនា ដែលព្រះពុទ្ធជាដើមទ្រង់ធ្វើដោយព្រះគាថា ៤ បាទក្នុងសមាគមនោះប្រសើរជាង, ដ្បិតថាទាននោះមានតម្លៃមិនដល់ចំរៀកទី ១៦ នៃព្រះ

គាថានោះ, ការសម្ដែងធម្មិកថា ការបង្រៀនធម៌ ស្ដាប់ធម៌ ជារឿងសំខាន់ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត បុគ្គលណា ធ្វើឲ្យមានការស្ដាប់ធម៌, អានិសង្សដ៏ធំក៏រមែងមានដល់ដល់ បុគ្គលនោះឯង ដែលព្រះពុទ្ធជាដើមឲ្យប្រព្រឹត្តទៅហើយ សូម្បីដោយអំណាចនៃការអនុមោទនា ដោយទីបំផុតត្រឹមតែ ព្រះគាថា ៤ បាទ ប្រសើរជាងទានដែលទាយកញ៉ាំងបាត ទាំងឡាយ ឲ្យពេញដោយបិណ្ឌបាតដ៏ប្រណីតហើយប្រគេន ដល់បរិស័ទបែបនោះផង ប្រសើរជាងភេសជ្ជទានដែល ទាយកញ៉ាំងបាតឲ្យពេញដោយទឹកដោះ និងប្រេងជាដើម ហើយប្រគេនផង ប្រសើរជាងសេនាសនទានដែលទាយក ឲ្យគេកសាងវិហារ ដូចជាមហាវិហារ និងប្រាសាទដូចជា លោហប្រាសាទទាំងច្រើនសែនហើយប្រគេនផង ប្រសើរ ជាងការបរិចាគដែលអនាថបិណ្ឌិកសេដ្ឋីជាដើម ប្រារព្ធវិហារ ទាំងឡាយហើយធ្វើផង ។ ព្រោះហេតុអ្វី ? ព្រោះថាជនទាំង ឡាយ កាលនឹងធ្វើបុណ្យបែបនោះបាន ទាល់តែបានស្ដាប់ ធម៌ហើយប៉ុណ្ណោះ ទើបអាចធ្វើបាន ។ ប្រសិនបើមិនបាន

ស្តាប់ទេ ក៏មិនអាចធ្វើបានទេ, បើសត្វទាំងនេះមិនបានស្តាប់ធម៌ទេនោះ ក៏មិនអាចថ្វាយបបរយាគូប្រមាណមួយបោយកត្តប្រមាណមួយវែកបានដែរ, ព្រោះហេតុនេះ ធម្មទានទើបឈ្នះអស់ទានទាំងពួង ប្រសើរជាងទានទាំងពួង ។

ម្យ៉ាងទៀត វៀរព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធចេញ សូម្បីព្រះសាវកទាំងឡាយ មានព្រះសារីបុត្តជាដើម ដែលមានបញ្ញាដែលអាចរាប់ដំណក់ទឹកបាន ក្នុងកាលដែលភ្លៀងធ្លាក់ចុះមកក្នុងកប្បទាំងមូល ក៏មិនអាចសម្រេចគុណវិសេសមានសោតាបត្តិផលជាដើម តាមធម្មតារបស់ខ្លួនបានដែរ, ទាល់តែបានស្តាប់ធម៌ដែលព្រះអស្សជិថេរជាដើម សម្តែងហើយ ទើបធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល, ហើយធ្វើឲ្យជាក់ច្បាស់នូវសាវកបារមីញាណ ដោយព្រះធម្មទេសនារបស់ព្រះមានព្រះភាគ, ព្រោះហេតុនេះ មហាបពិត្រ ធម្ម-ទាននោះឯង ទើបប្រសើរជាទីបំផុត ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា “ **សព្វទានំ ធម្មទានំ ជិនាតិ** ” ។

ម្យ៉ាងទៀត រសទាំងឡាយ មានរសកើតអំពីដើមជាដើមគ្រប់ប្រភេទ ដោយចំណែកជាន់ខ្ពស់ សូម្បីរសនៃសុធាភោជន៍របស់ទេវតាទាំងឡាយ រមែងជាបច្ច័យនៃការញ៉ាំងសត្វឲ្យធ្លាក់ទៅក្នុងសង្សារវដ្ដ ហើយសោយទុក្ខតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកព្រះធម្មរសពោលគឺពោធិបក្ខិយធម៌ ៣៧ ប្រការ និងលោកុត្តរធម៌ ៩ ប្រការនេះឯង ប្រសើរជាងរសទាំងពួង ព្រោះហេតុនោះ ទើបព្រះសាស្ដាត្រាស់ថា “**សព្វ-រសំ ធម្មរសោ ជិនាតិ**” ។

ម្យ៉ាងទៀត សូម្បីសេចក្ដីត្រេកអរក្នុងបុត្ត សេចក្ដីត្រេកអរក្នុងធីតា សេចក្ដីត្រេកអរក្នុងទ្រព្យ សេចក្ដីត្រេកអរក្នុងស្ដ្រី និងសេចក្ដីត្រេកអរមានប្រភេទមិនមែនតែម្យ៉ាងមានសេចក្ដីត្រេកអរក្នុងការរាំការច្រៀងការប្រគំជាដើម រមែងជាបច្ច័យនៃការញ៉ាំងសត្វឲ្យធ្លាក់ទៅក្នុងសង្សារវដ្ដ ហើយសោយទុក្ខតែម្យ៉ាង, ចំណែកសេចក្ដីត្រេកអរដែលកើតឡើងខាងក្នុងចិត្តនៃអ្នកសម្ដែងធម៌ក្ដី អ្នកស្ដាប់ធម៌ក្ដី អ្នកបង្រៀនធម៌ក្ដី រមែងញ៉ាំងចិត្តឲ្យរីករាយ ញ៉ាំងទឹកភ្នែកឲ្យហូរ ឲ្យកើត

ការព្រឺព្រួចរោម សេចក្តីត្រេកអរនោះ រមែងធ្វើទីបំផុតនៃសង្សារវដ្ត មានព្រះអរហត្តជាបរិយោសាន, សេចក្តីត្រេកអរក្នុងធម៌បែបនេះប្រសើរជាងសេចក្តីត្រេកអរទាំងពួង ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា " **សព្វរតឹ ធម្មរតិ ជិនាតិ** " ។

ចំណែកការអស់ទៅនៃតណ្ហា គឺព្រះអរហត្តដែលកើតឡើងក្នុងទីបំផុតនៃការអស់តណ្ហា, ព្រះអរហត្តនោះប្រសើរជាងធម៌ទាំងពួង ព្រោះគ្របសង្កត់វដ្តទុក្ខសូម្បីទាំងអស់បាន, ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា " **តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** " ។

កាលព្រះសាស្តា ទ្រង់ត្រាស់សេចក្តីនៃព្រះគាថានេះដោយប្រកសរជួច្នេះ ធម្មាភិសម័យ បានកើតមានដល់សត្វ ៨៤០០០ ។

ចំណែកសក្កទេវរាជ ទ្រង់ព្រះសណ្តាប់ធម្មកថារបស់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ ទូលសួរថា " បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីប្រយោជន៍អ្វី ទើបព្រះអង្គមិនត្រាស់

ឲ្យៗ ចំណែកបុណ្យដល់ពួកខ្ញុំព្រះអង្គ ក្នុងធម្មទានដែលឈ្នះអស់ទានទាំងពួងយ៉ាងនេះ ? ចាប់ពីពេលនេះទៅ សូមព្រះអង្គទ្រង់ព្រះមេត្តាត្រាស់ប្រាប់ភិក្ខុសង្ឃឲ្យៗ ចំណែកបុណ្យដល់ពួកខ្ញុំព្រះអង្គផងចុះ " ។ ព្រះសាស្តាទ្រង់ព្រះសណ្តាប់ពាក្យរបស់សក្កទេវរាជហើយ ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នាហើយ ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ចាប់ពីពេលនេះទៅពួកអ្នកធ្វើការស្តាប់ធម៌ធំក្តី ស្តាប់ធម៌តាមប្រក្រតីក្តី ពោលឧបនិសិន្នកថាក្តី ដោយទីបំផុតទៅ សូម្បីតែការអនុមោទនាហើយគប្បីឲ្យចំណែកបុណ្យដល់សត្វទាំងពួង ។

( រឿងសក្កទេវរាជ ចប់ )

8888888888888888

## ១១ រឿងសេដ្ឋីអូតមិនមានបុត្រ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះថា អបុត្តកៈ ត្រាស់ព្រះធម្មទេសនានេះថា " **ហន្តិ ភោគា ទុម្មេធំ** " ដូច្នេះជាដើម ។

## ប្រវត្តិកាលនៅមានជីវិតរបស់អបុត្តកសេដ្ឋី

បានឮមកថា ព្រះបាទបសេនទិកោសលទ្រង់ព្រះសណ្តាប់ការធ្វើមរណកាលរបស់សេដ្ឋីនោះហើយ ក៏ត្រាស់សួរថា " ទ្រព្យសម្បត្តិដែលគ្មានបុត្រ នឹងទៅជារបស់អ្នកណា ?" ទ្រង់ព្រះសណ្តាប់ថា " នឹងទៅជាព្រះរាជទ្រព្យ " ក៏ត្រាស់ឲ្យនាំទ្រព្យអំពីផ្ទះរបស់សេដ្ឋីនោះ មកកាន់រាជត្រកូល ( អស់ពេលវេលា ) ៧ ថ្ងៃ ហើយស្តេចយាងទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា " បពិត្រមហារាជព្រះអង្គស្តេចមកអំពីទីណាទាំងកណ្តាលថ្ងៃ " ក៏ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន គហបតីជាសេដ្ឋីក្រុងសាវត្ថីនេះធ្វើកាលកិរិយាហើយ ខ្ញុំព្រះអង្គនាំទ្រព្យសម្បត្តិដែលគ្មានបុត្តនោះ ទៅកាន់រាជសម្នាក់ហើយ ទើបមក " ។

រឿងទាំងពួង គប្បីជ្រាបតាមន័យដែលមានមកហើយក្នុងព្រះសូត្រនោះចុះ ។

កាលព្រះរាជាក្រាបទូលសេចក្តីយ៉ាងនេះថា " បាទព្រះមហាវេស្សន្តរ អ្នកទាំងឡាយ ... ថា សេដ្ឋីនោះ កាលអ្នកបម្រើនាំភោជនមានរសដ៏ប្រណីតផ្សេងៗ ចូលទៅឲ្យដោយថាសមាស ក៏ពោលថា មនុស្សទាំងឡាយតែងតែបរិភោគបែបនេះឬ , ពួកឯងមានចេតនាបញ្ឆោតយើងឬ ? កាលអ្នកបម្រើនាំភោជនចូលទៅតម្កល់ ទុកឲ្យ ក៏ប្រហារអ្នកបម្រើទាំងនោះ ដោយដុំដី និងដំបងជា ដើម ឲ្យចៀសចេញទៅ បរិភោគបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ដោយពោលថា នេះទើបជាភោជនសម្រាប់មនុស្ស, សូម្បីកាលអ្នកបម្រើចាត់ចែងរៀបចំសំពត់ យាន និងឆត្រដែលជាទីពេញចិត្តជូន ក៏ប្រហារអ្នកបម្រើនទាំងនោះឲ្យចៀសចេញទៅ ដោយដុំដី និងដំបងជាដើម ស្លៀកដណ្តប់សំពត់សម្បកឈើ ប្រើប្រាស់ឆត្រស្លឹកឈើ ហើយទៅណាមកណា រមែងទៅដោយរថកញ្ចាស់ ។

ទើបព្រះសាស្តា ត្រាស់សម្តែងបុព្វកម្មរបស់អបុត្តសេដ្ឋី នោះថា :-

## បុព្វកម្មរបស់អបុត្តកសេដ្ឋី

“ មហាបពិត្រ រឿងធ្លាប់មានមកហើយ គហបតីដែលជាសេដ្ឋីនោះ ទទួលព្រះបច្ចេកពុទ្ធព្រះនាមថាតគរសិខីដោយបិណ្ឌបាត ដោយពោលថា អ្នកទាំងឡាយ ចូរប្រគេនបិណ្ឌៈដល់សមណៈ ដូច្នេះហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ បានឮថា កាលសេដ្ឋីនោះ អ្នកមិនមានសទ្ធា ជាអ្នកល្ងង់ខ្លៅ ពោលយ៉ាងនេះហើយចៀសចេញទៅ ករិយារបស់គាត់ដែលជាអ្នកមានសទ្ធាជ្រះថ្លា គិតថា យូរណាស់មកហើយ យើងមិនដែលបានឮពាក្យថា ចូរឲ្យ អំពីមាត់របស់សេដ្ឋីនេះទេ ទើបតែបានឮក្នុងថ្ងៃនេះឯង, មនោរថរបស់យើងនឹងពេញក្នុងថ្ងៃនេះ, យើងនឹងថ្វាយបិណ្ឌបាត ហើយទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធ មកដាក់ភោជនដ៏ប្រណីតហើយប្រគេនព្រះបច្ចេកពុទ្ធ ។ ចំណែកសេដ្ឋីនោះត្រឡប់មក ឃើញព្រះបច្ចេកពុទ្ធនោះ ក៏សួរថា “ សមណៈលោកបានអ្វីៗ ហើយ

ឬ ” ហើយចាប់បាត្រឃើញបិណ្ឌបាតដ៏ប្រណីត ក៏មានសេចក្តីក្តៅក្រហាយស្តាយក្រោយ ទើបគិតយ៉ាងនេះថា “ ប្រសិនបើទុកបិណ្ឌបាតនេះ ឲ្យពួកទាសៈ ឬពួកកម្មករបរិភោគវិញប្រសើរជាង ព្រោះថា ពួកគេលុះបានបរិភោគបិណ្ឌបាតនេះហើយ នឹងធ្វើការងារឲ្យយើង, ចំណែកសមណៈធាន់ហើយក៏នឹងទៅដេកលក់យ៉ាងស្រួល, បិណ្ឌបាតរបស់យើងវិនាសអស់ហើយ ” មិនត្រឹមតែប៉ុណ្ណោះ សេដ្ឋីនោះបានសម្លាប់កូនប្រុសរបស់បងប្រុសខ្លួនម្នាក់ ព្រោះហេតុនៃទ្រព្យសម្បត្តិ ។ ក្មេងនោះចាប់ម្រាមដៃរបស់សេដ្ឋីនោះ ដើរទៅបណ្តើរពោលបណ្តើរថា “ យាននេះរបស់បិតាខ្ញុំ គោនេះក៏ជារបស់គាត់ដែរ ” ។ គ្រានោះ សេដ្ឋីគិតថា “ ឥឡូវនេះ ក្មេងនេះចេះពោលយ៉ាងនេះទៅហើយ, ក៏ក្នុងកាលក្មេងនេះចម្រើនវ័យហើយ នរណានឹងរក្សាទ្រព្យសម្បត្តិក្នុងផ្ទះនេះបាន ក៏នាំក្មេងនោះទៅកាន់ព្រៃ ចាប់ប្រចាប់ក.ដូចប្រចាប់មើមដំឡូង ឲ្យងាប់ក្បែរគុម្ពឈើមួយ ហើយបោះសាកសពក្មេងនោះចោលក្នុងទីនោះឯង ” ។ នេះជាបុព្វកម្មរបស់សេដ្ឋីនោះ ។

# សរុបកម្មនិងផលនៃកម្មរបស់សេដ្ឋី

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា “ មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋីទទួលព្រះបច្ចេកពុទ្ធព្រះនាមថាតគរសិខីដោយបិណ្ឌបាតនោះឯង ទើបសេដ្ឋីនោះទៅកាន់សុគតិសួគ៌ទេវលោក ៧ ដង, ដោយផលដ៏សេសនៃកម្មនោះ ទើបសេដ្ឋីនោះបានជាសេដ្ឋីនៅក្នុងក្រុងសាវត្ថីនេះឯងដល់ទៅ ៧ ដង ។ មហាបពិត្រ ដោយផលនៃកម្មដែលសេដ្ឋីនោះឲ្យទានហើយ មានការស្ដាយក្រោយថា ពួកទាសៈ ឬកម្មករគប្បីបរិភោគបិណ្ឌបាតនេះប្រសើរជាង, ទើបសេដ្ឋីនោះមិនបង្អោនចិត្តទៅដើម្បីបរិភោគភត្តដែលប្រណីត ៗ , មិនបង្អោនចិត្តទៅដើម្បីប្រើប្រាស់សំពត់ដែលប្រណីត ៗ , មិនបង្អោនចិត្តទៅដើម្បីប្រើប្រាស់យានដែលប្រណីត ៗ ,មិនបង្អោនចិត្តទៅដើម្បីបរិភោគកាមគុណទាំង ៥ ឲ្យសប្បាយចិត្ត ។ មហាបពិត្រ ដោយផលនៃកម្មដែលសេដ្ឋីនោះ ផ្ដាច់ជីវិតបុត្រតូចរបស់បងប្រុសម្នាក់ព្រោះហេតុនៃទ្រព្យសម្បត្តិ, ទើបសេដ្ឋីនោះឆេះក្នុងនរកអស់

ឆ្នាំជាច្រើន អស់រយឆ្នាំជាច្រើន អស់ពាន់ឆ្នាំជាច្រើន អស់សែនឆ្នាំជាច្រើន ។ ជនទាំងឡាយញុំាងទ្រព្យសម្បត្តិរបស់សេដ្ឋីដែលគ្មានបុត្រក្នុងជាតិទី ៧ នេះឲ្យចូលទៅកាន់ព្រះរាជឃ្លាំង ដោយផលដ៏សេសនៃកម្មនោះឯង ។ មហាបពិត្រម្យ៉ាងទៀត បុណ្យចាស់របស់សេដ្ឋីនោះអស់ហើយ ហើយបុណ្យថ្មីសេដ្ឋីនោះមិនបានសន្សំ, មហាបពិត្រ ថ្ងៃនេះ សេដ្ឋីនោះឆេះនៅក្នុងមហារោរុវនរក ។

## ភោគៈទាំងឡាយរមែងសម្លាប់បុគ្គលអប្បបញ្ញា

ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវព្រះតម្រាស់របស់ព្រះសាស្ដាហើយ ក៏ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន គួរអស្ចារ្យណាស់ នេះជាកម្មដ៏ធ្ងន់, សេដ្ឋីនោះ កាលភោគៈមានប្រមាណប៉ុណ្ណេះ មាន មិនបរិភោគដោយខ្លួនឯង, កាលព្រះពុទ្ធដូចជាព្រះអង្គ ទ្រង់គង់នៅក្នុងវិហារជិត ៗ ក៏មិនបានធ្វើបុណ្យ ” ។

ព្រះសាស្ដាត្រាស់ថា “ យ៉ាងហ្នឹងហើយ មហាបពិត្រធម្មតាបុគ្គលល្ងង់ខ្លៅ អប្បបញ្ញា បានភោគៈទាំងឡាយ

ហើយ រមែងមិនស្វែងរកនិព្វាន,ម្យ៉ាងទៀត តណ្ហាដែលកើតឡើង ព្រោះអាស្រ័យភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលទាំង នោះអស់កាលយូរ ” ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា ៖-

**១១ ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **នោ ច បារគវេសិនោ** សេចក្ដីថា ប៉ុន្តែភោគៈទាំងឡាយ រមែងមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានជាប្រក្រតី ។

បាទព្រះគាថាថា **ហន្តិ អញ្ញេវ អត្តនំ** សេចក្តីថា បុគ្គលអប្បបញ្ញា រមែងសម្លាប់ខ្លួនឯង ដូចសម្លាប់អ្នកដទៃ ព្រោះតណ្ហាដែលកើតឡើង ព្រោះអាស្រ័យភោគៈទាំងឡាយ

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងអបុត្តកសេដ្ឋី ចប់

# ១២ រឿងអង្កុរទេវបុត្ត

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅលើសិលាដូចជាសំពត់កម្ពលពណ៌លឿង ទ្រង់ប្រារព្ធអង្កុរទេវបុត្ត ត្រាស់ព្រះធម្មទេសនានេះថា " **តិណទោសានិ ខេត្តានិ** " ជាដើម ។

## ទានដែលបុគ្គលជ្រើសរើសហើយឲ្យ ព្រះពុទ្ធទ្រង់សរសើរ

ខ្ញុំម្ចាស់ធ្វើរឿងនេះឲ្យពិស្តារហើយ ក្នុងព្រះគាថាថា "**យេ ឈានបសុតា ធីរា**" ជាដើម ។ សមដូចពាក្យដែលខ្ញុំម្ចាស់ប្រារព្ធឥន្ទកទេវបុត្តពោលទុកក្នុងរឿងនោះដូច្នេះថា ៖-

“ បានឮថា ឥន្ទកទេវបុត្តនោះបានប្រគេនភិក្ខាមួយវែក ដែលនាំមកដើម្បីខ្លួន ចំពោះព្រះអនុរុទ្ធត្ថេរដែលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត, បុណ្យរបស់ឥន្ទកទេវបុត្តនោះ មានផលច្រើនជាងទានដែលអង្កុរទេវបុត្ត ធ្វើជួរនៃចង្ក្រានប្រមាណ ១២ យោជន៍ ថ្វាយហើយអស់មុឺនឆ្នាំ ” ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្តពោលយ៉ាងនោះ ។ កាលឥន្ទកទេវបុត្តពោលយ៉ាងនោះហើយ ព្រះសាស្ដាក៏ទ្រង់ត្រាស់ថា “ ម្នាលអង្កុរ ការជ្រើសរើសឲ្យទាន រមែងសមគួរ, ទានរបស់ឥន្ទកៈនោះ ជាទានមានផលច្រើន ដូចពូជដែលគេសាបព្រោះល្អហើយក្នុងស្រែល្អ ដូច្នោះដែរ, ប៉ុន្តែអ្នកមិនបានធ្វើយ៉ាងនោះ, ព្រោះហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន” កាលនឹងទ្រង់ប្រកាសសេចក្ដីនេះឲ្យពិស្ដារ ទើបត្រាស់ថា ៖-

ទានដែលបុគ្គលពិចារណាហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ទក្ខិណេយ្យបុគ្គលណា ដែលមាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមានផល

ច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ។ កាលទ្រង់ទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបបាន ទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

១២. តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វីគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន។ ស្រែទាំងឡាយ មាន ស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជា

ទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមាន ផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះ ហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នក មានមោហៈអស់ហើយ រមែងជាទានមានផល ច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួក សត្វលោកនេះ មានសេចក្ដីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់ អ្នកមានសេចក្ដីប្រាថ្នាអស់ហើយ រមែងជាទាន មានផលច្រើន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **តិណទោសានិ** សេចក្ដីថា ពិតណាស់ ស្មៅទាំងឡាយ មានស្មៅកែលលកជាដើម កាលដុះឡើង រមែងប្រទូស្តរាយនូវស្រែនៃបុព្វណ្ណជាតិ និង អបរណ្ណជាតិ, ព្រោះហេតុនោះ ទើបស្រែទាំងនោះមិនលូត

លាស់ចម្រើនឡើងបាន, រាគៈកាលកើតឡើងក្នុងខាងក្នុងនៃសត្វទាំងឡាយ រមែងប្រទូស្តរាយសត្វទាំងនោះ, ព្រោះហេតុនោះ ទានដែលឲ្យចំពោះបុគ្គលដែលត្រូវរាគៈប្រទូស្តទាំងនោះ ទើបជាទានមិនមានផលច្រើន, ចំណែកដែលឲ្យហើយចំពោះព្រះខីណាស្រពទាំងឡាយ ទើបជាទានមានផលច្រើន, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា " ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វមានរាគៈជាទោស, ហេតុដូច្នោះ ទានដែលឲ្យចំពោះបុគ្គលអ្នកប្រាសចាករាគៈ ទើបជាទានមានផលច្រើន " ។

សូម្បីក្នុងគាថាដ៏សេស ក៏មានន័យដូច្នេះដែរ ។

ក្នុងកាលចប់ទេសនា អង្កុរទេវបុត្ត និងឥន្ទកទេវបុត្តតាំងនៅក្នុងសោតាបត្តិផល, ទេសនាបានជាគុណប្រយោជន៍សូម្បីដល់ពួកទេវតាដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

( រឿងអង្កុរទេវបុត្ត ចប់ )

8888888888888888

តណ្ហាវគ្គវណ្ណនា ចប់

វគ្គទី ២៤ ចប់

ៜៜៜៜៜៜៜៜៜៜៜៜៜៜៜៜៜ

# ២៥. ភិក្ខុវគ្គវណ្ណនា

១ ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហា សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ប្រពៃ ការសង្រួមប្រមុះប្រពៃ ការសង្រួមអណ្តាត
ប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចា
ប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់
ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែង
រួចស្រឡះចាកទុក្ខទាំងពួងបាន ។

២ ហត្ថសញ្ញតោ បាទសញ្ញតោ
វាចាយ សញ្ញតោ សញ្ញតុត្តមោ
អជ្ឈត្តរតោ សមាហិតោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។

ជនណា សង្រួមដៃ សង្រួមជើង សង្រួម
វាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការ
ចម្រើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្ត
តម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរ
ក្នុងធម៌ បណ្ឌិតទាំងឡាយ ហៅជននោះថា ភិក្ខុ ។

៣ យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោល

ដោយបញ្ញា មានចិត្តមិនរាយមាយ សម្តែង

អត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះ

ទើបឈ្មោះថា ពីរោះ ។

៤ ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ

ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយ

ក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែង

មិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

៥ សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ

អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។

អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ

តំ វេ ទេវា បសំសន្តិ សុទ្ធាជីវឹ អតន្ទិតំ ។

ភិក្ខុ មិនគប្បីមើលងាយលាភរបស់ខ្លួន

( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្ត

ចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភ

របស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។

បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

៦ សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូប ថាជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯងតថាគតហៅថា ភិក្ខុ ។

៧ មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ

ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។

ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ
មា តន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។

នត្ថិ ឈានំ អបញ្ញស្ស នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។
តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។

បដិសន្ថារវុត្យស្ស អាចារកុសលតោ សិយ
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សសិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។ ម្នាលភិក្ខុ អ្នកចូរស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពីនោះនឹងអាចដល់នូវព្រះនិព្វាន ។ ភិក្ខុ គប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ភិក្ខុកន្លងកិលេសជាគ្រឿងជំពាក់ ៥ ( រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។ ម្នាលភិក្ខុ អ្នកចូរពិនិត្យផង ចូរជាអ្នកកុំប្រមាទផង ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំ

ប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាល ភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះ ឡើយ ។ ការពិនិត្យមិនមានដល់បុគ្គលអ្នកមិន មានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិន ពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃ ព្រះនិព្វាន ។ សេចក្តីត្រេកអរដែលមិនមែនជា របស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅ កាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ ដោយប្រពៃ ។ ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុង កាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។ គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្តី សន្តោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជា

ខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុ
អ្នកមានបញ្ញាក្នុងសាសនានេះ ( ម្នាលភិក្ខុ )
អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាម
ជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិល
ច្រអូស ។ ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ
គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំង
២ នោះ អ្នកនឹងបានបាមោជ្ជច្រើន នឹងធ្វើទីបំផុត
ទុក្ខបាន ។

៨ វស្សិកា វិយបុប្ផានិ មទ្ទវានិ បមុញ្ចតិ
ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បី
ជម្រុះរាគៈ និងទោសៈចេញ ដូចម្លិះជម្រុះម្លិះទាំង
ឡាយ ដែលស្វិតហើយ ដូច្នោះ ។

៩ សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ
វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។

ភិក្ខុអ្នកមានកាយស្ងប់រម្ងាប់ហើយ មាន

វាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

១០ អត្តនា ចោទយត្តានំ     បដិមំសេតមត្តនា
សោ អត្តគុត្តោ សតិមា  សុខំ ភិក្ខុ វិហាហិសិ ។
អត្តាហិ អត្តនោ នាថោ  អត្តនា ហិ អត្តនោ គតិ
តស្មា សញ្ញម អត្តានំ  អស្សំ ភទ្រំវ វាណិជោ ។

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។ មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជរវាំងសេះដ៏ល្អ ។

១១ បាមោជ្ជពហុលោ ភិក្ខុ  បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ     សង្ខារូបសមំ សុខំ ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះ

ថា ក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់
ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

**១២ យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**
**សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។**

ភិក្ខុណានៅកំលោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញ៉ាំងលោកឲ្យភ្លឺបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

## ២៥ ភិក្ខុវគ្គវណ្ណនា

# ១ រឿងភិក្ខុ ៥ រូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥ រូប ត្រាស់ព្រះធម្មទេសនានេះថា “**ចក្ខុនា សំវរោ សាធុ**” ជាដើម ។

## ភិក្ខុ ៥ រូបរក្សាទ្វារផ្សេងៗ គ្នា

បានឮថា បណ្តាភិក្ខុ ៥ រូបនោះ មួយរូបៗ រមែងរក្សាទ្វារទាំង ៥ មានចក្ខុទ្វារជាដើម មួយរូបទ្វារមួយប៉ុណ្ណោះ ។

ថ្ងៃមួយ ភិក្ខុទាំង ៥ រូបនោះប្រជុំគ្នាហើយ ជជែកគ្នាថា “ ខ្ញុំរមែងរក្សាទ្វារដែលរក្សាបានដោយកម្រ, ខ្ញុំរមែងរក្សាទ្វារដែលរក្សាបានដោយកម្រ ” ហើយពោលថា “ ពួកយើងទូលសួរព្រះសាស្តាហើយ នឹងដឹងនូវសេចក្តីនេះ”ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលសួរថា “ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គរក្សាទ្វារមានចក្ខុទ្វារជាដើមហើយ

រមែងសម្គាល់ថា ទ្វារដែលខ្លួនរក្សានោះ ជាទ្វារដែលរក្សាបានដោយកម្រ, បណ្ដាពួកខ្ញុំព្រះអង្គ អ្នកណាហ្ន៎ រមែងរក្សាទ្វារដែលរក្សាបានដោយកម្រ ?" ។

## ព្រះសាស្ដាទ្រង់កែខៃការយល់ខុសរបស់ភិក្ខុ ៥ រូប

ព្រះសាស្ដាមិនទ្រង់ញ៉ាំងភិក្ខុទាំងនោះ សូម្បីតែមួយរូបឲ្យតូចចិត្តឡើយ ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទ្វារទាំងនោះសូម្បីទាំងអស់ ជារបស់ដែលរក្សាបានដោយកម្រពិត ៗ,ម្យ៉ាងទៀត ពួកអ្នកមិនសង្រួមទ្វារទាំង ៥ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុន ក៏អ្នកទាំងឡាយមិនបានសង្រួមដែរ, អ្នកទាំងឡាយមិនប្រព្រឹត្តតាមឱវាទរបស់បណ្ឌិតទាំងឡាយ ដល់នូវការអស់ទៅនៃជីវិត ក៏ព្រោះទ្វារទាំងនោះ ដែលខ្លួនមិនបានសង្រួមនោះ" កាលភិក្ខុទាំងនោះទូលសួរថា "ក្នុងកាលណា ព្រះអង្គ ?" ក៏ទ្រង់ញ៉ាំងរឿងបញ្ចភិរុកជាតកឲ្យពិស្ដារ ហើយត្រាស់ព្រះគាថាទាំងនោះថា ៈ-

( ព្រះរាជាពោធិសត្វពោលថា )យើងមិនបានលុះ

ក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្តីព្យាយាមដ៏មាំ ក្នុងឧបាយគ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគ្របសង្កត់សេចក្តីខ្លាច នឹងសេចក្តីតក់ស្លុតផង សួស្តិភាពចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ ។

ដែលព្រះពោធិសត្វអ្នកបានទទួលការ អភិសេកហើយ ក្នុងកាលរាជត្រកូលដល់នូវការអស់ទៅនៃជីវិតព្រោះអំណាចនៃអារក្សទឹកទាំងឡាយ ទ្រង់គង់នៅលើរាជ-អាសនៈពួដ៏ក្រោមស្វេតច្ឆត្រ ទតមើលសិរីសម្បត្តិរបស់ព្រះអង្គហើយ ត្រាស់ថា "ដែលឈ្មោះថាសេចក្តីព្យាយាមនេះសត្វទាំងឡាយគួរតែបំពេញ" ហើយទ្រង់បន្លឺឧទានឡើងដោយអំណាចនៃសេចក្តីរីករាយ ទ្រង់ប្រជុំជាតកថា "សូម្បីកាលនោះ អ្នកទាំងឡាយជាជន ៥ នាក់ មានអាវុធក្នុងដៃ ចោមរោមព្រះរាជាពោធិសត្វ ដែលស្តេចចេញទៅដើម្បីដណ្តើមយករាជសម្បត្តិក្នុងក្រុងតក្កសិលា ធ្វើទៅតាមផ្លូវមិនសង្រួមក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ដែល

យក្ខិនីទាំងឡាយនាំចូលមក ដោយអំណាចនៃទ្វារមានចក្ខុទ្វារជាដើម ក្នុងចន្លោះផ្លូវ មិនប្រព្រឹត្តតាមឱវាទរបស់បិណ្ឌិតសម្លឹងមើលយក្ខិនីនោះ ត្រូវយក្ខិនីទាំងឡាយទំពាស៊ី ដល់នូវការអស់ទៅនៃជីវិត, ចំណែកព្រះរាជាដែលទ្រង់សង្រួមក្នុងអារម្មណ៍ទាំងនោះ មិនអើពើនិងនាងយក្ខិនីដែលមានភេទដូចជាទេវតា សូម្បីជាប់តាមទៅខាងក្រោយ ៗ ក៏ដោយ ក៏ស្តេចយាងទៅដល់ក្រុងតក្កសិលាដោយសិរីសួស្តី ហើយដល់ភាពជាព្រះរាជា គឺតថាគតនេះឯង" ហើយត្រាស់ថា "ធម្មតាភិក្ខុ គួរសង្រួមទ្វារសូម្បីទាំងអស់, ព្រោះថា ភិក្ខុជាសង្រួមទ្វារទាំងនោះហើយ រមែងរួចផុតចាកទុក្ខទាំងពួងបាន" ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

១ ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហា សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ

*សព្វត្ថ សំវុតោ ភិក្ខុ    សព្វទុក្ខា បមុច្ចតិ ។*

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

## អធិប្បាយគាថា

គប្បីជ្រាបការវិនិច្ឆ័យក្នុងបទថា **ចក្ខុនា** ជាដើម ក្នុងព្រះគាថានោះ ដូចតទៅនេះ ៖-

ក៏កាលណា រូបារម្មណ៍មកកាន់គន្លងចក្ខុទ្វាររបស់ភិក្ខុ, ក្នុងកាលនោះ កាលភិក្ខុមិនត្រេកអរនឹងអារម្មណ៍ដែលជាទីប្រាថ្នា មិនប្រទូស្តនឹងអារម្មណ៍ដែលមិនជាទីប្រាថ្នា មិនញុំាងមោហៈឲ្យកើតឡើង ក្នុងការសម្លឹងមើលនូវអារម្មណ៍ដែលមិនស្មើ, ការសង្រួម គឺការរារាំង បានដល់ការបិទ សំដៅដល់ការគ្រប់គ្រង ឈ្មោះថា ជាកិរិយាដែលភិក្ខុធ្វើហើយក្នុង

ទ្វារនោះ, ការសង្រួមចក្ខុទ្វារបែបនោះ របស់ភិក្ខុនោះ ជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ។ ន័យសូម្បីក្នុងទ្វារដទៃមានសោតទ្វារជាដើម ក៏ដូច្នេះដែរ ។

ក៏ការសង្រួមឬការមិនសង្រួម រមែងមិនកើតក្នុងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើមឡើយ, ប៉ុន្តែការសង្រួមឬការមិនសង្រួមនេះ រមែងមានក្នុងវិថីនៃជវនខាងមុខ, ពិតណាស់ក្នុងគ្រានោះ ការមិនសង្រួមកាលកើតឡើងជាអកុសលធម៌ ៥ យ៉ាងនេះគឺ "ការមិនជឿ ការមិនអត់ធន់ ការខ្ជិលច្រអូស ការវង្វេងភ្លេចសតិ ការមិនដឹង" រមែងមានក្នុងអកុសលវិថី។ ការសង្រួមកាលកើតឡើងជាកុសលធម៌ ៥ យ៉ាងនេះគឺ ការជឿ ១ ការអត់ធន់ ១ ការព្យាយាម ១ ការរលឹកបាន ១ការដឹង ១ " រមែងមានក្នុងកុសលវិថី ។

ក៏កាយបសាទក្តី ចោបនកាយក្តី រមែងបានក្នុងពីរបទនេះថា "**កាយេន សំវរោ**" ក៏ពាក្យថាបសាទកាយ និងចោបនកាយ សូម្បីទាំងពីរនោះ គឺកាយទ្វារនោះឯង ។ ក្នុងកាយទ្វារទាំងពីរនោះ ព្រះមានព្រះភាគត្រាស់ការសង្រួមនិងការ

មិនសង្រួមទុកក្នុងបសាទទ្វារ ។ ត្រាស់បាណាតិបាត អទិន្នាទាន និងមិច្ឆាចារដែលមានបសាទទ្វារនោះជាទីតាំងទុកក្នុងចោបនទ្វារ ។ ទ្វារនោះឈ្មោះថាភិក្ខុមិនសង្រួមហើយ ព្រោះអកុសលទាំងនោះ កើតឡើងក្នុងអកុសលវិថី ព្រមដោយបសាទទ្វារនិងចោបនទ្វារទាំងនោះ, ទ្វារនោះ ឈ្មោះថា ភិក្ខុនោះសង្រួមហើយ ព្រោះវិរតិទាំងឡាយ មានចេតនាជាគ្រឿងវៀរចាកបាណាតិបាតជាដើម កើតឡើងក្នុងកុសលវិថី

ចោបនវាចា ត្រាស់ទុកសូម្បីក្នុងបទពីរនេះថា "**សាធុ វាចាយ**" ទ្វារនោះឈ្មោះថាភិក្ខុមិនសង្រួមហើយ ព្រោះវចីទុច្ចរិតទាំងឡាយមានមុសាវាទជាដើម ដែលកើតឡើងព្រមដោយចោបនវាចានោះ, ឈ្មោះថា ភិក្ខុសង្រួមហើយ ព្រោះវិរតិទាំងឡាយមានចេតនាជាគ្រឿងវៀរចាកមុសាវាទជាដើម

មនោទុច្ចរិតទាំងឡាយមានអភិជ្ឈាជាដើម មួយអន្លើដោយចិត្តដទៃអំពីចិត្តដែលជាជវន រមែងមិនមានសូម្បីក្នុងពីរបទនេះថា " **មនសា សំវរោ** " ប៉ុន្តែទ្វារនោះ ឈ្មោះថាភិក្ខុមិនសង្រួម ព្រោះមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជា

ដើមកើតឡើងក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ, ឈ្មោះថា សង្រួមហើយ ព្រោះមនោសុចរិតទាំងឡាយមានអភិជ្ឈាជាដើម ដែលកើតឡើងក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ ។

ពីរបទថា **សាធុ សព្វត្ថ** សេចក្ដីថា ការសង្រួមទ្វារទាំងពួងមានចក្ខុទ្វារជាដើមនោះ ជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ។ ក៏ព្រះមានព្រះភាគទ្រង់សម្ដែងដែលភិក្ខុសង្រួម ៨ យ៉ាង និងទ្វារដែលភិក្ខុមិនសង្រួម ៨ យ៉ាងនោះ រមែងមិនផុតអំពីទុក្ខដែលមានវដ្ដៈជាមូលទេ, ចំណែកភិក្ខុអ្នកតាំងនៅក្នុងទ្វារដែលសង្រួង រមែងរួចផុតចាកទុក្ខទាំងពួងដែលមានវដ្ដៈជាមូល, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ **សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ** ” ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥ រូបនោះតាំងនៅក្នុងសោតាបត្តិផល, ទេសនាជាគុណជាតិមានប្រយោជន៍សូម្បីដល់មហាជនដែលប្រជុំគ្នាហើយ ។

រឿងភិក្ខុ ៥ រូប ចប់

## ២. រឿងភិក្ខុសម្លាប់ហង្ស

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកសម្លាប់ហង្សមួយរូប ត្រាស់ព្រះធម្មទេសនានេះថា " **ហត្ថសញ្ញតោ** " ជាដើម ។

### សម្លាញ់ពីរនាក់ចេញបួស

បានឮមកថា សម្លាញ់ពីរនាក់ដែលមានប្រក្រតីនៅក្នុងក្រុងសាវត្ថី បានបព្វជ្ជាឧបសម្បទាក្នុង ( សម្នាក់ ) ភិក្ខុទាំងឡាយហើយ ដោយច្រើនត្រាច់ទៅជាមួយគ្នា ។

ថ្ងៃមួយ ភិក្ខុពីររូបនោះទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹក ហើយ ហាលថ្ងៃ ឈរជជែកគ្នាអំពីសាភណីយកថា ។ ក្នុងខណៈនោះ មានហង្សពីរហើរមកតាមអាកាស ។

## ភិក្ខុមួយរូបប្រហារភ្នែកហង្សដោយដុំក្រួស

គ្រានោះ ភិក្ខុកំលោះមួយរូបចាប់ដុំក្រួស ហើយពោលថា " ខ្ញុំនឹងប្រហារភ្នែកហង្សមួយ " ភិក្ខុក្រៅនេះពោលថា " អ្នកនឹងមិនអាច " ។

ភិក្ខុរូបទី ១. ភ្នែកខាងនេះ ចូរលើកទុក, ខ្ញុំនឹងប្រហារភ្នែកខាងនោះ ។

ភិក្ខុរូបទី ២. សូម្បីភ្នែកខាងនេះ អ្នកក៏មិនអាចប្រហារបានដែរ ។

ភិក្ខុរូបទី ១.ពោលថា បើដូច្នោះ លោកចូរង់ចាំមើលចុះ លុះពោលដូច្នេះហើយ ក៏ចាប់ដុំក្រួសទី ២ គប់ទៅពីខាងក្រោយខ្នងហង្ស ។ ហង្សឮសំឡេងដុំក្រួសនោះក៏ងាកក្រោយមើល, ខណៈនោះ ភិក្ខុនោះចាប់ដុំក្រួសមួយដុំទៀត គប់ហង្សនោះចំភ្នែកខាងនាយ ញ៉ាំងដុំយក្រួសឲ្យចេញតាមភ្នែកខាង

អាយ ។ ហន្សស្រែក វិលជុំវិញ ( ប្រកាច់ ) ធ្លាក់ចុះមកក្បែរជើងភិក្ខុទាំងពីររូបនោះ ។

## ភិក្ខុទាំងឡាយតិះដៀលហើយ ក្រាបទូលរឿងនោះចំពោះព្រះសាស្តា

ភិក្ខុទាំងឡាយ ឈរក្នុងទីនោះៗ ឃើញហើយ ក៏ពោលថា " អ្នកមានអាយុ អ្នកបួសក្នុងព្រះពុទ្ធសាសនា ហើយធ្វើបាណាតិបាត ( ឈ្មោះថា ) ធ្វើកម្មមិនសមគួរ " ហើយនាំភិក្ខុទាំងពីររូបនោះទៅគាល់ព្រះតថាគត ។

## ព្រះសាស្តាប្រទានឱវាទ

ព្រះសាស្តាត្រាស់សួរថា " ម្នាលភិក្ខុ បានឮថា អ្នកបានធ្វើបាណាតិបាតពិតមែនឬ ?" កាលភិក្ខុនោះក្រាបទូលថា " ព្រះករុណា ព្រះអង្គ " ទើបត្រាស់ថា " ម្នាលភិក្ខុ អ្នកបួសក្នុងព្រះសាសនា ដែលជាហេតុនាំសត្វចេញចាកទុក្ខបែបនេះហើយ ហេតុដូចម្តេច ទើបអ្នកធ្វើបាណាតិបាត ? បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់ទ្រង់ឧប្បត្តិ នៅគ្រប់គ្រងផ្ទះ រង្កៀសក្នុងអំពើទាំងឡាយសូម្បីមានប្រមាណតិច ចំណែក

អ្នកបួសក្នុងព្រះពុទ្ធសាសនាបែបនេះ មិនបានធ្វើសេចក្ដីរង្កៀសសូម្បីតែបន្តិចបន្តួច " កាលភិក្ខុទាំងក្រាបទូលអាពធនាហើយ ក៏ទ្រង់នាំអតីតនិទាន មកត្រាស់ថា :-

## សីល ៥ ឈ្មោះថាគុរុធម៌

" ក្នុងអតីតកាល កាលព្រះបាទធនញ្ជ័យសោយរាជ-សម្បត្តិនៅក្នុងព្រះនគរ ឈ្មោះឥន្ទបត្ត: ក្នុងដែនកុរុ, ព្រះពោធិសត្វបដិសន្ធិក្នុងគភ៌នៃព្រះអគ្គមហេសី របស់ព្រះរាជាអង្គនោះ លុះចម្រើនវ័យហើយ ក៏ទ្រង់រៀនសិល្ប:ទាំងឡាយក្នុងក្រុងតក្កសិលា ត្រឡប់មកវិញ ត្រូវព្រះបិតាតែងតាំងជាឧបរាជ ក្រោយមក កាលព្រះបិតាសោយទិវង្គត បានទទួលរាជសម្បត្តិ ទ្រង់មិនប្រព្រឹត្តកន្លងរាជធម៌ទាំង ១០ ប្រការ [១] ទ្រង់សោយរាជសម្បត្តិដោយកុរុធម៌ ។ សីល ៥ ឈ្មោះថាកុរុធម៌ ព្រះពោធិសត្វទ្រង់រក្សាសីល ៥ នោះឲ្យបរិសុទ្ធ ។ ព្រះជននី ព្រះអគ្គមហេសីនៃព្រះពោធិសត្វផង ព្រះឧបរាជជាប្អូនប្រុសនៃព្រះពោធិសត្វផង ព្រាហ្មណ៍បុរោហិតផងអាមាត្យអ្នកកាន់ខ្សែផង សារថីផង សេដ្ឋីផង មហាអាមាត្យ

( ១ ) រាជធម៌ ១០ គឺ **ទានំ** ការឲ្យ ១ **សីលំ** សីល ១ **បរិច្ចាគំ** ការបរិច្ចាគ ១ **អាជ្ជវំ** ការពិចារណា ១ **មទ្ទវំ** ភាពទន់ភ្លន់ ១ **តបំ** សេចក្តីព្យាយាម ១ **អក្កោធំ** ការមិនក្រោធ ១ **អវិហឹសា** ការមិនបៀតបៀន ១ **ខន្តិ** សេចក្តីអត់ធន់ ១ **អវិរោធនំ** ការមិនពិរោធ ។

អ្នករក្សាឃ្លាំងផង អ្នករក្សាទ្វារផង នាងវណ្ណទាសីជាស្រ្តីលម្អនគរផង រមែងរក្សាសីល ៥ ដូចព្រះពោធិសត្វ ដោយប្រការដូច្នេះ ។

## ដែនកាលិង្គៈមានគ្រោះរាំងភ្លៀង

កាលជនទាំង ១១ នាក់នោះ រក្សាកុរុធម៌យ៉ាងនោះ, កាលព្រះរាជាទ្រង់ព្រះនាមកាលិង្គៈ សោយរាជសម្បត្តិនៅក្នុងនគរទន្តបុរី ដែនកាលិង្គៈ ភ្លៀងមិនបង្អុរចុះក្នុងដែនរបស់ព្រះអង្គ ។ ក៏ដំរីឈ្មោះអញ្ជនវសភៈរបស់ព្រះពោធិសត្វនោះជាសត្វមានបុណ្យច្រើន ។ អ្នកដែនក្រាបទូលព្រះរាជាដោយការយល់ថា កាលនាំដំរីនោះមកហើយ ភ្លៀងនឹងបង្អុរចុះ ។

ព្រះរាជទ្រង់បញ្ជូនពួកព្រាហ្មណ៍ទៅ ដើម្បីប្រយោជន៍ដល់ការនាំដំរីនោះមក ។ ព្រាហ្មណ៍ទាំងនោះទៅហើយ ទូលសូមដំរីអំពីព្រះពោធិសត្វ ។ ដើម្បីនឹងទ្រង់សម្តែងអាការ គឺការសូមរបស់ព្រាហ្មណ៍ទាំងនោះ ព្រះសាស្តាក៏ត្រាស់កុរុធម្ម-ជាតក ក្នុងតិកនិបាតដូច្នេះជាដើមថា :-

( ពួកព្រាហ្មណ៍ ក្រាបទូលថា ) បពិត្រព្រះជនាធិបតី យើងខ្ញុំទាំងឡាយ ដឹងច្បាស់នូវសទ្ធានិងសីលរបស់ព្រះអង្គ ហើយនឹងទទួលយកនូវដំរី មានសម្បុរប្រាកសស្មើ ដោយផ្កាអញ្ចន ទៅកាន់សម្នាក់នៃព្រះបាទកលិង្គៈ ។

( ព្រះពោធិសត្វ ពោលថា ) ពួកសត្វដែលយើងចិញ្ចឹមដោយបាយក្តី មិនចិញ្ចឹមក្តី សត្វណាក្នុងជីវលោកនេះ ដើរសំដៅមករកយើង ពួកសត្វទាំងអស់នោះ យើងមិនបានឃាត់ឡើយ នេះជារបស់បុព្វាចារ្យ ( មាតាបិតារបស់យើង ) ។

ព្រាហ្មណ៍ទាំងឡាយ យើងឲ្យដំរីនេះ ដែល

សមគួរដល់ព្រះរាជា ជាជំនិះរបស់ព្រះរាជា មានយសប្រជាប់តាក់តែងហើយ បំពាក់ហើយដោយបណ្តាញមាស ដល់អ្នកទាំងឡាយ អ្នកទាំងឡាយព្រមទាំងសារថី ( ចូរនាំ ) ទៅតាមប្រាថ្នាចុះ ។

ក៏កាលព្រាហ្មណ៍ទាំងនោះ នាំដំរីមកហើយ, ភ្លៀងនៅតែមិនបង្អុរចុះមក, ព្រះរាជាព្រះនាមកាលិង្គៈ ក៏ទ្រង់ព្រះតម្រិះថា “ ព្រះរាជាអង្គនោះទ្រង់រក្សាកុរុធម៌, ព្រោះដូច្នោះទើបភ្លៀងធ្លាក់ក្នុងដែនរបស់ព្រះអង្គ ” លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់បញ្ជូនពួកព្រាហ្មណ៍ និងអាមាត្យទៅទៀតដោយព្រះតម្រាស់ថា “ ពួកអ្នកចូរចារឹកកុរុធម៌ដែលព្រះរាជាអង្គនោះរក្សាពួដ៏ផែនមាស ( ក្រាំងមាស ) ហើយនាំមក ” កាលព្រាហ្មណ៍ និងអាមាត្យទាំងនោះទៅទូលសូម, ជនទាំងនោះសូម្បីទាំងអស់ ចាប់តាំងអំពីព្រះរាជាជាដើមទៅ ធ្វើការរង្កៀសបន្តិចបន្តួចខ្លះៗ ក្នុងសីលទាំងឡាយរបស់ខ្លួន ហើយប្រកែកថា “ សីលរបស់ពួកយើងមិនបរិសុទ្ធ ត្រូវព្រាហ្មណ៍ និងអាមាត្យទាំងនោះអង្វរថា ការបែកធ្លាយនៃសីល រមែង

មិនមានដោយហេតុមានប្រមាណប៉ុណ្ណោះទេ ” ទើបបានប្រាប់សីលរបស់ខ្លួនៗ ។

## ព្រះបាទកាលិង្គៈទ្រង់រក្សាកុរុធម៌ទើបភ្លៀងធ្លាក់

ព្រះបាទកាលិង្គៈ ទ្រង់ទតកុរុធម៌ដែលពួកព្រាហ្មណ៍និងអាមាត្យចារឹកព្ទដ៏ក្រាំងមាសហើយនាំមកនោះ ទ្រង់សមាទាន ហើយបំពេញឲ្យល្អ ទើបភ្លៀងបង្អុរចុះមកក្នុងដែនរបស់ព្រះអង្គ ។ ដែនបានក្សេមក្សាន្ត មានភិក្ខារកបានដោយងាយ

ព្រះសាស្ដាលុះទ្រង់នាំអតីតនិទានមកហើយ ទ្រង់ប្រជុំជាតកថា :-

ស្រីលម្អក្រុងក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា, អ្នករក្សាទ្វារ បានមកជាភិក្ខុឈ្មោះបុណ្ណៈ, អាមាត្យអ្នកកាន់ខ្សែ បានមកជាកច្ចានភិក្ខុ, ហើយអាមាត្យអ្នករក្សាឃ្លាំង បានមកជាកោលិកៈ, សេដ្ឋីក្នុងកាលនោះ បានជាសារីបុត្រ, នាយសារថី បានជាអនុរុទ្ធ, ព្រាហ្មណ៍ បានមកជាកស្សបៈ, ឧបរាជ បានជានន្ទបណ្ឌិត ព្រះ

មហេសី បានជាមាតារបស់រាហុល, ព្រះជននី បានជាព្រះនាងមាយាទេវី , ព្រះបាទកុរុ បានជាព្រះពោធិសត្វ, ពួកអ្នកចូរចាំជាតកទុកដោយអាការយ៉ាងនេះចុះ ។

ដូច្នេះហើយ ត្រាស់ថា “ ម្នាលភិក្ខុ បណ្ឌិតក្នុងកាលមុន កាលសេចក្ដីរង្កៀសសូម្បីមានប្រមាណតិចកើតឡើងហើយ ធ្វើនូវការបែកធ្លាយនៃសីលរបស់ខ្លួន ឲ្យជាគ្រឿងរង្កៀសហើយ, ចំណែកអ្នក បួសក្នុងសាសនាព្រះពុទ្ធ អ្នកប្រាកដស្មើដោយតថាគតហើយ នៅធ្វើបាណាតិបាតទៀត ( ឈ្មោះថា ) បានធ្វើកម្មដ៏ធ្ងន់ក្រៃលែង, ធម្មតាភិក្ខុ គួរជាអ្នកសង្រួមដៃ ជើង និងវាចា ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

២ ហត្ថសញ្ញតោ បាទសញ្ញតោ
វាចាយ សញ្ញតោ សញ្ញតុត្តមោ
អជ្ឈត្តរតោ សមាហិតោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយ ហៅជននោះថា ភិក្ខុ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ហត្ថសញ្ញតោ** សេចក្ដីថា ឈ្មោះថាអ្នកមានដៃសង្រួមហើយ ព្រោះមិនមានកាយវិការទាំងឡាយ មានការប្រលែងដោយដៃជាដើម ឬមិនមានការប្រហារសត្វដទៃដោយដៃជាដើម ។

ន័យសូម្បីក្នុងបទទីពីរ ក៏ដូចន័យនេះ ។

ដែលឈ្មោះថាអ្នកមានវាចាសង្រួមហើយ ព្រោះមិនធ្វើទុច្ចរិត មានការនិយាយកុហកតាមវាចាជាដើម ។

បទថា **សញ្ញតុត្តមោ** គឺអ្នកមានអត្តសង្រួមហើយ, អធិប្បាយថា អ្នកមិនធ្វើអាការប្លែក មានកម្រើកកាយ ងក់ក្បាល និងញាក់ចិញ្ចើមជាដើម ។

**អជ្ឈត្តរតោ** សេចក្តីថា ជាអ្នកត្រេកអរក្នុងការចំរើនកម្មដ្ឋានពោលគឺគោចរធម៌ដែលប្រព្រឹត្តទៅខាងក្នុង ។

បទថា **សមាហិតោ** គឺអ្នកមានចិត្តតម្កល់មាំហើយ ។

ពីរបទថា **ឯកោ សន្តុសិតោ** សេចក្តីថា ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ គឺមានចិត្តត្រេកអរហើយក្នុងអធិគមរបស់ខ្លួន ចាប់តាំងពីការប្រព្រឹត្តវិបស្សនាពិតណាស់ ព្រះសេក្ខបុគ្គលគ្រប់ជំពូក ចាប់ពីកល្យាណបុថុជ្ជនឡើងទៅ តែងតែត្រេកអរនិងអធិគមរបស់ខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថាអ្នកសន្តោស, ចំណែកព្រះអរហន្តជាអ្នកត្រេកអរហើយដោយចំណែកមួយ, ព្រះមានព្រះភាគទ្រង់សំដៅយកព្រះអរហន្តនោះ ទើបត្រាស់ព្រះតម្រាស់នោះថា “**ឯកោ សន្តុសិតោ**” ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងភិក្ខុសម្លាប់ហង្ស ចប់

# ៣.រឿងភិក្ខុឈ្មោះកោកាលិកៈ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះកោកាលិកៈ ត្រាស់ព្រះធម្មទេសនានេះថា "*យោ មុខសញ្ញតោ*" ជាដើម ។

## កោកាលិកៈកើតក្នុងនរកព្រោះជេរព្រះអគ្គសាវក

រឿងមានមកហើយក្នុងព្រះសូត្រថា “ គ្រានោះ ភិក្ខុឈ្មោះកោកាលិកៈ បានចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ” ជាដើម, ចំណែកសេចក្ដីនៃរឿងនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលព្រះអដ្ឋកថាចារ្យ ពោលទុកហើយក្នុងអដ្ឋកថានោះចុះ ។

ក៏កាលព្រះកោកាលិកៈកើតក្នុងបទុមនរក, ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា “ឱ ! ភិក្ខុឈ្មោះកោកាលិកៈដល់នូវសេចក្ដីវិនាសហើយ ព្រោះអាស្រ័យមាត់របស់ខ្លួន, ក៏កាលលោកជេរព្រះអគ្គសាវកទាំងពីរនោះ ផែនដីបានបើកចន្លោះហើយ” ។

ព្រះសាស្ដាស្ដេចមកហើយត្រាស់សួរថា “ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី ?” កាលភិក្ខុទាំងឡាយក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើនដោយកថាឈ្មោះនេះ ” ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះកោកាលិកៈ វិនាសព្រោះអាស្រ័យមាត់របស់ខ្លួនក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏ទេ, សូម្បីក្នុងកាលមុន ភិក្ខុ

ឈ្មោះកោកាលិកៈ ក៏វិនាសព្រោះអាស្រ័យមាត់របស់ខ្លួនដែរ កាលភិក្ខុទាំងឡាយ អ្នកប្រាថ្នានឹងស្ដាប់រឿងនោះអារាធនាហើយ ដើម្បីនឹងទ្រង់ប្រកាសរឿងនោះ បានទ្រង់នាំអតីតទានមកត្រាស់ថា ៖-

## ហង្សពីរនាំអណ្ដើកដែលជាសម្លាញ់ទៅគុហាររបស់ខ្លួន

ក្នុងអតីតកាល មានអណ្ដើកមួយនៅក្នុងស្រះ ក្នុងហិមវន្តប្រទេស ។ កូនហង្សពីរត្រាច់ទៅដើម្បីរកស៊ី ធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនិងអណ្ដើកនោះ ជាសត្វមានសេចក្ដីស្និទ្ធស្នាលយ៉ាងមាំ ថ្ងៃមួយ ហង្សទាំងពីរនោះសួរអណ្ដើកថា "ម្នាលសម្លាញ់ លំនៅរបស់ពួកយើងនៅក្នុងគុហាមាស លើផ្ទៃភ្នំឈ្មោះចិត្តកូដ ក្នុងហិមវន្តប្រទេសជាប្រទេសដ៏មនោរម្យ, តើអ្នកឯងចង់ទៅទីនោះជាមួយនិងពួកយើងទេ ?"

អណ្ដើក. ខ្ញុំនឹងទៅដូចម្ដេចបាន ?

ហង្ស. ប្រសិនបើអ្នកឯងអាចរក្សាមាត់បាន ពួកយើងនឹងនាំអ្នកឯងទៅ ។

អណ្ដើក. ម្នាលសម្លាញ់ ខ្ញុំអាចរក្សាមាត់បាន, សូមអ្នកទាំងពីរនាំខ្ញុំទៅចុះ ។

ហង្សទាំងពីរពោលថា " ប្រពៃហើយ " ហើយឲ្យអណ្ដើកខាំកំណាត់ឈើមួយ ចំណែកខ្លួនខាំចុងកំណាត់ឈើទាំងពីរនោះ ហើយហើរទៅកាន់អាកាស ។

## អណ្ដើករបូតមាត់អំពីកំណាត់ឈើដែលខាំធ្លាក់ស្លាប់

ពួកក្មេងអ្នកស្រុក ឃើញហង្សនាំអណ្ដើកទៅយ៉ាងនោះ ក៏និយាយគ្នាថា "ហង្សពីរនាំអណ្ដើកទៅដោយកំណាត់ឈើ" អណ្ដើកឮដូច្នោះក៏តបថា "នែអាក្មេងប្រេតទាំងឡាយ ការដែលសម្លាញ់របស់យើងទាំងពីរ នាំយើងទៅវាមានប្រយោជន៍អ្វីដល់ពួកឯង ក្នុងរឿងនេះ" ក៏ប្រលែងកំណាត់ឈើអំពីទីដែលខ្លួនខាំ ក្នុងវេលាដល់ចំណែកខាងលើព្រះរាជនិវេសន៍ ក្នុងព្រះនគរពារាណសី ព្រោះការដែលហង្សទាំងពីរនោះជាសត្វមានល្បឿនដ៏រហ័ស ទើបធ្លាក់ចុះទៅក្នុងព្រះលានហ្លួងបែកជាពីរចំណែក ។

## ការនិយាយច្រើនមិនត្រូវកាលវេលាឲ្យទោស

ព្រះសាស្តាលុះទ្រង់នាំអតីតទាននេះមកហើយ ទ្រង់ញ៉ាំងកច្ឆបជាតកក្នុងទុកនិបាតឲ្យពិស្តារថា ៖-

អណ្តើក កាលបើឈើខ្លួនពាំស៊ប់ហើយ ហា
និយាយសម្លាប់នូវខ្លួនឯង ឈ្មោះថាសម្លាប់ដោយ
វាចារបស់ខ្លួន ។

បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងជន ( ឯ
បណ្ឌិតបុរស ) ឃើញនូវហេតុនេះហើយ មិនគប្បី
បញ្ចេញវាចាជាកុសលឲ្យហួសវេលា ព្រះអង្គគង់
នឹងទតឃើញអណ្តើក ដែលដល់នូវសេចក្តីវិនាស
ព្រោះតែនិយាយច្រើន ។

ហើយត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកសង្រួមមាត់ ប្រព្រឹត្តស្មើ មិនរាយមាយ មានចិត្តស្ងប់ " ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**៣. យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ**
**អត្ថំ មុខសញ្ញតោ ភិក្ខុ មធុរំ តស្ស ភាសិត ។**

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា

មានចិត្តមិនរាយមាយ សំដែងអត្ថផង ធម៌ផងបាន
ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មុខសញ្ញតោ** សេចក្ដីថា ដែលឈ្មោះថា អ្នកសង្រួមមាត់ ព្រោះមិននិយាយពាក្យជាដើមថា “ ឯងជាអ្នកមានជាតិអាក្រក់ ឯងជាមនុស្សទ្រុស្ត-សីល ” ទៅកាន់ជនទាំងឡាយមានទាសៈ និងមនុស្សចណ្ឌាលជាដើម ។

បទថា **មន្តភាណី** សេចក្ដីថា បញ្ញា ព្រះមានព្រះភាគត្រាស់ហៅថា មន្តា, អ្នកមានប្រក្រតីនិយាយដោយបញ្ញា ។

បទថា **អនុទ្ធតោ** បានដល់ អ្នកមានចិត្តស្ងប់ហើយ ។

បាទព្រះគាថាថា **អត្ថំ ធម្មញ្ច ទីបេតិ** សេចក្ដីថា រមែងសម្ដែងអត្ថនៃភាសិត និងធម៌ គឺទេសនា ។

បទថា **មធុរំ** សេចក្ដីថា ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថាពីរោះ ។

ចំណែកភិក្ខុណា ញុំាងអត្ថតែម្យ៉ាងឲ្យដល់ព្រម, មិនញុំាងព្រះបាលីឲ្យដល់ព្រម, ញុំាងព្រះបាលីតែប៉ុណ្ណោះឲ្យដល់ព្រម, មិនញុំាងអត្ថឲ្យដល់ព្រម, ឬក៏មិនញុំាងទាំងពីរយ៉ាងឲ្យដល់ព្រម, ភាសិតរបស់ភិក្ខុនោះ មិនឈ្មោះថាជាភាសិតដ៏ពីរោះទេ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

( រឿងភិក្ខុឈ្មោះកោកាលិកៈ ចប់ )

8888888888888888888

# ៤ រឿងព្រះធម្មារាមត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ព្រះ-ធម្មារាមត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា " **ធម្មារាមោ ធម្មរតោ** " ជាដើម ។

ពួកភិក្ខុប្រឹក្សារឿងបរិនិព្វានរបស់ព្រះសាស្ដា

បានឮមកថា កាលព្រះសាស្ដាត្រាស់ប្រាប់ថា " ការបរិនិព្វានរបស់តថាគតនឹងមានដោយកន្លងទៅ ៤ ខែទៀត ចាប់តាំងពីថ្ងៃនេះទៅ ", ភិក្ខុច្រើនពាន់រូបត្រាច់ចោមរោមព្រះសាស្ដា ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជន មិនអាចនឹងទប់ទឹកភ្នែកបាន ។ ធម្មសង្វេគកើតឡើងដល់ភិក្ខុជាព្រះខីណាស្រពទាំងឡាយ ។ ភិក្ខុទាំងពួងប្រឹក្សាគ្នាថា " យើងនឹងធ្វើដូចម្ដេចហ្ន៎ " ដូច្នេះហើយ ក៏ត្រាច់ទៅដោយរួមគ្នាជាពួកៗ ។

ចំណែកភិក្ខុមួយរូប ឈ្មោះធម្មារាមៈ មិនចូលទៅកាន់សម្នាក់ភិក្ខុទាំងឡាយ, កាលភិក្ខុទាំងឡាយសួរថា " អ្នកមានអាយុ អ្នកកើតអ្វី ?" មិនឆ្លើយតប ដោយគិតថា " ឮថា

ព្រះសាស្តានឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត, ចំណែកយើងជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះ-សាស្តាទ្រង់ព្រះជន្មនៅ យើងនឹងព្យាយាមដើម្បីឲ្យបានសម្រេចព្រះអរហត្ត " ដូច្នេះហើយ ក៏ជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ រមែងរំពឹង នឹក គិត រឭកដល់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ។ ភិក្ខុទាំងឡាយក្រាបទូល ( រឿងនោះ ) ចំពោះព្រះតថាគតថា " បពិត្រព្រះអង្គ ព្រះធម្មារាមៈមិនបានធ្វើសេចក្តីស្នេហាក្នុងព្រះអង្គសូម្បីតែបន្តិចបន្តួច មិនធ្វើការប្រឹក្សាជាមួយនឹងពួកខ្ញុំព្រះអង្គសូម្បីតែបន្តិចបន្តួចថា " អ្នកមានអាយុទាំងឡាយ បានឮថា ព្រះសាស្តានឹងបរិនិព្វាន, តើពួកយើងនឹងធ្វើដូចម្តេច ?" ។

ព្រះសាស្តាត្រាស់ឲ្យហៅព្រះធម្មារាមៈមកគាល់

ព្រះសាស្តាត្រាស់ឲ្យហៅលោកមកហើយ ត្រាស់សួរថា " ម្នាលភិក្ខុ អ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?" ។

ព្រះធម្មារាមៈ. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. ព្រោះហេតុអ្វី ?

ព្រះធម្មារាមៈ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាន ឮថា ព្រះអង្គនឹងបរិនិព្វានដោយកាលកន្លងទៅ ៤ ខែទៀត, ចំណែកខ្ញុំព្រះអង្គជាអ្នកមានរាគៈមិនទាន់ទៅប្រាស, កាល ព្រះអង្គទ្រង់ព្រះជន្មនៅនោះឯង ខ្ញុំព្រះអង្គនឹងព្យាយាមដើម្បី ឲ្យបានសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គ រំពឹង នឹក គិតដល់ធម៌ដែលព្រះអង្គទ្រង់សម្ដែងហើយ ។

ព្រះសាស្ដាទ្រង់អនុមោទនា

ព្រះសាស្ដាទ្រង់ប្រទានសាធុការដល់លោកថា “ សាធុ សាធុ ” ហើយត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុណាស្រឡាញ់តថាគត គប្បីធ្វើដូចជាធម្មារាមភិក្ខុនេះចុះ, ពិតណាស់ ភិក្ខុណាបូជាដោយកម្រងផ្កា និងគ្រឿងក្រអូប ជាដើម មិនឈ្មោះថាបូជាតថាគតឡើយ, អ្នកបដិបត្តិធម៌ដ៏ សមគួរដល់ធម៌ប៉ុណ្ណោះ ទើបឈ្មោះថាបូជាតថាគត ”, ដូច្នេះ ហើយ ទ្រង់ត្រាស់ព្រះគាថានេះថា :-

**៤ ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ**
**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។**

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយ
ក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែង
មិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

## អធិប្បាយគាថា

គប្បីជ្រាបវិគ្គហៈក្នុងបទទាំងនោះថា ធម៌ គឺសមថៈ និងវិបស្សនា ជាទីត្រេកអររបស់ភិក្ខុនោះ ព្រោះអត្ថថា ជាទីនៅ ព្រោះហេតុនោះ ទើបឈ្មោះថាអ្នកមានធម៌ជាទីត្រេកអរ, ត្រេកអរហើយក្នុងធម៌នោះ ព្រោះហេតុនោះ ទើបឈ្មោះថាអ្នកត្រេកអរហើយក្នុងធម៌, ដែលឈ្មោះថាអ្នកពិចារណាធម៌ ព្រោះរឭកដល់ធម៌នោះរឿយៗ, អធិប្បាយថា អ្នកនឹកដល់ធម៌នោះ ។

បទថា **អនុស្សរំ** បានដល់ រឭកដល់ធម៌នោះឯង ។

បទថា **សទ្ធម្មា** សេចក្តីថា ភិក្ខុនោះ រមែងសាបសូន្យចាកពោធិបក្ខិយធម៌ ៣៧ ប្រការ និងលោកុត្តរធម៌ ៩ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងព្រះអរហត្ត, ទេសនាបានជាគុណជាតិមានប្រយោជន៍ សូម្បីដល់បរិស័ទដែលប្រជុំគ្នាហើយ ដោយប្រការដូច្នេះ ។

( រឿងព្រះធម្មារាមត្ថេរ ចប់ )

8888888888888888888

# ៥ រឿងភិក្ខុអ្នកសេពគប់ពួកខុសមួយរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកសេពគប់ភិក្ខុ ដែលជាបក្ខពួកអ្នកយល់ខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “ **សលាភំ នាតិមញ្ញេយ្យ** ” ជាដើម ។

## ភិក្ខុគប់រកភិក្ខុដែលជាបក្ខពួក ព្រះទេវទត្តព្រោះឃើញលាភ

បានឮថា ភិក្ខុដែលជាបក្ខពួកព្រះទេវទត្តមួយរូប ជាសម្លាញ់របស់ភិក្ខុរូបនោះ ។ ភិក្ខុដែលជាបក្ខពួករបស់ព្រះ-ទេវទត្តនោះ ឃើញភិក្ខុនោះត្រាច់ទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ធ្វើភត្តកិច្ចហើយ ( ត្រឡប់ ) មក ក៏សួរថា “ នែ អាវុសោ អ្នកទៅណា ?” ។

ភិក្ខុដែលជាបក្ខពួកព្រះសាស្តា. ខ្ញុំទៅកាន់ទីឈ្មោះឯណោះដើម្បីបិណ្ឌបាត ។

ភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត. អ្នកបានបិណ្ឌបាតហើយឬ ?

ភិក្ខុដែលជាបក្ខពួកព្រះសាស្តា. អើ ខ្ញុំបានហើយ ។

ភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត. នៅទីនេះ ពួកខ្ញុំមានលាភ និងសក្ការៈច្រើន, អ្នកចូរនៅក្នុងទីនេះ ២-៣ ថ្ងៃចុះ ។

ភិក្ខុដែលជាបក្ខពួកព្រះសាស្តានោះ នៅទីនោះ ២-៣ ថ្ងៃ តាមពាក្យរបស់ភិក្ខុនោះហើយ ក៏បានទៅកាន់លំនៅរបស់ខ្លួនវិញ ។

គ្រានោះ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះចំពោះព្រះតថាគតថា " បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបរិភោគលាភនិងសក្ការៈដែលកើតឡើងចំពោះព្រះទេវទត្ត, លោកជាបក្ខពួករបស់ព្រះទេវទត្ត " ។

ព្រះសាស្តា ត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា " ម្នាលភិក្ខុ តើអ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?" ។

ភិក្ខុ. ព្រះករុណា ព្រះអង្គ, ខ្ញុំព្រះអង្គអាស្រ័យភិក្ខុកំលោះមួយរូប បាននៅទីនោះ ២-៣ ថ្ងៃ , ក៏ប៉ុន្តែ ខ្ញុំព្រះអង្គមិនបានពេញចិត្តនឹងលទ្ធិរបស់ព្រះទេវទត្តទេ ។

## ភិក្ខុគួរត្រេកអរក្នុងលាភរបស់ខ្លួនប៉ុណ្ណោះ

គ្រានោះ ព្រះមានព្រះភាគត្រាស់ទៅកាន់ភិក្ខុនោះថា " ម្នាលភិក្ខុ អ្នកមិនពេញចិត្តនឹងលទ្ធិ ( របស់ព្រះទេវទត្ត ) នោះក៏ពិតមែនហើយ, ក៏ប៉ុន្តែ អ្នកបានត្រាច់ទៅជាមួយដូចជាពេញចិត្តនឹងលទ្ធិរបស់ជន ដែលអ្នកឃើញហើយដោយពិត, អ្នកបានធ្វើយ៉ាងនេះតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលបែបនេះដែរ ", កាលភិក្ខុទាំង-ឡាយទូលអារាធនាថា " បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ ពួកខ្ញុំព្រះអង្គឃើញភិក្ខុនេះដោយខ្លួនឯងហើយ, ប៉ុន្តែក្នុងកាលមុន ភិក្ខុនេះពេញចិត្តនឹងលទ្ធិរបស់បុគ្គលណា? សូមព្រះអង្គមេត្តាត្រាស់ប្រាប់ពួកខ្ញុំព្រះអង្គផង ", ទើបទ្រង់នាំអតីតនិទានមក ទ្រង់ញ៉ាំងមហិឡាមុខជាតកឲ្យពិស្តារថា :-

( អាមាត្យពោធិសត្វ ពោលថា ) ដំរីដ៏ឧត្តម

ឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរ ទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោក សម្លាប់ ( ហ្មដំរី ) លុះបានស្តាប់ពាក្យពួក លោកអ្នកមានខ្លួនសង្រួមហើយ ក៏បានតាំងនៅ ក្នុងគុណគ្រប់យ៉ាង ។

ហើយត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ គប្បីជាអ្នកត្រេកអរនឹងលាភរបស់ខ្លួនប៉ុណ្ណោះ, ការប្រាថ្នា លាភរបស់អ្នកដទៃ មិនសមគួរឡើយ, ព្រោះឈាន វិបស្សនា មគ្គ និងផលទាំងឡាយ សូម្បីតែមួយ៉ាងក៏រមែងមិនកើតឡើង ដល់ភិក្ខុអ្នកប្រាថ្នាលាភរបស់អ្នកដទៃ, ប៉ុន្តែគុណជាតិទាំង-ឡាយ មានឈានជាដើម រមែងកើតឡើងដល់ភិក្ខុអ្នកត្រេក-អរនឹងលាភរបស់ខ្លួនប៉ុណ្ណោះ " ដូច្នេះហើយ កាលនឹងទ្រង់ សម្តែងធម៌ បានទ្រង់ព្រះភាសិតព្រះគាថាទាំងនេះថា :-

**៥ សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ**
**អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។**
**អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ**

តំ វេ ទេវា បសំសន្តិ  សុទ្ធាជីវមតន្ទិតំ ។

ភិក្ខុ មិនគប្បីមើលងាយលាភរបស់ខ្លួន ( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្ត ចង់បានលាភរបស់ភិក្ខុដទៃ  បើចង់បានលាភ របស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។

បើភិក្ខុសូម្បីមានលាភតិច  មិនមើល ងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំង ឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នក ព្យាយាមជាគ្រឿងអាស្រ័យរស់នៅ  ដោយ បរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សលាភំ** បានដល់ លាភ ដែលកើតឡើងដល់ខ្លួន ។ ពិតណាស់ ភិក្ខុណាវៀរចាកការ ត្រាច់ទៅតាមលំដាប់ផ្ទះ  ចិញ្ចឹមជីវិតដោយការស្វែងរកមិន សមគួរ ភិក្ខុនោះឈ្មោះថា មើលងាយ គឺទៀយណាយ បាន

ដល់ ខ្ទើមខ្ទ្មើមនូវលាភរបស់ខ្លួន, ព្រោះហេតុនោះ ភិក្ខុមិនគួរមើលងាយលាភរបស់ខ្លួន ដោយការមិនធ្វើយ៉ាងនោះ ។

ពីរបទថា **អញ្ញេសំ បិហយំ** មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ ។

បាទព្រះគាថាថា **សមាធឹ នាធិគច្ឆតិ** សេចក្តីថា បើចង់បានរបស់ភិក្ខុដទៃ ដល់នូវសេចក្តីខ្វល់ខ្វាយក្នុងការធ្វើបរិក្ខារ មានចីវរជាដើមដល់ជនទាំងនោះ រមែងមិនបានអប្បនាសមាធិ ឬឧបចារសមាធិ ។

បាទព្រះគាថាថា **សលាភំ នាតិមញ្ញតិ** សេចក្តីថា ភិក្ខុសូម្បីជាអ្នកមានលាភតិច កាលត្រាច់ទៅតាមលំដាប់ត្រកូលដោយលំដាប់នៃត្រកូលខ្ពស់ និងទាប ឈ្មោះថា មិនមើលងាយលាភរបស់ខ្លួន ។

បទថា **តំ វេ** ជាដើម សេចក្តីថា ទេវតាទាំងឡាយរមែងសរសើរ គឺស្រឡាញ់ពេញចិត្តភិក្ខុនោះ គឺភិក្ខុបែបនោះឈ្មោះថាមានអាជីវៈបរិសុទ្ធ ព្រោះជាអ្នកមានជីវិតជាសារៈ

ឈ្មោះថាអ្នកមិនខ្ជិលច្រអូស ព្រោះជាអ្នកមិនរួញរា មិនខ្ជិលច្រអូសក្នុងការចិញ្ចឹមជីវិតដោយអាស្រ័យកម្លាំងស្មួន ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងភិក្ខុគប់រកភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត ចប់ )

8888888888888888888888888888888888888888888888

## ៦ រឿងព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក ត្រាស់ព្រះធម្មទេសនានេះថា ***“សព្វសោ នាមរូបស្មឹ”*** ជាដើម ។

### ហេតុផលដែលព្រាហ្មណ៍មានឈ្មោះថា បញ្ចគ្គទាយក

បានឮថា ព្រាហ្មណ៍នោះតែងតែថ្វាយទានឈ្មោះខេត្តគ្គៈក្នុងកាលនៃស្រែដែលខ្ទួនជម្រះហើយ, ក្នុងកាលនៃលាន

( កាលជាទីធ្វើលាន ) ក៏ថ្វាយទានឈ្មោះខលគ្គៈ, ក្នុងកាលបញ្ជាន់ស្រូវ ក៏ថ្វាយទានឈ្មោះខលភណ្ឌគ្គៈ, ក្នុងកាលដាក់អង្ករក្នុងឆ្នាំង ក៏ថ្វាយទានឈ្មោះឧក្ខលិកគ្គៈ ក្នុងកាលដែលខ្ទង់សបាយដាក់ក្នុងចាន ក៏ថ្វាយទានឈ្មោះបាជិគ្គៈ ព្រាហ្មណ៍តែងតែថ្វាយទានដ៏លើសទាំង ៥ យ៉ាងនេះ ។

ព្រាហ្មណ៍នោះ កាលដែលមិនទាន់ឲ្យទានដល់បដិគ្គាហកដែលមកដល់ហើយ រមែងមិនបរិភោគ ។ ព្រោះហេតុនោះ ទើបគាត់មានឈ្មោះថា " បញ្ចគ្គទាយក " ដូច្នេះឯង ។

## ព្រះសាស្តាស្តេចទៅប្រោសព្រាហ្មណ៍និងភរិយា

ព្រះសាស្តាទ្រង់ឃើញធម៌ដែលជាឧបនិស្ស័យនៃផលទាំង ៣ របស់ព្រាហ្មណ៍នោះនិងភរិយារបស់គាត់ ទើបស្តេចទៅក្នុងវេលាបរិភោគរបស់គាត់ ហើយទ្រង់ឈរក្បែរទ្វារ ។ ចំណែកព្រាហ្មណ៍នោះបែរមុខទៅក្នុងផ្ទះ អង្គុយបរិភោគក្បែរមាត់ទ្វារ, គាត់មិនឃើញព្រះសាស្តាដែលទ្រង់ឈរនៅក្បែរទ្វារ ។

ចំណែកកិរិយារបស់គាត់កំពុងបម្រើគាត់ ឃើញព្រះសាស្តាក៏គិតថា “ ព្រាហ្មណ៍នេះថ្វាយទានដ៏លើសក្នុងឋានៈទាំង ៥ ( មុន ) ហើយ ទើបបរិភោគ, ក៏ពេលនេះ ព្រះ-សមណគោតមមកឈរនៅក្បែរទ្វារ, ប្រសិនបើព្រាហ្មណ៍ឃើញព្រះសមណគោតមហើយ

នឹងនាំភត្តរបស់ខ្លួនទៅថ្វាយ, យើងនឹងមិនអាចចម្អិនភត្តដើម្បីព្រាហ្មណ៍នេះម្តងទៀតទេ ” ។ នាងគិតថា “ ព្រាហ្មណ៍នឹងមិនឃើញព្រះសមណគោតមដោយអាការយ៉ាងនេះ ” ទើបបែរខ្នងដាក់ព្រះសាស្តា ឈរឱនចុះបាំងព្រះសាស្តាអំពីខាងក្រោយព្រាហ្មណ៍ ដូចជាបាំងព្រះចន្ទពេញវង់ដោយបាតដៃដូច្នោះ ។ នាងព្រាហ្មណ៍បានឈរដោយអាការដូច្នោះ ក្រឡេកមើលព្រះសាស្តាដោយកន្ទុយភ្នែក ដោយគិតថា “ ព្រះសាស្តាស្តេចទៅហើយ ឬនៅ ” ។

ព្រាហ្មណ៍ឃើញព្រះសាស្តា

ព្រះសាស្តាទ្រង់ឈរនៅក្នុងទីនោះឯង ។ ចំណែកនាងមិនបានពោលថា សូមព្រះអង្គមេត្តាស្តេចទៅប្រោសសត្វខាង

មុខទៀតចុះ ” ព្រោះខ្លាចព្រាហ្មណ៍ឮ, ប៉ុន្តែនាងឱនទៅហើយខ្សឹបៗ ថា “ និមន្តទៅប្រោសសត្វខាងមុខទៀតចុះ ” ។

ព្រះសាស្តាទ្រង់គ្រវីព្រះសិរ្ស ដោយទ្រង់សម្តែងឲ្យដឹងថា “ តថាគតនឹងមិនទៅ ” កាលព្រះពុទ្ធជាគ្រូនៃសត្វលោកទ្រង់គ្រវីព្រះសិរ្ស ដោយទ្រង់សម្តែងឲ្យដឹងថា “ តថាគតនឹងមិនទៅ ” ( ដូច្នោះ ) នាងមិនអាចទប់សំណើចបាន ទើបសើចយ៉ាងខ្លាំង ។

គ្រានោះ ព្រះសាស្តាទ្រង់បញ្ចេញព្រះរស្មីចូលទៅកាន់ផ្ទះ ។ ចំណែកព្រាហ្មណ៍អង្គុយបែរខ្នងដាក់ព្រះសាស្តានោះ បានឮសំឡេងសើចរបស់នាងព្រាហ្មណីផង ក្រឡេកឃើញពន្លឺព្រះរស្មីមានពណ៌ ៦ ប្រការផង ក៏បានឃើញព្រះសាស្តា។

## ព្រាហ្មណ៍ថ្វាយកត្តចំពោះព្រះសាស្តា

ធម្មតា ព្រះពុទ្ធទាំងឡាយមិនទាន់ទ្រង់បង្ហាញព្រះអង្គដល់ជនទាំងឡាយអ្នកដល់ព្រមហើយដោយហេតុ ក្នុងស្រុកឬក្នុងព្រៃទេ រមែងមិនទ្រង់ចៀសចេញទៅ។ ចំណែកព្រាហ្មណ៍ឃើញព្រះសាស្តាហើយ ក៏ពោលថា “ នែនាងដ៏ចម្រើន នាង

មិនប្រាប់ព្រះរាជបុត្រ ដែលស្ដេចមកឈរក្បែរទ្វារដល់យើង ដូច្នេះហើយ យើងជាបុគ្គលត្រូវនាងឲ្យវិនាសហើយ, នាងបាន ធ្វើកម្មដ៏ធ្ងន់ហើយ " ដូច្នេះហើយ ក៏កាន់យកភាជនភត្តដែល ខ្ជួនបរិភោគអស់ពាក់កណ្ដាលហើយ ទៅកាន់សម្នាក់ព្រះ-សាស្ដា ហើយក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយទានដ៏លើសក្នុងឋានៈទាំង ៥ ហើយ ទើប បរិភោគ, ប៉ុន្តែចំណែកភត្តពាក់កណ្ដាលប៉ុណ្ណោះ ដែលខ្ញុំព្រះ អង្គបំបែកត្រង់កណ្ដាលអំពីចំណែកនេះបរិភោគ, ចំណែកនៃ ភត្តមួយចំណែកនៅសល់ សូមព្រះអង្គទទួកយកចំណែកនេះ ជារបស់ព្រះអង្គចុះ " ។

## ព្រាហ្មណ៍ជ្រះថ្លានឹងព្រះតម្រាស់របស់ព្រះសាស្ដា

ព្រះសាស្ដាមិនត្រាស់ថា " តថាគតមិនត្រូវការភត្ត ដែលសល់អំពីអ្នកទេ " ត្រាស់ថា "ម្នាលព្រាហ្មណ៍ ភត្តដ៏ ថ្លៃថ្លាក្ដី ភត្តដែលអ្នកបែងក្នុងទីពាក់កណ្ដាលហើយ បរិភោគ ក្ដី ជារបស់សមគួរដល់តថាគតទាំងអស់, សូម្បីដុំភត្តដែល ប្រព្រឹត្តទៅក្នុងកាលមុន ( បាយកក ) ក៏ជាវត្ថុសមគួរដល់

តថាគតដែរ, ម្នាលព្រាហ្មណ៍ ដ្បិតថា ពួកតថាគតជាអ្នក
អាស្រ័យអាហារដែលអ្នកដទៃឲ្យចិញ្ចឹមជីវិត ដូចជាពួក
ប្រេត ” ហើយត្រាស់ព្រះគាថានេះថា ៖-

ភិក្ខុអ្នកអាស្រ័យអាហារដែលបុគ្គលដទៃឲ្យចិញ្ចឹម
ជីវិត បានដុំបាយឯណា អំពីចំណែកដ៏ថ្លៃថ្នាក្ដី អំពី
ចំណែកពាក់កណ្ដាលក្ដី អំពីចំណែកដ៏សេសសល់
ក្ដី ភិក្ខុនោះជាអ្នកមិនគួរសរសើរដុំបាយនោះ, និង
មិនគួរតិះដៀល ហើយគប្បីធានដុំបាយនោះ, ធីរ-
ជនទាំងឡាយ រមែងសរសើរភិក្ខុនោះថា ជាមុនី ។

ព្រាហ្មណ៍លុះបានស្ដាប់ព្រះគាថានោះហើយ ក៏មាន
ចិត្តជ្រះថ្លា ហើយគិតថា “ ឱ ! គួរអស្ចារ្យពិតមែនហ្ន៎, ព្រះ
រាជបុត្រអ្នកជាម្ចាស់នៃទ្វីប មិនបានត្រាស់ថា “ តថាគតមិន
ត្រូវការភត្តដែលសល់អំពីអ្នកទេ នៅត្រាស់យ៉ាងនោះទៀត”
ហើយឈរនៅក្បែរទ្វារនោះឯង ទូលសួរបញ្ហាចំពោះព្រះសា
ស្ដាថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ហៅសាវក

របស់ព្រះអង្គថា “ភិក្ខុដោយហេតុមានប្រមាណប៉ុន្មាន ? ឈ្មោះថាជាភិក្ខុ” ។

## បុគ្គលអ្នកមិនត្រេកអរមិនជាប់ជំពាក់និងនាមរូបឈ្មោះថាភិក្ខុ

ព្រះសាស្តាទ្រង់ពិចារណាមើលថា “ធម្មទេសនាដូចម្ដេចហ្ន៎ ទើបជាគ្រឿងសប្បាយដល់ព្រាហ្មណ៍នេះ” ទ្រង់ព្រះតម្រិះថា “ជនទាំងពីរនេះ ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថាកស្សប បានស្ដាប់ពាក្យរបស់ភិក្ខុទាំងឡាយអ្នកពោលថានាមរូប, ការដែលតថាគតមិនលះបង់នាមរូប ហើយសម្ដែងធម៌ដល់ជនទាំងពីរនោះ រមែងគួរ” ហើយទើបត្រាស់ថា “ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមិនត្រេកអរ មិនជាប់ជំពាក់ មិនប្រកាន់មាំនូវនាមរូប ឈ្មោះថាភិក្ខុ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖-

**៦ សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណា មិនមានសេចក្ដីប្រកាន់ក្នុង

នាម និងរូប ថាជារបស់អញ ដោយប្រការទាំង
ពួង មួយទៀត បុគ្គលណា មិនសោកស្ដាយ
ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង
តថាគតហៅថា ភិក្ខុ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សព្វសោ** គឺក្នុងនាមរូប ដែលប្រព្រឹត្តទៅដោយអំណាចខន្ធ ៥ គឺនាមខន្ធ ៤ មាន វេទនាខន្ធជាដើម និងរូបក្ខន្ធ ។

បទថា **មមាយិតំ** សេចក្ដីថា សេចក្ដីប្រកាន់ថា យើង ឬថា របស់យើង មិនមានដល់បុគ្គលណា ។

បាទព្រះគាថាថា **អសតា ច ន សោចតិ** សេចក្ដីថា កាលនាមរូបនោះអស់ទៅនិងសូន្យទៅ បុគ្គលណាមិនសោក សៅ គឺមិនក្ដៅក្រហាយថា “រូបរបស់យើងអស់ទៅហើយ ។ល។ វិញ្ញាណរបស់យើងអស់ទៅហើយ គឺឃើញតាមការ ពិតថា នាមរូបដែលមានការអស់ទៅនិងសូន្យទៅជាធម្មតា នោះ បានអស់ទៅហើយ” ។

បទថា **ស វេ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ បានដល់ អ្នកវៀរចាកការប្រកាន់នាមរូបថាជារបស់យើងក្តី អ្នកមិនសោកសៅចំពោះនាមរូបនោះក្តី ព្រះសាស្តាត្រាស់ហៅថា ភិក្ខុ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍និងព្រាហ្មណីតាំងនៅក្នុងព្រះអនាគាមិផល, ទេសនាជាគុណជាតិមានប្រយោជន៍សូម្បីដល់បរិស័ទដែលប្រជុំគ្នានោះ ។

រឿងព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយក ចប់

## ៧ រឿងភិក្ខុច្រើនរូប

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ធម្មទេសនានេះថា “ **មេត្តាវិហារី** ” ជាដើម ។

# ប្រវត្តិព្រះសោណកុដិកណ្ណៈ

សេចក្តីពិស្តារថា សម័យមួយ កាលព្រះមហាកច្ចានៈអាស្រ័យកុររឃរនគរ ក្នុងអវន្តីជនបទ លើភ្នំឈ្មោះបវត្តៈ, ឧបាសកឈ្មោះសោណកុដិកណ្ណៈ ជ្រះថ្លានឹងធម្មកថារបស់ព្រះថេរៈ ប្រាថ្នានឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ សូម្បីត្រូវព្រះថេរៈហាមអស់ ២ ដងថា “ នែសោណៈ ព្រហ្មចរិយៈមានកត្តុតែមួយពេល ដេកតែមួយពេល រហូតជីវិត ជាអំពើដែលបុគ្គលធ្វើបានដោយក្រ ” ក៏ជាអ្នកកើតឧស្សាហ៍យ៉ាងខ្លាំងក្លាក្នុងការបព្វជ្ជា ក្នុងវារៈទី ៣ អង្វរព្រះថេរៈ បព្វជ្ជាហើយ ដោយកាលកន្លងទៅ ៣ ឆ្នាំ ទើបបានឧបសម្បទាព្រោះទក្ខិណាបថជនបទមានភិក្ខុតិច ជាអ្នកប្រាថ្នានឹងគាល់ព្រះសាស្តាក្នុងទីចំពោះព្រះភក្ត្រ ទើបថ្វាយបង្គំលាព្រះ-ឧបជ្ឈាយ៍ ទទួលយកបណ្តាំដែលព្រះឧបជ្ឈាយ៍ឲ្យហើយទៅកាន់វត្តជេតពន ដល់វត្តជេតពនហើយ ចូលទៅថ្វាយបង្គំព្រះសាស្តា បានទទួលការបដិសណ្ឋារៈដែលព្រះសាស្តាទ្រង់ធ្វើហើយ ជាអ្នកមានសេនាសនៈ ដែលព្រះសាស្តាទ្រង់

អនុញ្ញាតហើយក្នុងព្រះគន្ធកុដិជាមួយតែម្តង ញុំាងរាត្រីចំណែក ច្រើនឲ្យកន្លងទៅខាងក្រៅ ( កណ្តាលវាល ) ហើយចូលទៅកាន់ព្រះគន្ធកុដិក្នុងវេលារាត្រី ញុំាងចំណែកនៃរាត្រីនោះឲ្យកន្លងទៅហើយ ក្នុងសេនាសនៈសម្រាប់ខ្លួន ក្នុងវេលាជិតភ្លឺ កាលដែលព្រះសាស្តាត្រាស់ឲ្យសូធ្យព្រះសូត្រ ក៏បានសូធ្យព្រះសូត្រទាំងអស់ ១៦ សូត្រ ជារបៀបសារកញ្ញ ដែលចាត់ជាអដ្ឋកវគ្គ ។

គ្រានោះ ព្រះមានព្រះភាគកាលនឹងទ្រង់អនុមោទនាឲ្យក្រៃលែង ទើបបានប្រទានសាធុការដល់លោកក្នុងវេលាចប់សរកញ្ញាថា “ ម្នាលភិក្ខុ ប្រពៃហើយ ” ។

ភុម្មទេវតា នាគ និងគ្រុឌ បានឮសាធុការដែលព្រះ-សាស្តាទ្រង់ប្រទានហើយ ក៏បានឲ្យសាធុការដែរ, សំឡេងសាធុការបានមានក្នុងទីជាមួយគ្នា រហូតដល់ព្រហ្មលោកយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងគ្រានោះ សូម្បីទេវតាដែលស្ថិតនៅក្នុងផ្ទះរបស់មហាឧបាសិកា អ្នកជាមាតារបស់ព្រះថេរៈ ក្នុងក្រុងកុររឃរ

នគរ ដែលនៅឆ្ងាយអំពីវត្តជេតពនប្រមាណ ១២០ យោជន៍ ក៏បានឲ្យសាធុការដោយសំឡេងដ៏លាន់ឮដែរ ។

គ្រានោះ មហាឧបាសិកា សួរទេវតានោះថា “ នរណានុ៎ះ ឲ្យសាធុការ ?” ។

ទេវតា. ម្នាលប្អូនស្រី ខ្ញុំ ។

មហាឧបាសិកា. អ្នកជានរណា ?

ទេវតា. ខ្ញុំជាទេវតា អាស្រ័យនៅក្នុងផ្ទះរបស់អ្នក ។

មហាឲ្យបាសិកា. កាលពីមុន ហេតុអ្វី អ្នកមិនឲ្យសាធុការដល់ខ្ញុំ ? ថ្ងៃនេះទើបឲ្យ ។

ទេវតា. ខ្ញុំមិនបានឲ្យសាធុការដល់អ្នកទេ ។

មហាឧបាសិកា. កាលបើដូច្នោះ អ្នកឲ្យសាធុការដល់នរណា ?

ទេវតា. ខ្ញុំឲ្យដល់ព្រះសោណកុដិកណ្ណត្ថេរ ជាបុត្ររបស់អ្នក ។

មហាឧបាសិកា. បុត្ររបស់ខ្ញុំធ្វើអ្វី ?

ទេវតា. ថ្ងៃនេះ បុត្ររបស់អ្នកនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ហើយសម្តែងធម៌ថ្វាយព្រះសាស្តា, ព្រះ-សាស្តាទ្រង់ព្រះសណ្តាប់ធម៌នៃបុត្ររបស់អ្នក ហើយក៏ទ្រង់ជ្រះថ្លា ទើបបានប្រទានសាធុការ, ព្រោះហេតុនោះ សូម្បីខ្ញុំក៏ឲ្យសាធុការដល់ព្រះថេរៈនោះដែរ, ក៏ព្រោះទទួលសាធុការរបស់ព្រះសម្មាសម្ពុទ្ធ ទើបកើតសាធុការជាសំឡេងតែមួយចាប់តាំងអំពីភុម្មទេវា រហូតដល់ព្រហ្មលោក ។

មហាឧបាសិកា. នែអ្នកចម្រើន បុត្ររបស់ខ្ញុំសម្តែងធម៌ថ្វាយព្រះសាស្តា ឬក៏ព្រះសាស្តាសម្តែងធម៌ដល់បុត្ររបស់ខ្ញុំ ?

ទេវតា. បុត្ររបស់អ្នកសម្តែងធម៌ថ្វាយព្រះសាស្តា ។

កាលទេវតាពោលយ៉ាងនោះ, បីតិ ៥ ប្រការ កើតឡើងដល់ឧបាសិកា ផ្សាយទៅទូទាំងសរីរៈទាំងអស់ ។ គ្រានោះ មហាឧបាសិកានោះបានគិតយ៉ាងនេះថា “ ប្រសិនបើបុត្ររបស់យើងនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ហើយនៅអាចសម្តែងធម៌ថ្វាយព្រះសាស្តាបាន, ក៏នឹងអាចសម្តែង

ធម៌ដើម្បីយើងផងដែរ, យើងនឹងញុំាងបុគ្គលឲ្យស្តាប់ធម៌ ហើយស្តាប់ធម្មកថា ក្នុងកាលបុត្ររបស់យើងមកដល់ ” ។

## ព្រះសោណៈទូលសូមពរ ៥ ប្រការអំពីព្រះសាស្តា

ចំណែកព្រះសោណត្ថេរ កាលព្រះសាស្តាទ្រង់ប្រទានសាធុការហើយ, ក៏គិតថា “ ពេលនេះ ជាពេលសមគួរក្រាបទូលបណ្តាំដែលព្រះឧបជ្ឈាយ៍ឲ្យមក ” ដូច្នេះហើយ ទើបទូលសូមពរ ៥ ប្រការ អំពីព្រះមានព្រះភាគ ចាប់តាំងពីការឧបសម្បទាដោយគណៈសង្ឃមានភិក្ខុទ្រទ្រង់វិន័យជាគម្រប់ ៥ ក្នុងជនបទទាំងឡាយដែលតាំងនៅជាយដែនហើយ នៅក្នុងសម្នាក់ព្រះសាស្តា ២-៣ ថ្ងៃប៉ុណ្ណោះ ថ្វាយបង្គំលាព្រះសាស្តាថា “ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅសួរសុខទុក្ខព្រះឧបជ្ឈាយ៍ ” បានចេញអំពីវត្តជេតពន ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ដោយលំដាប់ ។

ថ្ងៃស្អែកឡើង ព្រះថេរនាំព្រះសោណនោះត្រាច់ទៅបិណ្ឌបាត បានទៅដល់ទ្វារផ្ទះរបស់ឧបាសិកាជាមាតា ។

ចំណែកឧបាសិកានោះ ឃើញបុត្រហើយក៏ត្រេកអរ ថ្វាយហើយ អង្គាសដោយគោរពហើយសួរថា "នៃលោកកូន បានឮថា លោកកូននៅក្នុងព្រះគន្ធកុដិជាមួយនិង ព្រះសាស្ដាហើយសម្ដែងធម្មកថាថ្វាយព្រះសាស្ដាពិតមែនឬ ?"

ព្រះសោណៈ. រឿងនេះ អ្នកណាប្រាប់ញោម ?

មហាឧបាសិកា. បពិត្រលោកកូន ទេវតាដែលនៅក្នុងផ្ទះនេះ ឲ្យសាធុការដោយសំឡេងដ៏លាន់ឮ, កាលញោមសួរថា អ្នកណានោះ ក៏ពោលថា ខ្ញុំ ហើយប្រាប់យ៉ាងនោះឯង, ព្រោះស្ដាប់រឿងនោះ ញោមក៏បានគិតយ៉ាងនេះថា ប្រសិនបើបុត្ររបស់យើងសម្ដែងធម្មកថាថ្វាយព្រះសាស្ដាបាន, លោកក៏អាចសម្ដែងធម៌ដល់យើងបានដែរ ។

គ្រានោះ មហាឧបាសិកាពោលទៅកាន់ព្រះសោណៈនោះថា "នៃលោកកូន លោកកូនសម្ដែងធម៌ចំពោះព្រះភក្ត្រព្រះសាស្ដាបាន, លោកកូនក៏អាចសម្ដែងធម៌សូម្បីដល់ញោមបានដែរ, ក្នុងថ្ងៃឯណោះ ញោមនឹងប្រកាសឲ្យគេមក

ស្តាប់ធម៌ ហើយនឹងស្តាប់ធម៌របស់លោកកូន" ព្រះសោណៈក៏ទទួលនិមន្ត ។

ឧបាសិកាគិតថា "យើងថ្វាយទានចំពោះភិក្ខុសង្ឃ ធ្វើការបូជាហើយនឹងស្តាប់ធម្មកថានៃបុត្ររបស់យើង " ទើបទុកទាសីម្នាក់ប៉ុណ្ណោះឲ្យនៅចាំផ្ទះ ហើយបាននាំយកបរិវារ-ជនទាំងអស់ទៅ ដើម្បីស្តាប់ធម្មកថារបស់បុត្រដែលនឹងឡើងកាន់ធម្មាសនៈដែលប្រដាប់តុបតែងហើយ ក្នុងមណ្ឌបដែលខ្ញុំនឲ្យគេសាងទុកខាងក្នុងព្រះនគរ ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ សម្តែងធម៌ ។

## ពួកចោរចូលប្លន់ផ្ទះមហាឧបាសិកា

ក៏ក្នុងកាលនោះ ពួកចោរ ៩០០ ឃ្លាំមើលចន្លោះក្នុងផ្ទះរបស់ឧបាសិកានោះ ។ ក៏ផ្ទះរបស់ឧបាសិកានោះ ឡោមព័ទ្ធដោយកំពែង ៧ ជាន់ ប្រកបដោយខ្លោងទ្វារ ៧ ។ គេចងសុនខកាចៗ ទុកក្នុងទីនោះៗ គ្រប់ៗ ខ្លោងទ្វារ, មិនត្រឹមតែប៉ុណ្ណោះ គេជីកគូត្រង់ទីទឹកធ្លាក់អំពីជំបូលព្ធដ៏ខាងក្នុងផ្ទះ ហើយក៏ដាក់សំណពេញគូនោះ វេលាថ្ងៃ សំណនោះរលាយ

ដោយកម្តៅថ្ងៃ ហាក់ដូចជាពុះហើយតាំងនៅ, វេលាយប់ សំណនោះកក ហាក់ដូចជាវត្ថុរឹង, គេកប់អន្ទប់ដែកដ៏ធំ តម្រៀបគ្នាក្នុងផ្ទៃនៃគូនោះ ដោយមិនមានចន្លោះ, ពួកចោរ ទាំងនោះមិនបានឱកាស ព្រោះអាស្រ័យការរក្សានេះ និង ព្រោះអាស្រ័យឧបាសិកានោះនៅខាងក្នុងផ្ទះ ថ្ងៃនោះដឹងថា ឧបាសិកានោះទៅស្តាប់ធម៌ ក៏ជីកឧមង្គចូលទៅកាន់ផ្ទះ តាម ចំណែកខាងក្រោមគូដែលពេញដោយសំណ និងអន្ទប់ដែក នោះ ហើយបញ្ជូនមេចោរទៅកាន់សម្នាក់របស់ឲ្យឧបាសិកា នោះ ដោយប្រាប់ថា ប្រសិនបើឧបាសិកានោះ បានដឹងថា ពួកយើងចូលកាន់ផ្ទះរបស់គេហើយ ត្រឡប់មកកាន់ផ្ទះ, លោកចូរប្រហារឧបាសិកានោះឲ្យស្លាប់ដោយដាវ " ។ មេ ចោរនោះ បានទៅឈរនៅក្នុងសម្នាក់របស់ឧបាសិកានោះ ។

ចំណែកពួកចោរ អុជប្រទីបឲ្យបំភ្លឺខាងក្នុងផ្ទះ ហើយ បើកទ្វារបន្ទប់ដាក់កហាបណៈ ។ នាងទាសីឃើញចោរនោះ ហើយ ក៏ទៅកាន់សម្នាក់ឧបាសិកា ហើយប្រាប់ថា " បពិត្រ

នាងម្ចាស់ ចោរដ៏ច្រើនចូលទៅកាន់ផ្ទះ បើកទ្វារបន្ទប់ដាក់កហាបណៈហើយ ” ។

មហាឧបាសិកា. ពួកចោរចូរនាំយកកហាបណៈដែលខ្ទួនឃើញទៅចុះ, យើងកំពុងស្តាប់ធម្មកថានៃបុត្ររបស់យើង, នាងកុំធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌របស់យើង, នាងចូរទៅផ្ទះចុះ ។

ចំណែកពួកចោរ ធ្វើបន្ទប់ដាក់កហាបណៈឲ្យទទេហើយ ក៏បើកបន្ទប់ដាក់ប្រាក់ ។ នាងទាសីនោះក៏ទៅប្រាប់ឧបាសិកាម្តងទៀត ។ ឧបាសិកានិយាយថា “ ពួកចោរចូរជញ្ជូនយកទ្រព្យដែលខ្ទួនត្រូវការទៅចុះ, យើងកំពុងស្តាប់ធម្មកថានៃបុត្ររបស់យើង នាងកុំធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌របស់យើងឡើយ ” ហើយក៏ឲ្យនាងទាសីនោះទៅផ្ទះវិញទៀត ។

ពួកចោរធ្វើបន្ទប់ដាក់ប្រាក់ឲ្យទទេហើយ ក៏បើកបន្ទប់ដាក់មាស ។ នាងទាសីនោះក៏ទៅប្រាប់រឿងនោះដល់ឧបាសិកាទៀត ។

គ្រានោះ ឧបាសិកាហៅនាងទាសីមក ហើយនិយាយថា “ នែហាងដ៏ចម្រើន នាងមកកាន់សម្នាក់របស់យើងអស់ច្រើនដងហើយ សូម្បីយើងប្រាប់ថា ពួកចោរចូរយកទ្រព្យតាមការពេញចិត្តចុះ, ព្រោះយើងកំពុងស្តាប់ធម្មកថានៃបុត្ររបស់យើង, នាងកុំធ្វើឲ្យអន្តរាយដល់ការស្តាប់ធម៌របស់យើងក៏មិនអើពើនឹងពាក្យរបស់យើង ចុះឡើងៗ ដដែលៗ, ឥឡូវនេះ ប្រសិនបើនាងនឹងមកទៀត, យើងនឹងដឹងកិច្ចដែលគួរធ្វើចំពោះនាង, នាងចូរត្រឡប់ទៅផ្ទះចុះ ” លុះពោលដូច្នោះហើយក៏បញ្ជូននាងទាសីឲ្យត្រឡប់ទៅផ្ទះ ។

ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌

មេចោរបានឮពាក្យរបស់ឧបាសិកានោះហើយ គិតថា “ កាលពួកយើងនាំទ្រព្យស្ត្រីបែបនេះទៅ រន្ទះបាញ់នឹងបាញ់បំបែកក្បាលរបស់ពួកយើង ” ដូច្នេះហើយ ក៏ទៅកាន់សម្នាក់ពួកចោរ ប្រាប់ថា “ អ្នកទាំងឡាយ ចូរជញ្ជូនយកទ្រព្យរបស់ឧបាសិកាទៅទុកកន្លែងដើមដោយរហ័ស ” ។ ចោរទាំងនោះ

ញុំាំងបន្ទប់ដាក់កហាបណៈឲ្យពេញដោយកហាបណៈ ញុំាំងបន្ទប់ប្រាក់ និងបន្ទប់មាសឲ្យពេញទៅដោយប្រាក់និងមាស។

បានឮថា ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ជាធម្មតា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា :-

ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌, ធម៌
ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំសេចក្តី
សុខមកឲ្យ, នេះជាអានិសង្សក្នុងធម៌ដែល
បុគ្គលប្រព្រឹត្តល្អហើយ, អ្នកមានប្រក្រតី
ប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ពួកចោរបានទៅឈរនៅក្នុងទីជាទីស្តាប់ធម៌ ។រីឯព្រះថេរសម្តែងធម៌ហើយ កាលរាត្រីភ្លឺច្បាស់ ក៏ចុះចាកអាសនៈ, ខណៈនោះមេចោរក្រាបចុះទៀបជើងរបស់ឧបាសិកា សូមទោសថា "ព្រះនាងម្ចាស់ មេត្តាអត់ទោសឲ្យខ្ញុំផងចុះ" ។

ឧបាសិកា. នែអ្នកដ៏ចម្រើន តើមានបញ្ហាអ្វី ?

មេចោរ. ខ្ញុំចងអាឃាត់ចំពោះនាង ប្រាថ្នានឹងសម្លាប់នាង ទើបបានមកឈរនៅទីនេះ ។

ឧបាសិកា. បើដូច្នោះ ខ្ញុំអត់ទោសឲ្យ ។

## ពួកចោរជ្រះថ្លាសូមព្រះសោណៈបួស

សូម្បីពួកចោរដ៏សេស ក៏បានធ្វើដូច្នោះដែរ កាលឧបាសិកាពោលថា "នែអ្នកទាំងឡាយ ខ្ញុំអត់ទោសឲ្យ" ក៏ពោលថា "បពិត្រនាងម្ចាស់ ប្រសិនបើនាងអត់ទោសឲ្យពួកខ្ញុំ, សូមនាងញុំាងពួកខ្ញុំឲ្យបានបព្វជ្ជាក្នុងសំណាក់បុត្ររបស់នាងផងចុះ" ។ ឧបាសិកានោះថ្វាយបង្គំបុត្រហើយ ពោលថា "បពិត្រលោកកូន ចោរទាំងនេះជ្រះថ្លានឹងគុណរបស់ញោម និងធម្មកថារបស់លោកកូន ក៏នាំគ្នាសូមបព្វជ្ជា, សូមលោកកូនបំបួសចោរទាំងនេះចុះ" ។

ព្រះថេរៈពោលថា "ប្រពៃហើយ" ហើយក៏ឲ្យកាត់ជាយសំពត់ដែលចោរទាំងនោះដណ្តប់ ហើយឲ្យយកទៅជ្រលក់និងដីក្រហម ឲ្យចោរទាំងនោះបួសហើយ ឲ្យតាំងនៅក្នុងសីល ។ នៅពេលដែលចោរទាំងនោះឧបសម្បទាហើយ ព្រះថេរបានឲ្យកម្មដ្ឋានផ្សេង ៗ គ្នាដល់ភិក្ខុទាំងនោះ ។ ភិក្ខុ

៥០០ រូបនោះរៀនកម្មដ្ឋាន ៥ យ៉ាងផ្សេង ៗ គ្នាហើយនាំគ្នាឡើងកាន់ភ្នំមួយអន្លុយធ្វើសមណធម៌ក្រោមម្លប់ឈើនោះៗ។

ព្រះសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារដែលមានចម្ងាយ ១២០ យោជន៍ ទ្រង់ពិចារណាមើលភិក្ខុទាំងនោះហើយ ទ្រង់កំណត់ព្រះធម្មទេសនាដោយអំណាចនៃការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ទ្រង់បញ្ចេញព្រះរស្មីទៅហាក់ដូចជាទ្រង់គង់នៅក្នុងទីចំពោះមុខ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖-

៧ មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។
ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ

មា លោហគុឡំ គិលី បមត្តោ
មា តន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។
នត្ថិ ឈានំ អបញ្ញស្ស នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។
តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស អាចារកុសលោ សិយ
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សសិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ម្នាលភិក្ខុ អ្នកចូរស្តោរទូក គឺអត្តភាពនេះ ទូក
ដែលអ្នកស្តោរហើយ នឹងដល់ត្រើយឆាប់ អ្នក
កាត់រាគៈ និងទោសៈបានហើយ អំពីនោះនឹង
អាចដល់នូវព្រះនិព្វាន ។ ភិក្ខុ គប្បីកាត់
ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់
ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើន
ឥន្ទ្រិយ ៥ តទៅ ភិក្ខុកន្លងកិលេសជាគ្រឿង
ជំពាក់ ៥ ( រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ )
បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។
ម្នាលភិក្ខុ អ្នកចូរពិនិត្យផង ចូរជាអ្នកកុំប្រមាទ
ផង ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំ
ប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាល
ភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះ
ឡើយ ។ ការពិនិត្យមិនមានដល់បុគ្គលអ្នកមិន
មានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិន
ពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា

បុគ្គលនោះឯង ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។ សេចក្តីត្រេកអរដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ ភិក្ខុពិចារណាការកើតឡើងនិងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។ គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្តីសន្តោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ( ម្នាលភិក្ខុ ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។ ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ

គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំង ២ នោះ អ្នកនឹងបានបាមោជ្ជច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មេត្តាវិហារី** សេចក្ដីថា បុគ្គលអ្នកធ្វើកម្មក្នុងកម្មដ្ឋានដែលប្រកបដោយមេត្តាក្ដី អ្នកញ៉ាំងឈានពួក ៣ និងពួក ៤ ឲ្យកើតឡើងដោយអំណាចនៃមេត្តាហើយតាំងនៅក្ដី ឈ្មោះថា អ្នកមានប្រក្រតីនៅដោយមេត្តាពិត ៗ ។

ពាក្យថា **បសន្នោ** សេចក្ដីថា ក៏ភិក្ខុណាជាអ្នកជ្រះថ្លាហើយ, អធិប្បាយថា រមែងបណ្ដុះសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ពីរបទថា **បទំ សន្តំ** នោះ ជាឈ្មោះនៃព្រះនិព្វាន ។ ពិតណាស់ ភិក្ខុបែបនោះ រមែងសម្រេចបាន ។ អធិប្បាយថា រមែងជួបប្រសព្វនូវព្រះនិព្វានដែលជាចំណែកនៃសេចក្ដីស្ងប់ ឈ្មោះថាជាទីចូលទៅស្ងប់សង្ខារ ព្រោះសង្ខារទាំងពួង

ជាសភាវៈស្ងប់ហើយ ដែលមានឈ្មោះថាថា សុខ ព្រោះជាសុខយ៉ាងក្រៃលែង ។

បាទព្រះគាថាថា **សិញ្ច ភិក្ខុ ឥមំ នាវំ** សេចក្ដីថា ម្នាលភិក្ខុ ចូរអ្នកស្ដារទូក គឺអត្តភាពនេះ ដែលមានទឹក គឺមិច្ឆាវិតក្កចេញ ។

បាទព្រះគាថាថា **សិត្តា តេ លហុមេស្សតិ** សេចក្ដីថា ដូចយ៉ាងថា ទូកដែលពេញប្រៀបដោយទឹកក្នុងមហាសមុទ្រ ជាទូកដែលគេស្ដារហើយ ព្រោះភាវៈនៃទឹកនោះជារបស់ដែលគេបិទប្រហោង ហើយស្ដារ ជាទូកស្រាល មិនលិចចុះក្នុងមហាសមុទ្រ រមែងស្ទុះទៅកាន់កំពង់បានឆាប់រហ័សយ៉ាងណា, ទូកគឺអត្តភាពរបស់អ្នកនេះ ក៏ពេញហើយដោយទឹក គឺមិច្ឆាវិតក្កដូច្នោះដែរ ដែលអ្នកស្ដារហើយ ព្រោះភាវៈនៃទឹក គឺមិច្ឆាវិតក្កដែលកើតឡើងហើយ ជារបស់ដែលអ្នកបិទប្រហោងទាំងឡាយ មានចក្ខុទ្វារជាដើម ដោយការសង្រួម ស្ដារចេញហើយទើបស្រាល មិនលិចចុះក្នុងសង្សារវដ្ដ នឹងដល់ព្រះនិព្វាន ។

បទថា **ឆេត្វា** ជាដើម សេចក្ដីថា អ្នកគប្បីកាត់ចំណង គឺរាគៈ និងទោសៈ លុះកាត់ចំណងទាំងនោះបានហើយ នឹងសម្រេចព្រះអរហត្ត, អធិប្បាយថា ពេលនោះគឺកាលក្រោយមក នឹងសម្រេចអនុបាទិសេសនិព្វាន ។

ពីរបទថា **បញ្ច ឆិន្ទេ** គឺគប្បីកាត់សំយោជនៈចំណែកខាងក្រោម ៥ យ៉ាង ដែលញុំាងសត្វឲ្យដល់អបាយខាងក្រោម ដោយពួក ៣ នៃមគ្គខាងក្រោម ដូចបុរសកាត់ខ្សែដែលចងជើងដោយសស្ត្រាដូច្នោះ ។

ពីរបទថា **បញ្ច ជហេ** សេចក្ដីថា គប្បីលះបង់ គឺផ្ដាច់ចោល, អធិប្បាយថា គប្បីកាត់សំយោជនៈខាងលើ ៥ យ៉ាង ដែលញុំាងសត្វឲ្យដល់ទេវលោកជាន់ខ្ពស់ ដោយព្រះអរហត្តមគ្គ ដូចបុរសកាត់ខ្សែដែលចងព្ធដ៏កដូច្នោះ ។

បាទព្រះគាថាថា **បញ្ច ឧត្តរិ ភាវយេ** គឺគប្បីចម្រើនឥន្ទ្រិយ ៥ មានសទ្ធាជាដើមឲ្យច្រើន ដើម្បីប្រយោជន៍ដល់ការលះសំយោជនៈខាងលើ ។

បទថា **បញ្ចសង្គាតិគោ** សេចក្ដីថា កាលបើដូច្នោះ ម្នាលភិក្ខុ អ្នកឈ្មោះថា កន្លងកិលេសជាគ្រឿងជាប់ជំពាក់ ៥ យ៉ាងបានហើយ ព្រោះឈានកន្លងកិលេសដែលជាគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានះ និងទិដ្ឋិ ៥ យ៉ាង ព្រះសាស្ដាត្រាស់ហៅថា " អ្នកឆ្លងអន្លង់បាន ", អធិប្បាយថា ភិក្ខុនោះ ព្រះសាស្ដាត្រាស់ហៅថា " អ្នកឆ្លងឱឃៈ ៤ បានដោយពិត " ។

ពីរបទថា **ឈាយ ភិក្ខុ** សេចក្ដីថា ម្នាលភិក្ខុ ចូរអ្នកសម្លឹងមើលដោយអំណាចនៃឈាន ២ យ៉ាង ( អារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ) ហើយឈ្មោះថា កុំប្រមាទ ព្រោះជាអ្នកមានប្រក្រតីមិនប្រមាទក្នុងកាយកម្មជាដើម ។

បទថា **ភមស្សុ** គឺចិត្តរបស់អ្នកចូរកុំវិលទៅរកកាមគុណ ៥ យ៉ាងឡើយ ។

បទថា **មា លោហគុឡំ** សេចក្ដីថា ក៏ជនទាំងឡាយអ្នកប្រមាទហើយដោយអំណាចការធ្វេសប្រហែស មានការបណ្ដែតបណ្ដោយសតិជាលក្ខណៈ រមែងទំពាស៊ីដុំលោហៈ

ដ៏ក្ដៅក្នុងនរក, ព្រោះហេតុនោះ ទើបតថាគតពោលទៅកាន់អ្នក, អ្នកកុំជាអ្នកប្រមាទ ទំពាស៊ីដុំលោហៈ, កុំជាអ្នកត្រូវភ្លើងឆេះរោលរាលក្នុងនរក ហើយកន្ទក់កន្ទេញថា “ នេះទុក្ខ នេះទុក្ខដូច្នេះឡើយ ” ។

ពីរបទថា **នត្ថិ ឈានំ** សេចក្ដីថា ឈ្មោះថា ឈានរមែងមិនមានដល់អ្នកមិនមានបញ្ញា ដោយបញ្ញាប្រកបដោយព្យាយាមជាគ្រឿងញុំាងឈានឲ្យកើតឡើង ។

ពីរបទថា **នត្ថិ បញ្ញា** សេចក្ដីថា បញ្ញាមានលក្ខណៈដូចដែលព្រះមានព្រះភាគត្រាស់ទុកថា “ ភិក្ខុអ្នកមានចិត្តតាំងមាំហើយ រមែងដឹង រមែងឃើញតាមការពិត ” រមែងមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ។

បាទព្រះគាថាថា **យម្ហិ ឈានញ្ច បញ្ញា ច** សេចក្ដីថា ឈាន និងបញ្ញាសូម្បីទាំង ២ នេះមាននៅក្នុងបុគ្គលណា, បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

បាទព្រះគាថាថា **សុញ្ញាគារំ បវិដ្ឋស្ស** គឺអ្នកអង្គុយដោយមិនលះបង់កម្មដ្ឋាន ដោយការធ្វើកម្មដ្ឋានទុកក្នុងចិត្តក្នុងឱកាសដ៏ស្ងាត់ណាមួយ ។

បទថា **សន្តចិត្តស្ស** គឺអ្នកមានចិត្តស្ងប់ហើយ ។

បទថា **សម្មា** ជាដើម សេចក្តីថា សេចក្តីត្រេកអរដែលមិនមែនជារបស់មនុស្ស ពោលគឺវិបស្សនាក្តី សេចក្តីត្រេកអរដែលជាទិព្វ ពោលគឺសមាបត្តិ ៨ ក្តី រមែងមាន, អធិប្បាយថា រមែងកើតឡើងដល់បុគ្គលអ្នកឃើញច្បាស់នូវធម៌ដោយហេតុ ដោយការណ៍ ។

បាទព្រះគាថាថា **យតោ យតោ សម្មសតិ** សេចក្តីថា ធ្វើកម្មក្នុងអារម្មណ៍ ៣៨ ប្រការ ដោយអាការណាៗ, គឺធ្វើកម្មក្នុងកាលទាំងឡាយ មានកាលមុនភត្តជាដើម ក្នុងកាលណាៗ ដែលខ្ជិនពេញចិត្តហើយ, ឬធ្វើកម្មក្នុងកម្មដ្ឋានដែលខ្ជិនពេញចិត្តហើយ ឈ្មោះថា រមែងពិចារណាឃើញ ។

បទថា **ឧទយព្វយំ** គឺនូវការកើតឡើងនៃខន្ធទាំង ៥ ដោយលក្ខណៈ ២៥ និងការវិនាសទៅនៃខន្ធ ៥ ដោយលក្ខណៈ ២៥ ដូចគ្នា ។

បទថា **បីតិបាមោជ្ជំ** គឺកាលពិចារណាការកើតឡើង និងការវិនាសទៅនៃខន្ធទាំងឡាយយ៉ាងនេះ ឈ្មោះថា រមែងបានបីតិនិងបាមោជ្ជក្នុងធម៌ ។

បទថា **អមតំ** សេចក្តីថា កាលនាមរូបព្រមទាំងបច្ច័យជាសភាវៈប្រាកដឡើង បីតិនិងបាមោជ្ជដែលកើតឡើងហើយនោះ ឈ្មោះថា ជាអមតៈរបស់អ្នកដឹងច្បាស់ទាំងឡាយ គឺជារបស់បណ្ឌិតដោយពិត ព្រោះបីតិ និងបាមោជ្ជជាធម៌ដែលញ៉ាំងសត្វឲ្យដល់អមតមហានិព្វាន ។

បាទព្រះគាថាថា **តត្រាយមាទិ ភវតិ** គឺ នេះជាខាងដើម គឺបីតិ និងបាមោជ្ជនេះ ជាឋានៈមាននៅខាងដើមក្នុងអមតធម៌នោះ ។

ពីរបទថា **ឥធ បញ្ញស្ស** គឺមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ។ ឥឡូវនេះ ព្រះសាស្តាកាលនឹងទ្រង់

សម្តែងឋានៈដែលជាខាងដើម ដែលព្រះអង្គត្រាស់ថា “អាទិ” នោះ ទើបត្រាស់ពាក្យជាដើមថា “ **ឥន្ទ្រិយគុត្តិ** ” ពិតណាស់ បារិសុទ្ធិសីល ៤ ឈ្មោះថា ជាខាងដើម ។

ការសង្រួមឥន្ទ្រិយ ឈ្មោះថា **ឥន្ទ្រិយគុត្តិ** ក្នុងព្រះគាថានោះ ។ សេចក្តីសន្តោសចំពោះបច្ច័យ ៤ ឈ្មោះថា **សន្តុដ្ឋិ** ។ អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ព្រះសាស្តាត្រាស់ទុកដោយបទថា **សន្តុដ្ឋិ** នោះ ។

ភាពជាអ្នកធ្វើឲ្យបរិបូណ៌នូវសីលដ៏ប្រសើរបំផុត គឺបាតិមោក្ខ ព្រះសាស្តាត្រាស់ទុកដោយបទថា **បាតិមោក្ខេ** ។

បាទព្រះគាថាថា **មិត្តេ ភជស្សុ កល្យាណេ** សេចក្តីថា អ្នកលះបង់សម្លាញ់ដែលមិនសមគួរ មានការងារលះបង់ហើយ ចូរសេព គឺចូរគប់រកកល្យាណមិត្ត អ្នកមានអាជីវៈដ៏បរិសុទ្ធ ព្រោះមានជីវិតប្រកបដោយសារៈ ឈ្មោះថា ជាអ្នកមិនខ្ជិលច្រអូស ព្រោះអាស្រ័យកម្លាំងស្ទួងចិញ្ចឹមជីវិត ។

បាទព្រះគាថាថា **បដិសណ្ឋារវុត្យស្ស** គឺគប្បីជាអ្នកប្រព្រឹត្តបដិសណ្ឋារៈ, ព្រោះជាអ្នកដល់ព្រមដោយអាមិស-

ប្បដិសណ្ឋារៈ និងធម្មប្បដិសណ្ឋារៈ, អធិប្បាយថា គប្បីជាអ្នកធ្វើបដិសណ្ឋារៈ ។

បទថា **អាចារកុសលោ** សេចក្តីថា សូម្បីសីល ក៏ឈ្មោះថា មារយាទ សូម្បីវត្តបដិបត្តិក៏ឈ្មោះថា មារយាទដែរ, គប្បីជាអ្នកឆ្លាត, អធិប្បាយថា គប្បីជាអ្នកឈ្លាសវៃក្នុងមារយាទនោះ ។

បាទព្រះគាថាថា **តតោ បាមោជ្ជពហុលោ** សេចក្តីថា ព្រោះហេតុទាំង ២ នោះ អ្នកនឹងមានបាមោជ្ជច្រើន ព្រោះជាអ្នករីករាយក្នុងធម៌ ដែលកើតឡើងហើយអំពីការប្រព្រឹត្តបដិសណ្ឋារៈ និងអំពីភាពជាអ្នកឈ្លាសក្នុងមារយាទនោះនឹងធ្វើទីបំផុតទុក្ខបាន ។

បណ្តាបទព្រះគាថាទាំងនេះ ដែលព្រះសាស្តាទ្រង់សម្តែងដោយអាការយ៉ាងនេះ កាលចប់ព្រះគាថាមួយៗ ភិក្ខុមួយរយៗ សម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ លើអាសនៈដែលខ្លួនអង្គុយនោះឯង ហោះឡើងទៅកាន់វេហាស៍ ភិក្ខុទាំងនោះសូម្បីទាំងអស់ ឈានកន្លងផ្លូវ

កន្តារ ១២០ យោជន៍តាមផ្លូវអាកាសនោះឯង សរសើរព្រះសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះតថាគត ហើយថ្វាយបង្គំព្រះបាទ ដូច្នេះឯង ។

( រឿងភិក្ខុច្រើនរូប ចប់ )

88888888888888888

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រមាណ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **"វស្សិកា វិយ បុប្ផានិ "** ជាដើម ។

បានឮថា ភិក្ខុទាំងនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា បំពេញសមណធម៌ក្នុងព្រៃ ឃើញផ្កាម្លិះរីកនៅពេលព្រលឹម រោយចាកទងក្នុងវេលាល្ងាច ក៏នាំគ្នាព្យាយាមដោយគិតថា " ពួកយើងនឹងរួចផុតចាកកិលេសមានរាគៈជាដើម មុនផ្កាឈើទាំងឡាយរោយចាកទង " ។

## ភិក្ខុគួរព្យាយាមឲ្យផុតចាកវដ្តទុក្ខ

ព្រះសាស្តាទ្រង់ទតឃើញភិក្ខុទាំងនោះហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីព្យាយាយមដើម្បីផុតចាកវដ្តទុក្ខឲ្យបាន ដូចផ្កាឈើដែលរោយចាកទងដូច្នោះ" ទ្រង់គង់នៅឯព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ហើយត្រាស់ព្រះគាថានេះថា ៖-

**៨. វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ**

*ឯវំ រាគញ្ច ទោសញ្ច  វិប្បមុញ្ចេថ ភិក្ខវោ ។*

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជំរុះរាគនិងទោសចេញ  ដូចម្ទិះជំរុះផ្កាទាំងឡាយដែលស្វិតហើយ ដូច្នោះ ។

**អធិប្បាយគាថា**

ម្ទិះ ឈ្មោះថា **វស្សិកា** ក្នុងព្រះគាថានោះ ។

បទថា **មទ្ទវានិ** ប្រែថា ស្វិតហើយ ។

លោកអធិប្បាយពាក្យនេះទុកថា ៖-

"វល្លិ៍ម្ទិះ រមែងជម្រុះ គឺរមែងពន្លៃងផ្កាដែលរីកអំពីថ្ងៃម្សិល ក្នុងថ្ងៃស្អែកឡើង ជាផ្កាឈើចាស់ ឲ្យរោយចាកទងយ៉ាងណា,  សូម្បីអ្នកទាំងឡាយ  ក៏គប្បីជម្រុះទោសទាំងឡាយ មានរាគជាដើមដូច្នោះដែរ" ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសូម្បីទាំងអស់តាំងនៅក្នុងព្រះអរហត្ត ដូច្នេះឯង ។

រឿងភិក្ខុប្រមាណ ៥០០ រូប ចប់

## ៩ រឿងព្រះសន្តកាយត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសន្តកាយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា "**សន្តកាយោ**" ជាដើម ។

## ព្រះថេរធ្លាប់កើតជារាជសីហ៍

បានឮថា ការរពឹសដៃរពឹសជើងរបស់ព្រះថេររូបនោះមិនបានមានហើយ ។ លោកជាអ្នកវៀរចាកការពត់កាយ ជាអ្នកមានអត្តភាពស្ងប់ ។

បានឮថា ព្រះថេររូបនោះមកអំពីកំណើតរាជសីហ៍ ។ បានឮថា រាជសីហ៍ទាំងឡាយ កាន់យកអាហារក្នុងថ្ងៃមួយហើយ ចូលទៅកាន់គុហាប្រាក់ គុហាមាស គុហាកែវមណី និងគុហាកែវប្រពាឡ គុហាណាមួយ ដេកលើលំអិតមនោ-សិលានិងហរិតាលសិលាអស់ ៧ ថ្ងៃ ថ្ងៃទី ៨ ក្រោកឡើងហើយ រមិលមើលនូវទីដែលខ្លួនដេកនោះ ប្រសិនបើលំអិតមនោសិលានិងហរិតាលសិលានោះរាត់រាយ ព្រោះកន្ទុយ

ត្រចៀក ឬជើងជាអវយវកម្រើក ក៏គិតថា "ការធ្វើដូច្នេះ មិនសមគួរដល់ជាតិនិងគោត្តរបស់ឯងទេ" ហើយក៏ដេកអត់អាហារ ៧ ថ្ងៃទៀត, ប៉ុន្តែបើលំអិតមនោសិលានិងហរិតាសិលាមិនរាត់រាយទេ ក៏គិតថា "ការធ្វើដូច្នេះ ទើបសមគួរដល់ជាតិនិងគោត្ររបស់ឯង" ដូច្នេះហើយ ក៏ចេញចាកទីអាស្រ័យ ពត់កាយ ក្រឡេកមើលទិសទាំងឡាយ បន្លឺសីហនាទ ៣ ដង ហើយក៏ចេញទៅរកស៊ី ។ ភិក្ខុនេះមកហើយដោយកំណើតរាជសីហ៍បែបនោះ ។

ភិក្ខុទាំងឡាយ ឃើញមារយាទដ៏ប្រពៃប្រចាំកាយរបស់ព្រះថេររូបនោះ ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដូចជាព្រះសន្តកាយថេរនោះ ពួកខ្ញុំព្រះអង្គមិនធ្លាប់បានឃើញឡើយ, ក៏ការរពឹសដៃ រពឹសជើង ឬការពត់កាយរបស់ភិក្ខុនេះ ក្នុងទីដែលភិក្ខុនេះអង្គុយហើយ មិនមានឡើយ" ។

## ភិក្ខុគួរជាអ្នកស្ងប់

ព្រះសាស្តាទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ គប្បីជាអ្នកស្ងប់តាមទ្វារទាំងឡាយ មានកាយទ្វារជាដើមដោយពិត ដូចសន្តកាយថេរដូច្នោះ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា:-

**៩ សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ**
**វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។**

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

## អធិប្បាយថា

បណ្តាបទទាំងនោះ បទថា **សន្តកាយោ** ជាដើម សេចក្តីថា ដែលឈ្មោះថា អ្នកមានកាយស្ងប់ហើយ ព្រោះមិនមានកាយទុច្ចរិតទាំងឡាយ មានបាណាតិបាតជាដើម ។ ដែលឈ្មោះថា អ្នកមានវាចាស្ងប់ហើយ ព្រោះមិនមានវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម, ដែលឈ្មោះថា អ្នក

មានចិត្តស្ងប់ហើយ ព្រោះមិនមានមនោទុច្ចរិតទាំងឡាយមាន អភិជ្ឈាជាដើម, ដែលឈ្មោះថា អ្នកមានចិត្តតម្កល់មាំហើយ ព្រោះទ្វារទាំង ៣ មានកាយទ្វារជាដើមតម្កល់មាំហើយដោយល្អ, ដែលឈ្មោះថា អ្នកមានអាមិសក្នុងលោកខ្ជាក់ចោលហើយ ព្រោះអាមិសក្នុងលោកជារបស់ដែលខ្លួនខ្ជាក់ចោលហើយដោយមគ្គ ៤, ព្រះសាស្តាត្រាស់ហៅថា អ្នកស្ងប់ ព្រោះកិលេសទាំងឡាយ មានរាគជាដើមខាងក្នុងស្ងបរម្ងាប់ហើយ ។

ក្នុងកាលចប់ទេសនា ព្រះថេរនោះតាំងនៅក្នុងព្រះអរហត្ត ទេសនាជាគុណជាតិមានប្រយោជន៍សូម្បីដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

រឿងព្រះសន្តកាយថេរ ចប់

# ១០ រឿងនន្ទលកូដគ្គេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រះនន្ទលកូដគ្គេរ ត្រាស់ព្រះធម្មទេសនានេះថា “ **អត្តនា ចោទយត្តានំ** ” ដូច្នេះជាដើម ។

## មនុស្សទុគ៌តបួសក្នុងព្រះពុទ្ធសាសនា

បានឮថា មនុស្សទុគ៌តម្នាក់ ស៊ីឈ្នួលគេចិញ្ចឹមជីវិត ។ ភិក្ខុមួយរូបឃើញមនុស្សទុគ៌តនោះ ស្លៀកក្រណាត់សម្ពត់ចាស់ លីនង្គ័លដើរទៅស្រែ ក៏សួរយ៉ាងនេះថា “ ម្នាលអ្នកដ៏ចម្រើន អ្នកបួសមិនប្រសើរជាងការរស់នៅយ៉ាងនេះទេឬ ?”

បុរសទុគ៌ត. បពិត្រលោកម្ចាស់ដ៏ចម្រើន អ្នកណាទៅ នឹងឲ្យខ្ញុំព្រះករុណា ដែលជាអ្នកសៅនៅយ៉ាងនេះបួសនោះ ។

ភិក្ខុ. ម្នាលអ្នកដ៏ចម្រើន ប្រសិនបើអ្នកចង់បួស អាត្មា នឹងឲ្យអ្នកបួស ។

បុរសទុគ៌ត. “ ប្រពៃហើយលោកម្ចាស់, ប្រសិនបើ លោកម្ចាស់ខ្ញុំបួស ខ្ញុំនឹងបួស ” ។

គ្រានោះ ព្រះថេរៈនាំបុរសទុគ៌តនោះទៅកាន់វត្តជេត-ពន ហើយឲ្យងូតទឹកដោយដៃរបស់ខ្លួន ឲ្យសម្រាកនៅក្នុង រោងហើយ បំបួស ឲ្យបុរសនោះទុកដាក់នង្គ័ល ព្រមទាំង ក្រណាត់សម្ពត់ចាស់ ដែលខ្លួនស្លៀកលើមែកឈើ ជិតរោង នោះ ។ ក្នុងកាលឧបសម្បទាហើយ បុរសទុគ៌តនោះ បាន ប្រាកដនាមថា “ នង្គលកូដត្ថេរ ” ។

## ភិក្ខុមានឧបាយទូន្មានខ្លួនឯង រមែងរម្ងាប់សេចក្តីអផ្សុកបាន

ព្រះនង្គលកូដត្ថេរនោះ អាស្រ័យលាភសក្ការៈដែល កើតឡើងចំពោះព្រះពុទ្ធទាំងឡាយចិញ្ចឹមជីវិត សេចក្តីអផ្សុក

ក៏កើតឡើង កាលមិនអាចបន្ទោបង់សេចក្តីអផ្សុកបាន ក៏សម្រេចចិត្តថា “ ឥឡូវនេះ យើងនឹងមិនស្តៀកដណ្តប់សម្ពត់កាសាយៈទាំងឡាយដែលគេឲ្យដោយសទ្ធាទៀតទេ ” ដូច្នេះហើយ ក៏ទៅកាន់គល់ឈើ ទូន្មានខ្លួនដោយខ្លួនឯងថា នែបុគ្គលមិនមានហិរិ មិនមានសេចក្តីអៀនខ្មាស ឯងចង់សឹក ស្លៀកដណ្តប់ក្រណាត់សម្ពត់មួយផ្ទាំងនេះ ហើយស៊ីឈ្នួលគេចិញ្ចឹមជីវិតឬ ” ។ កាលលោកទូន្មានខ្លួនយ៉ាងនោះ ចិត្តជាធម្មជាតិស្រាល ( អស់ការអផ្សុក ) ។

លោកត្រឡប់មកវិញ កន្លងទៅបាន ២-៣ ថ្ងៃ ក៏អផ្សុកទៀត ទើបទូន្មានខ្លួនដោយឧបាយដូចមុន, លោកក៏ត្រឡប់ចិត្តបានទៀត ។ ពេលអផ្សុកលោកក៏ទៅកាន់ទីនោះហើយទូន្មានខ្លួនដោយទំនងនេះឯង ។

គ្រានោះ ភិក្ខុទាំងឡាយឃើញលោកទៅកាន់ទីនោះរឿយៗ ក៏សួរថា “ នែអាវុសោនន្តលកូដៈ ហេតុអ្វី ទើបអ្នកទៅកាន់ទីនោះ ?” ។

លោកឆ្លើយតបថា “ អ្នកដ៏មានអាយុទាំងឡាយ ខ្ញុំទៅកាន់សម្នាក់អាចារ្យរបស់ខ្ញុំ ” ដូច្នេះហើយ ២-៣ ថ្ងៃក្រោយមក ( ក៏ ) បានសម្រេចព្រះអរហត្ត ។

ភិក្ខុទាំងឡាយកាលនឹងធ្វើការចំអកចំអន់លោក ក៏បានពោលថា “ នៃអាវុសោនន្ទលកុជៈ ផ្លូវដែលជាទីត្រាច់ទៅរបស់អ្នកហាក់ដូចជាមិនមានស្នាម ប្រហែលជាអ្នកមិនទៅកាន់សម្នាក់អាចារ្យរបស់អ្នកទៀតទេដឹង ” ។

ព្រះថេរៈ. បពិត្រអ្នកមានអាយុទាំងឡាយ យ៉ាងនោះហើយ, កាលកិលេសជាគ្រឿងជាប់ជំពាក់នៅមាន ខ្ញុំបានទៅកាន់ទីនោះ, ប៉ុន្តែឥឡូវនេះ កិលេសដែលជាគ្រឿងជាប់ជំពាក់នោះ ខ្ញុំកាត់បានហើយ ព្រោះហេតុនោះ ទើបខ្ញុំមិនទៅកាន់ទីនោះទៀត ។

ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ យល់ថា “ ភិក្ខុនេះពោលពាក្យមិនពិត ព្យាករព្រះអរហត្តផល ” ដូច្នេះហើយក៏ក្រាបទូលរឿងនោះចំពោះព្រះសាស្តា ។

## ភិក្ខុជាអ្នកទូន្មានខ្លួន

ព្រះសាស្តាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ នង្គល-
កូដៈបុត្ររបស់តថាគត ទូន្មានខ្លួនដោយខ្លួនឯងហើយ ទើប
ដល់នូវទីបំផុតនៃកិច្ចរបស់បព្វជិត ” ដូច្នេះហើយ កាលនឹង
ទ្រង់សម្តែងធម៌ បានទ្រង់ភាសិតព្រះគាថាទាំងនេះថា :-

**១០ អត្តនា ចោទយត្តានំ បដិមំសេតមត្តនា**
**សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។**
**អត្តាហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ**
**តស្មា សញ្ញម អត្តានំ អស្សំ ភទ្រំវ វាណិជោ ។**

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរ
ពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើ
មានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។
មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិ
របស់ខ្លួន ព្រោះហេតុនោះ អ្នកចូររាំងខ្លួន ដូច
ពាណិជរាំងសេះដ៏ល្អ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ចោទយត្តានំ** សេចក្ដីថា ចូរដាស់តឿនដោយខ្លួនឯង គឺចូរញុំាងខ្លួនឲ្យដឹងខ្លួនដោយខ្លួនឯង ។

បទថា **បដិមំសេ** ចូរពិនិត្យខ្លួនដោយខ្លួនឯង ។

បទថា **សោ** ជាដើម សេចក្ដីថា ម្នាលភិក្ខុ អ្នកនោះកាលដាស់តឿន ពិនិត្យមើលខ្លួនយ៉ាងនោះហើយ, ជាអ្នកឈ្មោះថា គ្រប់គ្រងខ្លួនបាន ព្រោះជាអ្នកមានខ្លួនគ្រប់គ្រងហើយដោយខ្លួនឯង ដែលឈ្មោះថា អ្នកមានសតិ ព្រោះជាអ្នកមានសតិតាំងមាំហើយ នឹងរស់នៅសុខគ្រប់ឥរិយាបថ ។

បទថា **នាថោ** សេចក្ដីថា ជាទីពឹង គឺជាទីពុំនាក់អាស្រ័យ ( អ្នកដទៃណាទៅ គប្បីជាទីពឹងបាន ) ព្រោះបុគ្គលអាស្រ័យអត្តភាពរបស់អ្នកដទៃ មិនអាចធ្វើកុសលហើយមានសួគ៌ជាទីទៅខាងមុខ ឬជាអ្នកញុំាងមគ្គឲ្យចម្រើនហើយ ធ្វើផលឲ្យជាក់ច្បាស់បាន, ព្រោះហេតុនោះ ទើបមានសេចក្ដីអធិប្បាយថា “ អ្នកដទៃណាទៅ អាចជាទីពឹងបាន ” ។

បទថា **តស្មា** ជាដើម សេចក្តីថា ខ្លួនជាគតិរបស់ខ្លួន គឺជាទីពុំនាក់អាស្រ័យ បានដល់ ជាសរណៈរបស់ខ្លួន ។

ឈ្មួញអាស្រ័យសេះដ៏ចម្រើន គឺសេះអាជានេយ្យនោះ ប្រាជ្ញាលាភ ទើបការពារការត្រាច់ទៅក្នុងវិសមស្ថាន ( ទីមិនសមគួរ ) នៃសេះនោះ ងូតទឹកឲ្យសេះនោះ ឲ្យបរិភោគក្នុង ១ ថ្ងៃ ៣ ដង ឈ្មោះថា រមែងប្រុងប្រយ័ត្ន គឺគ្រប់គ្រងថែទាំយ៉ាងណា ចំពោះអ្នកទាំងឡាយក៏ដូច្នោះដែរ កាលការពារការកើតឡើងនៃអកុសលដែលមិនទាន់កើត កម្ចាត់បង់អកុសលដែលកើតឡើងហើយ ព្រោះការវង្វេងភ្លេចសតិ ( ក៏ ) ឈ្មោះថា ស្ងួនគ្រង គឺគ្រប់គ្រងខ្លួន ដូច្នោះដែរ, កាលអ្នកគ្រប់គ្រងខ្លួនបានយ៉ាងនេះ អ្នកនឹងសម្រេចគុណវិសេសទាំងដែលជាលោកិយ ទាំងដែលជាលោកុត្តរៈ ផ្តើមពីបឋមជ្ឈានជាដើមទៅ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងព្រះនន្ទកុលកូដត្ថេរ ចប់ )

8888888888888888888

## ១១ រឿងព្រះវក្កលិត្ថេរ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះវក្កលិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា " **បាមោជ្ជ-ពហុលោ ភិក្ខុ** " ដូច្នេះជាដើម ។

### អ្នកឃើញធម៌ឈ្មោះថាឃើញព្រះសាស្ដា

បានឮថា ព្រះវក្កលិត្ថេរនោះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ចម្រើនវ័យហើយ ឃើញព្រះតថាគត ស្តេចចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត សម្លឹងមើលព្រះសរីរសម្បត្តិរបស់ព្រះសាស្តាហើយ មិនឆ្អែតដោយការមើលព្រះសរីរសម្បត្តិ, ក៏សូមបព្វជ្ជាក្នុងសម្នាក់ព្រះសាស្តា ដោយយល់ថា “ យើងនឹងបានឃើញព្រះតថាគតអស់កាលជានិច្ច ដោយឧបាយនេះ ” ដូច្នេះហើយ ក៏ឈរក្នុងទីដែលខ្លួនអាចមើលឃើញព្រះទសពលបាន, លះបង់កិច្ចវត្តទាំងឡាយ មានការស្វាធ្យាយ និងមនសិការក្នុងកម្មដ្ឋានជាដើម តាមតែមើលព្រះសាស្តា ។

ព្រះសាស្តា ទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់លោក ទើបមិនត្រាស់អ្វីៗ ក្រោយមកទ្រង់ជ្រាបថា “ ឥឡូវនេះ ញាណរបស់វក្កលិចាស់ក្លាហើយ ” ទើបឲ្យឱវាទថា ម្នាលវក្កលិ ប្រយោជន៍អ្វីរបស់អ្នក ដោយការចាំមើលកាយស្អុយនេះ, “ ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះ

ឈ្មោះថា ឃើញតថាគត, បុគ្គលណាឃើញតថាគត បុគ្គលនោះ ឈ្មោះថា ឃើញធម៌ ” ។

ព្រះវក្កលិនោះ សូម្បីព្រះសាស្ដាទ្រង់ទូន្មានយ៉ាងនោះ ក៏នៅតែមិនលះបង់ការមើលព្រះសាស្ដាក្នុងទីដទៃបាន ។

គ្រានោះ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា “ ភិក្ខុនេះ មិនបានសេចក្ដីសង្វេគ នឹងមិនបានត្រាស់ដឹង ” កាលវស្សូបនាយិកាជិតចូលមកដល់ ក៏ស្ដេចទៅកាន់ក្រុងរាជគ្រឹះ ក្នុងថ្ងៃចូលវស្សា ព្រះសាស្ដាទ្រង់បណ្ដេញព្រះវក្កលិដោយព្រះតម្រាស់ថា “ ម្នាលវក្កលិ អ្នកចូរចៀសចេញទៅ ” ។ ព្រះវក្កលិគិតថា “ ព្រះសាស្ដាមិនត្រាស់ហៅយើង ” មិនអាចនឹងនៅក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដា អស់ត្រៃមាសបាន ទើបគិតថា “ ជីវិតនេះ មានប្រយោជន៍អ្វីចំពោះយើងទៀត, យើងនឹងលោតចុះអំពីភ្នំឲ្យស្លាប់ ” លុះគិតដូច្នេះហើយ ក៏ឡើងកាន់ភ្នំគិជ្ឈកូដ ។ ព្រះសាស្ដា ទ្រង់ជ្រាបនូវសេចក្ដីលំបាករបស់ព្រះវក្កលិនោះហើយ ក៏ទ្រង់ព្រះតម្រិះថា “ ភិក្ខុនេះ កាលមិនបានការលួងលោមអំពីសម្នាក់តថាគតនឹងញ៉ាំង

ធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផលទាំងឡាយឲ្យវិនាស"
ទើបទ្រង់ផ្សាយព្រះរស្មីទៅ ដើម្បីនឹងទ្រង់សម្ដែងព្រះអង្គ (ឲ្យប្រាកដ) ។

គ្រានោះ សេចក្ដីសោកដ៏ធំដល់ម៉្លោះ បាត់អស់ទៅដំណាលគ្នានឹងការឃើញព្រះសាស្ដា ។

ព្រះសាស្ដា ដូចជាទេវតាដ៏វិសេស ញ៉ាំងស្រះដ៏ស្ងួតឲ្យពេញដោយទឹក ដើម្បីនឹងទ្រង់ញ៉ាំងបីតិ និងបាមោជ្ជដ៏មានកម្លាំងឲ្យកើតឡើងដល់ព្រះវក្កលិ ទើបត្រាស់ព្រះគាថានេះថា

**១១ បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**

ភិក្ខុអ្នកក្រាស់ដោយសេចក្ដីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា :-

ភិក្ខុអ្នកច្រើនដោយបាមោជ្ជជាប្រក្រតី រមែងបណ្តុះសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា, ភិក្ខុនោះជ្រះថ្លា ( ក្នុងព្រះពុទ្ធសាសនា ) ហើយយ៉ាងនោះ រមែងបាននូវបទដ៏ស្ងប់ គឺព្រះនិព្វានក្នុងព្រះពុទ្ធសាសនា ដែលមានឈ្មោះថា “សន្តិបទ ជាទីចូលទៅស្ងប់សង្ខារ ជាសុខ ” ។

ព្រះសាស្តា លុះត្រាស់ព្រះគាថានេះហើយ ទ្រង់លាតព្រះហស្ត ហើយត្រាស់ព្រះគាថាទាំងនេះដល់ព្រះវក្កលិថា :-

ម្នាលវក្កលិ ចូរមក ចូរកុំខ្លាចឡើយ ចូរក្រឡេកមើលតថាគតចុះ, តថាគតនឹងស្រង់អ្នកឡើង ដូចអាចារ្យដំរីស្រង់ដំរីកុញ្ជរដែលលិចក្នុងភក់ដូច្នោះ ។

ម្នាលវក្កលិ ចូរមក ចូរអ្នកុំខ្លាចឡើយ អ្នកចូរក្រឡេកមើលតថាគតចុះ, តថាគតនឹងស្រង់អ្នកឡើង ដូចទេវតាដ៏វិសេសជួយព្រះចន្ទដែលត្រូវរាហូចាប់ដូច្នោះ ។

ព្រះវក្កលិ ញុំាងបីតិដ៏មានកម្លាំងឲ្យកើតឡើងហើយ ដោយគំនិតថា “ យើងបានឃើញព្រះទសពលហើយ ”

ហើយព្រះសាស្ដាក៏ត្រាស់ហៅយើងថា " ម្នាលវក្កលិ អ្នកចូរមក, ទើបគិតថា " យើងនឹងទៅផ្លូវណាហ្ន៎ ?" កាលមិនឃើញផ្លូវទៅ ក៏ហោះឡើងទៅកាន់អាកាសក្នុងទីចំពោះព្រះ-ភក្ត្រព្រះទសពល កាលជំហានជាដំបូងតាំងនៅលើភ្នំនោះឯង ក៏នឹកគិតដល់ព្រះគាថាដែលព្រះសាស្ដាត្រាស់ហើយ សង្កត់បីតិបាទក្នុងអាកាសនោះ សម្រេចព្រះអរហត្ត ព្រមទាំងបដិ-សម្ភិទាទាំងឡាយ ថ្វាយបង្គំព្រះទសពលហើយ ចុះមកឈរក្នុងសម្នាក់ព្រះសាស្ដា ។

គ្រានោះ ព្រះសាស្ដាទ្រង់តាំងលោកទុកក្នុងតំណែងដ៏លើសជាងសាវកទាំងឡាយ អ្នកមានចិត្តស៊ប់សួនដោយសទ្ធា ( សទ្ធាធិមុត្ត ) ។

( រឿងវក្កលិត្ថេរ ចប់ )

## ១២ រឿងសុខសាមណេរ

## សេចក្ដីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធសុខសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា “ **យោ ហវេ** ” ដូច្នេះជាដើម ។

## បុព្វកម្មរបស់ព្រះអនុរុទ្ធ

អនុបុព្វីកថាក្នុងរឿងនោះ ដូចតទៅនេះ :-

បានឮថាក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថាបទុមុត្តរៈ កុលបុត្រម្នាក់ ឃើញព្រះសាស្តាទ្រង់តែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងជាឯតទគ្គផ្នែកខាងទិព្វចក្ខុ កណ្តាលបរិស័ទទាំង ៤ ប្រាថ្នាសម្បត្តិនោះ ទើបនិមន្តព្រះសាស្តា ថ្វាយទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយប្រាថ្នាថា “ បពិត្រព្រះអង្គដ៏ចម្រើន សូមឱ្យខ្ញុំព្រះអង្គក៏គប្បីជាអ្នកប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងអ្នកមានទិព្វចក្ខុ ក្នុងព្រះសាសនានៃព្រះពុទ្ធមួយព្រះអង្គក្នុងអនាគតដែរ” ។

ព្រះសាស្តា ទ្រង់ពិចារណាមើលអស់មួយសែនកប្បទ្រង់ជ្រាប ការសម្រេចនៃសេចក្តីប្រាថ្នារបស់កុលបុត្រនោះហើយ ទើបទ្រង់ព្យាករណ៍ថា“ក្នុងទីបំផុតមួយសែនកប្បអំពី

កប្បនេះទៅ អ្នកនឹងមានឈ្មោះថាអនុរុទ្ធត្ថេរ ប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងអ្នកមានទិព្វចក្ខុ ក្នុងសាសនានៃព្រះពុទ្ធទ្រង់ព្រះនាមថាគោតម” កុលបុត្រនោះស្តាប់ពាក្យព្យាករណ៍នោះហើយ ក៏សម្គាល់សម្បត្តិនោះថាដូចជាខ្លួននឹងបានក្នុងថ្ងៃស្អែក, កាលព្រះសាស្តាបរិនិព្វានហើយ, ក៏សួរភិក្ខុទាំងឡាយអំពីការបរិកម្មដើម្បីបានទិព្វចក្ខុ ភិក្ខុទាំងឡាយឲ្យធ្វើគោមប្រេីនពាន់ដើម ដាក់ជុំវិញព្រះស្តូបមាសដែលមានកំពស់និងទំហំ ៧ យោជន៍ ហើយឲ្យបូជាព្រះស្តូបដោយប្រទីប ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ត្រាច់រង្គត់ទៅមកក្នុងទេវលោក និងមនុស្សលោកអស់មួយសែនកប្ប ក្នុងភទ្ទកប្បនេះ កើតក្នុងត្រកូលអ្នកក្រ ក្នុងក្រុងពារាណសី អាស្រ័យសុមនសេដ្ឋី ជាអ្នកជញ្ជូនស្មៅឲ្យសេដ្ឋីនោះចិញ្ចឹមជីវិត ។ បុរសនោះមានឈ្មោះថា “អន្នភារៈ” ។

ចំណែកសុមនសេដ្ឋីក៏ថ្វាយមហាទាន ក្នុងព្រះនគរនោះ អស់កាលជានិច្ច ។

សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធព្រះនាមថាឧបរិដ្ឋៈ ចេញចាកនិរោធសមាបត្តិឯគន្ធមាទន៍ហើយ គិតថា "ថ្ងៃនេះ យើងនឹងសង្គ្រោះអ្នកណាហ្ន៎ ?" ទ្រង់ជ្រាបថា "ថ្ងៃនេះ ការដែលខ្ញុំសង្គ្រោះបុរសឈ្មោះអន្នភារៈ សមគួរណាស់, ក៏ឥឡូវនេះ គេកំពុងជញ្ជូនស្មៅអំពីព្រៃមកផ្ទះ" ដូច្នេះហើយ ក៏កាន់បាត្រនិងចីវរទៅដោយឫទ្ធិ ប្រាកដចំពោះមុខអន្នភារៈ ។ អន្នភារៈឃើញព្រះបច្ចេកពុទ្ធមានបាត្រទទេក្នុងព្រះហស្ត ក៏សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានភិក្ខាខ្លះហើយឬ ?" កាលព្រះបច្ចេកពុទ្ធតបថា " អាត្មាភាពនឹងបានអំពីអ្នកមានបុណ្យច្រើន " ក៏ប្រាប់ថា " បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់មេត្តារង់ចាំបន្តិចចុះ " ដូច្នេះហើយ ក៏បោះអម្រែកចោលនៅទីនោះ ហើយទៅកាន់ផ្ទះដោយរហ័ស សួរភរិយាថា "ម្នាលនាងដ៏ចម្រើនភត្តដែលនាងទុកសម្រាប់ខ្ញុំនោះមានដែរឬ ?" កាលភរិយាតបថា "បពិត្រនាយ មាន", ក៏ត្រឡប់មកដោយរហ័ស ទទួលយកបាត្ររបស់ព្រះបច្ចេកពុទ្ធទៅកាន់ផ្ទះដោយគិតថា កាលដែល

យើងប្រាថ្នានឹងឲ្យទាន ទេយ្យធម៌មិនមាន, កាលទេយ្យធម៌មាន យើងមិនបានបដិគ្គាហក ប៉ុន្តែថ្ងៃនេះបដិគ្គាហកក៏មាន ហើយទេយ្យធម៌របស់យើងក៏មាន, នេះជាលាភរបស់យើងហើយហ្ន៎ ” ឲ្យករិយាដាក់កត្តក្នុងបាត្រហើយ នាំត្រឡប់មកដាក់លើព្រះហស្តរបស់ព្រះបច្ចេកហើយប្រាថ្នាថា ៈ-

ដោយអំណាចនៃទាន ភាពជាអ្នកទាល់ក្រ
កុំបីមានដល់ខ្ញុំព្រះករុណាឡើយ, ពាក្យថា មិន
មាន កុំបីមានដល់ខ្ញុំព្រះករុណាក្នុងភពតូច និង
ភពធំឡើយ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមឲ្យខ្ញុំព្រះករុណារួចផុតអំពីការចិញ្ចឹមជីវិតដ៏លំបាកយ៉ាងនេះ, សូមកុំឲ្យខ្ញុំព្រះ-ករុណាបានឮបទថា មិនមានឡើយ ។

ព្រះបច្ចេកពុទ្ធអនុមោទនាថា នែអ្នកដ៏ចម្រើន សេចក្តីប្រាថ្នារបស់អ្នក ចូរសម្រេចតាមសេចក្តីប្រាថ្នាចុះ ដូច្នេះហើយក៏ចៀសចេញទៅ ។

ទេវតាដែលអាស្រ័យនៅព្រួជ៏ឆត្រ របស់សុមនសេដ្ឋី ពោលថា

ឱ ! ទានដ៏ក្រៃលែង អន្ធការបុរសបានតាំងទុក
ល្អហើយក្នុងព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋ ។
ហើយបានឲ្យសាធុការអស់វារៈ ៣ ដង ។

គ្រានោះ សេដ្ឋីពោលទៅកាន់ទេវតានោះថា អ្នកមិនឃើញយើងឲ្យទានអស់កាលមានប្រមាណប៉ុណ្ណោះទេឬ ?

ទេវតា. ខ្ញុំមិនមែនប្រារព្ធទានរបស់លោក ហើយឲ្យសាធុការនោះទេ, ប៉ុន្តែសាធុការនេះ ខ្ញុំឲ្យប្រព្រឹត្តទៅហើយក៏ព្រោះសេចក្ដីជ្រះថ្លាក្នុងបិណ្ឌបាតដែលអន្ធការៈថ្វាយហើយចំពោះព្រះបច្ចេកពុទ្ធ ។

សេដ្ឋីនោះគិតថា នែអ្នកដ៏ចម្រើន ហេតុគួរអស្ចារ្យណាស់ហ្ន៎, យើងថ្វាយទានអស់កាលប្រមាណប៉ុណ្ណោះ ក៏មិនអាចនឹងញ៉ាំងទេវតាឲ្យសាធុការបាន, អន្ធការៈរស់នៅអាស្រ័យយើង ញ៉ាំងទេវតាឲ្យឲ្យសាធុការដោយបិណ្ឌបាតតែមួយប៉ុណ្ណោះបាន, យើងនឹងឲ្យវត្ថុដ៏សមគួរចំពោះទានរបស់

គេ ហើយធ្វើបិណ្ឌបាតនោះឲ្យជារបស់យើង ដូច្នេះហើយ ក៏ឲ្យគេហៅអន្នភារៈមកសួរថា នែអន្នភារៈ ថ្ងៃនេះឯងបានឲ្យអ្វីដល់អ្នកណាខ្លះ ?

អន្នភារៈ. បពិត្រសេដ្ឋី ថ្ងៃនេះ ខ្ញុំបានថ្វាយភត្តាហារចំពោះព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋ ។

សេដ្ឋី. នែអន្នភារៈ បើដូច្នោះ អ្នកចូរកាន់យកកហាបណៈ ហើយឲ្យបិណ្ឌបាតនោះដល់ខ្ញុំចុះ ។

អន្នភារៈ. បពិត្រសេដ្ឋី ខ្ញុំជូនមិនបានទេ ។

សេដ្ឋីនោះតម្លើងថ្លៃរហូតដល់ពាន់នៃកហាបណៈ ។

ចំណែកអន្នភារៈ មិនបានជូនបិណ្ឌបាតនោះទៅសេដ្ឋីសូម្បីដោយទ្រព្យទាំងពាន់នៃកហាបណៈ ។

គ្រានោះ សេដ្ឋីពោលទៅកាន់អន្នភារៈថា នែអ្នកដ៏ចម្រើន រឿងនោះចូរលើកទុកសិនចុះ, ប្រសិនបើអ្នកមិនឲ្យបិណ្ឌបាតនោះដល់យើងទេ, អ្នកចូរកាន់យកទ្រព្យ ១០០០ ហើយឲ្យចំណែកបុណ្យដល់យើងចុះ ។

អន្ទការៈពោលថា ខ្ញុំប្រឹក្សាជាមួយនឹងលោកម្ចាស់ ហើយ នឹងដឹង ប្រញាប់ទៅទាន់ព្រះបច្ចេកពុទ្ធហើយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន សុមនសេដ្ឋីឲ្យទ្រព្យ ១០០០ កហាបណៈ ហើយសូមចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្ញុំព្រះករុណា, តើខ្ញុំព្រះករុណាត្រូវធ្វើយ៉ាងណា ?

គ្រានោះ ព្រះបច្ចេកពុទ្ធបាននាំមកនូវឧបមាឲ្យអន្ទការៈបានយល់ថា ម្នាលបណ្ឌិត អ្នកគប្បីយល់តាមការឧបមារបស់អាត្មាភាពដូច្នេះចុះ ប្រទីបក្នុងផ្ទះមួយក្នុងស្រុកដែលមានត្រកូលមួយរយអាចភ្លឺឡើងបាន, ដោយពួកជនដ៏សេសញ៉ាំងប្រឆេះឲ្យទទឹកដោយប្រេងរបស់ខ្លួន ហើយទៅអុជចម្លងភ្លើងអំពីដួងប្រទីបដទៃយកមក, ពន្លឺនៃប្រទីបក្នុងកាលមុន បុគ្គលគប្បីពោលថា មាន ឬថា មិនមាន ។

អន្ទការៈ. បពិត្រលោកម្ចាស់ដ៏ចម្រើន ពន្លឺរមែងមានដ៏លើសលប់ក្រៃលែងជាងមុន ។

ព្រះបច្ចេកពុទ្ធ. ម្នាលបណ្ឌិត យ៉ាងនោះឯង បបរមួយបោយ ឬថា បាយមួយវែកក៏ដោយ ចូរលើកទុកសិនចុះ,

កាលបុគ្គលឲ្យចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្លួន ដល់ជនទាំងឡាយមានប្រមាណប៉ុន្មាន, ចំណែកបុណ្យប៉ុណ្ណោះរមែងចម្រើន, ក៏អ្នកបានឲ្យបិណ្ឌបាតមួយចំណែកប៉ុណ្ណោះ, ប៉ុន្តែកាលអ្នកចំណែកបុណ្យដល់សេដ្ឋី, បិណ្ឌបាត ឈ្មោះថា ពីរចំណែក មួយចំណែកជារបស់អ្នក មួយចំណែកជារបស់សេដ្ឋី ។

អន្នភារៈយល់ព្រមដោយពាក្យថា ប្រពៃហើយលោកម្ចាស់ ហើយថ្វាយបង្គំព្រះបច្ចេកពុទ្ធទៅកាន់សម្នាក់សេដ្ឋីពោលថា បពិត្រសេដ្ឋី សូមលោកទទួលយកចំណែកបុណ្យនេះចុះ ។

សេដ្ឋី. បើដូច្នោះ អ្នកចូរទទួលយកកហាបណៈទាំងនេះចុះ ។

អន្នភារៈ. ខ្ញុំមិនលក់បិណ្ឌបាតទេ, ខ្ញុំជូនចំណែកបុណ្យនេះដល់លោកដោយសទ្ធា ។

សេដ្ឋីពោលថា អ្នកឯងឲ្យចំណែកបុណ្យដល់យើងដោយសទ្ធា, ចំណែកយើងក៏បូជាគុណអ្នកដោយសទ្ធាដែរ

ដូច្នោះ ចូរទទួលយកកហាបណៈចុះ, មួយវិញទៀត ចាប់ពីពេលនេះទៅ អ្នកឯងមិនចាំបាច់ធ្វើការងារដោយដៃរបស់ខ្លួនទេ, ចូរសង់ផ្ទះក្បែរថ្នល់ចុះ, ហើយចូរកាន់យកវត្ថុគ្រប់យ៉ាងដែលអ្នកឯងត្រូវការអំពីសម្នាក់របស់ខ្ញុំ ។

ក៏បិណ្ឌបាត ដែលបុគ្គលប្រគេនចំពោះព្រះអរហន្តដែលទើបតែចេញអំពីនិរោធសមាបត្តិ រមែងឲ្យផលក្នុងថ្ងៃនោះតែម្តង, ព្រោះហេតុដូច្នោះ សូម្បីព្រះរាជាទ្រង់ព្រះ-សណ្តាប់នូវរឿងនោះហើយ ក៏ត្រាស់ឲ្យហៅអន្នភារៈមកហើយ ទ្រង់ទទួលយកចំណែកបុណ្យ ព្រះរាជទានភោគៈដ៏ច្រើន ហើយត្រាស់ឲ្យព្រះរាជទាននូវតំណែងជាសេដ្ឋីដល់អន្នភារៈ ។

## ប្រវត្តិព្រះអនុរុទ្ធ

អន្នភារៈនោះ ជាសម្លាញ់របស់សុមនសេដ្ឋី ធ្វើបុណ្យទាំងឡាយរហូតអស់ជីវិត ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវលោក និងមនុស្សលោក, ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងសក្យត្រកូល ព្រះនាមថា

អមិតោទនៈ ក្នុងព្រះនគរកបិលពស្តុ ។ ព្រះញាតិទាំងឡាយ ទ្រង់ថ្វាយព្រះនាមព្រះកុមារនោះថា " អនុរុទ្ធ " ។ ព្រះកុមារនោះ ជាព្រះកនិដ្ឋភាតា ( អនុជ ) នៃសក្យមហានាម ជាព្រះឱរសរបស់ព្រះបាទមានៃព្រះសាស្ដា ជាសុខុមាលជាតិ ជាអ្នកមានបុណ្យច្រើន ។

បានឮថា ថ្ងៃមួយ កាលក្សត្រទាំង ៦ អង្គលេងឃ្លីយកនំធ្វើជាគ្រឿងភ្នាល់, ព្រះអនុរុទ្ធចាញ់, ក៏បញ្ជូនដំណឹងទៅកាន់សម្នាក់ព្រះមាតាដើម្បីត្រូវការនំ ។ ព្រះមាតានោះញុំាំថាសមាសមួយធំឲ្យពេញដោយនំហើយ បញ្ជូនទៅថ្វាយ ។ ព្រះអនុរុទ្ធសោយនំហើយ ទ្រង់លេងចាញ់ទៀត ក៏បញ្ជូនដំណឹងទៅដូច្នោះទៀត ។

កាលមនុស្សនាំនំមកយ៉ាងនេះអស់វារៈ ៣ ដង, ក្នុងវារៈទី ៤ ព្រះមាតាបញ្ជូនដំណឹងទៅថា " ឥឡូវនេះ នំមិនមាន " ព្រះអនុរុទ្ធ ទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ព្រះមាតាហើយ ក៏សម្គាល់ថា " នំដែលមានឈ្មោះថា មិនមាន នឹងមានក្នុងកាលឥឡូវនេះ " ព្រោះបទថា " មិនមាន " ជាបទ

ដែលខ្លួនមិនធ្លាប់ឮពីមុនមក ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា “ អ្នកចូរទៅ ចូរនាំនំមិនមាននោះមក ” ។

គ្រានោះ ព្រះមាតារបស់ព្រះកុមារនោះ កាលអ្នកបំរើទូលថា “បពិត្រព្រះម៉ែម្ចាស់ សូមព្រះម៉ែម្ចាស់ឲ្យ នំមិនមាននោះ” ក៏ទ្រង់ព្រះតម្រិះថា “បទថាមិនមានបុត្តរបស់យើងមិនធ្លាប់បានឮពីមុនមក, យើងគប្បីឲ្យគេដឹង ថានំមិនដោយពិធីណាហ្ន៎ ?” លុះទ្រង់ព្រះតម្រិះដូច្នេះ ហើយ ក៏ទ្រង់លាងថាសមាសហើយ បិទដោយថាសមួយទៀតបញ្ជូនទៅថា “នែអ្នកដ៏ចម្រើន អ្នកឯងចូរឲ្យថាស មាសនេះដល់បុត្តរបស់យើងចុះ” ។

គ្រានោះ ទេវតាទាំងឡាយអ្នករក្សាព្រះគនរ គិតថា “ព្រះអនុរុទ្ធកុមារនេះ ជាម្ចាស់របស់ពួកយើង ថ្វាយភត្តដែលជាចំណែករបស់ខ្លួន ចំពោះព្រះបច្ចេកពុទ្ធព្រះនាមថា ឧបរិដ្ឋៈ ក្នុងកាលដែលខ្លួនជាអ្នកជញ្ជូនស្មៅឈ្មោះអន្នភារៈ ហើយប្រាថ្នាថា សូមកុំឲ្យយើងបានឮពាក្យថា មិនមាន ។ ប្រសិនបើយើងដឹងរឿងនោះហើយ ព្រងើយកន្តើយមិនអើពើនោះ

សីរសៈរបស់យើងនឹងបែកជា ៧ ចំរៀកមិនខាន” លុះគិតដូច្នេះហើយ ក៏ញ៉ាំងថាសមាសឲ្យពេញដោយនំទិព្វទាំងឡាយ ។ បុរសនោះនាំថាសមាសមកតកល់ទុកក្នុងសម្នាក់ក្សត្រទាំងនោះ ហើយគម្រប់ចេញ ។ ក្លិននំទិព្វទាំងនោះផ្សាយទៅកាន់នគរទាំងមូល ។ ក៏កាលនំគ្រាន់តែក្សត្រទាំងនោះទ្រង់ដាក់ទៅក្នុងព្រះឱស្ឋភ្លាម ក្លិននោះបានផ្សាយទៅកាន់សរសៃសម្រាប់ទទួលរសទាំង ៧ ពាន់ ។

ព្រះអនុរុទ្ធទ្រង់ព្រះតម្រិះថា “កាលមុនអំពីនេះ ព្រះមាតាប្រហែលជាមិនស្រឡាញ់យើងទេមើលទៅ ព្រោះក្នុងកាលដទៃ ព្រះមាតារបស់យើងនោះមិនដែលចៀននំមិនមានឲ្យយើងបរិភោគឡើយ” ។ ព្រះកុមារនោះទៅកាន់សម្នាក់ព្រះមាតាហើយ ទូលសួរយ៉ាងនេះថា “បពិត្រព្រះមាតា ខ្ញុំមិនជាទីស្រឡាញ់របស់អ្នកឬ ?” ។

មាតា. នែកូន កូនឯងនិយាយអ្វី ? កូនឯងជាទីស្រឡាញ់របស់មាតា សូម្បីជាងភ្នែកទាំងពីរ សូម្បីជាងសាច់បេះដូងរបស់មាតាទៅទៀត ។

អនុរុទ្ធ. បពិត្រមាតា ប្រសិនបើខ្ញុំជាទីស្រឡាញ់របស់មាតានោះ ហេតុអ្វី ក្នុងកាលមុន មាតាមិនប្រទាននំមិនមានបែបនេះឲ្យខ្ញុំ ។

ព្រះមាតារបស់ព្រះអនុរុទ្ធត្រាស់សួរបុរសនោះថា "នែអ្នកដ៏ចម្រើន អ្វីបានមាននៅក្នុងថាសឬ ?"

បុរសនោះទូលថា "បពិត្រព្រះម៉ែម្ចាស់ មាន, ថាសពេញទៅដោយនំទាំងឡាយ, នំបែបនេះខ្ញុំមិនដែលឃើញឡើយ" ។

ព្រះនាងទ្រង់ព្រះតម្រិះថា "បុត្ររបស់យើងបានធ្វើបុណ្យទុកហើយ, នំទិព្វនឹងជារបស់ដែលទេវតាទាំងឡាយបញ្ជូនទៅឲ្យបុត្ររបស់យើង" ។

ចំណែកព្រះអនុរុទ្ធ ក៏ទូលព្រះមាតាថា "បពិត្រម៉ែ នំបែបនេះ ខ្ញុំមិនដែលបានបរិភោគឡើយ, ចាប់ពីពេលនេះទៅសូមមាតាចៀននំមិនមាននេះប៉ុណ្ណោះឲ្យខ្ញុំបរិភោគ" ។

ចាប់ពីពេលនោះមក ព្រះនាងទ្រង់លាងថាសមាសបិទដោយថាសមាសមួយទៀតហើយ បញ្ជូនទៅ ( ឲ្យ )

នៅពេលដែលព្រះអនុរុទ្ធទូលថា បពិត្រម៉ែ ខ្ញុំចង់បរិភោគនំៗ ទៀតទាំងឡាយតែងតែញ៉ាំងថាសឲ្យពេញ ( ដោយនំ ) ។ ព្រះកុមារនោះ កាលនៅក្នុងកណ្ដាលព្រះរាជវាំង មិនទ្រង់ជ្រាបនូវសេចក្ដីនៃបទថា "មិនមាន" សោយតែនំទិព្វដោយអាការយ៉ាងនេះ ។

ក៏កាលព្រះកុមារនៃសាក្យទាំងឡាយ បួសតាមលំដាប់ត្រកូល ដើម្បីជាបរិវានៃព្រះសាស្ដា ។ កាលព្រះមហានាមសាក្យៈត្រាស់ថា "នែប្អូនប្រុស ក្នុងត្រកូលរបស់ពួកយើងមិនទាន់មានអ្នកណាចេញបួសទេ ប្អូនឯងឬបងគួរតែបួស" ។ ព្រះអនុរុទ្ធត្រាស់ថា "បពិត្របងប្រុស ខ្ញុំជាសុខុមាលជាតិយ៉ាងក្រៃលែង មិនអាចបួសបានទេ" ។

មហានាម. បើដូច្នោះ ប្អូនឯងចូររៀនការងារចុះ បងនឹងបួស ។

អនុរុទ្ធ. ដែលឈ្មោះថាការងារនុ៎ះ ជាអ្វី ?

ពិតណាស់ ព្រះអនុរុទ្ធរមែងមិនដឹងសូម្បីទូរទីកើតឡើងនៃភត្តផង, នឹងដឹងការងារបានយ៉ាងណា ? ព្រោះហេតុនោះ ទើបត្រាស់សួរយ៉ាងនោះ ។

ថ្ងៃមួយ សាក្យ ៣ ព្រះអង្គគឺ អនុរុទ្ធ ភទ្ទិយៈ កិម្ពិលៈ ប្រឹក្សាគ្នាថា "ដែលឈ្មោះថាភត្ត កើតក្នុងទីណា ?" បណ្ដាសាក្យៈទាំង ៣ ព្រះអង្គនោះ កិម្ពិលៈត្រាស់ថា "ភត្តកើតក្នុងជង្រុក" ។ បានឮថា ថ្ងៃមួយព្រះកិម្ពិលៈនោះ បានឃើញគេបញ្ជូនស្រូវដាក់ជង្រុក, ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះដោយសម្គាល់ថា "ភត្ត រមែងកើតឡើងអំពីជង្រុក" ។

គ្រានោះ ព្រះភទ្ទិយៈត្រាស់ទៅកាន់ព្រះកិម្ពិលៈថា "នែអ្នកដ៏ចម្រើន អ្នកមិនទាន់ជ្រាបទេ" ដូច្នេះហើយ ត្រាស់ថា "ធម្មតាភត្ត រមែងកើតអំពីឆ្នាំង" ។ បានឮថា ថ្ងៃមួយព្រះភទ្ទិយៈនោះ ឃើញជនទាំងឡាយដួសភត្តអំពីឆ្នាំងហើយក៏បានធ្វើការសម្គាល់ថា "ភត្តនោះកើតអំពីឆ្នាំងនេះឯង", ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនោះ ។

ព្រះអនុរុទ្ធត្រាស់ទៅសាក្យៈទាំងពីរនោះថា "សូម្បីអ្នកទាំងពីរក៏មិនទាន់ជ្រាប" ហើយត្រាស់ថា "ភត្តតែងកើតអំពីថាសមាសដ៏ធំ ដែលមានកំពស់មួយគក់" ។

បានឮថា ព្រះអនុរុទ្ធនោះមិនដែលឃើញគេបុកស្រូវ មិនធ្លាប់ឃើញគេចំអិនភត្ត, ឃើញតែភត្តដែលគេដួសដាក់ក្នុងថាសមាសហើយ តំដល់ទុកចំពោះព្រះភក្ត្រប៉ុណ្ណោះ, ព្រោះហេតុនោះ ទើបសម្គាល់ថា "ភត្តនោះ រមែងកើតអំពីថាសមាសនោះឯង, ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនោះ។ កុលបុត្តអ្នកមានបុណ្យច្រើន កាលមិនដឹងសូម្បីនូវទីកើតឡើងនៃភត្តយ៉ាងនោះ នឹងដឹងការងារទាំងឡាយយ៉ាងណាបាន ។

ព្រះអនុរុទ្ធ ទ្រង់ព្រះសណ្ដាប់នូវការងារទាំងឡាយដែលព្រះមហានាមត្រាស់ប្រាប់ដោយន័យជាដើមថា "នែអនុរុទ្ធ ចូរមកណេះ បងនឹងបង្រៀននូវការងារក្នុងការនៅគ្រប់គ្រងផ្ទះដល់ឯង, អ្នកគ្រប់គ្រងផ្ទះ ចាំបាច់ត្រូវចាត់ចែងឲ្យគេភ្ជួរជាមុន" ដូច្នេះជាដើម ក៏ទ្រង់ព្រះតម្រិះថា ការងារ

នេះជាការកើតមិនមានទីបំផុត សេចក្ដីត្រូវការរបស់អញ ក៏មិនមានទីបំផុតដែរ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទូលលាព្រះមាតាថា "បពិត្រព្រះមាតា ខ្ញុំមិនត្រូវការនៅគ្រប់គ្រងផ្ទះទេ" ហើយស្ដេចចេញទៅមួយអន្លើដោយឱរសនៃសាក្យៈប្រាំព្រះអង្គ មានព្រះភទ្ទិយៈជាប្រធាន ចូលទៅគាល់ព្រះសាស្ដាឯអនុបិយអម្ពវ័ន ហើយទ្រង់ព្រះផ្នួស, លុះទ្រង់ព្រះផ្នួសហើយ ព្រះអនុរុទ្ធជាអ្នកប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ដោយលំដាប់ គង់នៅលើអាសនៈតែមួយ អាចក្រឡេងមើលលោកធាតុមួយពាន់បានដោយទិព្វចក្ខុ ដូចផ្លែកន្ទួតព្រៃដែលបុគ្គលដាក់លើបាតដៃដូច្នោះ ហើយបន្លឺឧទានឡើងថា ៖-

> យើងអាចដឹងនូវខន្ធបញ្ចកៈ ដែលយើងធ្លាប់
> នៅអាស្រ័យហើយក្នុងកាលមុន, ទិព្វចក្ខុយើង
> ក៏ជម្រះហើយ, យើងជាអ្នកបានវិជ្ជា ៣ ជាអ្នក
> ដល់ហើយនូវឫទ្ធិ, ពាក្យប្រៀនប្រដៅរបស់ព្រះ
> ពុទ្ធ យើងបានធ្វើហើយ ។

ពិចារណាមើលថា “តើយើងបានកម្មអ្វីហ្ន៎ ? ទើបបាន សម្បត្តិនេះ” ជ្រាបបានថា “យើងបានតាំងសេចក្តីប្រាថ្នាទុក ទៀបបាទមូលព្រះពុទ្ធទ្រង់ព្រះនាមថាបទុមុត្តរៈ” ជ្រាបតទៅទៀតថា “យើងអន្ទោលទៅមកក្នុងសង្សារវដ្ត ក្នុងកាលមួយនោះ បានអាស្រ័យសុមនសេដ្ឋី ក្នុងក្រុងពារាណសីចិញ្ចឹមជីវិត ជាអ្នកមានឈ្មោះថា អន្នភារៈ” ដូច្នេះហើយ ពោលថា

ក្នុងកាលមុន យើងជាបុរសឈ្មោះអន្នភារៈ ជាអ្នក
កំសត់ ជាអ្នកនាំទៅនូវស្មៅ, យើងបានប្រគេនបិណ្ឌ-
បាតចំពោះព្រះឧបរិដ្ឋបច្ចេកពុទ្ធ អ្នកដ៏មានយស ។

## ព្រះថេរលើកជល់សម្លាញ់ចាស់

គ្រានោះ ព្រះអនុរុទ្ធមានសេចក្តីត្រិះរិះដូច្នេះថា “សុមនសេដ្ឋីដែលជាសម្លាញ់របស់យើង ឲ្យកហាបណៈ ហើយកាន់យកចំណែកបុណ្យអំពីបិណ្ឌបាត ដែលយើងប្រគេនចំពោះព្រះឧបរិដ្ឋបច្ចេកពុទ្ធ ក្នុងកាលនោះ, ឥឡូវនេះ កើតក្នុងទីណាហ្ន៎ ?” ពេលនោះ លោកបានឃើញសេដ្ឋីនោះថា “មានស្រុកមួយឈ្មោះមុណ្ឌៈនិគម នៅក្បែរជើងភ្នំ ក្នុង

ជនព្រៃដែលត្រូវភ្លើងឆេះ, ឧបាសកឈ្មោះមហាមុណ្ឌៈដែល មានប្រក្រតីនៅក្នុងមុណ្ឌនិគមនោះ មានបុត្តពីរនាក់ គឺមហា សុមនៈ ចូឡសុមនៈ, បណ្ដាបុត្តទាំងពីរនោះ សុមនសេដ្ឋី ជាចូឡសុមនៈ" លុះព្រះអនុរុទ្ធឃើញហើយ គិតថា "កាល យើងទៅកាន់ទីនោះ, តើមានប្រយោជន៍ ឬក៏មិនមាន ?" ព្រះអនុរុទ្ធលោកពិចារណាបានឃើញហេតុនេះថា "កាល យើងទៅកាន់ទីនោះ, ចូឡសុមនៈនោះមានអាយុ ៧ ខួប ប៉ុណ្ណោះនឹងចេញបួស, ហើយនឹងសម្រេចព្រះអរហត្តក្នុង វេលាកោសក់ហើយនោះឯង" លុះលោកឃើញដូច្នេះហើយ កាលវជ្ជូវក្សៀងជិតចូលមកដល់ លោកក៏ទៅកាន់ទីនោះតាម អាកាសចុះក្បែរខ្លោងទ្វារស្រុក ។ ចំណែកមហាមុណ្ឌ ឧបាសក ក៏ជាអ្នកធ្លាប់ស្និទ្ធស្នាលនិងព្រះថេរក្នុងកាលមុន ដែរ ។ ឧបាសកនោះឃើញព្រះថេរគ្រងចីវរក្នុងវេលាបិណ្ឌ- បាត ក៏ពោលទៅកាន់មហាសុមនៈជាបុត្តថា "នែមហាសុមនៈ លោកម្ចាស់អនុរុទ្ធរបស់យើងមកហើយ, កូនឯងចូរទៅ ទទួលបាត្ររបស់លោកឲ្យទាន់វេលាដែលអ្នកដទៃ មិនទាន់

ទទួលបាត្ររបស់លោកទៅ, ពុកនឹងឲ្យគេក្រាលអាសនៈ” មហាសុមនៈបានឆ្លើយយ៉ាងនោះ ។ ឧបាសកអង្គាសព្រះថេរ ខាងផ្ទះដោយគោរពហើយ ទទួលបដិញ្ញាដើម្បីត្រូវការដល់ការចាំវស្សារហូតត្រៃមាស ។ ព្រះថេរក៏ទទួលនិមន្ត ។

គ្រានោះ ឧបាសកបដិបត្តិព្រះថេរនោះរហូតត្រៃមាស ដូចបដិបត្តិតែមួយថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃមហាបវារណា បាននាំត្រៃចីវរនិងអាហារវត្ថុទាំងឡាយ មានទឹកអំពៅ ប្រេង និងបាយជាដើមមកតំកល់ទុកទៀបជើងព្រះថេរ ហើយប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់ទទួលយកចុះ”

## មិនទទួលវត្ថុត្រឡប់បានសាមណេរ

ព្រះថេរ. កុំឡើយឧបាសក សេចក្តីត្រូវការវត្ថុនេះរបស់អាត្មាភាព មិនមានទេ ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាវស្សាវាសិកលាភ ( គឺលាភកើតឡើងដល់អ្នកចាំវស្សា ), សូមលោកម្ចាស់ទទួលយកវត្ថុនេះចុះ ។

ព្រះថេរ. ឧបាសក កុំឡើយ ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបលោកម្ចាស់មិនទទួល ? ។

ព្រះថេរ. សូម្បីសាមណេរដែលជាកប្បិយការក ក្នុងសម្នាក់របស់អាត្មាភាពក៏មិនមាន ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ មហាសុមនៈដែលជាបុត្តរបស់ខ្ញុំព្រះករុណានឹងជាសាមណេរ

ព្រះថេរ. ឧបាសក អាត្មាមិនត្រូវការមហាសុមនៈទេ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់បំបួសចូឡសុមនៈចុះ ។

ព្រះថេរ. ទទួលថា "ប្រពៃហើយ" ហើយបំបួសចូឡសុមនៈ ។ ចូឡសុមនៈនោះ បានសម្រេចព្រះអរហត្តក្នុងវេលាកោរសក់ហើយនោះឯង ។

ព្រះថេរ នៅទីនោះជាមួយនិងចូឡសុមនៈសាមណេរនោះប្រមាណកន្លះខែហើយ លាពួកញាតិរបស់លោកថា "ពួកអាត្មានឹងទៅគាល់ព្រះសាស្តា" ដូច្នេះហើយ បានទៅ

តាមអាកាស ចុះក្បែរកុដិដែលតាំងនៅក្នុងព្រៃ ក្នុងហិមវន្តប្រទេស ។

## ព្រះថេរប្រារព្ធសេចក្តីព្យាយាមជានិច្ច

ក៏ព្រះថេរនោះ តាមប្រក្រតីជាអ្នកប្រារព្ធសេចក្តីព្យាយាម, កាលលោកកំពុងចង្រ្កមនៅទីនោះ រាត្រីជំបូងនិងរាត្រីតមក ខ្យល់ក្នុងផ្ទៃបានកើតឡើងដល់លោក ។

គ្រានោះ សាមណេរឃើញលោកលំបាក ក៏សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន តើលោកម្ចាស់កើតរោគអ្វី ? រោគអ្វីរមែងចាក់ដោតលោកម្ចាស់ ?

ព្រះថេរ. ខ្យល់ចាក់ដោតក្នុងផ្ទៃកើតឡើងដល់ខ្ញុំ ។

សាមណេរ. បពិត្រលោកម្ចាស់ដ៏ចម្រើន កាលអំពីមុន ខ្យល់ចាក់ដោតក្នុងផ្ទៃធ្លាប់កើតឡើងដល់លោកម្ចាស់ដែរឬ ?

ព្រះថេរ. អើ អ្នកមានអាយុ ធ្លាប់កើតដែរ ។

សាមណេរ. បពិត្រលោកម្ចាស់ តើសេចក្តីសប្បាយរមែងមានដោយភេសជ្ជៈអ្វី ?

ព្រះថេរ. ម្នាលអ្នកមានអាយុ កាលខ្ញុំបានទឹកផឹកអំពីអនោតត្តស្រះ សេចក្ដីសប្បាយរមែងមាន ។

សាមណេរ. បពិត្រលោកម្ចាស់ បើដូច្នោះខ្ញុំព្រះករុណានឹងនាំមកប្រគេន ។

ព្រះថេរ. ម្នាលសាមណេរ អ្នកនឹងអាចនាំមកឬ ?

សាមណេរ. ព្រះករុណា លោកម្ចាស់ ។

ព្រះថេរ. បើដូច្នោះ នាគរាជឈ្មោះបន្នកៈ ដែលនៅក្នុងអនោតត្តស្រះនោះស្គាល់ខ្ញុំ ។ អ្នកចូរប្រាប់នាគរាជនោះហើយនាំដបទឹកមួយដបមកដើម្បីប្រយោជន៍ដល់ការផ្សំថ្នាំ ។

សាមណេរទទួលយល់ព្រមដោយពាក្យថា "ប្រពៃហើយ លោកម្ចាស់" ហើយថ្វាយបង្គំព្រះឧបជ្ឈាយ៍ ហោះឡើងកាន់វេហាស៍ បានទៅកាន់ទីប្រមាណ ៥០០ យោជន៍ ។

## សាមណេរតទល់នឹងស្ដេចនាគ

ក៏ថ្ងៃនោះ នាគរាជមាននាគរបាំរោមរោមហើយ ប្រាថ្នានឹងលេងទឹក ។ នាគរាជនោះ គ្រាន់តែឃើញសាមណេរនោះភ្លាម ក៏ក្រោធ ហើយគិតថា " សមណៈត្រងោលនេះ ដើរ

ធ្វើឲ្យធូលីដែលជាប់នឹងបាតជើង ហុយមកលើក្បាលយើង, សមណៈត្រងោលនេះមកដើម្បីត្រូវការទឹកផឹកអនោតត្តស្រះ ឥឡូវនេះ យើងនឹងមិនឲ្យទឹកផឹកដល់សមណៈត្រងោលនេះ” ដូច្នេះហើយ ដេកបិទអនោតត្តស្រះដែលមានប្រមាណ ៥០ យោជន៍ពពា ដូចបុគ្គលបិទឆ្នាំងបាយដោយថាសដ៏ធំដូច្នោះ ។

សាមណេរ គ្រាន់តែឃើញអាការរបស់នាគរាជនោះ ភ្វាម ក៏ដឹងថា “ នាគរាជនេះក្រោធហើយ ” ទើបពោល គាថានេះថា :-

“ ម្នាលនាគរាជ អ្នកមានតេជៈដ៏ខ្លាំងក្លា មាន កម្លាំងច្រើន ចូរស្តាប់ ( ពាក្យ ) របស់អាត្មា, ចូរ ឲ្យក្អមដ៏ពេញដោយទឹកផឹកដល់អាត្មា, អាត្មាជា អ្នកមកហើយ ដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ ផ្សំថ្នាំ ” ។

នាគរាជស្តាប់គាថានោះហើយ ពោលគាថានេះថា :-

“ ស្ទឹងធំឈ្មោះគង្គា នៅខាងទិសបូព៌ា រមែង ហូរទៅកាន់មហាសមុទ្រ, លោកចូរនាំយកទឹកផឹក

អំពីស្ទឹងគង្គានោះទៅចុះ " ។

សាមណេរស្តាប់ពាក្យនោះហើយ គិតថា " ស្តេចនាគនេះនឹងមិនឲ្យតាមសេចក្តីប្រាថ្នារបស់ខ្លួន, យើងនឹងគំរាមកំហែងធ្វើឲ្យវាដឹងនូវអានុភាពដ៏ធំ នឹងគ្របសង្កត់ស្តេចនាគនេះហើយ នាំទឹកផឹកទៅ " ដូច្នេះហើយ ពោលថា " មហារាជ ព្រះឧបជ្ឈាយ៍ឲ្យអាត្មានាំទឹកអំពីអនោតត្តស្រះប៉ុណ្ណោះ, ព្រោះហេតុនោះ ទើបអាត្មានាំយកទឹកអំពីស្រះនេះប៉ុណ្ណោះទៅ, អ្នកចូរចៀសចេញទៅ ចូរកុំហាមឃាត់អាត្មាឡើយ " ដូច្នេះហើយ ពោលគាថានេះថា :-

" អាត្មាត្រូវការតែទឹកផឹកអំពីអនោតត្តស្រះ
នេះប៉ុណ្ណោះ, អាត្មាត្រូវការទឹកផឹកនេះប៉ុណ្ណោះ,
ម្នាលនាគរាជ ប្រសិនបើកម្លាំង និងសេចក្តី
ក្លាហានរបស់អ្នកមាន, អ្នកចូរហាមឃាត់ចុះ ។

គ្រានោះ នាគរាជពោលទៅកាន់សាមណេរនោះថា :-

" នែ សាមណេរ ប្រសិនបើសេចក្តីព្យាយាម
ដែលបុគ្គលគប្បីឈានកន្លងសម្រាប់បុរស របស់

លោកមាន, ខ្ញុំត្រេកអរក្រៃលែងណាស់ លោកចូរនាំទឹករបស់ខ្ញុំទៅចុះ " ។

គ្រានោះ ឆ្លើយតបនឹងនាគរាជនោះថា " មហារាជ អាត្មានឹងនាំទៅយ៉ាងនោះ, កាលស្តេចនាគពោលថា " កាលលោកម្ចាស់អាចកាន់យកបាន ក៏ចូរនាំយកទៅចុះ " ទទួលប្តេជ្ញាអស់ ៣ ដងថា " បើដូច្នោះ អ្នកចូរដឹងចុះ " ហើយគិតថា " ការដែលយើងសម្តែងអានុភាពនៃព្រះពុទ្ធសាសនាហើយទើបនាំទៅ គួរ " បានទៅកាន់សម្នាក់ទេវតាដែលស្ថិតនៅក្នុងអាកាសមុន ។ ទេវតាទាំងនោះមកថ្វាយបង្គំហើយពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន មានការណ៍អ្វី ?" ។

សាមណេរពោលថា " សង្គ្រាមរបស់អាត្មាជាមួយនឹងស្តេចនាគឈ្មោះបន្នកៈនឹងមានលើខ្នងអនោតត្តស្រះនេះ, អ្នកទាំងឡាយចូរទៅកាន់ទីនោះ មើលការឈ្នះនិងការចាញ់ " ។ សាមណេរនោះចូលទៅរកលោកបាលទាំងបួន និងសក្កទេវរាជ សុយាមទេវរាជ សន្តុសិតទេវរាជ សុនិម្មិតទេវរាជ និងវសវត្តីទេវរាជ ហើយប្រាប់សេចក្តីនោះដោយទំនងនោះឯង។

តអំពីនោះទៅ សាមណេរទៅដោយលំដាប់ រហូតដល់ព្រហ្មលោក កាលដែលព្រហ្មទាំងឡាយក្នុងទីនោះៗ មកថ្វាយបង្គំហើយ សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន មានការណ៍អ្វី ?" ក៏ប្រាប់សេចក្តីនោះ ។

សាមណេរនោះត្រាច់ទៅប្រាប់គ្រប់ទ្បីកន្ទែង អស់កាលមួយរំពេចប៉ុណ្ណោះ វៀរលែងតែអសញ្ញីសត្វ និងអរូបព្រហ្មដោយអាការយ៉ាងនេះ ។

ចំណែកទេវតាគ្រប់ៗ ជំពូក ស្តាប់ពាក្យរបស់លោកហើយ ប្រជុំគ្នាពេញអាការកេចន្លោះគ្មាន លើខ្នងអនោតត្តស្រះ ដូចលម្អិតនំដែលបុគ្គលដាក់ក្នុងនាឡិ ដូច្នោះ ។

## សាមណេរអញ្ជើញទេវតាមកមើលចម្បាំង

កាលពួកទេវតាប្រជុំគ្នាហើយ, សាមណេរឈរនៅលើអាកាស ពោលទៅកាន់ស្តេចនាគថា :-

" ម្នាលនាគរាជ អ្នកមានតេជះដ៏ខ្លាំងក្លា មានកម្លាំងច្រើន ចូរស្តាប់ ( ពាក្យ ) របស់អាត្មា, ចូរឲ្យក្អមដ៏ពេញដោយទឹកផឹកដល់អាត្មា, អាត្មាជា

អ្នកមកហើយ ដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ផ្សំថ្នាំ " ។

លំដាប់នោះ ស្តេចនាគពោលទៅកាន់សាមណេរថា :-

" នែ សាមណេរ ប្រសិនបើសេចក្តីព្យាយាមដែលបុគ្គលគប្បីឈានកន្លងសម្រាប់បុរស របស់លោកមាន, ខ្ញុំត្រេកអរក្រៃលែងណាស់ លោកចូរនាំទឹករបស់ខ្ញុំទៅចុះ " ។

សាមណេរនោះទទួលការប្តេជ្ញារបស់នាគរាជអស់ ៣ ដងហើយ ឈរនៅលើអាកាសនោះឯង និម្មិតអត្តភាពជាព្រហ្មប្រមាណ ១២ យោជន៍ ហើយចុះចាកអាកាស ជាន់លើពពារបស់ស្តេចនាគ សង្កត់ឲ្យមានមុខចុះក្រោម ។ ក្នុងខណៈនោះឯង កាលសាមណេរជាន់ពពាស្តេចនាគនោះភ្លាម ផ្ទាំងពពាបានរួញចូលប្រមាណប៉ុនវែក ដូចស្បែកស្រស់ដែលបុរសមានកម្លាំងជាន់ហើយដូច្នោះ ។

ខ្សែទឹកប្រមាណប៉ុនដើមត្នោត បានខ្ទាតឡើងក្នុងទីដែលផុតចាកពពាទាំងឡាយរបស់នាគរាជ ។

សាមណេរ ញុំាងជូទឹកផឹកឲ្យពេញនៅលើអាកាសនោះឯង ។ ពួកទេវតាបានឲ្យសាធុការ ។

## ស្តេចនាគចាញ់សាមណេរ

ស្តេចនាគនោះអៀនខ្មាស ក្រោធខឹងសាមណេរ ។ ភ្នែកទាំងពីររបស់នាគរាជនោះមានពណ៌ដូចផ្កាច្បា ។ ស្តេចនាគនោះគិតថា “សមណៈត្រងោលនេះឲ្យពួកទេព្តាប្រជុំគ្នាហើយ កាន់យកទឹកផឹក ញុំាងយើងឲ្យខ្មាស, យើងនឹងចាប់សមណៈត្រងោលនេះដាក់ដៃចូលទៅក្នុងមាត់ហើយ ប្របាច់សាច់បេះដូងសមណៈនេះ, ឬនឹងចាប់ជើងសមណៈនេះបោះទៅខាងនាយស្ទឹងគង្គា” លុះគិតដូច្នេះហើយ ក៏តាមទៅដោយរហ័ស ។ សូម្បីដេញតាមសាមណេរដោយរហ័សយ៉ាងណាក៏ដោយ ក៏តាមមិនទាន់សាមណេរដែរ ។

សាមណេរមកដល់កន្លែងហើយ ដាក់ទឹកផឹកលើព្រះហស្តព្រះឧបជ្ឈាយ៍ហើយប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តឆាន់ទឹក” ។

## ស្តេចនាគនិយាយកុហកប៉ុន្តែសាមណេរ

## មិននិយាយកុហក

ចំណែកស្តេចនាគ មកតាមក្រោយសាមណេរហើយ ប្រាប់ព្រះអនុរុទ្ធថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សាមណេរកាន់យកទឹកដែលខ្ញុំព្រះករុណាមិនទាន់ឲ្យមក, សូមលោកម្ចាស់កុំឆាន់" ។

ព្រះថេរៈសួរថា "ម្នាលសាមណេរ ពិតមែនឬ ?

សាមណេរ. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកនិមន្តឆាន់ចុះ, ទឹកដែលខ្ញុំព្រះករុណានាំមកនេះ ស្តេចនាគឲ្យខ្ញុំព្រះករុណាហើយ ។

ព្រះថេរៈជ្រាបថា " ការពោលពាក្យកុហករបស់សាមណេរអ្នកជាខីណាស្រព រមែងមិនមាន" ទើបឆាន់ទឹកនោះ ។ អាពាធរបស់លោកក៏ស្ងប់ខណៈនោះឯង ។

ស្តេចនាគពោលទៅកាន់ព្រះថេរៈទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ត្រូវសាមណេរធ្វើឲ្យខ្មាសពួកទេវតាហើយ ខ្ញុំម្ចាស់នឹងពុះបេះដូងសាមណេរនេះ , ឬនឹងចាប់ជើងហើយបោះទៅខាងនាយនៃស្ទឹងគង្គា ។

ព្រះថេរៈពោលថា “ បពិត្រមហារាជ សាមណេរនេះមានអានុភាពច្រើន អ្នកមិនអាចទប់ទល់នឹងសាមណេរបានទេ , អ្នកចូរឲ្យសាមណេរនោះអត់ទោសឲ្យ ហើយត្រឡប់ទៅវិញចុះ ” ។

## ស្តេចនាគសូមខមាទោសសាមណេរ

ស្តេចនាគនោះ ដឹងអានុភាពរបស់សាមណេរដោយខ្លួនឯងដែរ, ប៉ុន្តែនៅជាប់តាមមក ព្រោះសេចក្តីខ្មាស ។

គ្រានោះ ស្តេចនាគឲ្យសាមណេរនោះអត់ទោសតាមពាក្យរបស់ព្រះថេរៈហើយ ដើម្បីជាសេចក្តីស្និទ្ធស្នាលដោយភាពជាមិត្រជាមួយនិងសាមណេរ ទើបពោលថា “ចាប់អំពីពេលនេះទៅ កាលសេចក្តីត្រូវការដោយទឹកក្នុងអនោតត្តស្រះមាន, កិច្ចដោយការមកនៃលោកម្ចាស់ រមែងមិនមាន សូមលោកម្ចាស់បញ្ជូនដំណឹងទៅឲ្យខ្ញុំព្រះករុណា, ខ្ញុំព្រះ-ករុណានឹងនាំទឹកមកប្រគេន” លុះពោលដូច្នេះហើយ ក៏ចៀសចេញទៅ, សូម្បីព្រះថេរៈក៏សាមណេរទៅដែរ ។

ព្រះសាស្តាទ្រង់ជ្រាបការមកនៃព្រះថេរៈហើយ ទ្រង់គង់ទតការមកនៃព្រះថេរៈលើប្រាសាទរបស់មិគារមាតា ។

ចំណែកពួកភិក្ខុឃើញព្រះថេរៈនិមន្តមក ក៏ក្រោកឡើងទៅទទួលបាត្រនិងចីវរ ។

## ពួកភិក្ខុលេងនិងសាមណេរ

គ្រានោះ ភិក្ខុពួកខ្លះចាប់សាមណេរត្រង់ក្បាលខ្លះត្រចៀកទាំង ២ ខ្លះ ភិក្ខុអង្គខ្លះចាប់ដៃអង្រួនបណ្តើរ ពោលបណ្តើរថា “ ម្នាលសាមណេរ អ្នកមិនអផ្សុកទេឬ ” ។

ព្រះសាស្តា ទ្រង់ទតឃើញអំពើរបស់ភិក្ខុទាំងនោះហើយ ទ្រង់ព្រះតម្រិះថា “ កម្មរបស់ភិក្ខុទាំងនេះធ្ងន់ណាស់ហ្ន៎, ភិក្ខុទាំងនេះ ចាប់សាមណេរដូចចាប់អាសិរពិសត្រង់-ក, ពួកភិក្ខុទាំងនេះមិនដឹងអានុភាពរបស់សាមណេរទេ, ថ្ងៃនេះការដែលតថាគត ញុំាងគុណរបស់សុមនសាមណេរឲ្យប្រាកដ រមែងសមគួរ ” ។ សូម្បីព្រះថេរៈ ក៏មកថ្វាយបង្គំព្រះសាស្តាហើយ គង់នៅក្នុងទីនោះដែរ ។

## ព្រះសាស្តាទ្រង់ញុំាងគុណ

## របស់សាមណេរឲ្យប្រាកដ

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងព្រះថេរៈ ហើយ ត្រាស់ហៅព្រះអានន្ទត្ថេរមកថា “ ម្នាលអានន្ទ តថាគតប្រាថ្នាលាងជើងទាំងពីរ ដោយទឹកក្នុងអនោតត្តស្រះ អ្នកចូរក្រុមដល់ពួកសាមណេរ ហើយឲ្យនាំទឹកមកចុះ ” ។

ព្រះថេរៈ ឲ្យសាមណេរប្រមាណ ៥០០ ក្នុងវិហារ ប្រជុំគ្នា ។

បណ្តាសាមណេរទាំងនោះ សុមនសាមណេរជា សាមណេរថ្មីជាងសាមណេរទាំងអស់ ។ ព្រះថេរៈពោលទៅ កាន់សាមណេរចាស់ជាងគេបង្អស់ថា “ ម្នាលសាមណេរ ព្រះសាស្តាមានព្រះបំណងនឹងលាងព្រះបាទទាំងពីរ ដោយ ទឹកក្នុងអនោតត្តស្រះ, អ្នកចូរកាន់យកក្អមទឹកទៅនាំទឹកមក ចុះ ”។ សាមណេរនោះមិនប្រាថ្នា ដោយពោលថា “ បពិត្រ លោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនអាច ” ។ ព្រះថេរៈសួរសាមណេរ ទាំងឡាយដ៏សេសដោយលំដាប់ ។ សូម្បីសាមណេរទាំង នោះ ក៏ប្រកែកដូចគ្នា ។

មានពាក្យសួរថា “ ក៏បណ្ដាសាមណេរទាំងនេះ សាមណេរជាព្រះខីណាស្រព មិនមានឬ ?” ។

ឆ្លើយថា “ មាន ។ ប៉ុន្ដែ សាមណេរទាំង នោះប្រកែក មិនព្រមទៅ ដោយគិតឃើញថា “ កម្រងផ្កានេះ ព្រះសាស្ដា មិនទ្រង់ចងទុកដើម្បីពួកយើងទេ ព្រះអង្គទ្រង់ចងទុកដើម្បី សុមនសាមណេរតែមួយរូបប៉ុណ្ណោះ ។

ទីបំផុត កាលវារៈដល់សុមនសាមណេរ ព្រះថេរៈ ពោលថា “ ម្នាលសាមណេរ ព្រះសាស្ដាមានព្រះបំណង លាងព្រះបាទទាំងពីរដោយទឹកក្នុងអនោតត្តស្រះ, ដូច្នេះ អ្នក កាន់យកក្អមទឹកទៅនាំទឹកនោះមក ” សុមនសាមណេរនោះ ពោលថា “ប្រសិនបើព្រះសាស្ដាទ្រង់ឲ្យនាំមក, ខ្ញុំនឹងនាំមក” ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្ដា ក្រាបទូលថា “ បពិត្រ ព្រះអង្គដ៏ចម្រើន បានឮថា ព្រះអង្គឲ្យខ្ញុំព្រះអង្គនាំទឹកអំពី អនោតត្តស្រះមកឬ ?” ។

ព្រះសាស្ដា ត្រាស់ថា “ ម្នាលសុមនៈ ពិតហើយ ”។

សុមនសាមណេរនោះ យកដៃចាប់ក្អមធំមួយ ដែលអាចដាក់ទឹកបាន ៦០ ក្អម បណ្ដាក្អមសម្រាប់សេនាសនៈ ដែលជំដោយមាសទាំងដុំ ដែលមហាឧបាសិកាវិសាខាឲ្យគេធ្វើប្រគេន កាន់ទៅដោយគិតថា " សេចក្ដីត្រូវការរបស់យើងដោយក្អមដែលយើងដាក់លើចង្កួយស្មា រមែងមិនមាន " ហោះឡើងទៅកាន់វេហាស៍ មានមុខឆ្ពោះទៅកាន់ហិមវន្ត-ប្រទេស ដោយរហ័ស ។

នាគរាជឃើញសាមណេរអំពីចម្ងាយ ក៏ក្រោកឡើងទៅទទួលក្អមដោយស្មា ហើយពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន កាលអ្នកបម្រើដូចជាខ្ញុំព្រះករុណាមាន ហេតុអ្វី ទើបលោកម្ចាស់និមន្តមកដោយខ្លួនឯងយ៉ាងនេះ, កាលលោកម្ចាស់ត្រូវការទឹក ហេតុអ្វី លោកម្ចាស់មិនបញ្ជូនដំណឹងមក " ដូច្នេះហើយ យកក្អមដងទឹកខ្លួនឯង ហើយពោលថា " និមន្តលោកម្ចាស់លុបលាងមុខសិនចុះ ខ្ញុំម្ចាស់នឹងនាំទៅដោយខ្លួនឯង " ។ សាមណេរពោលថា " បពិត្រមហារាជអ្នកចូរឈប់ចុះ, អាត្មាជាអ្នកដែលព្រះសម្មាសម្ពុទ្ធប្រើឲ្យមក"

ដូច្នេះហើយ ឲ្យនាគរាជត្រឡប់ហើយ ចាប់កណ្ដាប់មាត់ក្អម ដោយដៃ ហោះមកតាមអាកាស ។

គ្រានោះ ព្រះសាស្ដាទ្រង់ក្រឡេកឃើញសាមណេរ ដែលកំពុងមក ក៏ត្រាស់ហៅពួកភិក្ខុមកហើយ ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមើលដំណើររបស់សាមណេរនោះចុះ, សាមណេរនោះមានដំណើរល្អដូចស្ដេចហង្សដ៏ពួអាកាសដូច្នោះ " ។

ចំណែកសាមណេរនោះដាក់ក្អមទឹកហើយ ថ្វាយបង្គំព្រះសាស្ដា រួចហើយឈរក្នុងទីដ៏សមគួរមួយ ។

គ្រានោះ ព្រះសាស្ដាត្រាស់ទៅកាន់សាមណេរនោះថា "ម្នាលសុមនៈ អ្នកមានអាយុប៉ុន្មាន ? សាមណេរក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានអាយុ ៧ ឆ្នាំ "។

ព្រះសាស្ដាត្រាស់ថា " ម្នាលសុមនៈ បើដូច្នោះ ចាប់ពីថ្ងៃទៅ អ្នកចូរជាភិក្ខុចុះ " ដូច្នេះហើយបានប្រទានទាយជ្ជ-ឧបសម្បទា ។

បានឮថា សាមណេរអ្នកមានអាយុ ៧ ឆ្នាំ មាន ២ រូបប៉ុណ្ណោះ បានឧបសម្បទា គឺសុមនសាមណេរនេះមួយរូប សោបាកសាមណេរមួយរូប កាលសុមនសាមណេរនោះឧបសម្បទាហើយយ៉ាងនោះ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម៌ថា " អ្នកមានអាយុទាំងឡាយ ហេតុគួរអស្ចារ្យណាស់ហ្ន៎ អានុភាពរបស់សាមណេរតូចយ៉ាងនេះ អានុភាពបែបនេះ ពួកយើងមិនធ្លាប់ឃើញហើយអំពីកាលមុន " ។ សម្បត្តិរមែងសម្រេចដល់ក្មេងៗ បាន

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ ?" កាលភិក្ខុទាំងនោះក្រាបទូលថា " អំពីរឿងឈ្មោះនេះ ព្រះអង្គ " ក៏ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនារបស់តថាគត បុគ្គលសូម្បីនៅក្មេងក៏ដោយ ឲ្យតែបតិបត្តិប្រពៃហើយ រមែងបានសម្បត្តិបែបនេះដូចគ្នា " កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា :-

**១២ យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**

សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។

ភិក្ខុណានៅកំលោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកឲ្យភ្លឺបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

## <u>អធិប្បាយគាថា</u>

បណ្តាបទទាំងនោះ បទថា **យុញ្ជតិ** ប្រឹងប្រែង គឺព្យាយាម ។

បទថា **បភាសេតិ** ជាដើម សេចក្តីថា ភិក្ខុនោះរមែងញុំាងលោក មានខន្ធលោកជាដើមឲ្យភ្លឺបាន គឺធ្វើឲ្យមានពន្លឺភ្លឺស្វាងតែមួយដោយញាណ ដែលសម្បយុត្តជាមួយនឹងអរហត្តមគ្គរបស់ខ្លួន ។ ដូចព្រះចន្ទដែលរះផុតហើយអំពីគ្រឿងបិទបាំង មានពពកជាដើមដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៙

( រឿងសុមនសាមណេរ ចប់ )

ភិក្ខុវណ្ណនា ចប់

វគ្គទី ២៥ ចប់

ssssssssssssss

# ២៦ ព្រាហ្មណវគ្គវណ្ណនា

១ ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ អ្នកប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងនូវព្រះ

និព្វានដែលបច្ច័យតាក់តែងមិនបាន ។

២ យទា ទ្វយេសុ ធម្មេសុ   បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្វេ សំយោគា   អត្ថំ គច្ឆន្តិ ជានតោ ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និងវិបស្សនាធម៌ ក្នុងកាលនោះ កិលេសគ្រឿងប្រកបសត្វទុកទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

៣ យស្ស បារំ អបារំ វា   បារាបារំ ន វិជ្ជតិ
វីតទ្ទរំ វិសញ្ញុត្តំ   តមហំ ព្រូមិ ព្រាហ្មណំ ។

ត្រើយក្តី ទីមិនមានត្រើយក្តី ត្រើយ និងមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា ( ការប្រកាន់អាយតនៈមិនមានដល់បុគ្គលណា ) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

៤ ឈាយឹ វិរជមាសីនំ កតកិច្ចំ អនាសវំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ៗ
តថាគតហៅបុគ្គលអ្នកចម្រើនឈាន មាន
ធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង
អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមាន
អាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយ
លំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ៗ
៥ ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ
អថ សព្វមហោរត្តិំ ពុទ្ធោ តបតិ តេជសា ៗ
ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទ
រុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញ
យសហើយ រមែងរុងរឿង សមណព្រាហ្មណ៍
អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ
រមែងរុងរឿងដោយតេជះ ទាំងយប់ ទាំងថ្ងៃ ៗ
៦ ពាហិតបាបោ ហិ ព្រាហ្មណោ

សមចរិយា សមណោតិ វុច្ចតិ
បព្វាជយមត្តនោ មលំ
តស្មា បព្វជិតោតិ វុច្ចតិ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគត ហៅថា សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្តេញមន្ទិលនៃខ្លួន ហេតុនោះទើបតថាគត ហៅថា បព្វជិត ។

៧ ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។
ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទានិសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ ( ចំណែក ) ព្រាហ្មណ៍ ( ដែលត្រូវគេប្រហារ

ហើយ ) គប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះក្រៃលែងជាងនោះទៅទៀត ។ ការហាមឃាត់ចិត្តចាកអារម្មណ៍ជាទីស្រឡាញ់របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ឆាកចេញចាកវត្ថុណាៗ សេចក្ដីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

**៨ យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ**
**សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។**

អំពើអាក្រក់ ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង ៣ នោះ ថាជាព្រាហ្មណ៍ ។

**៩ យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ**

**សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។**

បុគ្គលចេះធម៌អាចិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើង ដូច្នោះដែរ ។

**១០ ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ**
**យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។**

បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ព្រោះផ្នួងសក់ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង ។

**១១ កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា**
**អព្ភន្តរន្តេ គហនំ ពហិរំ បរិមជ្ជសិ ។**

នែអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកមាន

ប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែក
ឃ្លា បើសន្តានខាងក្នុងរបស់អ្នក សឹងសាំញ៉ាំ
ដោយរាគាទិក្កិលេស អ្នកឈ្មោះថា ដុសខាត់
តែខាងក្រៅទេ ។

**១២ បំសុកូលធរំ ជន្តុំ កិសន្ធមនិសន្ថតំ**
**ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅ បុគ្គលអ្នកទ្រទ្រង់សំពត់
បំសុកូល មានកាយស្គម មានខ្លួនរវាមដោយ
សរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃ
នោះ ថាជាព្រាហ្មណ៍ ។

**១៣ ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ**
**ភោវាទី នាម សោ ហោតិ ស វេ ហោតិ កិញ្ចនោ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតនឹងហៅអ្នកកើត អំពីកំណើត អ្នកកើត
ក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ ក៏ទេ
បុគ្គលនោះគ្រាន់តែបាននាមថា ភោវាទី ( អ្នក

ពោលថាចម្រើន ) ព្រោះបុគ្គលនោះឯង ជាអ្នក
មានកិលេសគ្រឿងកង្វល់នៅឡើយ តថាគត
ហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នក
មិនមានសេចក្តីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

**១៤ សព្វសំ យោជនំ ឆេត្វា យោ វេ ន បរិតស្សតិ**
**សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា កាត់សំយោជនៈទាំងអស់បាន
មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មាន
កិលេសជាគ្រឿងចំពាក់ អ្នករួចស្រឡះចាក
កិលេស ថាជាព្រាហ្មណ៍ ។

**១៥ ឆេត្វា នទ្ធឹ វរត្តញ្ច សន្ទានំ សហានុក្កមំ**
**ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលដែលកាត់សេចក្តីក្រោធ
ដូចព្រួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ
៦២ ដូចទឹក ព្រមទាំងអនុស័យ ដូចអ្នកដើរ
តាមផង អ្នកមានអវិជ្ជា ដូចសសរខឿន ដក

បោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង
ថាជាព្រាហ្មណ៍ ។

**១៦ អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ**
**ខន្តីពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរ ផង ការបៀតបៀន និងការចងផងបាន ទើប តថាគតហៅបុគ្គលដែលមានខន្តីជាពលៈ មាន ខន្តីជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍ ។

**១៧ អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សទំ**
**ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តី ក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយ ទូន្មានហើយ មានសរីរៈឋិតនៅ ក្នុងទីបំផុត នោះ ថាជាព្រាហ្មណ៍ ។

**១៨ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ**

**យោ វេ ន លិម្បតិ កាមេសុ  តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុង
កាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូច
គ្រាប់ស្ពៃលើចុងដែលស្រួច  តថាគតហៅ
បុគ្គល ថាជាព្រាហ្មណ៍ ។

**១៩ យោ ទុក្ខស្ស បជានាតិ  ឥធេវ ខយមត្តនោ**
**បន្នភារំ វិសញ្ញុត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់
នូវការអស់ទុក្ខរបស់ខ្លួន  តថាគតហៅបុគ្គល
នោះ ដែលមានខន្ធការៈ ដាក់ចុះហើយ ដែល
រួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

**២០ គម្ភីរបញ្ញំ មេធាវី  មគ្គាមគ្គស្ស កោវិទំ**
**ឧត្តមត្ថំ អនុប្បត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅ បុគ្គលអ្នកប្រាជ្ញាជ្រៅ មាន
ប្រាជ្ញាជាគ្រឿងទម្លាយកិលេស  អ្នកឈ្លាស
ក្នុងផ្លូវ និងមិនមែនផ្លូវ បានសម្រេចប្រ-

យោជន៍ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

**២១ អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ**
**អនោកសារី អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនច្រឡំ ដោយជនទាំងឡាយ ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅដោយមិនមានសេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

**២២ និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច**
**យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

**២៣ អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ**
**សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករំលត់ចំពោះពួកជនដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

**២៤ យស្ស រាគោ ច ទោសោ ច មានោ មោក្ខោ ច បាតិតោ**
**សាសបោរិ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។**

រាគៈ ទោសៈ មានះ និងមក្ខៈ ដែលបុគ្គលណាជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

**២៥ អក្កកសំ វិញ្ញាបនី គិរំ សច្ចំ ឧទីរយេ**
**យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

២៦ យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ
លោកេ អទិន្នំ នាទិយតិ  តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលនា មិនយករបស់វែង ឬខ្លី តូច ឬធំ
អាក្រក់ ឬល្អ ដែលគេមិនបានឲ្យហើយក្នុងលោក
នេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

២៧ អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច
និរាសយំ វិសំយុត្តំ    តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា  មិនមានសេចក្តីប្រាថ្នាក្នុងលោក
នេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គល
នោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះ
ចាកកិលេស ថាជាព្រាហ្មណ៍ ។

២៨ យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី
អមតោគធំ អនុប្បត្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា
មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹង
ច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមាន

ចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលព្រះអរហត្ត-
ផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

**២៩ យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា**
**អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ
និងបាបទាំង ២ និងកិលេសជាគ្រឿងចំពាក់
( មានរាគៈជាដើម ) ចេញហើយ តថាគត
ហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តី
សោក មានធូលី គឺកិលេសអស់ហើយ ជា
អ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

**៣០ ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ**
**នន្ទិភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលមិនមានសេចក្តី
សៅហ្មង ដូចព្រះចន្ទប្រាសចាកមន្ទិល ជាអ្នក
បរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់
សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

៣១ យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កន្លងផ្លូវ គឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្ដីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

៣២ យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ
កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាក

កាមបាន តថាគតហៅបុគ្គលនោះ ដែលអស់
កាមភពហើយ ថាជាព្រាហ្មណ៍ ។

**៣៣ យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ**
**តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហា
ហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហា
បាន តថាគតហៅបុគ្គល ដែលអស់តណ្ហា និង
ភពហើយនោះ ថាជាព្រាហ្មណ៍ ។

**៣៤ ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា**
**សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា លះកិលេសជាគ្រឿងប្រកប
ដែលជារបស់មនុស្ស កន្លងកិលេសជាគ្រឿង
ប្រកប ដែលជារបស់ទិព្វបានហើយ តថាគត
ហៅបុគ្គល ដែលផុតស្រឡះ ចាកកិលេសជា
គ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

**៣៥ ហិត្វា រតឹ អរតិញ្ច សីតិភូតំ និរូបធឹ**

*សព្វលោកាភិភុំ វីរំ   តមហំ ព្រូមិ ព្រាហ្មណំ ។*

តថាគតហៅបុគ្គល ដែលលះបង់សេចក្តី ត្រេកអរក្នុងកាមគុណ  និងមិនត្រេកអរក្នុង កិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់ មិន មានឧបក្កិលេស  គ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

៣៦ *ចុតឹ យោ វេទិ សត្តានំ  ឧបបត្តិញ្ចសព្វសោ*
*អសត្តំ សុគតឹ ពុទ្ធំ  តមហំ ព្រូមិ ព្រាហ្មណំ ។*
*យស្ស គតឹ ន ជានន្តិ   ទេវា គន្ធព្វមានុសា*
*ខីណាសវំ អរហន្តំ   តមហំ ព្រូមិ ព្រាហ្មណំ ។*

បុគ្គលណា  ដឹងច្បាស់ចុតិ  និងបដិសន្ធិ របស់ពួកសត្វ ដោយអាការទាំងពួងបាន តថា- គតហៅបុគ្គល ដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នក ត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។ ទេវតា គន្ធព្វ និងពួងមនុស្សទាំងឡាយ មិនដឹង

គតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្ត នោះ ថាជាព្រាហ្មណ៍ ។

**៣៧ យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

**៣៨ ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ**
**អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

**៣៩ ពុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ**

អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ
សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់ឋានសួរគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ចប់សព្វគ្រប់ហើយនោះ ថាជាព្រហ្មណ៍ ។

# ២៦ ព្រាហ្មណវគ្គវណ្ណនា

## ១ រឿងព្រាហ្មណ៍អ្នកច្រើនដោយសេចក្តីជ្រះថ្លា

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកច្រើនដោយសេចក្តីជ្រះថ្លា ត្រាស់ព្រះធម្មទេសនានេះថា “ **ឆិន្ទ សោតំ បរក្កម្ម** ” ជាដើម ។*

## ពួកភិក្ខុវៀសវាទៈរបសព្រាហ្មណ៍

បានឮថា ព្រាហ្មណ៍នោះស្ដាប់ធម្មទេសនារបស់ព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា តាំងផ្ដើមនូវនិច្ចភត្តដើម្បីភិក្ខុប្រមាណ ១៦ រូប ទុកក្នុងផ្ទះរបស់ខ្លួន ទទួលបាត្រក្នុងពេលដែលភិក្ខុទាំងឡាយមកហើយ ពោលថា "សូមព្រះអរហន្តដ៏ចម្រើន ចូរមក, សូមព្រះអរហន្តដ៏ចម្រើន និមន្តគង់" កាលពោលនូវពាក្យណាមួយ ក៏ពោលពាក្យប្រកបដោយវាទៈថាព្រះអរហន្តប៉ុណ្ណោះ ។ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុដែលជាបុថុជ្ជនគិតគ្នាថា "ព្រាហ្មណ៍នេះ តែងសម្គាល់ពួកយើងថាជាព្រះអរហន្ត" ពួកភិក្ខុដែលជាព្រះអរហន្តក៏គិតថា "ព្រាហ្មណ៍នេះ រមែងដឹងពួកយើងថាជាព្រះខីណាស្រព" ភិក្ខុទាំងអស់នោះ វៀសពាក្យរបស់ព្រាហ្មណ៍យ៉ាងនេះ ទើបមិនទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះកើតទុក្ខចិត្តហើយគិតថា "ព្រោះហេតុអ្វីហ្ន៎ ? ទើបលោកម្ចាស់ទាំងឡាយ មិននិមន្តមកផ្ទះយើង" លុះគិតដូច្នេះហើយក៏ទៅកាន់វិហារថ្វាយបង្គំព្រះសាស្ដា ក្រាបទូលសេចក្ដីនោះ។

## មិនជាអាបត្តិព្រោះមិនត្រេកអរចំពោះវាទៈនោះ

ព្រះសាស្ដា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ តើសេចក្ដីនោះជាយ៉ាងណា" កាលភិក្ខុទាំងនោះក្រាបទូលសេចក្ដីនោះហើយ, ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏អ្នកទាំងឡាយត្រេកអរនិងវាទៈថា ជាព្រះអរហន្តឬ ?" ។

ពួកភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនមានត្រេកអរទេ ។

ព្រះសាស្ដា. បើដូច្នោះ, ពាក្យនោះ ជាពាក្យពោលដោយសេចក្ដីជ្រះថ្លារបស់មនុស្សទាំងឡាយប៉ុណ្ណោះ, ភិក្ខុទាំងឡាយ មិនជាអាបត្តិព្រោះការពោលដោយសេចក្ដីជ្រះថ្លាទេ, មួយវិញទៀត សេចក្ដីស្រឡាញ់ព្រះអរហន្តទាំងឡាយរបស់ព្រាហ្មណ៍ មានប្រមាណក្រៃលែង, ហេតុនោះ សូម្បីពួកអ្នកកាត់ក្រសែតណ្ហាហើយសម្រេចព្រះអរហន្តនោះ គួរ" ដូច្នេះហើយ កាលនឹងទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖-

**១ ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ**

**សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។**

ម្នាលព្រាហ្មណ៍ អ្នកប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងនូវព្រះនិព្វានដែលបច្ច័យតាក់តែងមិនបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បរក្កម្ម** ជាដើម សេចក្ដីថា ដែលឈ្មោះថា ក្រសែតណ្ហា នរណា ៗ មិនអាចដើម្បីនឹងកាត់បានដោយសេចក្ដីព្យាយាមមានប្រមាណតិច, ហេតុនោះ អ្នកចូរព្យាយាមកាត់ខ្សែនោះ ដោយសេចក្ដីព្យាយាមដ៏ធំ ដែលប្រកបជាមួយនិងញាណ គឺចូរបន្ទោបង់ បានដល់ ចូរបញ្ចេញកាមទាំងពីរចេញចុះ ។

ពាក្យថា **ព្រាហ្មណ៍** នោះ ជាពាក្យហៅព្រះខីណាស្រពទាំងឡាយ ។

បទថា **សន្ធាកនំ** សេចក្ដីថា ដឹងនូវកិរិយាអស់ទៅនៃខន្ធ ៥ ។

បទថា **អកតញ្ញូ** សេចក្ដីថា កាលបើដូច្នោះ អ្នកឈ្មោះថា អកតញ្ញូ ព្រោះដឹងនូវព្រះនិញ្វនដែលបុគ្គលធ្វើមិនដោយវត្ថុជាតុទាំងឡាយ មានមាសជាដើម ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងព្រាហ្មណ៍អ្នកច្រើនដោយសេចក្ដីជ្រះថ្លា ចប់

## ២.រឿងភិក្ខុច្រើនរូប

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ធម៌ទេសនានេះថា “ **យទា ទ្វយេសុ ធម្មេសុ** ” ជាដើម ។

## ព្រះសារីបុត្រទូលសួរបញ្ហាដើម្បីពួកភិក្ខុ

ថ្ងៃមួយ ភិក្ខុដែលនៅក្នុងទិសប្រមាណ ៣០ រូប មកថ្វាយបង្គំព្រះសាស្ដា ហើយអង្គុយក្នុងដ៏សមគួរ ។ ព្រះ-

សារីបុត្តត្ថេរ ឃើញធម៌ដែលជាឧបនិស្ស័យនៃព្រះអរហត្ត របស់ភិក្ខុទាំងនោះហើយ ចូលទៅគាល់ព្រះសាស្ដា ទូលសួរបញ្ហានេះថា “ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយដែលព្រះអង្គត្រាស់ហៅថា ធម៌ ២ ប្រការៗ ដូច្នេះ, ធម៌ ២ ប្រការនោះ តើដូចម្ដេច ?” ។

គ្រានោះ ព្រះសាស្ដាត្រាស់ទៅកាន់ព្រះសារីបុត្រថា “ ម្នាលសារីបុត្រ សមថៈ និងវិបស្សនា ហៅថា ធម៌ ២ ប្រការ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**២ យទា ទ្វយេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ**
**អថស្ស សព្វេ សំយោគា អត្ថំ គច្ឆន្តិ ជានតោ ។**

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និងវិបស្សនាធម៌ ក្នុងកាលនោះ កិលេសគ្រឿងប្រកបសត្វទុកទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **យទា** ជាដើម សេចក្ដីថា ក្នុងកាលណាព្រះខីណាស្រពអ្នកដល់ត្រើយ ក្នុងធម៌ គឺសមថៈ និងវិបស្សនា ដែលតាំងនៅក្នុងចំណែកទាំង ២ ដោយអំណាចនៃការដល់នូវត្រើយ គឺអភិញ្ញាជាដើម, ក្នុងកាលនោះកិលេសជាគ្រឿងប្រកបទាំងឡាយ មានកិលេសគ្រឿងប្រកប គឺកាមជាដើមទាំងពួង ដែលអាចប្រកបទុកក្នុងវដ្ដៈរបស់ព្រះខីណា-ស្រពនោះ អ្នកដឹងយ៉ាងនោះ រមែងដល់នូវការតាំងនៅមិនបាន គឺអស់ទៅ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសូម្បីទាំងអស់ តាំងនៅក្នុងព្រះអរហត្ត ៕

( រឿងភិក្ខុច្រើនរូប ចប់ )

# ៣ រឿងមារ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា “ **យស្ស បារំ អបារំ វា** ” ជាដើម ។

## មានបន្ទំខ្ទួនទូលសួររឿងត្រើយ

បានឮថា ថ្ងៃមួយ មានក្មេងខ្ជួនជាបុរសម្នាក់ចូលទៅគាល់ព្រះសាស្តា ហើយទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលព្រះអង្គត្រាស់ថា ត្រើយៗ, អ្វីហ្ន៎ ឈ្មោះថាត្រើយនុ៎ះ ?” ។

ព្រះសាស្តាទ្រង់ជ្រាបថា “ នេះជាមារ ” ទើបត្រាស់ថា “ម្នាលមារអ្នកមានចិត្តបាប ប្រយោជន៍អ្វីរបស់អ្នកដោយត្រើយ, ត្រើយនោះ អ្នកមានរាគៈទៅប្រាសហើយទាំងឡាយគប្បីដល់ ” ដូច្នេះហើយ ត្រាស់ធម្មទេសនានេះថា :-

**៣ យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ**
**វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

ត្រើយក្តី ទីមិនមានត្រើយក្តី ត្រើយ និងមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា ( ការប្រកាន់អាយតនៈមិនមានដល់បុគ្គលណា ) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

# អធិប្បាយគាថា

អាយតនៈខាងក្នុង ៦ ឈ្មោះថា **បារំ** ក្នុងព្រះគាថានោះ ។ អាយតនៈខាងក្រៅ ៦ ឈ្មោះថា **អបារំ** ។ អាយតនៈទាំង ២ នោះ ឈ្មោះថា **បារាបារំ** ។

បទថា **ន វិជ្ជតិ** សេចក្តីថា ត្រើយ និងមិនមែនត្រើយទាំងអស់នោះ មិនមានដល់អ្នកណា ព្រោះមិនមានការប្រកាន់ថា " យើង " ឬថា " របស់យើង ", តថាគតហៅអ្នក គឺអ្នកដែលមានសេចក្តីក្រវល់ក្រវាយទៅប្រាសហើយ ព្រោះទៅប្រាសនៃសេចក្តីក្រវល់ក្រវាយ គឺកិលេសទាំងឡាយ អ្នកប្រាសចាកកិលេសទាំងពួងបានហើយថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងមារ ចប់ )

## ៤ រឿងព្រាហ្មណ៍ម្នាក់

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **ឈាយឹ** ” ជាដើម ។

### ព្រាហ្មណ៍ទូលសួររឿងព្រាហ្មណ៍ចំពោះព្រះសាស្ដា

បានឮថា ព្រាហ្មណ៍នោះគិតថា “ ព្រះសាស្តាត្រាស់ហៅសាវករបស់ព្រះអង្គថា ព្រាហ្មណ៍, ចំណែកយើងជាព្រាហ្មណ៍ដោយជាតិ និងគោត្រ, ការដែលព្រះអង្គត្រាស់ហៅយើងដូច្នោះដែរ គួរ ”, ព្រាហ្មណ៍នោះចូលទៅគាល់ព្រះ-សាស្តា ទូលសួរសេចក្តីនោះ ។

ព្រះសាស្តាត្រាស់ថា “ តថាគតមិនហៅបុគ្គលថាព្រាហ្មណ៍ ដោយហេតុត្រឹមតែជាតិ និងគោត្រប៉ុណ្ណោះទេ, ប៉ុន្តែ តថាគតហៅបុគ្គលអ្នកសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុតប៉ុណ្ណោះ ( ថាជាព្រាហ្មណ៍ ) ដូច្នេះហើយ ត្រាស់ព្រះ-គាថានេះថា :-

**៤ ឈាយឹ វិរជមាសីនំ កតកិច្ចំ អនាសវំ**
**ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលអ្នកចម្រើនឈាន មាន
ធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង
អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមាន
អាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយ

លំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឈាយឹ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលអ្នកសម្ងឹងដោយឈាន ២ យ៉ាង អ្នកប្រាសចាកធូលី ដោយធូលីគឺកាម នៅតែម្នាក់ឯងក្នុងព្រៃ ឈ្មោះថា អ្នកមានកិច្ចធ្វើស្រេចហើយ ព្រោះកិច្ច ១៦ យ៉ាង ខ្លួនបានធ្វើដោយមគ្គ ៤ ហើយ ឈ្មោះថា មិនមានអាសវៈ ព្រោះមិនមានអាសវៈទាំងឡាយ សម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះអរហត្តហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះ តាំងនៅក្នុងសោតាបត្តិផល ទេសនាបានជាប្រយោជន៍សូម្បីដល់ជនអ្នកមកប្រជុំគ្នាហើយ ៕

( រឿងព្រាហ្មណ៍ម្នាក់ ចប់ )

# ៥ រឿងព្រះអានន្ទត្ថេរ

## *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងប្រាសាទរបស់ឧបាសិកាឈ្មោះមិគារមាតា ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **ទិវា តបតិ អាទិច្ចោ** ” ជាដើម ។*

# រស្មីនៃវត្ថុ ៥ យ៉ាងផ្សេងគ្នា

បានឮថា ក្នុងថ្ងៃមហាបវារណា ព្រះបាទបសេនទិ-កោសលទ្រង់ប្រដាប់គ្រឿងរាជឥស្សរិយាកណ្ឌទាំងពួង ទ្រង់កាន់យកវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើម ស្តេចទៅកាន់វិហារ ។

ក្នុងខណៈនោះ ព្រះកាឡុទាយិត្ថេរគង់ចូលឈានក្នុងទីបំផុតបរិស័ទ ។ ក៏ពាក្យថា កាឡុទាយិត្ថេរ នុ៎ះ ជាឈ្មោះរបស់ព្រះថេរៈនោះឯង ។ សរីរៈ ( របស់លោក ) មានពណ៌ដូចមាស ។ ក៏ក្នុងខណៈនោះព្រះចន្ទកំពុងរះឡើង, ព្រះ-អាទិត្យកំពុងអស្តង្គត ។

ព្រះអានន្ទត្ថេរ សម្លឹងមើលរស្មីព្រះអាទិត្យដែលកំពុងអស្តង្គត និងព្រះចន្ទដែលកំពុងរះឡើង ហើយសម្លឹងមើលសរីរោភាសរបស់ព្រះរាជា សរីរោភាសរបស់ព្រះថេរៈ និងព្រះសរីរោភាសរបស់ព្រះតថាគត ។ បណ្តាជនទាំងនោះព្រះសាស្តារមែងរុងរឿងកន្លងរស្មីទាំងពួង ។ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា “ ថ្ងៃនេះ កាលខ្ញុំព្រះអង្គ

សម្លឹងមើលរស្មីទាំងនេះ, ព្រះរស្មីរបស់ព្រះអង្គប៉ុណ្ណោះរមែងជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ, ព្រោះថា ព្រះសរីរៈរបស់ព្រះ-អង្គ រមែងរុងរឿងកន្លងរស្មីទាំងពួង ” ។

គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់ព្រះអានន្ទថា “ ម្នាលអានន្ទ ធម្មតាព្រះអាទិត្យរមែងរុងរឿងក្នុងវេលាថ្ងៃ, ព្រះចន្ទរមែងរុងរឿងក្នុងវេលាយប់, ព្រះរាជារមែងរុងរឿងក្នុងវេលាទ្រង់ប្រដាប់ហើយប៉ុណ្ណោះ, ព្រះខីណាស្រព លះបង់ការប្រឡូកប្រឡំដោយពួក រមែងរុងរឿងខាងក្នុងសមាបត្តិប៉ុណ្ណោះ, ចំណែកព្រះពុទ្ធ រមែងរុងរឿងដោយតេជៈ ៥ យ៉ាង ទាំងក្នុងពេលយប់ ទាំងក្នុងពេលថ្ងៃ ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**៥ ទិវា តបតិ អាទិច្ចោ  រត្តិមាភាតិ ចន្ទិមា**
**សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ**
**អថ សព្វមហោរត្តិំ  ពុទ្ធោ តបតិ តេជសា ។**

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទ
រុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញ

យសហើយ រមែងរុងរឿង សមណព្រាហ្មណ៍
អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធ
រមែងរុងរឿងដោយតេជះ ទាំងយប់ ទាំងថ្ងៃ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **ទិវា តបតិ** សេចក្ដីថា ព្រះអាទិត្យរមែងរុងរឿងក្នុងវេលាថ្ងៃប៉ុណ្ណោះ, ប៉ុន្តែសូម្បីផ្លូវដែលព្រះអាទិត្យនោះទៅ រមែងមិនប្រាកដក្នុងវេលាយប់ ។

បទថា **ចន្ទិមា** សេចក្ដីថា សូម្បីព្រះចន្ទដែលផុតចាកមន្ទិល មានពពកជាដើម ក៏រុងរឿងតែក្នុងវេលាយប់ប៉ុណ្ណោះ មិនរុងរឿងក្នុងវេលាថ្ងៃ ។

បទថា **សន្នទ្ធោ** សេចក្ដីថា ព្រះរាជាដែលទ្រង់ប្រដាប់ដោយអាភរណៈទាំងពួង ដ៏វិចិត្រដោយមាស និងកែវមណី ដែលសេនាមានអង្គ ៤ ចោមរោមហើយ រមែងរុងរឿង, ដែលទ្រង់បិតនៅដោយភេទជាអ្នកដែលបុគ្គលដទៃមិនស្គាល់ ( បន្លំភេទ ) រមែងមិនរុងរឿង ។

បទថា **ឈាយី** សេចក្ដីថា ចំណែកព្រះខីណាស្រព លះបង់ពួកគណៈហើយ អន្ទុយស្និងស្ថាធិ៍ រមែងរុងរឿង ។

បទថា **តេជសា** សេចក្ដីថា ចំណែកព្រះសម្មាសម្ពុទ្ធ ទ្រង់គ្របសង្កត់តេជះនៃការទ្រុស្តសីល ដោយតេជះនៃសីល តេជះនៃអំពើអាក្រក់ ដោយតេជះនៃអំពើល្អ តេជះនៃអវិជ្ជា ដោយតេជះនៃបញ្ញា តេជះនៃអំពើដែលមិនមែនជាបុណ្យ ដោយតេជះនៃបុណ្យ តេជះនៃអធម៌ ដោយតេជះនៃធម៌ រមែងរុងរឿងដោយតេជះ ៥ យ៉ាងនេះ រហូតអស់កាលជានិច្ច ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ល៕

( រឿងព្រះអានន្ទត្ថេរ ចប់ )